ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia

Nation Religion King

Royaume du Cambodge

Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber

Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរ
# នៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី "ឌុច"
# អសាធារណៈ

សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសដ

**ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៩**

**កិច្ចប្រជុំរៀបចំសវនាការ**

**ចៅក្រមសាលាដំបូង៖**

លោក និល ណុន ជាប្រធាន

លោកស្រី ស៊ីលវ៉ា ខាតរ៉ាយថ៍

*(Judge Silvia Carwright)*

លោក យ៉ា សុខន

លោក ហ្សង់ម៉ាក ឡាវែន៍

*(Judge Jean-Marc Lavegne)*

លោក ធូ មណី

លោក យូរ ឧត្តរា

លោកស្រី ក្លូឌា ហ្វេនស៍

*(Judge Claudia Fenz)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក លឹម ស៊ុយហុង

លោក អាលីណា ប្រាយអ័ត *(Ms. Alina BRIOT)*

លោកស្រី សែ កុលវុឌ្ឍី

កញ្ញា ណាតាចា វិចស៊ែល

*(Ms. Natacha Wexels-Riser)*

លោក ឌុច ផារី

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក សេង ប៊ុនឃាង

លោក វីលៀម ស្មីត *(Mr. William Smith)*

លោក ពេជ្រ សម្បត្តិ

លោក ស្ទូអាត ហ្វដ *(Mr. Stuart FORD)*

**ជនជាប់ចោទ៖**

លោក កាំង ហ្គេកអ៊ាវ

**មេធាវីការពារជនជាប់ចោទ៖**

លោក ការ សាវុត្ថ

លោកហ្វ្រង់ស្វ័រ រូ *(Mr. François ROUX)*

លោកស្រី ហេឡឺន អ៊ុយណាក់

*(Ms. Heleyn UÑAC)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ហុង គីមសួន

លោក គង់ ពិសី

លោក ម៉ុច សុវណ្ណារី

លោកស្រី ស៊ីលឃី ស្ទូតហ្សីនស្គី

*(Ms. Silke Studzinsky)*

កញ្ញា ទី ស្រ៊ីនណា

លោក អាឡាំង វ៉ែនណឺ

*(Mr. Alain Werner)*

លោកស្រី អេលីហ្សាប៊ែត រ៉ាបេសាន់ដ្រាតាណា

*(Ms. Elizabeth RABESANDRATANA)*

**ការិយាល័យរដ្ឋបាលសាធារណៈ៖**

លោក ក្រាញ់ តូនី

លោក រូសាន់ហោក ឃ្នុត

*(Mr. Knut ROSANDHAK)*

លោក ថារីក អាឌុលឡាក់

*(Mr. Tarik ABDULHAK )*

លោក មីសែល ឃីធីង

*(Ms. Michelle KEATING)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

ឯកសារ:

**បញ្ជីឈ្មោះ អ្នកនិយាយ៖**

ភាសា ដែលប្រើប្រាស់ លើកលែងតែបានកំណត់ជាក់លាក់នៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍ | អង់គ្លេស |
| លោក ហុង គឹមសួន | ខ្មែរ |
| លោក ការ សាវុត្ថ | ខ្មែរ |
| លោក គង់ ពិសី | ខ្មែរ |
| លោក ក្រាញ់ តូនី | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវ៉ែន៍ | បារាំង |
| លោកស្រី វ៉ាបេសាន់ដ្រាតាណា | បារាំង |
| លោក រូជឺ | អង់គ្លេស |
| លោក ហ្វ្រង់ស្វ័រ រូ | បារាំង |
| លោក សេង ប៊ុនឃាង | ខ្មែរ |
| លោក វីលៀម ស្មីត | អង់គ្លេស |
| លោកស្រី ស៊ីលឃី ស្ទួតហ្វ៊ីនស្តី | អង់គ្លេស |
| កញ្ញា ទី ស្រ៊ីនណា | ខ្មែរ |
| ជនជាប់ចោទ | ខ្មែរ |
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំជម្រះ) | ខ្មែរ |
| លោក អាឡាំង វ៉ែនណឺ | អង់គ្លេស |

# កិច្ចដំណើរការនីតិវិធី

[០៩:០៥:៣៥]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។

ជម្រាបសួរអស់លោក លោកស្រី! នៅថ្ងៃនេះ អង្គជំនុំជម្រះសាលាដំបូង រៀបចំនូវដំណើរការកិច្ចការចំនួនពីរដោយឡែកពីគ្នា ។ ទីមួយ ដំណើរការនីតិវិធីធ្វើសម្បថសម្រាប់អ្នកស៊ើបអង្កេតនៅការិយាល័យសហចៅក្រមស៊ើបអង្កេត ដែលមានខ្មែរមួយរូប ហើយនិងជនជាតិបរទេសមួយរូប ដែលទើបបានទទួលនីតិសម្បទាតាមប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។ ហើយនិងកិច្ចការទីពីរ បន្ទាប់មកគឺយើងនឹងរៀបចំតាមនូវកិច្ចប្រជុំពិភាក្សាក្នុងការរៀបចំដំណើរសវនាការរបស់យើង ពីពេលនេះទៅថ្ងៃមុខ ។ ដូច្នេះ ខ្ញុំសូមចាប់ផ្តើមដំណើរការបើកនីតិវិធីធ្វើសម្បថសម្រាប់អ្នកស៊ើបអង្កេត ។

អនុលោមតាមវិធាន១៦ នៃវិធានផ្ទៃក្នុងរបស់អង្គជនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អ្នកស៊ើបអង្កេត ដែលទទួលបាននីតិសម្បទាត្រឹមត្រូវហើយ តម្រូវឲ្យធ្វើសម្បថនៅចំពោះមុខអង្គជំនុំជម្រះណាមួយនៃអង្គជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងប្រកាសធ្វើនីតិវិធីសម្បថសម្រាប់មន្ត្រីច្បាប់ និងអ្នកស៊ើបអង្កេតរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតឲ្យធ្វើសច្ចាប្រណិធាននៅចំពោះអង្គជម្រះសាលាដំបូង ដែលមានរូបយើង និល ណុន ជាប្រធាន, ចៅក្រមលោកស្រី ខាតវ៉ាយថ៍ ជាចៅក្រម, លោកចៅក្រម យ៉ា សុខន, លោកចៅក្រម ហ្សង់ ម៉ាកឡាវែន៍, លោកចៅក្រម ធូ មណី និងមានចៅក្រមបម្រុងចំនួនពីររូប គឺលោកចៅក្រម យូរ ឧត្តរា លោកស្រីចៅក្រម ក្លូឌា ហ្វេនស៍ ។

លោក ឌុច ផារី តើមន្ត្រីច្បាប់និងអ្នកស៊ើបអង្កេត ដែលត្រូវធ្វើសច្ចាប្រណិធាននាពេលនេះ មានវត្តមានហើយឬនៅ?

**លោក ឌុច ផារី៖**

សូមគោរពលោកប្រធាន! អ្នកស៊ើបអង្កេតទាំងពីរនាក់មានវត្តមានគ្រប់ចំនួនហើយនៅព្រឹកនេះ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

តំណាងសហព្រះរាជអាជ្ញា តើលោកចង់មានយោបល់ ឬក៏មានការកត់សម្គាល់អ្វីដែរឬទេ

ចំពោះនីតិវិធីធ្វើសម្បថនាពេលនេះ?

[០៩:០៩:៥០]

**លោក សេង ប៊ុនឃាង៖**

អរគុណលោកប្រធាន តំណាងអយ្យការមិនមានអ្វីយល់ទាស់នឹងនីតិវិធីនេះទេ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

ជាកិច្ចបន្តនេះ ខ្ញុំសូមអាននូវប្រកាសក្រសួងយុត្តិធម៌៖

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការក្រសួរយុត្តិធម៌ លេខ៤៩ កយប្រក/០៩

រាជធានីភ្នំពេញថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៩

ប្រកាសស្តីពីការផ្តល់នីតិសម្បទានដល់មន្ត្រីច្បាប់ និងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។

បានឃើញព្រះរាជក្រមលេខ នសរកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌ ។

បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១២ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតឲ្យមាន អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

បានឃើញវិធានផ្ទៃក្នុង នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០៧ ។

បានឃើញវិធានផ្ទៃក្នុង នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលបានវិសោធនកម្មចុះថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០០៨ ។

យោងលិខិតស្នើសុំលេខ រល៧១៣ អ.រ.ត.ក/រប ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០០៩ របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**សម្រេច៖**

ប្រការ១: ត្រូវបានផ្តល់នីតិសម្បទាដល់មន្ត្រីច្បាប់ និងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលមានឈ្មោះដូចខាងក្រោមនេះ៖

១) នាក់ សើគីរីន ភេទប្រុស សញ្ជាតិខ្មែរ មន្ត្រីច្បាប់ ។ ថ្ងៃខែឆ្នាំកំណើត ២០ វិច្ឆិកា ឆ្នាំ១៩៨០ ថ្ងៃចូលបម្រើការងារ ថ្ងៃទី១ ខែមេសា ឆ្នាំ២០០៩ ។

២) ផៅឡូ ផាស្ទ័រ ស្តុចជិ ភេទប្រុស សញ្ជាតិអ៊ីតាលី អ្នកស៊ើបអង្កេត ថ្ងៃខែឆ្នាំកំណើត ២៥ ខែមិថុនា ឆ្នាំ១៩៦០ ថ្ងៃចូលបម្រើការងារ ២២ មេសា ២០០៩ ។

ប្រការ២: ការផ្តល់នីតិសម្បទាដល់មន្ត្រីច្បាប់ និងអ្នកស៊ើបអង្កេតនេះ នឹងអស់សុពលភាពក្នុងលក្ខខណ្ឌដូចខាងក្រោម៖

នៅពេលអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាចប់បេសកម្មរបស់ខ្លួន ឬសាមីខ្លួនពុំបានអនុវត្តតាមលក្ខខណ្ឌរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាមីខ្លួនបញ្ចប់ភារកិច្ចរបស់ខ្លួនក្នុងមុខងារបម្រើការនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

ប្រការ៣: សាមីខ្លួនដែលមានឈ្មោះ ដូចក្នុងប្រការមួយ និងអង្គជំនុំជម្រះក្នុងតុលាការកម្ពុជាត្រូវអនុវត្តប្រកាសនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

ហត្ថលេខា និងត្រា

អង្គ វង្សវឌ្ឍានា

**ចម្លងជូន:**

ទីស្តីការគណៈរដ្ឋមន្ត្រី ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី ដើម្បីជូនជ្រាបដូចប្រការ៣ ដើម្បីអនុវត្តកាលប្បវត្តិឯកសារ ។

លោក នាក់ សើគីរីនក្រឡាបញ្ជីយកពាក្យសច្ចាប្រណិធាន ជាភាសាខ្មែរមួយច្បាប់ជូនទៅលោក នាក់ សើគីរីន។

នាក់ សើគីរីន អាននូវពាក្យសច្ចាប្រណិធាន ហើយក្រោយពីចប់កិច្ចនេះ លោកត្រូវចុះហត្ថលេខាលើកំណត់ហេតុនៃការធ្វើសច្ចាប្រណិធាននេះ ។ សូមអញ្ជើញ ។

[០៩:១៦:០៨]

**លោក នាក់ សើគីរីន ៖**

ខ្ញុំសូមប្រកាសជាឱឡារិកថា ខ្ញុំនឹងបំពេញតួនាទី និងប្រើប្រាស់អំណាចជាអ្នកស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តិឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ដោយថ្លៃថ្នូរ ស្មោះត្រង់ មិនលម្អៀង និងដោយសម្បជញ្ញៈ ហើយខ្ញុំនឹងមិនស្វែងរក ឬទទួលបង្គាប់បញ្ជាក្នុងការអនុវត្តតួនាទីទាំងនោះ ឬប្រើអំណាចទាំងនោះ ពីប្រភពមួយណាមួយផ្សេងក្រៅពី សហចៅក្រមស៊ើបអង្កេត នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាឡើយ ។

**ប្រធានអង្គជំនុំ៖**

លោកអាចនៅទីនេះសិន ហើយលោក ឌុច ផារី ទៅអញ្ជើញអ្នកស៊ើបអង្កេត ផៅឡូ ផាស្ទ័រ ស្តុចជិ ចូលមកកាន់កន្លែងធ្វើសម្បថ ។

មន្ត្រីច្បាប់សូមយកនូវពាក្យសច្ចាប្រណិធានជូនលោក ផៅឡូ ផាស្ទ័រ ស្តុចជិ ។ លោក ផៅឡូ ផាស្ទ័រ ស្តុចជិ សូមអញ្ជើញអាននូវពាក្យសម្បថដែលមន្ត្រីច្បាប់បានជូនលោកអម្បាញ់មិញនេះ ។

**លោក ផៅឡូ ផាស្ទ័រ ស្តុចជិ៖**

ខ្ញុំសូមប្រកាសជាឱឡារិកថា ខ្ញុំនឹងបំពេញតួនាទី និងប្រើប្រាស់អំណាចជាអ្នកស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តិឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ដោយថ្លៃថ្នូរ ស្មោះត្រង់ មិនលម្អៀង និងដោយសម្បជញ្ញៈ ហើយខ្ញុំនឹងមិនស្វែងរក ឬទទួលបង្គាប់បញ្ជានៅក្នុងការអនុវត្តតួនាទីទាំងនេះ ឬប្រើអំណាចទាំងនេះ ពីប្រភពមួយណាមួយផ្សេងពីសហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាឡើយ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោក នាក់ សើគីរីនមកកាន់ទីនេះជាមួយគាត់ ។

អង្គជំនុំជម្រះសូមធ្វើផ្តាំផ្ញើថា លោកទាំងពីរដែលបានទទួលការជ្រើសរើសឱ្យចូលមកបម្រើការងារនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដោយគណៈកម្មាធិការជ្រើសរើសចម្រុះជាតិ និងអន្តរជាតិ ដែលបានជ្រើសរើសលោកមកទីនេះ ។ ទីពីរ លោកបានទទួលនូវនីតិសម្បទាពេញលេញជា

អ្នកស៊ើបអង្កេត ជាមន្ត្រីច្បាប់សម្រាប់ធ្វើការងារនូវការិយាល័យសហចៅក្រមស៊ើបអង្កេត ។ ហើយទីបី លោកបានធ្វើសច្ចាប្រណិធាននៅចំពោះអង្គជំនុំជម្រះ ដោយពេលនេះ គឺមានភ្ញៀវកិត្តិយសចូលរួមជាច្រើនបានដឹងឮ ហើយអង្គជំនុំជម្រះសង្ឃឹមជឿជាក់លើលោកទាំងពីរថា លោកនឹងប្រឹងប្រែធ្វើកិច្ចការបំពេញភារកិច្ចឲ្យបានល្អប្រសើរ ដូចអ្វីដែលលោកបានធ្វើសច្ចាប្រណិធាន ចំពោះមុខអង្គជំនុំជម្រះនាពេលនេះជាមិនខាន ។

ហើយជាកិច្ចបន្ត គឺអង្គជំនុំជម្រះសូមជូនពរលោកទាំងពីរមានសុខភាពល្អ មានប្រាជ្ញាឈ្លាសវៃទទួលបានជោគជ័យក្នុងការបំពេញភារកិច្ច និងទទួលសេចក្តីសុខក្សេមក្សាន្តសុភមង្គល គ្រប់ពេលវេលា ។ ចប់ប៉ុណ្ណេះ សូមអញ្ជើញទៅចុះ។

អង្គជំនុំជម្រះប្រកាសបញ្ចប់នូវនីតិវិធីធ្វើសម្បថត្រឹមនេះ សម្រាប់សម្បថមន្ត្រីច្បាប់ទាំងពីររូប។ ចប់ហើយសូមអញ្ជើញត្រឡប់ទៅវិញចុះ ។

ជាកិច្ចបន្តសាជាថ្មីម្តងទៀត ខ្ញុំសូមជម្រាបសួរឯកឧត្តម អស់លោក លោកស្រី នាងកញ្ញា ទាំងអស់ដែលមានវត្តមាននៅទីនេះ ។ អនុលោមតាមវិធាន ៧៩.៧ នៃវិធានផ្ទៃក្នុង ដែលបានចែងថា ដើម្បីសម្របសម្រួលដល់ការប្រព្រឹត្តទៅ នៃដំណើរការនីតិវិធីប្រកបដោយយុត្តិធម៌ និងបានឆាប់រហ័ស អង្គជំនុំជម្រះសាលាដំបូងអាចពិគ្រោះយោបល់ជាមួយភាគីទាំងឡាយដោយធ្វើការប្រជុំរៀបចំសវនាការ ហើយដែលកិច្ចការប្រជុំនេះត្រូវធ្វើជាអសាធារណៈ ។

តាមបទពិសោធន៍នៃការគ្រប់គ្រងដឹកនាំកិច្ចពិភាក្សាដេញដោល ចាប់ពីពេលបើកដំណើរការសវនាការរឿងក្តីលេខ០០១ ចាប់ពីថ្ងៃទី៣១ ខែមីនា ឆ្នាំ ២០០៩ មកដល់ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ម្សិលមិញនេះ អង្គជំនុំជម្រះបានកត់សម្គាល់ឃើញថា មានបញ្ហាមួយចំនួនគប្បីអង្គជំនុំជម្រះ លើកយកមកពិភាក្សាពិគ្រោះយោបល់ជាមួយនឹងភាគី និងជាមួយនឹងអង្គភាពពាក់ព័ន្ធជាពិសេសការិយាល័យរដ្ឋបាល អំពីបញ្ហាមួយចំនួនដែលការងាររបស់ការិយាល័យរដ្ឋបាលត្រូវគាំទ្រដល់អង្គជំនុំជម្រះសាលាដំបូង ។ ហើយបញ្ហាទាំងនោះអាចរារាំង ឬក៏នាំឲ្យមានការអូសបន្លាយពេលវេលាដំណើរការសវនាការដេញដោល ។ ហេតុដូច្នេះហើយ អង្គជំនុំជម្រះសាលាដំបូង ឆ្លៀតឱកាសនេះរៀបចំឲ្យមានកិច្ចប្រជុំនាថ្ងៃនេះ។ តាងនាមឲ្យអង្គជំនុំជម្រះសាលាដំបូង ខ្ញុំសូមសម្តែងស្វាគមន៍ចំពោះការអញ្ជើញចូលរួមរបស់ឯកឧត្តមប្រធាន អនុប្រធានការិយាល័យរដ្ឋបាល អស់លោក លោកស្រី នាងកញ្ញាដែលជាតំណាងសហព្រះរាជអាជ្ញា មេធាវី ការពារជនជាប់ចោទ ជនជាប់ចោទ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី

និងដើមបណ្ដឹងរដ្ឋប្បវេណីមួយចំនួន ។ កិច្ចប្រជុំនេះក៏ជាឱកាសមួយល្អសម្រាប់ពិភាក្សា និងផ្លាស់ប្ដូរមតិយោបល់រវាងភាគីទាំងអស់នៃរឿងក្ដី និងអង្គភាពដែលពាក់ព័ន្ធ ដើម្បីសម្របសម្រួលដល់បញ្ហាមួយចំនួនដូចខាងក្រោមនេះ៖

មួយ) ការប៉ាន់ប្រមាណអំពីរយៈពេលសវនាការ ។

ពីរ) លទ្ធភាពចូលរួមក្នុងដំណើរការសវនាការរបស់ភាគី និងការគាំទ្រក្នុងដំណើរការនីតិវិធីសវនាការពីសំណាក់មន្ត្រីបុគ្គលិកចំណុះឲ្យការិយាល័យរដ្ឋបាល ។ ចំនួនថ្ងៃ និងម៉ោងពេលសម្រាប់ធ្វើសវនាការ ការសម្រាកមិនធ្វើសវនាការដោយមូលហេតុថ្ងៃបុណ្យជាតិ បុណ្យអន្តរជាតិ ថ្ងៃដែលត្រូវអង្គបុរេជំនុំជម្រះ យកសាលសវនាការធ្វើសវនាការរបស់ខ្លួន ឬពេលដែលមានកិច្ចប្រជុំពេញអង្គនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

[០៩:២៤:៤៥]

ការណែនាំអនុវត្តវិធាន៨៧ នៃវិធានផ្ទៃក្នុងជាពិសេស វិធាន៨៧.៣ និង៨៧.៦ ដែលអង្គជំនុំជម្រះសាលាដំបូង បានធ្វើសំណើសុំធ្វើវិសោធនកម្មក្នុងកិច្ចប្រជុំពេញអង្គនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែលនឹងប្រព្រឹត្តទៅនាដើមខែកញ្ញា ឆ្នាំ២០០៩ ខាងមុខនេះ ។ ការបែងចែកនូវពេលវេលាសម្រាប់ដើមបណ្ដឹងរដ្ឋប្បវេណី ដែលបានជ្រើសរើសឲ្យមកថ្លែងការណ៍ចំពោះមុខអង្គជំនុំជម្រះតាមសំណើរបស់មេធាវីជាអ្នកតំណាងឲ្យដើមបណ្ដឹងរដ្ឋប្បវេណី និងបញ្ហាផ្សេងៗទៀត ដែលការិយា-ល័យរដ្ឋបាល ឬភាគី ឬអង្គជំនុំជម្រះ ឬចៅក្រមនៃអង្គជំនុំជម្រះ ដែលយល់ឃើញថាមានសារសំខាន់ដល់ការធ្វើសវនាការប្រកបដោយភាពយុត្តិធម៌និងឆាប់រហ័ស ។ អង្គជំនុំជម្រះសាលាដំបូងសង្ឃឹមជឿជាក់លើឯកឧត្ដម អស់លោក លោកស្រី នាងកញ្ញា ពិតជាចូលរួមជ្រោមជ្រែងអង្គជំនុំជម្រះសាលាដំបូងឲ្យដំណើរការដោយរលូន និងដោះស្រាយបញ្ហាមួយចំនួនរួមគ្នាដូចមានក្នុងរបៀបវារៈដែលបានជម្រាបជូនខាងលើ ។

ខ្ញុំសូមប្រកាសបើកនូវ កិច្ចប្រជុំរៀបចំដំណើរការសវនាការចាប់ពីពេលនេះតទៅ ។

ដូចខ្ញុំបានជម្រាបហើយអម្បាញ់មិញនេះ គឺអំពីការរបៀបវារៈដែលប៉ុនប៉ង ក្នុងការលើកឡើងយកមកជជែកពិភាក្សានាពេលនេះ ។ ហើយរបៀបវារៈទីមួយ គឺនិយាយអំពីការប៉ាន់ស្មាននូវកាលវេលាពីបច្ចុប្បន្ននេះរហូតដល់ត្រឹមខែធ្នូ ឆ្នាំ២០០៩ ដោយបញ្ហានេះយើងមានបទពិសោធន៍នៅក្នុងការគណនាពេលវេលាកន្លងមកនេះ ដែលអង្គជំនុំជម្រះបានប្រជុំពិភាក្សាប្ដូរយោបល់គ្នា ហើយដាក់ផែនការរួមនៅ

ក្នុងដំណើរការសវនាការ គឺគណនាបឋម គឺយើងគិតថាត្រឹមតែខែ១១ ប៉ុណ្ណោះ ដែលអាចនឹងបញ្ចប់នូវដំណើរការនីតិវិធីសវនាការដេញដោលរឿងក្តីទីមួយនេះ ។ ប៉ុន្តែ ដោយការកត់សម្គាល់របស់អង្គជំនុំជម្រះកន្លងមកនេះមានបញ្ហាជាច្រើន ដែលនាំឲ្យមានការពន្យារពេលនៃដំណើរការសវនាការដោយហេតុទីមួយ គឺមានបញ្ហាតវ៉ានៅក្នុងអំឡុងពេលនៃដំណើរការសវនាការជាពិសេស គឺការស្តាប់សក្ខីកម្មរបស់អ្នកជំនាញ ក្រេក អេតធេសាន់ ដែលក្នុងខណៈពេលនោះ គឺមានការប្រកាន់យករៀងៗខ្លួននូវនីតិវិធីដែលមានចែងនៅក្នុងវិធាន៨៧ ស្តីពីការពិនិត្យភស្តុតាងដោយជាឯកសារ ដោយការអាន ឬក៏ការសង្ខេបនោះបើប្រៀបធៀបនឹងលទ្ធភាពដែលយើងធ្វើពេលវេលាដែលអាចធ្វើបាន ហើយនិងសំណុំឯកសារដ៏ច្រើនសន្ធឹកសន្ធាប់របៀបនេះ យើងមិនអាចដំណើរការរបៀបនេះបានទេ ។ ហើយអំឡុងពេលនោះ យើងមានចម្រូងចម្រាស់ជាច្រើនដែលអង្គជំនុំជម្រះត្រូវដកថយជាញឹកញាប់ រហូតដល់ថ្ងៃមួយខ្ញុំនៅចាំ គឺស្ទើរតែយើងមិនបានសួរដេញដោលទាល់តែសោះ ដោយសារមូលហេតុនៃបញ្ហាជំទាស់នៃដំណើរការនីតិវិធីនេះដែលយើងជួបប្រទះ ។ ហើយនោះជាការត្រឹមត្រូវដោយសារវិធានចែងដូច្នេះ ហើយច្បាប់ជាតិក៏ចែងដូច្នេះដែរ ។ អ៊ីចឹង យើងមានដំណោះស្រាយកន្លងមកដោយសារការយោគយល់ ដោយសារគឺសម្បទាន គឺយើងអាចដោះស្រាយបាន ។ ប៉ុន្តែ យ៉ាងហោចណាស់ក៏ពេលវេលាដែលយើងបានគណនានោះ គឺបានពន្យារពេលជាច្រើន ។

[០៩:២៩:០២]

ទីពីរ នៅក្នុងអំឡុងពេលនៃជជែកដេញដោលឃើញថា មានបញ្ហាខ្លះ ឃើញថា មានការពន្យារពេល ឬក៏ការបច្ចេកទេសក្នុងការតាំងសំណួរអីផ្សេងៗជាការជាន់គ្នា ជាការអូសបន្លាយ ដែលថាតាំងសំណួរវែង នាំឲ្យមានការឆ្លើយវែង ឬក៏សំណួរហ្នឹងសួរទៅជនជាប់ចោទ គាត់ប្រើប្រាស់នៅក្នុងពេលវេលាដើម្បីបកស្រាយ ។ ពីព្រោះខ្ញុំគិតថា បុគ្គលិកលក្ខណៈសម្បត្តិរបស់គាត់ជាអ្នកជាសាស្ត្រាចារ្យគណិតវិទ្យា គឺជាចិត្តសាស្ត្រតាមការយល់ឃើញរបស់ខ្ញុំ ដែលខ្ញុំបានកត់សម្គាល់ អ្នកដែលមានចិត្តសាស្ត្ររបៀបនេះ តែងតែប្រើប្រាស់វិធីនៅក្នុងការពន្យល់បកស្រាយ ដោយលើកឧទាហរណ៍មកផ្ទុះបញ្ជាំងនូវគំនិតក្នុងការបង្ហាញរបស់ខ្លួន ក្រែងគេមិនយល់ ។ អ៊ីចឹង គឺថាមានការវែង អ៊ីចឹងគឺថា បញ្ហាទាំងអស់នេះ យើងនឹងជជែកវែកញែកគ្នា ។

ហើយចុងក្រោយនេះយើងឃើញថា ដោយសារការពិភាក្សាអូសបន្លាយដូច្នេះហើយ នាំឲ្យមានបញ្ហាម្សិលមិញយើងគិតហើយឃើញថា គ្រោងថា នឹងសួរសាក្សីរហូតដល់ពីរនាក់នៅក្នុងអង្គហេតុ

ជម្លោះប្រដាប់អាវុធ យើងត្រូវអាក់ខានទាំងស្រុងតែម្តង ត្រូវលើកទៅថ្ងៃក្រោយដោយឥតមានកំណត់ទេ ។ នេះជាបញ្ហាដែលជួបប្រទះ ហើយនិងហេតុផលមួយទៀត គឺលទ្ធភាពនៃការតឹងតែងនៃកិច្ចការរបស់អង្គជំនុំជម្រះត្រូវតែធ្វើនៅពេលដែលមានជំទាស់ មានការតវ៉ា មានការកត់សម្គាល់នូវបញ្ហាប្រព្រឹត្តទៅនៃដំណើរការជជែកដេញដោលនោះ ជាកាតព្វកិច្ច ជាមុខងាររបស់អង្គជំនុំជម្រះត្រូវរកដំណោះស្រាយសមស្រប ដែលអាចឲ្យដំណើរការទៅបាន ។ ហើយការជជែកដេញដោលរបៀបនេះឃើញថាត្រូវថយទៅពិចារណា ពេលខ្លះគណនា គ្រាន់តែពេលវេលាថយទៅពិចារណានោះ ក៏យើងគណនាមិនត្រូវដែរ ដោយស្ថានភាពស្មុគស្មាញនៃបញ្ហា យើងដកថយថា មួយម៉ោង មួយម៉ោងកន្លះ យើងដកអត់បានទេ ។ ពេលខ្លះ យើងជាញឹកញាប់យើងមកសុំពន្យារ ពេលនៃការឈប់សម្រាកម្តងហើយ ម្តងទៀត ។ អានេះក៏ជាបទពិសោធន៍របស់អង្គជំនុំជម្រះដែរ ត្រូវគណនាពេលវេលាទាំងអស់នេះ ។

[០៩:៣១:១៥]

ហើយទៅដោយហេតុផលទាំងអស់នេះ គឺអង្គជំនុំជម្រះក៏មានបញ្ហាលំបាកស្មុគស្មាញរបស់ខ្លួនដែលត្រូវចេញសេចក្តីណែនាំ ឬសេចក្តីសម្រេចផ្សេងៗដើម្បីឲ្យប្រព្រឹត្តទៅបាននេះដោយចំណាយពេលវេលាទាំងការពិភាក្សា ទាំងការបកប្រែភាសា ដើម្បីជជែកគ្នាឲ្យបានច្បាស់លាស់ ។ អ៊ីចឹងក៏មានបញ្ហា ។ ដូច្នេះហើយ គឺខ្ញុំសូមដាក់បញ្ហានេះ ដើម្បីជូនអង្គប្រជុំដើម្បីលើកមកពិភាក្សា ថាតើការប៉ាន់ស្មាននៃពេលវេលាហ្នឹង តើអស់លោក លោកស្រីមានយោបល់យ៉ាងដូចម្តេចលើបញ្ហានេះ?

នេះខ្ញុំលើកពីបញ្ហារបៀបវារៈទីមួយមុន ដើម្បីជជែកវែកញែកបញ្ហានេះ ។ ហើយហេតុផលផ្សេងទៀតនោះ គឺមានបញ្ហាព័ត៌មានដែលខ្ញុំទទួលបានពីឯកឧត្តម គង់ ស្រ៊ីម បានធ្វើការជាមួយនឹងឯកឧត្តមអនុប្រធានការិយាល័យរដ្ឋបាលអន្តរជាតិ ដែលលោកបានមានការចាប់អារម្មណ៍ និងសំណូមពរមកខាងខ្ញុំដើម្បីឲ្យពិនិត្យពិចារណារៀបរំកិលនូវកាលវិភាគ សម្រាប់ដំណើរសវនាការឲ្យបានឆាប់រហ័សសម្រាប់ខែ៧ និងខែ៨ ក្នុងគោលបំណងថាបើមានកិច្ចការចាំបាច់នោះ វានឹងងាយក្នុងការដោះស្រាយជាមួយនឹងបុគ្គលិកអន្តរជាតិ ពីព្រោះដូចជា ខ្ញុំមិនយល់ដែរ ខ្ញុំមិនដឹងថាទម្លាប់ ឬក៏របៀបរបបនៅខាងអន្តរជាតិយ៉ាងម៉េចទេថា នៅខែ៨ ឬក៏ខែ៧ ខែ៧ ខែ៨ តែងតែមានការឈប់សម្រាក ឬក៏វ៉ាកង ។ អ៊ីចឹងគឺអាចមានគេដាក់ពាក្យសុំឈប់សម្រាកអ៊ីចឹង ។ ប៉ុន្តែ តម្រូវការរបស់យើងខាងអង្គជំនុំជម្រះ គឺមិនមានការបំណងណាមួយថា មិនធ្វើសវនាការទេ យើងប្រឹងប្រែង ធ្វើសវនាការដោយសារបរិស្ថានសម្ពាធនៃបញ្ហាសង្គមកម្ពុជាបច្ចុប្បន្នសង្កត់មកអង្គជំនុំជម្រះសាលាដំបូងយ៉ាងខ្លាំង អំពីការថា ពន្យារពេលដើម្បី

ផលប្រយោជន៍ផ្ទាល់ខ្លួន ដើម្បីប្រាក់ខែច្រើនអីៗអ៊ីចឹង ឃើញថា ម្តងហើយ ម្តងទៀត មានការថ្លែងការណ៍នៅក្នុងសារព័ត៌មាន ឬក៏វិទ្យុ ឬក៏ទូរទស្សន៍ជាញឹកញាប់ នេះធ្វើឲ្យមានការឈឺក្បាលមែនទែនលើបញ្ហានេះ ។ ហើយដើម្បីច្បាស់ តើលោក លោកស្រីចៅក្រមមានអី បន្ថែមទេ លើរបៀបវារៈទីមួយនេះក្នុងការពិភាក្សា?

[០៩:៣៣:៣២]

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំនឹងចង់បាន ទទួលនូវសំណើពីភាគីពាក់ព័ន្ធនានា និងពីការិយាល័យរដ្ឋបាលទៅលើបញ្ហាមួយចំនួន ហើយប្រហែលជា បើសិនជាខ្ញុំអាចសង្ខេបបាននោះ គឺលោកប្រធានគាត់បានបង្ហាញថា ការវាយតម្លៃបច្ចុប្បន្នរបស់យើងទៅលើអំឡុងពេលនៃការស្តាប់សក្ខីកម្មនៅក្នុងអង្គសវនាការនេះ គឺប្រហែលជាអាចបន្តពេលរហូតដល់ខែធ្នូ ។ យ៉ាងលឿនបំផុត គឺខែធ្នូ ទើបចប់សវនាការនេះ ។ ដូច្នេះ យើងចង់បានព័ត៌មានមួយចំនួនពីភាគីពាក់ព័ន្ធជាពិសេសបើសិនជាអាចមានការបង្ហាញអំពីថ្ងៃខែ ឬក៏ដែលថាមេធាវីនៃដើមបណ្តឹងរដ្ឋប្បវេណីក្រុមមួយបាននិយាយអំពីភាពលំបាកដែលពួកគេនឹងមានលទ្ធភាពក្នុងការចូលរួមនៅក្នុងសវនាការដែលមានរយៈពេលវែងនេះ ។ ដូច្នេះ ពួកយើងខ្ញុំនឹងពេញចិត្តណាស់ បើសិនជាអាចយល់ដឹងបានពីបញ្ហាទាំងនេះទាក់ទងទៅនឹងភាពលំបាករបស់មេធាវី ដូច្នេះ យើងខ្ញុំនឹងបញ្ចូលបញ្ហានេះដើម្បីពិចារណានៅក្នុងការរៀបចំផែនការរបស់យើង ។

[០៩:៣៥:០០]

ចំណុចទីពីរ យើងខ្ញុំក៏នឹងពេញចិត្តដែរ ប្រសិនបើខាងការិយាល័យរដ្ឋបាល អាចលើកឡើងអំពីបញ្ហាដែលជាការបារម្ភនានា ទាក់ទងទៅនឹងការឈប់សម្រាករបស់បុគ្គលិក ហើយនិងធនធានជាដើម ហើយនិងអាចបញ្ហាផ្សេង ដែលពួកគេអាចនឹងមាន ។ ដូច្នេះបើសិនជាមានមតិយោបល់ពីខាងការិយាល័យរដ្ឋបាលនោះ គឺជាការប្រសើរ ។ ដូចដែលលោកប្រធានបាននិយាយអ៊ីចឹង គឺយើងមិនបានរៀបចំការឈប់សម្រាកសម្រាប់សវនាការទេ សម្រាប់ខែកក្កដា និងខែសីហា នោះ ពីព្រោះយើងត្រូវតែបន្តសវនាការទៅមុខទៀត ។ ក៏ប៉ុន្តែ បើសិនជាមេធាវីមួយចំនួនអាចមានបញ្ហានោះ ពួកយើងខ្ញុំចង់ដឹងថាតើពួកគេនឹងអាចបញ្ហាអ្វីទេ សម្រាប់ខែកក្កដា-សីហា នោះ ហើយបើសិនជាសវនាការនៅបន្តរហូតដល់ខែធ្នូ នោះ គឺយើងមានការឯកភាពគ្នាជាបណ្តោះអាសន្នថា យើងត្រូវឈប់មួយរយៈសម្រាប់ពេលបុណ្យណូអែល និងបុណ្យគ្រិស្តស្ហ៊ីស ។ លោកប្រធានក៏បាននិយាយផងដែរ ថាយើងមានការបារម្ភខ្លាំងណាស់

ទៅលើការលើកឡើងនៅសំណួរ ដែលជាន់គ្នាដដែលៗ ហើយនិងសំណួរដែលទាក់ទងទៅនឹងអង្គហេតុដែលមិនទាន់មានមកដល់នៅឡើយ ។ ហើយអង្គជំនុំជម្រះសាលាដំបូង គឺបានឯកភាពដូច្នេះថា នឹងមិនអនុញ្ញាតឲ្យធ្វើការសួរបែបនេះទៀតទេ ។ ទោះបីជាយ៉ាងណាក្តី អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ឃើញការប្រឹងប្រែងកាលពីម្សិលមិញក្នុងការកាត់បន្ថយពេលវេលា ក្នុងការសួរសំណួរ ហើយសូមអរគុណមេធាវីទាំងឡាយដែលបានព្យាយាមកាត់បន្ថយពេលវេលានោះ ។

អង្គជំនុំជម្រះសាលាដំបូងក៏នឹងសួរមេធាវីតំណាងឲ្យរដ្ឋប្បវេណីមួយក្រុមៗ អំពីពេលវេលាដែលពួកគេត្រូវការ ដើម្បីសួរចម្លើយ ហើយនៅពេលដែលដល់ម៉ោងដែលបានកំណត់ហើយនោះ គឺអង្គជំនុំជម្រះនឹងបញ្ឈប់ការសួរចម្លើយនោះ ។ ហើយខ្ញុំក៏ចង់បន្ថែមទៀត អង្គជំនុំជម្រះនឹងពេញចិត្តខ្លាំងណាស់ប្រសិនបើជនជាប់ចោទត្រូវបានស្តាប់ឲ្យបានច្បាស់ទៅលើសំណួរ ហើយត្រូវបានឆ្លើយឲ្យបានសង្ខេបបំផុតទៅតាមការដែលអាចធ្វើទៅបាន ។ ហើយមានកត្តាមួយទៀតដែលលោកប្រធាន បាននិយាយនោះគឺពេលវេលាដែលអង្គជំនុំជម្រះសាលាដំបូងខ្លួនឯងត្រូវការ ដើម្បីដកខ្លួនទៅជំនុំជម្រះដកខ្លួនទៅពិចារណានិងចេញសេចក្តីសម្រេច ហើយដែលសេចក្តីសម្រេចនោះ ត្រូវធ្វើការបកប្រែទៀត ។

[០៩:៣៨:១២]

ដូច្នេះគឺអង្គជំនុំជម្រះមានសម្ពាធខ្លាំងណាស់ នៅក្នុងការធ្វើសេចក្តីសម្រេចបែបនេះនៅក្នុងអំឡុងពេលម៉ោងសវនាការ ។ ដូច្នេះហើយ គឺបង្កឲ្យមានការពន្យារពេលដល់ដំណើរការនីតិវិធីសវនាការនេះជាដើម ។ ដូច្នេះ អង្គជំនុំជម្រះសាលាដំបូង បានពិចារណាយល់ទៅលើការអនុវត្ត ដែលគួរតែគិតថាយើងគួរតែបើកសវនាការបីថ្ងៃក្នុងមួយសប្តាហ៍រៀងរាល់ពីរសប្តាហ៍ម្តង ។ ដូច្នេះ យើងនឹងមានពេលគ្រប់គ្រាន់ ដើម្បីបំពេញភារកិច្ចរបស់យើងទាក់ទងទៅនឹងបញ្ហាផ្សេងៗ និងទាក់ទងទៅនឹងសេចក្តីសម្រេចចិត្តរបស់យើង ។ ពួកយើងយល់ថា នេះគឺនឹងបង្កសវនាការហ្នឹងកាន់តែពន្យារពេលទៅមុខទៀត ។ ប៉ុន្តែកិច្ចការនេះ ជាកិច្ចការចាំបាច់ដែលអង្គសវនាការត្រូវតែធ្វើ ហើយអង្គជំនុំជម្រះសាលាដំបូងនឹងអាចមានការប្រែប្រួលបានទៅលើវិធីសាស្ត្រដែលបានស្នើឡើងនេះ ហើយនឹងធ្វើការប្រកាសថាតើអង្គជំនុំជម្រះនឹងមានផែនការអ្វីសម្រាប់សប្តាហ៍ខាងមុខៗទៀត ។ ដូច្នេះ អ្វីៗដែលលើកឡើងទាំងអស់នេះ គឺជាបញ្ហាដែលលោកប្រធានចង់ឲ្យភាគីពាក់ព័ន្ធនានា បញ្ចេញមតិយោបល់ទៅលើចំណុចអស់ទាំងនេះ ។ ហើយខ្ញុំមិនដឹងថា តើភាគីណាមួយគួរតែឡើងនិយាយមុន ។ លោកប្រធានប្រហែលជាខាងការិយាល័យរដ្ឋបាលអាចនឹងឡើងមុននិយាយពីបញ្ហាពាក់ព័ន្ធទៅនឹងការិយាល័យរដ្ឋបាល ហើយបន្ទាប់មកទៀត

ទើបចាំឲ្យភាគីនៅក្នុងរឿងក្តីនេះ ។ តើជាការត្រឹមត្រូវដែរឬទេ លោកប្រធាន?

**ប្រធានអង្គជំនុំ៖**

បាទ, អញ្ជើញ ។

**លោក គង់ ពិសី៖**

ខ្ញុំសូមមានយោបល់តែបន្តិច ។ សូមអរគុណលោកប្រធាន ។ ខ្ញុំបាទសូមជូនស្នើជាយោបល់បន្តិចទាក់ទងទៅនឹងថ្ងៃឈប់សម្រាក បើសិនជាណាការិយាល័យខាងរដ្ឋបាលហ្នឹង មានកាលវិភាគនៃការឈប់សម្រាកក្នុងខែនីមួយៗហ្នឹង យកមកដាក់បញ្ចាំងទៅ យើងឃើញថាថ្ងៃឈប់សម្រាកហ្នឹង វាមានថ្ងៃឈប់សម្រាករបស់ជាតិផងរបស់អន្តរជាតិផង ។ អ៊ីចឹងយើងគួរតែបញ្ចាំងទៅ យើងឃើញថាតើថ្ងៃឈប់សម្រាកជាតិហ្នឹងគួរតែឈប់នៅថ្ងៃណា? ហើយអន្តរជាតិហ្នឹងឈប់ថ្ងៃណា? ហើយឯកភាពគ្នានៅពេលហ្នឹង អាថ្ងៃឈប់សម្រាកជាតិសិន ។ សូមអរគុណប៉ុណ្ណឹង ហើយទុកនាទីនេះ ជូនទៅខាងរដ្ឋបាល ។

[០៩:៤២:០៦]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញប្រធាននិងអនុប្រធានការិយាល័យរដ្ឋបាល សូមមានការពាក់ព័ន្ធនឹងបញ្ហា ព្រោះជាសំណើសុំរបស់ខាងការិយាល័យរដ្ឋបាលពាក់ព័ន្ធជាមួយនឹងស្ថានភាពនៃការគាំទ្ររបស់បុគ្គលិក ជាពិសេសបុគ្គលិកអន្តរជាតិ ដែលនឹងអាចមានបញ្ហានៅក្នុងអំឡុងពេលខែ៧ ខែ៨ ដែលជារដូវនៃការឈប់សម្រាកវ៉ាកងរបស់អន្តរជាតិ ហើយនិងនៅក្នុងអំឡុងពេលខែ១២ គឺខែធ្នូ ឬខែមករា ដែលពាក់ព័ន្ធជាមួយនឹងបុណ្យគ្រីះស្មាស់ បុណ្យដាច់ឆ្នាំ នោះគឺអាចមានបញ្ហា ប្រសិនបើភាគីផ្សេងទៀតបានព្រមព្រៀងគ្នាហើយបើខាងការគាំទ្ររបស់ខាងអន្តររដ្ឋបាល មិនអាចមានលទ្ធភាពនៅក្នុងការគាំទ្រ ដល់ដំណើរការបាននោះ ក៏ការព្រមព្រៀងរបស់ភាគីផ្សេងទៀតហ្នឹង ក៏អត់មានន័យអីដែរ ។ អ៊ីចឹងហើយបានជាមានការចាប់អារម្មណ៍ថា សូមលើកបញ្ហានេះ ។ ហើយអំមិញខាងមេធាវី គាត់សុំឲ្យមានការស្នើសុំអំពីការកំណត់នៅកាលវេលានៃការឈប់សម្រាកប្រចាំឆ្នាំសម្រាប់ទាំងបុណ្យជាតិ និងបុណ្យអន្តរជាតិ ។ ខ្ញុំគិតថា ភាគីផ្សេងទៀតដូចមានរួចហើយ មិនដឹងថាមេធាវី ប្រហែលជាខាងរដ្ឋបាលមិនបានផ្តល់ឲ្យនូវឯកសារទាំងអស់នោះ ឬក៏យ៉ាងម៉េច?

បញ្ហាទីពីរ ក៏ចាប់អារម្មណ៍ផងដែរ ដោយសារបញ្ហាបុណ្យជាតិ គឺថានៅក្នុងអនុក្រឹត្យស្តីពីការ

កំណត់ថ្ងៃបុណ្យឈប់សម្រាកប្រចាំឆ្នាំហ្នឹង គឺមានថ្ងៃសងជំនួស ។ ប្រសិនបើយើងមិនភ្លេចអាថ្ងៃសងជំនួសហ្នឹង ក៏អាចមានបញ្ហាដែរ ត្រូវគិតគូរឲ្យហើយពីបញ្ហាថ្ងៃសងជំនួស បើឈប់ចំថ្ងៃសៅរ៍ ឬថ្ងៃអាទិត្យ គឺត្រូវសងជំនួសមួយថ្ងៃបន្ទាប់ ។ នេះជាច្បាប់ ជាអនុក្រឹត្យ ដែលចេញដោយរាជរដ្ឋាភិបាលកម្ពុជា ។ អ៊ីចឹងគឺយកមកគិតនៅក្នុងបញ្ហានេះដែរ ដើម្បីយើងដកចេញ ចាត់ទុកថាជាថ្ងៃឈប់សម្រាកអាហ្នឹងបានយើងធ្វើទៅបាន ។

សូមអញ្ជើញ បើសិនជាមានការពាក់ព័ន្ធនឹងបញ្ហាថានេះ ។ លោកឯកឧត្តមប្រធានស្ដីទី ឬក៏ឯកឧត្តមអនុប្រធាន ។

[០៩:៤៤:១៣]

**លោក ក្រាញ់ តូនី៖**

សូមគោរពអង្គប្រជុំឯកឧត្តមប្រធាននិងអង្គប្រជុំទាំងមូល! ពាក់ព័ន្ធលើបញ្ហាការឈប់សម្រាកនេះ ខ្ញុំសូមអនុញ្ញាតមានមតិជាខ្លី ខ្ញុំបាទយល់ឃើញថា កិច្ចការអាទិភាព គឺដំណើរការនៃសវនាការអាទិភាពទីមួយ ។ ពាក់ព័ន្ធនឹងសិទ្ធិក្នុងការឈប់សម្រាករបស់បុគ្គលិក និងអ្នកធ្វើការនៃអ្នករដ្ឋបាលយើងខ្ញុំ ខ្ញុំបាទយល់ឃើញថា រដ្ឋបាលនឹងសម្របសម្រួលទៅតាមក្រោយ ។ យល់ឃើញថា អាទិភាពទីមួយ គឺដំណើរការរបស់សវនាការ ។ ការឈប់សម្រាក រដ្ឋបាលយើងនឹងសម្របសម្រួលទៅតាមនោះ គឺអត់មានអ្នកណាបាត់សិទ្ធិក្នុងការឈប់សម្រាកទេ ។ ប៉ុន្តែ ក្នុងដំណើរការ ខ្ញុំយល់ឃើញថា អាទិភាពទីមួយ គឺអង្គសវនាការ ។ ខ្ញុំបាទសូមមានមតិខ្លីប៉ុណ្ណឹងសិន ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

ខ្ញុំគិតថា អាហ្នឹងប្រហែលជានៅក្នុងអំឡុងពេលខែកក្កដា ឬក៏ខែសីហាទេ ។ ចុះចំណែកដល់ខែធ្នូវិញ ពីព្រោះគម្រោងផែនការនៃយើងវិញ យើងមានការធ្វើការរួម ហើយនិងផែនការកិល តាមបីខែម្ដង ។ អ៊ីចឹងអាផែនការរួមហ្នឹង បើសិនជាយើងធ្វើ វាត្រូវ យើងប្រហែលជាយើងគណនាពេលវេលាអីវាត្រូវហើយ ពីព្រោះយើងគណនាម្ដងហើយ ម្ដងទៀត ដូចជាវាមិនត្រឹម ពីព្រោះបញ្ហាហ្នឹង ខែ១២ ថាតើយើងត្រឹមតែយ៉ាងម៉េចនៅលទ្ធភាពនៃការបុណ្យទាន ដែលគេត្រូវទៅជួបជុំគ្រួសារ ប្រពន្ធកូនគេអីហ្នឹង អាចមានបញ្ហាយ៉ាងម៉េចខ្លះ ពីព្រោះបញ្ហានេះ ជាវប្បធម៌ ជាផ្នែកខាងបុណ្យជាតិ នៅពេលដែលមានការចាប់អារម្មណ៍ ជាពិសេសអឺរ៉ុប ខ្ញុំគិតថាមានការចាប់អារម្មណ៍ខ្លាំងណាស់នៅពេលដែលបុណ្យណូអែលនេះ គឺជាបុណ្យធំរបស់គេ ។

**លោក ក្រាញ់ តូនី៖**

លោកប្រធានអាចឲ្យខ្ញុំមានមតិម្តងទៀត គឺថាក្នុងអ្វីដែលខ្ញុំនិយាយថា នឹងការសម្របសម្រួលហ្នឹង ខ្ញុំបាទគិតឃើញក្នុងខែ១២នេះហើយបាទ ខ្ញុំចង់ជម្រាបឯកឧត្តម និងអង្គជំនុំជម្រះ អង្គប្រជុំយើងទាំងមូលថា ក្នុងកិច្ចការនេះ ភាគីខ្មែរ ក៏ដូចភាគីអន្តរជាតិដែរ បានឯកភាពគ្នាលើគោលការណ៍រួមហើយ ។ យើងចង់មានភាសាតែមួយក្នុងការងារនេះ ហើយជាសរុបមកគឺថា យើងអាចប្រមើលមើលគិតមើលទៅក្នុងការឈប់សម្រាកនេះ នៅចុងឆ្នាំនេះហើយបាទដែលយើងហៅថា បុណ្យណូអែលបុណ្យចូលឆ្នាំសកលនេះ យើងអាចសម្របសម្រួលក្នុងពេលនោះ ។ ខ្ញុំមិនដឹងថា ខ្ញុំឆ្លើយនឹងសំណួរលោកប្រធានទេ ឬមួយក៏ឯកឧត្តមប្រធានអនុញ្ញាតឲ្យលោក ឃ្មុត មានចំណាប់អារម្មណ៍ ។ សូមអរគុណ ។

[០៩:៤៦:៣៩]

**ប្រធានអង្គជំនុំ៖**

បញ្ហានេះ វាមានបន្តិច វាអាចខុសគ្នាបន្តិច បញ្ហាដែលខ្ញុំបានធ្វើផែនការនេះរួចហើយនេះ វាមានការជជែកគ្នាមួយថា រវាងក្នុងខែ១២ យើងយកពីរសប្តាហ៍ តែឧបមាយើងយកសប្តាហ៍ទីមួយ និងសប្តាហ៍ទីពីរ ហើយធ្វើសវនាការ ។ បានន័យថាលទ្ធភាពសប្តាហ៍ទីបី ដែលទាំងគាត់ធ្វើដំណើរផងអាចទៅទាន់ពេលដែលគាត់ទៅបុណ្យទានតាមសាសនា តាមប្រពៃណី ជនជាតិនីមួយៗនៅអឺរ៉ុបនោះ តើវាសម្របទេ ឬក៏យើងថា អេ៎! វាធ្វើអ៊ីចឹង វាអាចថា វាអាចនាំឲ្យប៉ះពាល់ដល់ដំណើរការទៅ ដូចតែអត់បានទៅដែរហ្នឹង គ្រាន់តែទៅដល់ប្អូនដប់ថ្ងៃអ៊ីចឹង វាអាចមិនទាន់អ៊ីចឹង ។ ជានេះជារឿងដែលយើងត្រូវរកដោះស្រាយ ពីព្រោះថ្ងៃឆ្នាំទៅ ខ្ញុំឃើញមានកត់សម្គាល់អ៊ីចឹង កត់សម្គាល់ផ្ទាល់ថា ដល់ពេលចុងខែ១២នេះ ហាក់ដូចជាមនុស្សមានការថយច្រើន បានន័យថា មនុស្សថយច្រើនពីនៅក្នុងអង្គភាពរបស់យើង ជាពិសេសខាងអន្តរជាតិ ដោយសារការបុណ្យណូអែលនេះ ការបុណ្យចុងឆ្នាំនេះ ។ អ៊ីចឹង យើងចង់បញ្ជាក់បញ្ហាឲ្យច្បាស់ ប្រសិនទៅឥឡូវលទ្ធភាពថា អាចបើមានគឺត្រឹមតែសប្តាហ៍ទីបី ទីបួន ខែធ្នូ ។

អ៊ីចឹងយើងគិតគណនាថា ខែ១២ ពីរអាទិត្យនៃសប្តាហ៍ទីមួយ ទីពីរ នៃខែ១២នេះ យើងត្រូវកំណត់ជាក់លាក់ថា ធ្វើដំណើរការសវនាការ ។ ហើយបើបានលើសនេះ ក៏រឹតតែល្អដែរ ពីព្រោះប្រឹងប្រែង ដើម្បីឲ្យការដោះស្រាយបញ្ហាហ្នឹង ទោះបីមានការរិះគន់ទិតៀន ពីសាធារណជនក្តី ប៉ុន្តែឲ្យកត់សម្គាល់ថា កិច្ចប្រឹងប្រែងរបស់យើង គឺប្រឹងប្រែងឲ្យអស់ពីលទ្ធភាព អស់ពីស្ថានភាពដែលអាចធ្វើទៅ

រួច ។ ដោយសារទំហំរឿង និងបញ្ហាស្មុគស្មាញនៃរឿងទេ ដែលនាំឲ្យយើងមានការយឺតយ៉ាវនោះ ។

សូមអញ្ជើញលោកស្រីចៅក្រម ។

[០៩:៤៨:៣០]

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំមិនទាន់ច្បាស់ទេថា អាចនឹងស្ដាប់ភាសាអង់គ្លេសបកប្រែច្បាស់ដែរឬទេ? ប៉ុន្តែ អង្គជំនុំជម្រះសាលាដំបូងបម្រុងនឹងឲ្យបុគ្គលិកទទួលយកទាំងអស់នៅថ្ងៃបុណ្យជាតិ ថ្ងៃបុណ្យសាធារណៈ ជាបុណ្យដែលមានកំណត់រួចស្រេចហើយ ហើយនិងការរំឭកបុណ្យខួបអីផ្សេងៗ ដែលបានកំណត់ជាផ្លូវការរួចហើយ ហើយក៏អង្គជំនុំជម្រះ ក៏នឹងការធ្វើសវនាការពីរថ្ងៃនៅក្នុងសប្ដាហ៍មួយនៅក្នុងខែកក្កដា ដែលថាអង្គបុរេ ក៏នឹងប្រើសាលសវនាការដែរ ។ ហើយបន្ទាប់មកទៀត នឹងមានកិច្ចប្រជុំពេញអង្គក្នុងថ្ងៃទី៧ ហើយនិងថ្ងៃទី១១ ខែកញ្ញា ហើយនិងក្នុងពេលនោះ គឺអង្គជំនុំជម្រះសាលាដំបូងមិនបាន មិនគ្រោងថា នឹងធ្វើសវនាការនៅបន្ទាប់ពីនោះទេ ។ អ៊ីចឹងហើយការប៉ាន់ប្រមាណពេលវេលារបស់យើងសម្រាប់ការបញ្ចប់ការធ្វើសវនាការលើសក្ខីកម្ម នៅខែធ្នូឆ្នាំនេះ គឺការគម្រោងបញ្ចប់នោះ គឺយើងមិនទាន់ប្រាកដថានឹងមានពេលនៅក្នុងខែធ្នូ ដើម្បីឲ្យមានសេចក្ដីសន្និដ្ឋានស្ដាពរ ដើម្បីឲ្យមានជាសាលក្រមនោះទេ ។ អ៊ីចឹងហើយនៅក្នុងឆ្នាំថ្មីមួយទៀត យើងអាចនឹងទទួលការស្គាល់ ទទួលស្គាល់នូវការភ្ជាប់ទំនាក់ទំនងពីដំណាក់កាលនៃសវនាការនេះ ។ សូមអរគុណ ។

**លោក អាឡាំង វែ៉នណឺ៖**

ខ្ញុំអភ័យទោសដែលខ្ញុំរំខាន ហើយសូមឲ្យលោកស្រី ខាតវ៉ាយថ៍ សូមបញ្ជាក់ម្ដងទៀត ថាតើថ្ងៃណាខ្លះក្នុងខែកក្កដា ដើម្បីយើងអាចកត់ត្រាបាន លោកស្រីបានបញ្ជាក់ចំណុចផ្សេងទៀត ។ សូមបញ្ជាក់ឲ្យបានច្បាស់ ហើយយើងមិនដឹងច្បាស់ ថាតើមួយសប្ដាហ៍ពេញ ឬក៏បើសិនជាលោកស្រីដឹងថា-- ដឹងច្បាស់ហ្នឹង?

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

ខ្ញុំគ្រាន់តែសួរទៅភាគអំពីថា ថ្ងៃច័ន្ទ ដល់ថ្ងៃអង្គារនៅក្នុងសប្ដាហ៍ហ្នឹងគឺថា បានគ្រោងសម្រាប់អង្គបុរេជំនុំជម្រះ ដែលអ៊ីចឹងហើយតុលាការនេះនឹងធ្វើសវនាការថ្ងៃច័ន្ទ និងថ្ងៃអង្គារ ។ អ៊ីចឹងគឺថាក្រឡាបញ្ជីនឹងបញ្ជាក់កាលថ្ងៃជាក់លាក់ ។ អ៊ីចឹងពីថ្ងៃទី៧ ដល់ថ្ងៃទី១១ នៅក្នុងខែកញ្ញា អ៊ីចឹងហើយយើងមានស្រាប់ហើយអំពីថ្ងៃបុណ្យជាតិ និងបុណ្យជាផ្លូវការហ្នឹងគ្រប់ស្រេចជាមួយនោះ ។ អ៊ីចឹង នៅថ្ងៃទី២៧

និងថ្ងៃទី២៨ នៃខែកក្កដា ថ្ងៃដែលសល់ក្នុងសប្ដាហ៍ៗនោះ អង្គបុរេជំនុំជម្រះ និងប្រើសាលសវនាការដើម្បីគោលបំណងរបស់គាត់ ។ តើលោកមេធាវីច្បាស់ទេ?

**លោក អាឡាំង វ៉ែនណឺ៖**

ច្បាស់ហើយ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

ឯកឧត្ដមប្រធានរដ្ឋបាលអំមិញខាងមេធាវីការពារក្ដី មេធាវីតំណាងខាងដើមបណ្ដឹងរដ្ឋប្បវេណីគាត់ ប្រហែលជាគាត់បានទទួលនូវសេចក្ដីកំណត់ ស្ដីពីកាលបរិច្ឆេទនៃការឈប់សម្រាកជាតិ និងអន្តរ-ជាតិ អាចជូនឲ្យគាត់បានទេ?

ចែកជូនទៅគាត់ទៅ ហើយខាងអង្គជំនុំជម្រះដូចមានគ្រប់សព្វ ។ ហើយលោកមេធាវីគិតផងបញ្ហានេះមានៗការអនុក្រឹត្យស្ដីពីការកំណត់ថ្ងៃឈប់សម្រាកហ្នឹង គឺវាអាចនាំឲ្យមានការដែលគិតហ្នឹងត្រូវតែគិតផ្គូផ្គងជាមួយនិងប្រក្រតិទិនទៀតទើបអាចត្រូវ ។ យកទៅដល់ផ្គូផ្គងជាមួយនឹងប្រក្រតិទិនផ្ទៀតផ្ទាត់រួចហើយ បានន័យថានៅការសងជំនួសទៀត ថ្ងៃឈប់សម្រាកថ្ងៃសៅរ៍ អាទិត្យហ្នឹង គឺត្រូវសងជំនួសមួយថ្ងៃទៀត ។ ពិតមែនតែថ្ងៃហ្នឹង គឺមិនឲ្យសម្រាក ប៉ុន្តែការកំណត់ថ្ងៃសម្រាកចំថ្ងៃសៅរ៍អាទិត្យត្រូវជំនួសមួយថ្ងៃទៀត អ៊ីចឹងអាមួយថ្ងៃធ្វើការដាក់នៅក្នុងប្រក្រតិទិននេះត្រូវគូសចេញដែរ ។ បានន័យថា ត្រូវសម្រាក មិនធ្វើការដែរ ។

[០៩:៥៣:០០]

តំណាងសហព្រះរាជអាជ្ញាមានបញ្ហាអីទេ ពីបញ្ហាដែលបានលើកឡើងអំពីកាលវេលានៃដំណើរការសវនាការនេះ?

**លោក សេង ប៊ុនឃាង៖**

សូមអរគុណលោកប្រធាន ។ ដែលអនុញ្ញាតឲ្យតំណាងអយ្យការបញ្ចេញយោបល់ទាក់ទងនឹងកាលបរិច្ឆេទបញ្ចប់សវនាការនៃអង្គជំនុំជម្រះសាលាដំបូងនេះ ។ តំណាងអយ្យការយល់ដឹងថា អំពីភាពលំបាករបស់អង្គជំនុំជម្រះសាលាដំបូង ប៉ុន្តែ និយាយដោយស្មោះទៅ គឺឃើញថា វាហាក់បីដូចជាមានរយៈពេលវែងបន្តិច ។ ហើយតំណាងអយ្យការសូមស្នើដោយគោរពថា រយៈពេលនេះគួរតែកាត់បន្ថយឲ្យបានខ្លីតាមដែលអាចធ្វើទៅបាន ។ ហើយឬក៏យ៉ាងហោចណាស់គួរកំណត់មិនឲ្យហួសត្រឹមខែតុលាឆ្នាំ២០០៩ ព្រោះថារយៈពេលដែលកំណត់ដោយអង្គជំនុំជម្រះសាលាដំបូងនេះ ហាក់បីដូចជាយូរបន្តិច

ហើយ ។ ហើយវាអាចធ្វើឲ្យប៉ះពាល់ទៅដល់មតិជាតិ ឬក៏មតិអន្តរជាតិ អំពីដំណើរការរបស់អង្គជំនុំជម្រះនេះ ។

[០៩:៥៥:០២]

តំណាងអយ្យការយល់ឃើញថា វាជាការពិតហើយដែលសំណុំរឿងនេះ វាមានភាពលំបាកស្មុគស្មាញច្រើន ហើយដែលត្រូវតែបង្ហាញភស្តុតាង និងធ្វើការបំភ្លឺឲ្យបានច្បាស់ ដើម្បីរកឲ្យឃើញអំពីការទទួលខុសត្រូវរបស់ជនត្រូវចោទ ។ បើយើងគិតពីពេលវេលាចាប់ពីថ្ងៃបើកសវនាការរបស់អង្គជំនុំជម្រះសាលាដំបូង នៅថ្ងៃទី៣០ ខែមីនា រហូតមកដល់ខែតុលា ដែលតំណាងអយ្យការបានស្នើសុំអម្បាញ់មិញនេះ គឺវាមានរយៈពេលប្រាំពីរខែ ។ អ៊ីចឹងរយៈពេលនេះ គឺវាជារយៈពេលមួយសមល្មមដែលអាចបញ្ចប់សំណុំរឿងក្តីនេះបាន ។

សហព្រះរាជអាជ្ញាជឿជាក់ថា សំណុំរឿងនេះគួរតែបញ្ចប់ឲ្យបាននៅចុងខែតុលា ឆ្នាំ២០០៩ គឺជាការសមរម្យ ពីព្រោះដើម្បីជួយឲ្យបង្ហាញអំពីភាពជឿជាក់របស់មតិសាធារណៈអំពីដំណើរការរបស់អង្គជំនុំជម្រះយើងនេះ ។ ហើយជាពិសេស ជួយដល់ប្រជាជនកម្ពុជាឲ្យបានយល់ដឹងឲ្យច្បាស់អំពីអ្វីដែល កើតមានឡើងទាក់ទងនឹង ជាពិសេសគឺអ្វីដែលកើតមានឡើងនៅក្នុងមន្ទីរ ស-២១ ដែលមានជនជាប់ចោទជាអ្នកគ្រប់គ្រង ។

[០៩:៥៦:៤៩]

ហើយបញ្ហានេះ គឺដើម្បីស្វែងរកយុត្តិធម៌ និងស្វែងរកការពិតចំពោះជនរងគ្រោះដែលបានកើតឡើងកន្លងមកផងដែរ ។ អ៊ីចឹងបញ្ហានេះ តំណាងអយ្យការគិតថាវាប្រហែលជាមិនជាការងាយពេកទេ ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយតំណាងអយ្យការជឿជាក់ថា ប្រហែលជាអាចធ្វើទៅបាន ហើយសហការីអន្តរជាតិរបស់ខ្ញុំនឹងបង្ហាញអំពីភាពលម្អិតនេះបន្ថែមទៀត ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ។

**លោក វីលៀម ស្មីត៖**

សហព្រះរាជអាជ្ញាសូមអរគុណលោកប្រធាន សូមអរគុណលោកចៅក្រម ហើយនិងភាគីទាំងអស់ ។ លោកចៅក្រមយើងអរគុណដែលបានផ្តល់ឱកាសឲ្យយើងថ្ងៃនេះ ដើម្បីគិតរកដំណោះស្រាយដែលត្រូវលើកមកពិចារណា ដើម្បីធ្វើឲ្យការជំនុំជម្រះរបស់យើងអាចបញ្ចប់បានដោយមានប្រសិទ្ធភាព

ដោយយុត្តិធម៌ នៅក្នុងរយៈពេលដែលសមស្របមួយ ។

ខ្ញុំគិតថា ជាការពិតណាស់ដែលយើងអាចនិយាយថា យើងទាំងអស់គ្នានៅទីនេះ យើងយល់អំពីសម្ពាធមកពីសាធារណជនហ្នឹងច្រើនណាស់ ។ ជាពិសេសពីសហគមន៍អន្តរជាតិ ដើម្បីឲ្យការជំនុំជម្រះនេះបញ្ចប់នៅក្នុងយុត្តិធម៌ ដោយយុត្តិធម៌ ហើយឲ្យបានឆាប់រហ័សទៀត ។ ហើយយើងមានការគោរពជាច្រើនទៅលើគោលការណ៍ ដែលថាតើយើងបញ្ជាក់ហេតុផលថា ហេតុអីបានជាការជំនុំជម្រះត្រូវការប្រើពេលចំនួនប៉ុន្មានខែ ឬឆ្នាំ ក៏ដោយក៏យើងនឹងត្រូវប្រឈមមុខនឹង-- ហើយនិងសាធារណជនជាតិ និងអន្តរជាតិដែលគេយល់ថា ការដំណើរការហ្នឹងគឺមិនសម្រេចបានដូចអ្វីដែលគេគិតនោះ ។ អ៊ីចឹងហើយសាធារណជនគេនឹងពិនិត្យមើល ។ ខ្ញុំនិយាយពីសាធារណជននោះ ខ្ញុំនិយាយពីសង្គម សហគមន៍ជនស៊ីវិល ហើយនិងអន្តរជាតិ និងអន្តរជាតិ ហើយនិងសហគមន៍អ្នកច្បាប់ ហើយនិងរដ្ឋាភិបាល ។ អ៊ីចឹងហើយគឺថា តើតុលាការនេះមានលទ្ធភាពអាចនឹងដោះស្រាយបញ្ហារឿងក្តីទីពីរ បានដែរឬអត់?

ដោយហេតុថា នៅក្នុងរឿងក្តីនោះ គឺថាវាមានទំហំធំ វាមានភាពស្មុគស្មាញជាង អ៊ីចឹងហើយហើងនឹងទទួលការវិនិច្ឆ័យលើលទ្ធភាពរបស់យើង ក្នុងការដោះស្រាយរឿងក្តីទីមួយនេះ បានមានប្រសិទ្ធភាពលឿនដែរឬអត់?

[០៩:៥៩:៣០]

អ៊ីចឹងហើយនឹងទទួលការវិនិច្ឆ័យថា តើយើងអាចនឹងធ្វើលើរឿងផ្សេងទៀតដែលថា តើយើងអាចធ្វើនៅលើរឿងក្តីទីពីរបានឬមិនបាន? អ៊ីចឹងហើយការពិតដែលយើងប្រឈមមុខទាំងអស់គ្នានៅតុលាការនេះ ។ ខ្ញុំក៏សូមអរគុណផងដែរ ដែលលោកចៅក្រមបានកត់សម្គាល់ថា វិធីដែលការជំនុំជម្រះដែលអនុវត្តបន្តមក ហើយបន្តតាមរបៀបដែលយើងធ្វើហ្នឹងគឺយើងមិនបញ្ចប់ទេ នៅឆ្នាំក្រោយ នៅឆ្នាំ ២០១០ នៅក្នុងពិធីបុណ្យណូអែលផងដែរនោះ ។ នៅក្នុងករណីនេះ យើងនឹងមើលក្នុងខែមីនា ឬក៏ខែមេសា ឆ្នាំ២០១០ ។

លោកចៅក្រម ប្រហែលជាគំនិតមួយខ្ញុំអាចនិយាយឆ្លើយតបទៅនឹងរបៀបវារៈថ្ងៃនេះ ហើយនិងមានប្រធានបទមួយចំនួនយើងបានបញ្ចូលទៅនឹងជាចំណុចមួយ ហើយចំណុចនោះ ថាតើការជំនុំជម្រះហ្នឹងអាចនឹងបញ្ចប់បានដោយជាក់ស្តែងនៅពេលណា ហើយនិងធ្វើដោយរបៀបណា? ខ្ញុំសូមអនុញ្ញាតពន្យល់ចំណុចមួយមុននឹងចូលទៅដល់សេចក្តីលម្អិត ហើយអ៊ីចឹងហើយយើងមានតារាងនៅក្នុងការិយាល័យសហចៅក្រមស៊ើបអង្កេត ។ អ៊ីចឹងហើយដែលយើងអាចនឹងបញ្ជាក់ចំណុចពិសេសបាន

ហើយអ៊ីចឹងហើយខ្ញុំចង់លើកជំហររបស់ព្រះរាជអាជ្ញាមកពិភាក្សាដែរ ។

[១០:០០:៥៥]

នៅពេលដែលសាលាក្តីនេះចាប់ផ្តើមដំបូងនោះ សមាជិកទាំងអស់នៃបុគ្គលិក គឺមានការបណ្តុះបណ្តាលទាំងចៅក្រម សហព្រះរាជអាជ្ញា អ្នកស៊ើបអង្កេត ហើយយើងបានលើកឡើងគំនិតមួយចំនួនដែលចៅក្រមក្នុងប្រព័ន្ធស៊ីវិលនៅក្នុងតុលាការនេះ ។ អ៊ីចឹងហើយដំណាក់កាលស៊ើបអង្កេតនោះ គឺថាមាន ៨០% នៃពេលវេលាដែលប្រើនៅក្នុងប្រព័ន្ធស៊ីវិល ហើយនៅក្នុងដំណាក់កាលជំនុំជម្រះនោះ គឺថាអាចនឹង២០% ។ អ៊ីចឹងយើងពិនិត្យមើលទៅ នៅក្នុងនេះគឺថា យើងទំនងជាការជំនុំជម្រះវែងជាងការស៊ើបអង្កេតទៅវិញ ដែលគេប្រើនៅក្នុងប្រព័ន្ធស៊ីវិលដែលសម្រាប់យកមកប្រើក្នុងតុលាការនេះ ។ នៅក្នុងន័យនេះជាក់ស្តែងយើងសូមជំរុញលើកទឹកចិត្ត ដើម្បីឲ្យប្រើប្រព័ន្ធស៊ីវិលឲ្យបានត្រឹមត្រូវ ។

ដូចបានបញ្ជាក់ពីបញ្ហានេះ លោកចៅក្រមជាទីគោរព! គឺសហព្រះរាជអាជ្ញាបានដឹងច្បាស់ហើយអំពីការលំបាកក្នុងការបង្កើតនៅតុលាការនេះ ហើយនិងទទួលឲ្យបាននូវការស្រុះស្រួលមតិគ្នា ហើយនិងការអនុវត្តនៅក្នុងបរិដ្ឋានថ្មីនៃការងារ ។ ហើយជាបទពិសោធខុសគ្នា ហើយនៅក្នុងន័យនេះឯងយើងក៏បានយល់ដែរថា អ្វីដែលបានធម្មតា ដែលយើងនឹងប្រើពេលនោះ ប្រហែលជាពេលវេលាបន្ថែមត្រូវតែយកមកអនុវត្ត ដែលអាចនឹងធ្វើទៅកើត ។ ដូច្នេះហើយការជំនុំជម្រះទំនងជានឹងមានរយៈពេលវែងជាងរយៈពេលនៃការស៊ើបអង្កេត នេះហើយជាចំណុចដែលមិនត្រូវចាត់ទុកថាជាប្រព័ន្ធល្អនៅក្នុងប្រព័ន្ធនេះទេ ។

[១០:០២:៤១]

នោះខ្ញុំចង់និយាយដែរថា គឺភាគីពាក់ព័ន្ធទាំងអស់ដែលជាអ្នកដាក់រួមបញ្ចូលបណ្តាលឲ្យសវនាការនោះ វាអាចមានពេលវែងជាងនោះ ។ បើសិនជាយើងចង់និយាយទៅ គឺថាវាទាក់ទងទៅនឹងគោលបំណងរបស់ភាគីនីមួយៗ ហើយវាមិនបានគិតអំពីបច្ចេកទេសពិសេស ឬក៏ពីប្រភេទសំណួរដែលត្រូវសួរ ។ អ៊ីចឹងខ្ញុំគិតថា អ្វីដែលខ្ញុំនិយាយហ្នឹង គឺខ្ញុំនិយាយតំណាងឲ្យខាងការិយាល័យសហព្រះរាជអាជ្ញា គឺយើងទាំងអស់គ្នាមានភារកិច្ច ដើម្បីធ្វើឲ្យដំណើរការហ្នឹងបានដំណើរការទៅដោយមានប្រសិទ្ធភាពនិងឆាប់រហ័ស ។ ហើយទាក់ទងទៅនឹងចំណុចនេះ លោកចៅក្រមខ្ញុំបានស្តាប់ឮនៅអ្វីដែលលោកចៅក្រមបាននិយាយហើយ ។ ឥឡូវនេះគឺជាសវនាការអសាធារណៈនៅថ្ងៃនេះ ដើម្បីឲ្យយើងបញ្ចេញមតិទាំងអស់គ្នា ។ ហើយយើងបាននិយាយថា រាល់មតិយោបល់ទាំងអស់ដែលបានដាក់បញ្ចេញពីខាងការិយា-

ល័យសហព្រះរាជអាជ្ញាហ្នឹង គឺថាត្រូវតែយកទៅប្រើយ៉ាងពេញលេញនោះទេ ។ ប៉ុន្តែនេះគ្រាន់តែជាគំនិតមតិយោបល់សម្រាប់ការពិចារណាសម្រាប់អង្គសាលាដំបូង និងភាគីព័ន្ធនានាពិចារណានៅពេលដែលយើងបន្តទៅមុខទៀត ។

[១០:០៣:៥៨]

មុននឹងខ្ញុំនិយាយអំពីវិធីសាស្ត្រដែលខ្ញុំគិតថា ហ្នឹងយើងអាចបញ្ចប់ការជំនុំជម្រះនេះនៅមុនថ្ងៃ ៣១ ខែតុលា នោះ ទោះបីជាយើងយល់ថា ប្រហែលជាមិនអាចធ្វើបានក៏ដោយក៏ខ្ញុំនឹងអាចលើកអំពីចំណុចដើម្បីបញ្ជាក់ដែរ ។ ខ្ញុំចង់លើកអំពីវិធានមួយ ចំណុចសំខាន់ជាសារវន្តសម្រាប់អង្គជំនុំជម្រះនេះ គឺដើម្បីធានាថា តុលាការហ្នឹងគឺមានយុត្តិធម៌ ហើយនិងត្រូវបានលឿនទៅតាមលក្ខន្តិកៈដែលមានចែងនៅក្នុងមាត្រាទី៣១ ហើយក៏ជាចំណុចសំខាន់ផងដែរ ដែលយើងយល់ថាការបកស្រាយទៅលើលក្ខន្តិកៈហ្នឹង គឺយើងបកស្រាយវិធានដែលធ្វើឲ្យតុលាការនេះ អាចដំណើរការទៅមុខយុត្តិធម៌ ហើយនិងដោយលឿន ។ ហើយការបកស្រាយយ៉ាងណាក៏ដោយនោះ គឺគួរតែធ្វើឲ្យយើងដល់ចំណុចដែលយើងចង់បាននេះ ។ ដូច្នេះ នៅពេលដែលយើងមើលទៅលើវិធាន ដូចជាវិធាន៨៧ ឬក៏វិធានផ្សេងទៀតក៏ដោយអ្វីដែលជាការទទួលបន្ទុកខុសត្រូវរបស់ចៅក្រម ឬរបស់អង្គសវនាការនេះ គឺមានន័យថា ការជំនុំជម្រះហ្នឹងវាលឿន ហើយវាមានយុត្តិធម៌ ហើយនៅក្នុងប្រព័ន្ធស៊ីវិល ។ ដូច្នេះ យើងធ្វើអ្វីៗ គឺស្ថិតនៅក្នុងបរិបទនៃប្រព័ន្ធនេះ មិនមែនឲ្យគេក្រឡេកមើលមកទៅលើការជំនុំជម្រះនេះ ហើយយល់ថានេះគឺជាកន្លែងមួយដែលនិយាយអំពីបណ្តាប្រទេសផ្សេងដូចជានៅ អូស្ត្រាលី ឬក៏នៅអាល្លឺម៉ង់ នោះទេ ។ គឺគេមិនគិតអំពីចំណុចនោះទេ គឺគេគិតថា តើតុលាការហ្នឹងមានយុត្តិធម៌ និងលឿនឬក៏អត់? ហើយទាក់ទងទៅនឹងចំណុចនេះ លោកចៅក្រម ខ្ញុំសូមលើកឡើងបន្តិចនូវវិធាន៣៣ ដែលនិយាយថា ប្រសិនបើមិនភាពច្បាស់លាស់ទាក់ទងទៅនឹងការបកស្រាយវិធាន ឬក៏ការអនុវត្តវិធាន ឬក៏មានសំណួរទាក់ទងទៅនឹងភាពមិនស៊ីគ្នាទៅនឹងបទដ្ឋានអន្តរជាតិ គឺអាចនឹងស្នើសុំឲ្យមានការណែនាំទៅត្រឹមកម្រិតអន្តរជាតិ ។

ដូច្នេះ លោកចៅក្រម ការសន្និដ្ឋានរបស់យើងខ្ញុំ គឺថាដើម្បីកំណត់ទៅលើវិធីដែលនីតិវិធីត្រូវតែបន្តធ្វើពីពេលឥឡូវនេះដោយយោងទៅលើចំណុចដែលថា នៅមិនមាននរណាមួយក្នុងតុលាការនេះមិនសប្បាយចិត្តទៅនឹងដំណើរការនីតិវិធីដែលបានធ្វើមកដល់ពេលនេះទេ គឺប្រហែលជាមកពីការចូលរួមរបស់យើងនីមួយៗ ។ ដូច្នេះ យើងគួរតែពិនិត្យមើលទៅលើវិធាននេះ ហើយពិនិត្យមើលថាតើយើងអាចធ្វើអ្វីបានទៀតដើម្បីធានាថា សវនាការនេះ គឺមានយុត្តិធម៌ និងមានភាពលឿន ហើយដើម្បីធ្វើដូច្នេះបាន

គឺយើងត្រូវពិចារណាផងដែរថា តើតុលាការដទៃទៀតដូចជា តុលាការអន្តរជាតិនៅ រ្វ៉ាន់ដា , យូហ្គោ-ស្លាវី, សេរ៉ាឡេអូន ពួកគេមានការអនុវត្តដ៏ច្រើនទាក់ទងទៅនឹងសំណុំរឿងបែបនេះ ហើយនិង ក៏មានការធ្វើហើយ ឆ្លើយកាត់តាមរយៈកំហុសផ្សេងៗដើម្បីទទួលបាននូវផលប្រយោជន៍នោះ ហើយក៏មានការអនុវត្ត នៅក្នុងតុលាការនោះដែរ ដែលថាវាមិនដែល ។

[១០:០៧:១១]

គឺថាតុលាការនុ៎ះ មិនមែនជាតុលាការដែលល្អឥតខ្ចោះនោះទេ ប៉ុន្តែគឺថាយើង គេបានដោះស្រាយជាមួយនឹងបញ្ហាផ្សេងៗ ទៅនឹងភាពស្មុគស្មាញនៃទំហំរឿងក្ដីដូចដែលយើងមាននេះ ។ ហើយជាការធម្មតាទេ ដែលយើងនិយាយនៅពេលដែលពួកគេចាប់ផ្ដើម គឺពួកគេចាប់ផ្ដើមដោយមានវិធានមួយចំនួនដែលក្រោយមក គឺមានការបង្ហាញច្បាស់ថា គឺថាវិធានមួយចំនួនហ្នឹង នឹងមិនដំណើរការទេ ហើយបើសិនជាយើងមើលទៅលើប្រវត្តិនៃវិសោធនកម្ម គឺយើងអាចមើលឃើញផងដែរ ដូចជានៅក្នុងតុលាការយូហ្គោស្លាវី គឺតុលាការនេះបានដើរចេញពី *ខំមិនឡូ* មកទៅវិធីសាស្ត្រដោយយោងតាមស៊ីវិលឡូ ។ របៀបដែល ដុកឃ្យូមិន ត្រូវទទួលដែលត្រូវធ្វើឡើងឲ្យលឿនដើម្បីធ្វើការពិចារណានោះ ។

ទោះបីជានិយាយដូច្នេះក៏ដោយ ក៏ជាការត្រឹមត្រូវដែរ ដែលយើងត្រូវនិយាយថា តុលាការនៅប្រទេសបារាំង នៅអាល្លឺម៉ង់ និងនៅក្នុងប្រព័ន្ធស៊ីវិលដទៃទៀត គឺគេដោះស្រាយជាមួយនឹងបញ្ហាផ្សេងៗដោយលឿន ។ ទាក់ទងទៅនឹងការបង្ហាញ ឬក៏ការទទួលយកឯកសារជាងពីអ្វីដែលយើងកំពុងអនុវត្តនៅក្នុងតុលាការនេះ ។ ដូច្នេះ ប្រហែលជាពួកយើងអាចបង្ហាញអំពីករណីមួយចំនួនដែលកើតមានឡើងនៅ ប្រទេសបារាំង និងនៅប្រទេសអាល្លឺម៉ង់ ដែលបង្ហាញអំពីភាពលឿនដូច្នេះ ។

ដូច្នេះ មានន័យថា មិនចាំបាច់អានឯកសារ ឬក៏ផ្ដល់សេចក្ដីសង្ខេបនៅក្នុងសវនាការទេ ។ គឺធ្វើដូច្នេះដើម្បីឲ្យមានប្រសិទ្ធភាព ហើយឯកសារហ្នឹង គឺអាចធ្វើការបង្ហាញដល់ខាងភាគីពាក់ព័ន្ធនានា ដូចជាមេធាវីការពារក្ដី ឬក៏មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី ឬរបស់លោកចៅក្រមដើម្បីឲ្យអាន គឺគេមានវិធីហើយយន្តការផ្សេងៗទៀត នៅក្នុងប្រព័ន្ធស៊ីវិលនៅក្នុងប្រទេសបារាំង និងនៅក្នុងប្រទេសអាល្លឺម៉ង់ ដែលមិនត្រូវការឲ្យអានឯកសារទាំងនោះទេ ។ ហើយយើងក៏អាចគិតផងដែរថា អំពីរឿងដ៏ធំទាក់ទងទៅនឹងរឿងបទឧក្រិដ្ឋកុំព្យូទ័រជាដើម គឺនឹងតម្រូវការឲ្យបន្តរហូតបើសិនជាយើងត្រូវការអានឯកសារនៅក្នុងអង្គសវនាការនោះ ។

[១០:០៩:១៥]

ដូច្នេះ បទដ្ឋានអន្តរជាតិ ទាំងនៅក្នុងប្រព័ន្ធស៊ីវិល ហើយនិងច្បាប់អន្តរជាតិដូចដែលលោកចៅក្រម-- ខ្ញុំចង់ឲ្យលោកចៅក្រមពិនិត្យមើលទៅលើចំណុចអស់ទាំងហ្នឹង ទាក់ទងទៅនឹងវិធីសាស្ត្រដែលពួកគេបានអនុវត្តផ្សេងៗគ្នា ។ ហើយខ្ញុំក៏ចង់និយាយដែលថា គឺថាយើងគួរតែបានជំរុញឲ្យពិនិត្យមើលទៅលើវិធាន គឺការស្នើទៅលើវិសោធនកម្ម វិធាន៨៧ ពីព្រោះយើងគិតថាវាមិន បើសិនជាឲ្យវាស៊ីគ្នាជាមួយនឹងបទដ្ឋានអន្តរជាតិនោះ ហ្នឹងគឺជាការប្រសើរ ទាក់ទងទៅនឹងការដោះស្រាយជាមួយនឹងឯកសារ ។ ហើយចំណុចសំខាន់មួយទៀត ហើយប្រហែលជាការផ្ទុះបញ្ហាំងនៅក្នុងវិធាននោះដែរ គឺថាសវនាការ នេះគួរតែជាសាធារណៈ ហើយនិងបើកចំហ ។ ខាងសហព្រះរាជអាជ្ញាយល់ឃើញថា គឺថាតុលាការហ្នឹង ត្រូវតែធ្វើ ធ្វើឲ្យបានសមរម្យសម្រាប់ជនជាប់ចោទ ទោះបីជាលទ្ធផលបានមកយ៉ាងម៉េចក៏ដោយ ក៏ប៉ុន្តែ ជាការសំខាន់ផងដែរ សម្រាប់ឲ្យសាធារណជនបានមើលឃើញ ។ ដូច្នេះ យើងយល់ថា ត្រូវតែមានការទទួលស្គាល់អំពីភស្តុតាង តើតាមវិធីណាមួយ?

[១០:១០:២០]

ក៏ប៉ុន្តែ មិនមែនតាមវិធីដែលខ្ញុំយល់ថាអាចធ្វើឲ្យពួកគេហ្នឹងធុញទ្រាន់នោះទេ បន្ទាប់ពីយើងបានអាននូវឯកសារមួយហើយ មួយទៀត គឺថាវានឹងមានឥទ្ធិពលផ្ទុយពីនេះទៅវិញ ។ ហើយផ្នែកមួយនៃវិធាននោះ គឺថាដើម្បីជាការផ្ដល់ព័ត៌មានដល់សាធារណជន ដើម្បីឲ្យពួកគេបានទទួលព័ត៌មានអស់ទាំងនុ៎ង ។ ពីព្រោះខ្ញុំគិតថា បើសិនជាមិនដូច្នេះទេ ពួកគេនឹងធុញទ្រាន់នៅក្នុងការអានឯកសារមួយហើយមួយទៀត ។ ហើយខ្ញុំចង់លើកឡើងអំពីការបកស្រាយទាក់ទងទៅនឹងការពិនិត្យមើលឯកសារអស់ទាំងហ្នឹង ។ តាមពិត គឺថាមេធាវីការពារក្ដីបានលើកឡើងផងដែរទាក់ទងទៅនឹងឯកសារនោះ ថាតើយើងអាចបកស្រាយវិធាននោះយ៉ាងដូចម្ដេចដើម្បីអនុញ្ញាតឲ្យពួកយើងដោះស្រាយបានទាក់ទងទៅនឹងឯកសារហ្នឹងឲ្យបានលឿន ទម្រាំយើងទទួលបាននូវវិសោធនកម្មទៅលើវិធាននោះ ។

ដូច្នេះ ឥឡូវនេះខ្ញុំនឹងលែងនិយាយអំពីចំណុចនេះហើយ ខ្ញុំនឹងនិយាយអំពីវិធាន៣៥.២ ម្ដង ៣៥ថ្មីម្ដង គឺបាននិយាយអំពីការកាត់ទោសទៅលើជនជាប់ចោទ និងសិទ្ធិរបស់ជនជាប់ចោទ ដើម្បីទទួលមើលបាននូវភស្តុតាងដែលចោទប្រកាន់ចំពោះលើគាត់នោះ ។ ប៉ុន្តែ អ្វីដែលជនជាប់ចោទត្រូវដឹងនោះ គឺវាខុសគ្នាពីការអាន ឬក៏ធ្វើសេចក្ដីសង្ខេបនៅក្នុងអង្គសវនាការ ។ ទាក់ទងទៅនឹងចំណុចនេះ បើសាធារណជនទូទៅមានក្ដីសង្ឃឹមនិងរំពឹងទុកថា តុលាការនេះ គឺជាមានជោគជ័យ ឬក៏អត់នោះ គឺវាអាចមានឥទ្ធិពលដល់ប្រតិបត្តិការនៅពេលអនាគតរបស់តុលាការនេះ ។ ដូចដែលលោកចៅក្រមបានដឹង

ហើយ បើសិនជាយើងរកមាននូវការអនុវត្ត ឬក៏វិធីសាស្ត្រមួយចំនួនដែលបានលើកឡើង ហើយដែលត្រូវបានអនុវត្តនៅក្នុងតុលាការអន្តរជាតិដទៃទៀត ទាក់ទងទៅនឹងបញ្ហាដូចគ្នានេះ គឺបញ្ហាដែលយើងកំពុងតែដោះស្រាយរួមគ្នានៅក្នុងអង្គសវនាការនេះ ។ ហើយការលើកឡើងដំបូងរបស់ខ្ញុំ តំណាងឲ្យខាងការិយាល័យសហព្រះរាជអាជ្ញាហ្នឹង គឺថាយើងត្រូវកំណត់កាលបរិច្ឆេទបញ្ចប់នៃសវនាការនេះ ។ ខាងសហព្រះរាជអាជ្ញា បានឯកភាពគ្នាទៅលើអ្វីដែល សហសេវិករបស់ខ្ញុំបានលើកឡើង គឺយើងត្រូវមានជំនឿថា តុលាការនោះត្រូវចប់នៅថ្ងៃទី៣១ ខែតុលា ដោយមានហេតុផលមួយចំនួន ទោះបីជាត្រូវរើសកាលបរិច្ឆេទណាក៏ដោយ គឺថាចាំបាច់យើងត្រូវតែរើសកាលបរិច្ឆេទបញ្ចប់ ។ ហើយនៅពេលដែលយើងរើសបានហើយនោះ ហើយសំណើដែលខ្ញុំនឹងលើក ឡើងសម្រាប់ការអនុវត្តនោះ គឺឲ្យភាគីពាក់ព័ន្ធដាក់បញ្ចូលនូវសំណើអស់ទាំងហ្នឹង ដើម្បីយល់ថា តើវាមានយុត្តិធម៌ ឬក៏អត់? អាចធ្វើទៅបានឬក៏អត់?

[១០:១៣:០៨]

ហើយបើសិនជាភាគីយល់ថា ការបែងចែកពេលវេលា នុំងវាមានយុត្តិធម៌ហើយៗគឺអាចដាក់ជាសំណើដល់ទៅលោកចៅក្រមបាន ហើយប្រហែលជាយើងអាចសម្រេចនូវដំណោះស្រាយណាមួយប្រសើរជាងការបញ្ចប់នៅឆ្នាំ២០១០ ឯណោះ ។

ហើយចំណុចទីមួយដែលខ្ញុំអាចលើកស្នើឡើងបាននោះ គឺការបកស្រាយវិធាន៨៧.៣ ដែលយើងអាចបកស្រាយមិនមែនជាការកែច្នៃទេ ប៉ុន្តែ ជាការបកស្រាយទៅតាមវិធីមួយដែលយើងអាចធ្វើឲ្យវិធានហ្នឹងដំណើរការបានល្អប្រសើរសម្រាប់អង្គសវនាការនេះ រហូតដល់ពេលវិធាននោះត្រូវបានធ្វើវិសោធនកម្ម ។ ប៉ុន្តែ គឺវាមិនមែនធ្វើឲ្យប៉ះពាល់ដល់គោលបំណងចំណងរបស់អង្គសវនាការនេះដែលធ្វើឲ្យដំណើរការជំនុំជម្រះហ្នឹងយុត្តិធម៌ និងលឿននោះ ។

អ៊ីចឹងការបកស្រាយ ដែលខ្ញុំនឹងលើកឡើង គឺថានៅក្នុងភាសាអង់គ្លេស បើសិនជាយើងពិនិត្យ មើលទៅដូចមានន័យថា វាគេអាចពិចារណាទៅលើភស្តុតាងហ្នឹងបាន បើសិនជាមានភស្តុតាងនោះត្រូវបានគេសង្ខេប ឬមួយក៏ត្រូវបានអាននៅក្នុងសវនាការ ។

[១០:១៤:២២]

ទាក់ទងទៅនឹងការបកស្រាយនេះ ហាក់បីដូច ជាមានការបង្ហាញថា បើយើងមើលទៅតាមន័យដែលនិយាយនោះ គឺមានន័យថា ព័ត៌មាននោះត្រូវតែធ្វើសង្ខេបជាមុន ហើយមិនមែនសេចក្តីសង្ខេបនោះទេ ដែលត្រូវយកមកអាននៅក្នុងសវនាការ ។ ហើយចំណុចមួយទៀតក្នុងការបកស្រាយវិធាន

គឺថា ប្រសិនបើឯកសារណាមួយត្រូវបានធ្វើសង្ខេបទៅតាមវិធាននោះ គឺឯកសារនោះត្រូវបាន គួរតែធ្វើសង្ខេបជាក្រុម ។ ឧទាហរណ៍ សំណើមួយដែលត្រូវបានដាក់ជូន ពីខាងមេធាវីការពារក្តី ហើយដូចឧទាហរណ៍ សារព័ត៌មានអន្តរជាតិ គឺថាប្រហែលជាអាចសង្ខេបជាក្រុមឯកសារនោះតែម្តង ឬក៏អាចបញ្ចូលជាកូនសៀវភៅ ចងក្រងជាកូនសៀវភៅ ឬក៏អាចចងក្រងជាឯកសារមួយសន្លឹកនិយាយអំពីឯកសារនោះ តើអត្ថបទទីមួយនិយាយអំពីអ្វី? នៅថ្ងៃខែឆ្នាំបរិច្ឆេទ? និយាយអំពីអី? និយាយអំពីជម្លោះប្រដាប់អាវុធ? ឬក៏យ៉ាងម៉េច? មានន័យថា យើងធ្វើសេចក្តីសង្ខេបសម្រាប់ឯកសារជាក្រុមនោះ ។ ពេលនុ៎ងឯងមានន័យថា សាធារណជននឹងចាប់អារម្មណ៍ជាង ហើយជាការប្រាកដណាស់ គឺអាចវាស៊ីគ្នាទៅនឹងវិធានដែលបានលើកឡើងនោះ ពីព្រោះអី? គឺមានន័យថា ឯកសារនោះ ត្រូវបានសង្ខេបរួចហើយ ។ ហើយបើសិនជាធ្វើសេចក្តីសង្ខេបនៅក្នុងសវនាការ គួរតែធ្វើសេចក្តីសង្ខេប ជាក្រុមបែបនេះ គឺជាសេចក្តីសង្ខេបដែលវាមានភាពស្រដៀងគ្នាទៅនឹងអត្ថបទពេញលេញ ឬក៏អាចធ្វើបានដោយសង្ខេបបំផុត ។ នេះជាសំណើដ៏ខ្លីដែលខ្ញុំបានលើកឡើង ហើយយើងអាចនិយាយពីចំណុចនេះនៅពេលក្រោយទៀត ។

ហើយលោកចៅក្រម! ជាសង្ខេបខ្ញុំយល់ថាការយល់ដឹងរបស់លោកចៅក្រមប្រសើរជាងខ្ញុំទាក់ទងទៅនឹងវិសោធនកម្ម ដែលលើកឡើងទាក់ទងទៅនឹងការធ្វើសេចក្តីសង្ខេបរបស់ឯកសារ ។

[១០:១៦:១១]

ប៉ុន្តែ នៅពេលដែលយើងឃើញវិសោធនកម្មលើកដំបូងនោះ គឺថាយើងសប្បាយចិត្តនឹងឃើញណាស់ គឺមានន័យថាការលើកធ្វើវិសោធនកម្មនុ៎ងមានន័យថា សំណុំរឿងនេះវាធំណាស់ ហើយវាគឺដូចជាតម្រងមួយអ៊ីចឹង ។ ដូច្នេះ មេធាវីការពារក្តី ហើយនិងខាងសហព្រះរាជអាជ្ញាបានដឹងថា តើយើងពិចារណាអំពីអ្វីខ្លះនៅក្នុងសំណុំរឿងនេះ ដើម្បីកំណត់ទៅលើភស្តុតាង ដើម្បីកំណត់ទៅលើជនជាប់ចោទ ហើយអ្វីដែលកើតឡើងនៅក្នុងតុលាការអន្តរជាតិដទៃទៀតនោះ គឺគេបង្កើតជាតម្រងមួយ នេះទៅតាមវិធីសាស្ត្រផ្សេងៗគ្នា ។ ប៉ុន្តែ នៅតែជាតម្រងដដែល មានន័យថា ការបញ្ជីបង្ហាញភស្តុតាងនៅចំពោះមុខអង្គសវនាការមុនពេលសវនាការចាប់ផ្តើម ។ ឧទាហរណ៍ថា ភស្តុតាងមួយចំនួនត្រូវដាក់បង្ហាញជាមុន ពីភស្តុតាងដ៏ច្រើនដែលអាចនឹងត្រូវយកមកបង្ហាញនៅក្នុងសំណុំរឿង គឺគេកំណត់ ហើយនិងទទួលស្គាល់ថាតើ-- ហើយនៅពេលហ្នឹង មេធាវីការពារក្តី ហើយនិងខាងក្រុមគេហ្នឹងអាចដឹងថា តើភស្តុតាងអ្វីខ្លះ ដែលជាភស្តុតាងដាក់បន្ទុកទៅលើគេនោះ? ហើយក្រោយមក ក៏គេប្រាប់ខ្ញុំផងដែរថា

ចំណុចសំខាន់នៃវិធាននោះ គឺជាការសំខាន់ណាស់ សម្រាប់ឲ្យសាធារណជនបានឮដឹង ពីព្រោះនៅក្នុងប្រព័ន្ធស៊ីវិល ប្រហែលជាសាធារណជនមិនបានឮទេ ពីព្រោះពួកគេបានពិនិត្យមើលឯកសារ ។ ប៉ុន្តែមិនមានអ្វីទាំងអស់ត្រូវបានមកផ្តល់ជាសក្ខីកម្មនោះទេ ។ នេះជាចំណុចសំខាន់មួយផងដែរ ។ ប៉ុន្តែ នេះគឺមិនស៊ីគ្នាទៅនឹងគោលបំណងរបស់វិធាននោះទេ ប្រសិនជាយល់ថា ភស្តុតាងមួយចំនួនដែលជាក្រុមឯកសារ ឬក៏ឯកសាររាប់រយ ដើម្បីបង្ហាញអំពីចំណុចណាមួយ ហើយបើយល់ថាវាសំខាន់នោះ គឺបើសិនជាយើងត្រូវអានម្តងមួយៗ មានន័យថា គឺនឹងអាចធ្វើឲ្យសាធារណជនហ្នឹងមិនៗចាប់អារម្មណ៍ ប៉ុន្តែ បើសិនជា យើងធ្វើសេចក្តីសង្ខេបជាក្រុម មានន័យថា យើងបំពេញតម្រូវការទៅលើវិធាននោះ ហើយៗធ្វើឲ្យសាធារណជនចាប់អារម្មណ៍ផងដែរ ។ ហើយបើសិនជាខ្ញុំអាចបន្តទៀតនុំង លោកចៅក្រម ចំណុចដែលខ្ញុំចង់និយាយបន្ទាប់នោះ បើសិនជាយើងអាចធ្វើដូច្នេះបាន ទាក់ទងទៅនឹងបទសម្ភាសន៍របស់សាក្សី ប្រហែលជាអាចត្រូវបានជូនដល់អង្គសវនាការក្នុងទម្រង់ជាសេចក្តីសង្ខេប ហើយសេចក្តីសង្ខេបទាំងនុំង ដូចជាសេចក្តីសង្ខេបរបស់សាក្សី របស់ខាងសហព្រះរាជអាជ្ញានោះ គឺថាមិនមែនជាភស្តុតាងទេ ។ គឺថាសហព្រះរាជអាជ្ញាមិនគិតថាសេចក្តីសង្ខេបរបស់សាក្សីដែលបានដាក់ជូនសវនាការនោះ ជាសាក្សីទេ ប៉ុន្តែគ្រាន់តែជាវិធីមួយដើម្បីឲ្យយើងយល់ ឲ្យអង្គសវនាការយល់អំពីផ្នែកមួយនៃភស្តុតាង ដើម្បីគាំទ្រដល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ។ ដូច្នេះ សេចក្តីសង្ខេបគ្រាន់តែជាវិធីមួយដើម្បីឲ្យយល់ដល់ចំណុចអស់ទាំងនុំង ។

[១០:១៩:១៤]

ដូច្នេះ ប្រសិនបើភាគីអាចទទួលស្គាល់បាន អាចបង្ហាញប្រាប់លោកចៅក្រមអំពីឯកសារដែលពួកគេនឹងត្រូវពិចារណា តាមរយៈទម្រង់បែបនេះ។ ដូច្នេះ សក្ខីកម្ម គឺថាអាចមានរយៈខ្លីៗច្រើនជាងនេះ ហើយបើសិនជាយើង មិនអាចធ្វើនេះបាន បើសិនជាយើងមិនអាចធ្វើបានដូច្នេះទេនោះ គឺថាយើងស្ថិតនៅក្នុងស្ថានភាពមួយដែលខាងសហព្រះរាជអាជ្ញា ដែលត្រូវមានភារកិច្ចដើម្បីបង្ហាញរឿងការចោទប្រកាន់ឲ្យលើសពីវិមតិសង្ស័យនុំង គឺថា ត្រូវធានាថារាល់ភស្តុតាងពាក់ព័ន្ធនានាទាំងឡាយត្រូវតែដាក់បង្ហាញមុខ នៅចំពោះមុខអង្គសវនាការ តាមរយៈការធ្វើសក្ខីកម្ម ។ ហើយដូច្នេះមានន័យថា គឺកិច្ចជំនុំជម្រះនៅក្នុង ខំមិនឡ ហ្នឹង វាស៊ីពេលច្រើនជាងនៅក្នុងស៊ីវិលឡ ។ ហើយចំណុចសំខាន់ហ្នឹង គឺនេះហើយដែលជាហេតុផលដែលអង្គជំនុំជម្រះ នៅក្នុងទម្រង់ស៊ីវិលឡ នេះវាស៊ីពេលច្រើនជាងនៅក្នុងទម្រង់ជាខំមិនឡ ។ ហើយអ្វីដែលខ្ញុំចង់ស្នើទៅលោកចៅក្រម គឺយើងត្រឡប់ទៅប្រព័ន្ធស៊ីវិលឡ វិញ

មានន័យថា យើងត្រូវទទួលថា តើនៅក្នុងសំណុំរឿងហ្នឹងមានឯកសារណាដែលយើងចង់បាន ហើយនៅពេលដែលយើងសួរសំណួរទៅលើសាក្សី គឺយើងចង់និយាយថា ខ្ញុំចង់និយាយអំពីចំណុចជាក់លាក់ណាមួយអំពីឯកសារនៅក្នុងសំណុំរឿងនោះ ។ ហើយតំបន់ ឬក៏ផ្នែកណាមួយនៃឯកសារដែលជាចំណុចជំទាស់ ហើយនិងកម្រិតនៃការទទួលខុសត្រូវរបស់ជនជាប់ចោទនោះ តើគាត់ហ្នឹងធ្វើដល់កម្រិតណានៅស-២១?

[១០:២០:៤៩]

ដូច្នេះ យើងអាចផ្តោតអារម្មណ៍ ទៅលើការប្រព្រឹត្តិទៅរបស់ជនជាប់ចោទ ដូចមិនចាំបាច់ផ្តោតអារម្មណ៍ខ្លាំងពេកទៅលើចំណុចហ្នឹង ។ ប៉ុន្តែ ក៏តុលាការនៅតែមានភារកិច្ចដើម្បីធានាថានីតិវិធីនេះ ដោយជាចំណុចមួយនៃការផ្សះផ្សាហ្នឹង គឺអាចស្វែងរកការពិត ដើម្បីឲ្យប្រទេសកម្ពុជាអាចបន្តដំណើរទៅមុខទៀតបាន ។

ដូច្នេះ យើងត្រូវបង្ហាញចំណុចខ្លះនៃឧក្រិដ្ឋកម្មនោះ ដើម្បីឲ្យសាធារណជនបានយល់ដឹងអំពីឧក្រិដ្ឋកម្មអស់ទាំងនុ៎ង ។ ហើយយើងប្រហែលជាអាចផ្តោតអារម្មណ៍ តែទៅលើចំណុចសំខាន់ៗ នៃសំណុំរឿង ។ ហើយថាតើភាគីនីមួយៗហ្នឹង ត្រូវស៊ីពេលប៉ុន្មាន ដើម្បីធ្វើការបង្ហាញនោះ មានន័យថាពេលហ្នឹងគឺយើងអាចផ្តោតអារម្មណ៍ទៅលើចំណុចសំខាន់ៗនៃភស្តុតាងអស់ទាំងនុ៎ងហើយ ។ ហើយខ្ញុំគិតថានេះគឺជាអ្វីដែលលោកចៅក្រមនឹងធ្វើនៅដំណាក់ដំបូងនៃសវនាការ ពីព្រោះអ្វីៗទាំងអស់គឺជាសេចក្តីសម្រេចរបស់លោក លោកស្រីចៅក្រមនៃសាលាដំបូងនេះ ។

ទាក់ទងទៅនឹងបញ្ហានោះ លោកចៅក្រម យើងខ្ញុំស្នើថា ផ្នែកនីមួយៗនៃសំណុំរឿងនៅពេលនេះ យើងពិនិត្យមើលសាក្សី គឺថាយើងមាន៤៩ សាក្សីដែលនៅសល់ ហើយ២៩ នៅក្នុងចំណុចនោះ គឺថាទាក់ទងទៅនឹងផ្នែកសំខាន់ ។ គឺការប្រព្រឹត្តទៅនៃស-២១, ជើងឯក ហើយនិងព្រៃស សាក្សីនៅព្រៃស ហើយយើងបានកំណត់ពេលជាក់លាក់មួយចំនួន។ ឧទាហរណ៍ថា ជនជាប់ចោទបានផ្តល់សក្ខីកម្មទាក់ទងទៅនឹងស-២១ ហើយនិងជើងឯក ។ សហព្រះរាជអាជ្ញាស្នើថា នេះគឺជាឯកសារដ៏សំខាន់នៃផ្នែកសំខាន់នៃសំណុំរឿង ។ បញ្ហាផ្សេងៗទៀតយើងនឹងដាក់ចូលនៅក្នុងបរិបទហ្នឹង ដើម្បីបញ្ជាក់ពីយុត្តាធិការ ។

អ៊ីចឹងហើយជាទិដ្ឋភាពសំខាន់នៃរឿងក្តី ថាតើស-២១ និងជើងឯក ដំណើរដូការដូចម្តេច? អ៊ីចឹងយើងស្នើថា សក្ខីកម្មរបស់ជនជាប់ចោទ អំពីបញ្ហាហ្នឹង គឺតាមពិតវាអាចនឹងត្រូវប្រើពេលពីរសប្តាហ៍

កន្លះ ពីព្រោះថាជាផ្នែកសំខាន់ ហ្នឹងគឺថា ជាពេលដែលភាគីទាំងអស់អាចសួរគាត់បានទាក់ទងទៅនឹងផ្នែកសំខាន់នៃរឿងក្តី ដោយមិនគិតពីការកម្រិតពេលដែលយើងត្រូវពិភាក្សា ប៉ុន្តែ យើងកំណត់ពេលវេលាសម្រាប់រឿងហ្នឹង ។ ជាមួយសាក្សីមួយចំនួននៅក្នុងស-២១ និងព្រៃស ការគណនារបស់យើងគឺថាយើងមានសាក្សីម្ភៃប្រាំបួនសម្រាប់សវនាការរឿងនេះ ។ ជាបឋម គឺថាយើង ហើយមិនឲ្យមានការបំបែកចេញព្រៃស ពីស-២១ ទេ ។ ប្រសិនជាមានការបែងចែក គឺអាចនឹងសាក្សីភាគីច្រើនដែលអញ្ជើញមកទាក់ទងទៅនឹងស-២១ និងជើងឯក ក៏ថាអ្នកខ្លះក៏អាចមកពីខាងព្រៃសនោះដែរ ។ ហេតុផលដែលយើងស្នើមិនឲ្យបំបែកនោះ គឺថាយើងយល់ថា ផ្អែកលើសក្ខីកម្មដែលយើងពិនិត្យថ្ងៃនេះ ។ គឺខ្ញុំមិនវិនិច្ឆ័យទៅជំហររបស់មេធាវីទេ ហើយជនជាប់ចោទមិនបានទៅព្រៃសជាញឹកញាប់ទេ គឺថាក្នុងឱកាសមួយចំនួនប៉ុណ្ណោះ ។ ប្រសិនជារឿងនេះជាការលើកឡើងជាអង្គហេតុនោះ អ៊ីចឹង គឺថាតើគាត់បានដឹងអ្វីដែលនៅកន្លែងនោះ ជាជាងអ្វីដែលគាត់ដឹងនៅស-២១ នោះ? ពេលដែលយើងសួរសំណួរទៅជនជាប់ចោទអំពីព្រៃសនិងជើងឯក បើមិនមានសក្ខីកម្មទៅលើផ្សេងទៀតទេ អំពីបុគ្គលិកលក្ខណៈរបស់គាត់ពីបញ្ហាផ្លូវចិត្ត និងផ្លូវសង្គមរបស់គាត់ទេ យើងយល់ថា យើងគួរតែពិនិត្យមើលដែលថា យើងអាចនឹងឈានទៅដល់ការកាត់ទោស សម្រេចទោសនៅក្នុងរឿងក្តី ។

[១០:២៤:៤២]

ទាក់ទងទៅនឹងបញ្ហានេះ យើងស្នើថា យើងនឹងមានវិធានមួយដែលថា គឺថាសាក្សីមួយសម្រាប់មួយថ្ងៃ ។ ប្រសិនបើយើងពិនិត្យមើលថាតើតុលាការ-- ខ្ញុំសូមប្តូរថាបើសិនជាភាគីនឹងបន្តការងារថ្ងៃនេះ គឺថាយើងខ្ញុំចាំមានបញ្ហាមួយចំនួនត្រូវបានលើកបន្ថែម ។ យើងមិនអាចបញ្ចប់បានក្នុងតែមួយថ្ងៃទេ ពីព្រោះយើងមានអ្វីលើកឡើងថែមទៀត ។ អ៊ីចឹងបើយើងពិនិត្យមើលវិធាន៨៧.៣ គឺថាបើសិនមានឯក-សារមួយចំនួនត្រូវធ្វើសង្ខេប ត្រូវអានយ៉ាងដូចម្តេចនោះ? យើងមិនអាចបញ្ចប់បានសាក្សីមួយក្នុងមួយថ្ងៃទេ ។ សាក្សីខ្លះ គឺថា អាចសំខាន់ជាងសាក្សីផ្សេងទៀត ហើយជននោះគឺថាអាចនឹងប្រើពេលពីរថ្ងៃ ឬពីរថ្ងៃកន្លះ ។ បន្ទាប់មកគឺថា មានសាក្សីខ្លះនឹងប្រើពេលតែកន្លះថ្ងៃ ។

[១០:២៥:៣៦]

លោកចៅក្រមជាទីគោរព! គឺថាមកពីខាងសហព្រះរាជអាជ្ញា យើងខ្ញុំជម្រាបលោកចៅក្រមថា ប្រសិនជាយើងបញ្ចប់ការសួរសំណួររួចហើយនោះ សហព្រះរាជអាជ្ញាបានស្តាប់សំណួរអង្គជំនុំជម្រះរួចហើយ យើងយល់ថាយើងមិនមានអ្វីត្រូវសួរទៀតទេ មិនមានចំណុចណា ឬក៏វិធីសាស្ត្រអីដែលយើង

នឹងត្រូវបំភ្លឺបន្ថែមទៀតទេ ។ ហើយយើងនឹងធ្វើសំណួរដោយសង្ខេប ដូចដែលលោកចៅក្រមបានស្នើឲ្យយើងធ្វើ ហើយឲ្យស្តាប់អ្វីដែលលោកចៅក្រមបានធ្វើបានបញ្ជាក់ ហើយប្រសិនបើបានធ្វើរួចហើយ គឺវាចប់នោះហើយ ។ ប៉ុន្តែ តាមពិតជួនកាលវាពិបាកនឹងគិតគ្រប់អ្វីៗទាំងអស់នោះណាស់ អ៊ីចឹងហើយក៏ខ្ញុំនឹងយកពីចំណុចមួយ ហើយយើងនឹងស្តាប់ដោយយកចិត្តទុកដាក់ ហើយនិងលើសពីសេចក្តីសន្និដ្ឋានរបស់យើង ។ អ៊ីចឹងហើយ យើងពិនិត្យមើលកិច្ចការហ្នឹង ដូចថាសាក្សីមួយប្រើមួយថ្ងៃ សាក្សីមួយទៀតពីរថ្ងៃ អ៊ីចឹងហើយយើងនឹងអាចប៉ាន់ពេលវេលាថា អាចនឹងម្តៃប្រាំបួនថ្ងៃ ។ អ៊ីចឹង ខ្ញុំសូមបញ្ចប់ត្រង់ចំណុចមួយដែលខ្ញុំចង់ពន្យល់ ហើយខ្ញុំមិនបន្តថែមទៀតនៅក្នុងផ្នែកផ្សេងទៀតទេ ។

[១០:២៦:៥២]

ប្រសិនបើសេចក្តីថ្លែងការណ៍មាននៅក្នុងសំណុំរឿងហើយៗយើងលើកមកពីចារណា ហើយយើងមិនអាចលេខERN មួយហើយមួយទៀតនោះទេ ដោយយោងទៅបន្ទាត់ ឬក៏ឃ្លានៅក្នុងប្រយោគ។ ប្រសិនបើព្រះរាជអាជ្ញាមានដប់សំណួរដើម្បីសួរសាក្សី ហើយលោកចៅក្រមប្រាប់យើងថាមានតែដប់សំណួរផ្អែកទៅលើតែសេចក្តីថ្លែងការណ៍នោះ ។ អ៊ីចឹង សំណួរដប់ហ្នឹង ជាសំណួរដែលខ្លាំងណាស់ ដោយបានដឹងថា ភស្តុតាងដែលនៅក្នុងសេចក្តីកំណត់ហេតុសួរចម្លើយនោះ គឺថាវាអាចទាក់ទងទៅនឹងចម្រូងចម្រាស់ជាមួយនឹងទិដ្ឋភាពដែលថាជនជាប់ចោទ ហើយនិងដើមបណ្តឹងរដ្ឋប្បវេណី ក៏អាចសួរសាក្សីហ្នឹងដែរ។ អ៊ីចឹង យើងមិនមានការព្រួយបារម្ភណ៍អំពីចំណុចលម្អិតទាំងអស់នុ៎ងនោះទេ ។ ហើយយើងមិនព្រួយពីចំនួនសរុប ហើយនិងទិដ្ឋភាពទាំងអស់នេះទេ ។ តាមពិតទស្សនៈមួយគឺថា អាចនឹងកែតម្រូវទៅលើថា យើងមានអង្គហេតុដែលឯកភាពគ្នារួចហើយនោះ ។ ពិតជាបានជួយយើងចំណុចនេះ ប៉ុន្តែ វាមិនជួយយើងក្នុងន័យដែលថា រឿងក្តីត្រូវតែបង្ហាញភស្តុតាងឲ្យហួសពីវិមតិសង្ស័យ ហើយជនជាប់ចោទបានឯកភាព គាត់បានមិនឃើញ ឬក៏មិនបានឃើញពីមួយថ្ងៃទៅមួយថ្ងៃទេ ។ ហ្នឹងគឺជាបញ្ហាដែលទាក់ទងទៅនឹងការបង្ហាញសក្ខីកម្ម ។

ដូច្នេះ គឺថាអ្វីៗផ្អែកទៅលើអង្គហេតុសំណុំរឿង ឯកសារសំណុំរឿង គឺថាគាត់បានឃើញលក្ខណៈខណ្ឌការប្រព្រឹត្តិនោះជារៀងរាល់ថ្ងៃ ។ អ៊ីចឹងគឺថាយើងវាមានការពិបាកនៅក្នុងការសរុបជាគំនិតផ្លូវច្បាប់នោះ ដើម្បីឲ្យគាត់សាក្សីបង្ហាញអំពីលក្ខខណ្ឌជាបន្ត ។ អ៊ីចឹង គឺគាត់ៗនូវបញ្ជាក់លក្ខខណ្ឌអំពីការពាក់ព័ន្ធ ហើយនិងគឺការសន្និដ្ឋានដ៏សមស្របមួយអំពីហេតុការណ៍ហ្នឹង ។

[១០:២៨:៤៦]

អ៊ីចឹងក្នុងន័យអំពីការបង្ហាញភស្តុតាង ហើយនិងភាពបូរណភាពទាំងស្រុងនៃការជំនុំជម្រះនោះ គឺថាខ្ញុំសូមស្នើថា ប្រសិនបើមានកំណត់ហេតុសួរចម្លើយ ឬសេចក្តីថ្លែងការណ៍ហើយ យើងអាច យើងនឹងបន្ថយចំណួរឲ្យបានតិច ហើយនិងផ្តោតទៅលើការទទួលខុសត្រូវ ហើយនិងលទ្ធភាពរបស់ជនជាប់ចោទ ហើយនិងការបំភ្លឺបន្តិចបន្តួច នេះជាចំណុចមួយ ។ អ៊ីចឹងហើយយើងចូលទៅដល់ដើមបណ្តឹងរដ្ឋប្បវេណី ថាតើគាត់ត្រូវការពេលប៉ុនណាដើម្បីនិយាយដោយខ្លួនឯងនោះ? ប្រហែលជាអាចនឹងបួន ឬប្រាំថ្ងៃ គឺថាអាស្រ័យហ្នឹងពេលវេលា ដែលគេត្រូវប្រើពេល ជនរងគ្រោះ ឬក៏សមាជិកក្រុមគ្រួសារ ។ និយាយអំពីបុគ្គលិកលក្ខណៈ គឺថាអាចនឹងគឺថាបួនថ្ងៃ អំពីការកំណត់ទោស គឺថាអាចនឹងប្រើពេលបួនថ្ងៃ ដោយមានឯកសារក្នុងសំណុំរឿង ។ ហើយនៅក្នុងសេចក្តីសន្និដ្ឋានបញ្ចប់ គឺថាអាចនឹប្រើពេលបីថ្ងៃ ។

ប្រសិបបើមានពេលកំណត់តឹងរ៉ឹងនោះ ចំពោះផ្នែកមួយៗ ក្នុងសំណុំរឿងហ្នឹង ប្រសិនជាភាគីបានដឹងគេមានតែមួយម៉ោង ឬក៏កន្លះម៉ោង ដើម្បីសួរអ្នកជំនាញដែលនិយាយអំពីរឿងការកាត់សេចក្តីនោះ គឺថាខ្ញុំសូមធានាថា គុណភាពនៃសំណួរនឹងអាចកើនជាសំខាន់ ហើយយ៉ាងខ្លាំង ។

ចំពោះទាក់ទងទៅនឹងសាក្សីពិសេសមួយចំនួន ថាតើយើងអាចបែងចែកពេលវេលាដូចម្តេចឲ្យបានសមស្របសម្រាប់ពួកគេ? យើងពិនិត្យមើលចំនួនពីយប់មិញនេះ គឺថាយើងគិតថា តាមពិតអង្គជំនុំជម្រះសាលាដំបូង ការធ្វើការពិនិត្យហ្នឹង គឺថាវែងជាគេបំផុតហើយនៅក្នុងផ្នែកនេះ គឺថាជាភារកិច្ចចម្បង គឺថាអាចនឹងពីរម៉ោង ឯសហព្រះរាជអាជ្ញា គឺថានឹងផ្តល់ពេលមួយម៉ោងអតិបរមា ឬក៏ដើមបណ្តឹងរដ្ឋប្បវេណីគឺថាមួយម៉ោងអតិបរមា ឬក៏ថា គឺថាមួយម៉ោងកន្លះ ខ្ញុំដាក់ជាសមាមាត្រនៅកន្លែងនោះ ដើម្បីព្យាយាម ដើម្បីឲ្យមានតុល្យភាពសមស្រប ហើយរវាងភាគីទាំងអស់ ។

បញ្ហាមួយទៀតដែលគាំទ្រគំនិតនៃការកំណត់រយៈនេះចំពោះការសួរសំណួរសម្រាប់ផ្នែកផ្សេងៗនៃរឿងក្តីនោះ ។ សំណើមួយផ្សេងទៀត ដែលខ្ញុំជូនអង្គជំនុំជម្រះជ្រាបដែរនោះ ប្រហែលជាអាចនឹង គឺអាចនឹងវាវិលឡើងវិលចុះ គឺថាអាចនឹងសាធារណជនអាចនឹងដឹង គឺថាការសួរឡើងវិញនូវសំណួរទៅជនជាប់ចោទ បន្ទាប់ពីសាក្សីបានផ្តល់សក្ខីកម្មរួចហើយ ។

[១០:៣១:២៧]

ខ្ញុំស្នើថា វិធានដែលយើងប្រើនៅកន្លែងនេះ គឺអនុញ្ញាតឲ្យជនជាប់ចោទហ្នឹងផ្តល់សក្ខីកម្មមុននៅពេលដែលយើងរំពឹងទុក ហើយនៅពេលដែលយើងបំបែកសំណុំរឿង រឿងក្តីដែលយើងធ្វើហ្នឹង គឺ

ថាប្រសិនតែយើងស្តាប់សក្ខីកម្មទាំងស្រុងរបស់ជនជាប់ចោទហើយ សាក្សីហ្នឹងមកជាបន្ទាប់ ។ ខ្ញុំគិតថា ជាគំនិតដែលល្អសមស្រប ដើម្បីបំបែកអង្គហេតុដូចដែលចំណុចមួយៗ ដូចដែលលោកចៅក្រម ឬអង្គជំនុំជម្រះបានធ្វើហ្នឹង ។

ប៉ុន្តែ យើងចូលទៅដល់ផ្នែកដ៏សំខាន់នៃរឿងក្តីហើយ ក្រៅពីចំណុចដែលថាការកំណត់ទោសនោះដែលយើងនិយាយអំពីចំណុចចិត្តសាស្ត្រនិងអត្តចរិកនោះ ។ នៅពេលដែលជនជាប់ចោទផ្តល់សក្ខីកម្មអំពីស-២១ ជើងឯក ហើយនិងព្រៃស ជាមួយគ្នានោះ ។ អ៊ីចឹងហើយសំណួរដោយភាគី ហើយសាក្សីនោះបានមកបំភ្លឺ ហើយចៅក្រមនឹងសួរសាក្សី ហើយនិងភាគីក៏សួរបន្ទាប់ពីហ្នឹងមក ។ ហើយនៅក្នុងពេលដែលមេធាវីសួរសំណួរ ប្រសិនបើគេចង់ឲ្យជនជាប់ចោទ ដើម្បីតទល់ជាមួយសាក្សី គឺអនុញ្ញាតឲ្យគាត់តទល់ជាមួយសាក្សី តាមរយៈមេធាវី ឬក៏ដោយផ្ទាល់ ។

បន្ទាប់ពីចំណុចនោះមក មិនឲ្យមានការសួរជាជុំទីពីរដោយភាគីទៀតទេ របស់ជនជាប់ចោទ ឬក៏ដោយភាគីផ្សេងនោះ ។ អ៊ីចឹង ខ្ញុំយល់ឃើញថា យើងមានការសួររបៀបវិលជុំពីរផ្អែកទៅលើប្រធានបទតែមួយ អ៊ីចឹងការសួរជុំទីពីរទៅលើជនជាប់ចោទបន្ទាប់ពីសាក្សីផ្តល់សក្ខីកម្មហើយ គឺអាចនឹងបន្ថែមការប្រើពេលដ៏វែងច្រើនទៀតចំពោះរឿងក្តីនេះ ។

អ៊ីចឹង ជាសំណើខ្ញុំមិនគិត មិនច្បាស់ថា តើការសួរជាលើកជុំទីពីរទៅជនជាប់ចោទនោះ អាចបានកំណត់នៅក្នុងច្បាប់ដែរឬទេ? អ៊ីចឹងហើយ អង្គជំនុំជម្រះមានលទ្ធភាពដើម្បីពិនិត្យមើលស្តង់ដារអន្តរជាតិ ថាតើយើងអាចធ្វើដូចម្តេច ដើម្បីពន្លឿននីតិវិធី? សូមមេត្តាគិតមិនអនុញ្ញាតឲ្យមានការសួរជុំទីពីរ ដែលលើកឡើងដោយភាគី ។ ហើយអង្គជំនុំជម្រះ ជាពិសេសអាចនឹងផ្តល់ឱកាសឲ្យជនជាប់ចោទអាចប្រឈមតទល់ជាមួយនឹងសាក្សី ទៅតាមពេលដែលកំណត់ឲ្យ ឬក៏មេធាវីការពារណាមួយដែលសមស្របនោះ ។ ប្រហែលជាខ្ញុំសូមបញ្ចប់ ។ វិធីសាស្ត្រផ្សេងទៀត ដែលយើងចង់លើកស្នើដែរនោះអ្វីជាការលំបាកសម្រាប់សាក្សីទាំងអស់នេះ ហើយជួនកាលខ្ញុំបានភ្លេច ហើយយើងបានភ្លេច ពួកគេបានមកទីនេះបន្ទាប់ពីរឿងសាមសិបឆ្នាំហើយ គាត់បានព្យាយាមគិតឡើងវិញ រំឭកឡើងវិញ ។ អ៊ីចឹង ជនជាប់ចោទគាត់បានដូចជាមិនសូវធម្មតាទេ គឺខុសពីធម្មតា ដែលថាគាត់ពូកែចាំណាស់ ។ អ៊ីចឹង ហើយគឺសាក្សីមួយចំនួនគឺគាត់មិនអាចចាំអ្វីៗបានទេ សាមសិបឆ្នាំនោះកន្លងផុតមកហើយ ។ អ៊ីចឹងដែលនៅពេលដែលគេមកសវនាការ ជាលើកដំបូង ហើយគេត្រូវប្រឈមមុខនឹងសំណួរមួយចំនួនច្រើនដោយមិនមានការរំឭក អំពីការធ្វើរំឭកឲ្យគាត់ត្រឡប់ដឹងរឿងនៅពេលនោះទេ គឺថាគាត់មានការលំបាក ។

[១០:៣៥:០០]

អ៊ីចឹងបញ្ហានោះ ខ្ញុំគិតថាមួយម៉ោង ឬក៏កន្លះម៉ោងដំបូង គឺជាការរំឭកពញ្ញាក់ស្មារតីការចងចាំរបស់គាត់វិញ ។ ហើយអ៊ីចឹងហើយ យើងអាចចាប់ផ្ដើមបញ្ជាក់ពីរឿងទីមួយដែលគាត់ចាំ ប្រសិនគាត់នឹកហើយឃើញហើយ បើសិនការចងចាំហ្នឹងត្រឹមត្រូវហើយ វាច្បាស់លាស់ រូបថតបានធ្វើ ហើយឯកសារត្រូវបានផលិត ហើយបើសិនជាការចងចាំហ្នឹងគាត់បានច្បាស់ អ៊ីចឹងពឹងផ្អែកដំបូងនៃការស្ដាប់សក្ខីកម្មនោះ គឺមិនមានប្រសិទ្ធភាពដូចយើងការរកការពិតឲ្យឃើញដែលយើងចង់បាននោះទេ ។

សំណើមួយក្នុងចំណុចនេះ ដើម្បីធ្វើឲ្យសក្ខីកម្មនោះឲ្យកាត់ឲ្យខ្លី ដែលស្របទៅតាម ដែលយើងកំណត់នោះ ប្រហែលជាមន្ត្រីច្បាប់មកពីអង្គជំនុំជម្រះ អាចធ្វើជួបជាមួយសាក្សីមួយថ្ងៃមុន ហើយយកកំណត់ហេតុសួរចម្លើយទៅឲ្យសាក្សីឲ្យគាត់អាន ពីព្រោះថា សាក្សីហ្នឹងគាត់បានផ្ដល់ជាចម្លើយក្នុងកំណត់ហេតុហ្នឹង មិនចាំបាច់មានការពិភាក្សាច្រើនទេ ។ ណែនាំសាក្សីអំពីវិធីសាស្ត្រតុលាការនឹងត្រូវសួរ ហើយនិងលើកឡើង ថាតើភាគីគេនឹងធ្វើម៉េចចំពោះគាត់ ហើយអនុញ្ញាតឲ្យពួកគាត់រំឭកឡើងវិញនូវអ្វីដែលបានដឹង គឺមិនប្រាប់ថាឲ្យគាត់និយាយអ្វីនោះទេ ដែលថាឲ្យសាក្សីមិនជាការបង្គាប់ឲ្យនិយាយបែបនេះ បែបនោះ នោះទេ ។ គឺគ្រាន់តែឲ្យគាត់ស្ថិតនៅក្នុងស្ថានភាពមួយមួយ ដូចដែលគាត់នៅក្នុងស-២១ នៅពេលដែលគាត់មកតុលាការ គឺគាត់បាននឹកឃើញអ្វី ចងចាំអ្វី ហើយអាចនឹងឆ្លើយ អាចនឹងគេផ្ដល់សក្ខីកម្មបានល្អប្រសើរ ហើយនិងប្រើពេលវេលា ហើយនិងលទ្ធភាព ដើម្បីនឹងបញ្ជាក់ការពិតឲ្យមានប្រសិទ្ធភាពកាន់តែល្អ ។ នៅក្នុងន័យនុ៎ង នេះគឺជាសំណើមួយរបស់ខ្ញុំ ។

សំណើខ្លីមួយទៀត បើយើងមិនគិតអំពីគោលជំហរ ដែលតុលាការយើងប្រកាន់ទេ យើងសង្ឃឹមហើយយើងស្នើដោយគោរពថា យើងនឹងធ្វើឲ្យនីតិវិធីនេះដំណើរការលឿន ដែលថាសាក្សីទាក់ទងទៅនឹងបញ្ជាក់ថា ការសាក្សីហ្នឹងបង្ហាញពីអត្តសញ្ញាណ ឬតាមបញ្ហារបស់ភាគី ។ អ៊ីចឹងគឺថា យើងនិយាយថានៅម៉ោងប្រាំមួយ ឬម៉ោងប្រាំពីរនៅយប់ម្សិលមិញនោះ ប្រសិនបើភាគីចង់ប្រើឯកសារ ឬក៏ប្រើរូបថត ឬក៏អ្វីដែលយកចេញមកពីសំណុំរឿង មិនមែនថា ជាចំណុចសំខាន់នៃកំណត់ហេតុ ឬក៏ចម្លើយរបស់គេ ដែលត្រូវពិចារណាដោយអង្គជំនុំជម្រះ ។ គេបញ្ជូនជាអ៊ីម៉ែល ជាក្រុមមួយទៅឲ្យទៅភាគីទាំងអស់ហ្នឹង ហើយគ្រាន់តែបញ្ជាក់ថា ខ្ញុំនឹងប្រើឯកសារនេះ ឯកសារមួយនេះៗ សម្រាប់ថ្ងៃស្អែកដើម្បីឲ្យភាគីមិនអាចនឹងភ្ញាក់បានឯកសារទាំងអស់ហ្នឹង ។ ពិនិត្យមើលERN ទាំងអស់ ។ អ៊ីចឹងដើម្បីធ្វើម៉េចឲ្យយើងបានរៀបចំ បានល្អសម្រាប់នឹងធ្វើសក្ខីកម្មហ្នឹងឲ្យបានសមស្រប ។

[១០:៣៨:១០]

អ្វីដែលខ្ញុំបានលើកឡើងជូនចៅក្រមហ្នឹង គឺថាខ្ញុំឃើញថាមានប្រើពេលច្រើន ដើម្បីឲ្យភាគីរកឯកសារហ្នឹង ថាតើនៅកន្លែងណា បកប្រែត្រឹមត្រូវឬអត់? គឺយើងចំណាយពេលច្រើនកន្លែងហ្នឹង ។

អ៊ីចឹង ខ្ញុំជិតដល់ចំណុចចប់ ខ្ញុំសូមថ្លែងអំណរគុណ ហើយយើងនៅតែសម្តែងនូវការអំណរគុណគំនិតដែលថា ការជំទាស់នោះត្រូវបានសម្រេចភ្លាមៗដោយអង្គជំនុំជម្រះ ហើយសំណួរដែលថាទាក់ទងថាបញ្ហាត្រូវការថយទៅពិភាក្សានៅថ្ងៃណា ហើយសេចក្តីសម្រេចត្រូវពិចាណាពេលណា ហើយត្រូវដោះស្រាយទៅលើការជំទាស់ហ្នឹង គឺថាបើធ្វើភ្លាមៗគឺពិតជាពន្លឿននូវនីតិវិធីនោះបាន ។ ប្រហែលខ្ញុំសូមបញ្ចប់នូវមតិរបស់ខ្ញុំដោយមិនសូវខ្លីនោះ ។ គឺសូមអរគុណ ។

លោកចៅក្រមជាទីគោរព! ជំហររបស់សហព្រះរាជអាជ្ញាថ្ងៃបុណ្យដែលបានកំណត់ជាផ្លូវការរួចហើយនោះ មានភ្ជុំបិណ្ឌហើយនិងបុណ្យជាតិ ហើយនិងថ្ងៃបុណ្យសម្រាករបស់*យូអ៊ិន* នោះ គឺគ្រប់គ្រាន់ហើយ ។ សម្រាប់ពួកយើងខ្ញុំដើម្បីឲ្យយើងអាចបន្តការងារ ហើយនិងបញ្ចប់សវនាការដោយបានឆាប់រហ័ស ។

ដូចដែលលោកចៅក្រមបានពិនិត្យឃើញហើយ យើងទទួលការទទួលខុសត្រូវក្នុងការចូលពាក់ព័ន្ធជាមួយនឹងរឿងក្តីនេះយ៉ាងម៉ឺងម៉ាត់ ហើយយើងក៏យល់ដែរថា អ្វីដែលគេរង់ចាំលទ្ធផលហ្នឹង តើសាធារណជន គេយល់ដូចម្តេច? ជាពិសេសទាក់ទងជាទៅនឹងថ្ងៃបុណ្យ ។ តាមទស្សនៈរបស់សហព្រះរាជអាជ្ញានោះ យើងនឹងមិនស្នើសុំការឈប់សម្រាបបន្ថែមទៅអ្វីហ្នឹងបុណ្យសម្រាកជាផ្លូវការដែលកំណត់រួចហើយនោះទេ ។ អ៊ីចឹងហើយបញ្ហាទាំងមូលដែលទាក់ទងទៅនឹងបុណ្យណូអែល គឺអនុលោមទៅការសម្រេចរបស់លោក លោកស្រីចៅក្រម ហើយនិងភាគីផ្សេងៗ ហើយយើងនឹងព្យាយាម យើងនឹងយើងព្យាយាមបញ្ចប់កិច្ចការនីតិវិធីនេះ គឺថានៅចុងខែតុលា ឆ្នាំ២០០៩ ។ ហើយអ៊ីចឹងហើយបុណ្យណូអែលមិនជាបញ្ហានោះទេ ។ ប៉ុន្តែ និយាយអំពីការសរសេរសាលក្រមហ្នឹង គឺថាភាគីយល់ហើយគឺថាបន្ទាប់ពីមានសេចក្តីសន្និដ្ឋានបញ្ចប់ចុងក្រោយហើយ។ ប៉ុន្តែ ចំពោះទស្សនទានសាធារណជនវិញ គឺថាគេអាចនឹងយល់ថា រឿងក្តីនោះចប់ហើយ ។

អ៊ីចឹង ហើយពាក្យដែលប្រើនៅក្នុងតុលាការគេមិនទាន់យល់ច្បាប់នោះ ។ អ៊ីចឹង បើយើងរង់ចាំសេចក្តីសម្រេចសន្និដ្ឋានចុងក្រោយរបស់ភាគី ប៉ុន្តែ តុលាការនឹងពិនិត្យមើលទស្សនៈរបស់ភាគីដូចម្តេចទេ ប៉ុន្តែបើពិនិត្យមើលមតិរបស់សហព្រះរាជអាជ្ញា យើងស្នើថា យើងអាចនឹងត្រូវមានពេលបីម៉ោងសម្រាប់

សហព្រះរាជអាជ្ញា គឺថាសេចក្តីប្រកាសបើក គឺថាពីរម៉ោង គឺថា ប្រសិនបើលោកចៅក្រមថាលោកមិនអាចមានបីម៉ោងត្រូវមានពីរម៉ោង យើងនឹងត្រូវគោរពទៅតាមនោះហើយ ។

[១០:៤១:២៥]

អ្វីដែលសហព្រះរាជអាជ្ញា ពិនិត្យរកមើលនោះ គឺថាផ្អែកលើបទពិសោធន៍ទៅលើតុលាការអន្តរជាតិផ្សេងទៀត ។ ខ្ញុំយល់ឃើញថា លើកលែងតែលោកចៅក្រម ផ្តល់នូវពេលវេលាកំណត់ម៉ឺងម៉ាត់ចំពោះរឿងក្តីជាក់លាក់នោះ ពេលសម្រាប់សាក្សី ពេលសួរសំណួរ ។ បើមិនធ្វើដូច្នោះទេ គឺពិបាកនឹងគ្រប់គ្រងសវនាការណាស់ ។ ជាពិសេសពេលនោះ គឺថាវាមានផលប៉ះពាល់ទៅដល់ខាងសហព្រះរាជអាជ្ញាដែលថា ដែលអាចយើងធ្វើដូចម្តេច យើងអាចធ្វើដូចម្តេចនៅក្នុងតុលាការ ។ ជាពិសេសគឺថា អង្គជំនុំជម្រះត្រូវតែកុងត្រូល ត្រូវតែគ្រប់គ្រងឲ្យបាននូវការបែងចែក និងការគោរពពេលវេលានេះ ។

អ៊ីចឹងហើយគឺថាតាមយើង យើងគិតថាអាចនៅតែបញ្ចប់បាននៅចុងខែតុលា ឆ្នាំ២០០៩ ។ នេះហើយសំណើពីសហព្រះរាជអាជ្ញា ផ្អែកទៅលើគំនិតរបស់លោក លោកស្រីចៅក្រម ហើយខាងមេធាវីហើយនិងទម្លាប់អនុវត្តអន្តរជាតិ ហើយនិងទម្លាប់អនុវត្តរបស់ប្រព័ន្ធស៊ីវិលឡ នៅក្នុងបារាំង ហើយនិងប្រទេសបារាំង ប្រទេសអាល្លឺម៉ង់ ។ ជាពិសេស ការពិភាក្សាអំពីបញ្ហាអង្គច្បាប់ ឬក៏បញ្ហាទាក់ទងទៅនឹងវិធានថាតើគួរបកស្រាយយ៉ាងម៉េចនោះ បើតាមជាក់ស្តែងនោះ គឺថាយើងរង់ចាំ និងឆ្លើយទៅនឹងសំណួរបើសិនជាមាននៅពេលនេះ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អរគុណច្រើនតំណាងសហព្រះរាជអាជ្ញាជាតិ និងអន្តរជាតិ ដែលបានលើកឡើងនូវមតិយោបល់ដ៏ល្អៗជាច្រើននៅក្នុងគោលបំណងនៃការបង្កើនល្បឿន នៅក្នុងដំណើរការនីតិវិធីសវនាការឲ្យប្រកបទៅដោយយុត្តិធម៌និងបានឆាប់រហ័សនេះ ។ ហើយអរគុណណាស់ ពីព្រោះថានេះជាការប៉ុនប៉ងរបស់អង្គជំនុំជម្រះ ហើយប្រហែលជាផែនការដែលលោកបានលើកឡើងនេះ គឺជាផែនការរបស់ខ្ញុំ របស់អង្គជំនុំជម្រះដែលបានឯកភាពគ្នាកំណត់កាលបរិច្ឆេទបឋមដំបូង ដែលកំណត់ត្រឹមដាច់ខែតុលា ឆ្នាំ២០០៩ ចប់នោះ ។ ប៉ុន្តែ អ្វីដែលខ្ញុំបានលើកឡើងអម្បាញ់មិញនេះ ដោយសារការគណនារបស់ខ្ញុំគឺបានខុសរហូតដល់ទៅពីរសប្តាហ៍ឯណោះ ។ បើនិយាយរំកិលទៅមុខដោយសារហេតុផលនៃបញ្ហាដែលបន្តបន្ទាប់នេះ គឺកិលរហូតដល់ពីរសប្តាហ៍ ។ អ៊ីចឹងឃើញហើយកាលវិភាគ ហើយខ្ញុំបានបែងចែកជូនអស់លោកលោកស្រី ភាគីដែលពាក់ព័ន្ធឃើញថា ខុសនូវអ្វីដែលបានគ្រោងទុក ។

អ៊ីចឹងគណនាពេលវេលាទាំងម៉ោង ទាំងពេលដែលត្រូវសួរប៉ុន្មានអីប៉ុន្មាននេះ យើងបានគណនាយ៉ាងតឹងរ៉ឹងបំផុត ដើម្បីបំណងនៃការធ្វើសវនាការបានឆាប់រហ័សនេះ ។

[១០:៤៥:០៩]

ហើយអរគុណណាស់ពីព្រោះថា អ្នកទាំងអស់គ្នាមានការប្រឈមនឹងសម្ពាធនៃការរិះគន់ជាច្រើន ហើយតួឯកគឺខ្ញុំតែម្តង ដែលមានការរិះគន់ជាច្រើន ។ ពិសេសមតិសាធារណៈ មតិជាតិ គឺមានបញ្ហាសម្រុកមកខ្ញុំជាច្រើន ។ ដោយសារខ្ញុំមានអ្នកដែលស្គាល់ច្រើនដែរ ជាពិសេសអ្នកច្បាប់ខ្មែរហ្នឹងស្គាល់ខ្ញុំច្រើន ។ អ៊ីចឹង ការអនុវត្តនៅកម្ពុជាដែលមិនធ្លាប់ជួប ។ អ៊ីចឹងគឺមានបញ្ហាជាច្រើនចំពោះខ្លួនខ្ញុំផ្ទាល់ ។ តេឡេហ្វូន គឺថារាល់ថ្ងៃ ពេលយប់ក៏គេរិះគន់ ។ តេឡេហ្វូន គេរិះគន់ពីភាពមិនជឿនលឿន ឬក៏រិះគន់ពីការពន្យឺតក្នុងការប៉ុនប៉ងនៃការពន្យឺតដែរ ។ ប៉ុន្តែ ប្រហែលជាជាក់ស្តែងហើយ យើងឃើញថាយើងប្រឹងប្រែងមែនទែន សូម្បីតែប្រាំមីនុត ដប់មីនុត ក៏យើងធ្វើសវនាការដែរ ។ យើងមិនងាយនឹងការលះបង់នូវពេលវេលាអត់ប្រយោជន៍ទេ ។ ប៉ុន្តែ បញ្ហាផ្សេងៗទៀតគឺ ខ្ញុំគិតថា ស្មារតីនៃការទទួលខុសត្រូវ ក៏ដូចជាទស្សនទានដែលល្អៗពីសហព្រះរាជអាជ្ញា ខ្ញុំសង្ឃឹមថានឹងអនុវត្តទៅបានល្អប្រសើរ ហើយភាគីផ្សេងទៀតក៏ដូចជាគួរតែត្រូវបានយល់អំពីគោលបំណងនេះដែរ ។

ហើយវិធីសាស្ត្រផ្សេងទៀត ដែលអង្គជំនុំជម្រះប៉ុនប៉ងនឹងធ្វើ ក៏លោកស្រីចៅក្រម ខាត់រ៉ាយថ៍ បានជម្រាបជូនភាគី និងអ្នកចូលរួមទាំងអស់បានជ្រាបពីម្សិលមិញហើយនៃការប៉ុនប៉ងធ្វើវិសោធនកម្មនៅក្នុងវិធាន៨៧.៣ ហើយនិងបន្ថែមនូវវិធានថ្មី គឺវិធាន៨៧.៦ ដែលក្នុងគោលបំណងនៃការបង្កើនល្បឿននៅក្នុងការជជែកដេញដោលពិភាក្សាហ្នឹងហើយ ។ នៅក្នុងនោះគឺមានការពិនិត្យនូវគោលការណ៍នៃការពិនិត្យភស្តុតាងនេះ ហើយនិងគោលការណ៍នៃការផ្អែកព្រមព្រៀងលើអង្គហេតុ ។ ប៉ុន្តែ ខ្ញុំគ្រាន់តែអាចរំឭកអ៊ីចេះដែរថា ទស្សនៈនៃការយល់ដឹងទាំងអស់គ្នា គឺខ្ញុំឃើញជាសំឡេងជាទូទៅ សុទ្ធតែយកប្រៀបលើប្រើពាក្យថា ម្នាក់ៗប៉ុនប៉ង ជំរុញឲ្យលឿនឲ្យឆាប់រហ័ស ។ គ្រប់ភាគីទាំងអស់សំឡេងនេះគឺគេបានប្រើប្រាស់ ហើយពេលខ្លះខ្ញុំឃើញប្រើប្រាស់ប្រៀបជាង អង្គជំនុំជម្រះសាលាដំបូងទៅទៀតនៅក្នុងការប្រឹងប្រែងនេះ ។ ប៉ុន្តែ នោះជាការមាត់ថា ប៉ុន្តែសកម្មភាព ខ្ញុំឃើញកត់សម្គាល់ឃើញថាអាចដើរផ្ទុយទៅវិញ ។

ជាក់ស្តែងកន្លងមកយើងបានកាត់នូវសហព្រះរាជអាជ្ញា អំពីតំណាងសហព្រះរាជអាជ្ញាអំពីការជជែកដេញដោលនេះ ។ អ៊ីចឹងសហព្រះរាជអាជ្ញាបានតវ៉ាអំពីលទ្ធភាពនៅក្នុងការកាត់បន្ថយនូវអំឡុង

ពេលវេលាក្នុងការសួរដេញដោល ទៅនឹងការបង្ហាញភស្តុតាងឲ្យលើសពីស្ថានភាពនៃវិមតិសង្ស័យ ។ អ៊ីចឹង វាអាចផ្ទុយគ្នាសញ្ញាណពីរនេះ រវាងការបន្ថយពេលវេលាក្នុងការជជែកដេញដោល ហើយនិងលទ្ធភាពក្នុងការបង្ហាញភស្តុតាង ដើម្បីឲ្យដាក់បន្ទុកឲ្យហួសពីមតិសង្ស័យ ។ នេះក៏ជាបញ្ហា ។ ប៉ុន្តែថ្ងៃនេះគឺរីករាយ ដោយសារមានមតិល្អយោបល់ល្អៗ ហើយនិងប៉ុនប៉ងទាំងអស់គ្នា ។ ខ្ញុំសង្ឃឹមថា ភាគីដទៃទៀតក៏នឹងមានជាមតិយោបល់អ៊ីចឹងដែរ ។

លោកស្រីចៅក្រមមានមតិអីទេ ឬក៏សម្រាកសិន?

ជានេះហើយ យើងប្រកាសសម្រាកដប់ប្រាំពីរមីនុតទៅចុះ ហើយរហូតដល់ម៉ោងដប់មួយ សូមយើងអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចប្រជុំពិភាក្សារបស់យើងតទៅទៀត ។ ហើយការគិតរបស់យើងគឺថា ប្រហែលជាប្រឹងប្រែងម៉ោងដប់មួយព្រឹកនេះ ចប់ ហើយឥឡូវគ្រាន់តែជជែកហ្នឹងឯងគ្រោងថាមួយព្រឹកប្រឹងប្រែថាចប់ ឥឡូវជិតមួយព្រឹកហើយទើបតែបានភាគីតំណាងសហព្រះរាជអាជ្ញានៅឡើយ ភាគីផ្សេងទៀតមិនទាន់បានជួយផង ហើយនៅមានរបៀបវារៈជាច្រើនទៀតដែរ ។ នេះជាបញ្ហាគណនាពេលវេលាប្រហែលជាមិនត្រូវអ៊ីចឹង ។ សូមអរគុណ សូមសម្រាកសិនចុះ ។

*[កិច្ចប្រជុំសម្រាកពីម៉ោង ១០:៤៨ នាទីដល់ម៉ោង ១១:០៨ នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។

យើងបន្តដំណើរការពិភាក្សាតទៅទៀត ។ ហើយអំមិញបានចប់ផ្នែកខាងតំណាងសហព្រះរាជអាជ្ញាហើយ ឥឡូវហ្នឹងដល់ជូនវេទិកាទៅមេធាវីការពារក្តី តើចង់មានមតិយោបល់អ្វីទេ នូវប្រធានបទដែលបានដាក់ពិភាក្សានេះ?

លោក អាឡាំង វែនណឺ?

**លោក ហ្វ្រង់ស្វ័រ រូ៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំមានសំណួរមួយទាក់ទងទៅនឹងការចាត់ចែងការងារនេះ ។ តើជាការអញ្ជើញឲ្យចូលរួមនៅក្នុងនីតិវិធីនេះបានដែរ គឺថាប្រធានខាងផ្នែកការពារក្តី ពីព្រោះខ្ញុំគិតថាប្រធានខាងផ្នែកការិយាល័យការពារក្តី គឺមានការចាប់អារម្មណ៍និងការព្រួយបារម្ភចំពោះការពិភាក្សាគ្នា

នេះ ជាពិសេសទាក់ទងទៅនឹងបញ្ហាថវិកា ពីព្រោះមិនដែលមានគម្រោងនៅក្នុងថវិកាទេសម្រាប់សវនាការរយៈពេលវែងនេះ ។ ដូច្នេះ ខ្ញុំយល់ថា ជាការសំខាន់ណាស់ដែលលោក វីឆាត រូជឺ គួរតែត្រូវមកចូលរួមនៅក្នុងការពិភាក្សាគ្នាផងដែរ ហើយនិងអាចផ្តល់នូវព័ត៌មានដែលគាត់មានទាក់ទងទៅនឹងបញ្ហានេះ ។

**លោក អាឡាំង វែ៊នណឺ៖**

លោកប្រធាន! ដោយសារខ្ញុំមានសំណើមួយដែលទាក់ទងទៅនឹងសំណើរបស់មេធាវីការពារក្តី តើយើងអាចមានលទ្ធភាព ក្នុងការប្រាប់ទៅមន្ត្រីខាងតុលាការ ទាំងខាងផ្នែករដ្ឋបាលទាំងពីរនាក់ ពីព្រោះពួកយើងខ្ញុំមានការបារម្ភណាស់ ដែលថា បញ្ហាទាក់ទងទៅនឹងថវិកា គឺយើងចង់ឲ្យអង្គសវនាការធ្វើការសួរមន្ត្រីទាំងពីរនាក់ដែលជាអ្នកតំណាងឲ្យការិយាល័យរដ្ឋបាល ។ ហើយខ្ញុំមិនដឹងថា ពួកគេបានចាកចេញទៅបាត់សោះ ។ បើសិនជាលោកប្រធានអាចអញ្ជើញឲ្យប្រធានខាងផ្នែកការិយល័យរដ្ឋបាលដើម្បីមកចូលរួមនៅពេលដែលយើងពិភាក្សាទលើបញ្ហានេះ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកស្រីចៅក្រម ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន ។ ទាក់ទងទៅនឹងចំណុចទីពីរ ដែលលើកឡើងនេះ តើខ្ញុំចង់ដឹងថា តើមន្ត្រីដែលជាមន្ត្រីជាន់ខ្ពស់ នៅក្នុងការិយាល័យរដ្ឋបាលនេះអាចផ្តល់ព័ត៌មានបានទេ? ទាក់ទងទៅនឹងវត្តមានរបស់លោកប្រធាន អ្នកតំណាងលោកប្រធាន ហើយនិងខាងអនុប្រធានរបស់ការិយាល័យរដ្ឋ-បាលនោះ?

[១១:១១:១៣]

**លោក អាល់ឌុលឡាក់ ថារីក៖**

គឺថាយើងអាចធ្វើបានធ្វើបានដូច្នេះហើយ លោកស្រីចៅក្រម ។

**លោក អាឡាំង វែ៊នណឺ៖**

បើអ៊ីចឹងគឺថា យើងឯកភាពទៅលើចំណុចនេះ ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ខ្លួនខ្ញុំផ្ទាល់ ខ្ញុំមិនជំទាស់ទៅលើចំណុចនេះទេ ក៏ប៉ុន្តែ ផ្ទុយទៅវិញនោះ ខ្ញុំជឿថា គឺជាគំនិតល្អណាស់ ដែលត្រូវឲ្យប្រធានផ្នែកការពារក្តីហ្នឹង ចូលរួមនៅក្នុងការពិភាក្សាគ្នានេះ ។

*(ចៅក្រមពិភាក្សា)*

**ប្រធានអង្គជំនុំ៖**

បញ្ហានេះ គឺអង្គជំនុំជម្រះ យល់ព្រមតាមសំណើរបស់មេធាវីការពារក្តី ដែលសុំអញ្ជើញប្រធានការិយាល័យអង្គភាពការពារក្តីហ្នឹង មកចូលរួមក្នុងប្រជុំនាពេលនេះ ។ ក្រឡាបញ្ជីអាច ណាតាសា អាចចាត់ចែងដើម្បី អញ្ជើញឲ្យគាត់ចូលរួមប្រជុំ ។

អញ្ជើញ ។

**លោក គង់ ពិសី៖**

សូមអរគុណ លោកប្រធាន និងសូមគោរពអង្គជំនុំជម្រះ និងលោកស្រីចៅក្រម និងលោកចៅក្រមទាំងអស់ ដែលបានអនុញ្ញាតឲ្យខ្ញុំ ឡើងមកជូនជាយោបល់ខ្លះៗទាក់ទងទៅនឹងពេលវេលានៃការធ្វើសវនាការនេះ ។ តាមការពិតទៅ ខ្ញុំបាទចង់សុំលើកឡើងមុនពេលសម្រាកម្ដេះ ដើម្បីឲ្យស៊ីគ្នាជាមួយនឹងសហព្រះរាជអាជ្ញាអន្តរជាតិ ដែលគាត់បានលើកឡើង ។ ហើយទាក់ទងទៅនឹងការពន្លឿនសវនាការនេះគឺថា សហព្រះរាជអាជ្ញាបានលើកឡើងហ្នឹង គឺជាការប្រសើរហើយ ប៉ុន្តែ ខ្ញុំសូមលើកពីពាក្យពីរដែលយកមកសុំឲ្យអង្គប្រជុំហ្នឹង ធ្វើការពិចារណា ដែលជាភាសាអង់គ្លេស គេហៅថា *អេហ្វេសិនស៊ី* គឺថា ហើយនិង *អេហ្វេទីវណេស* គឺវា ប្រសិទ្ធភាព ហើយនិងប្រសិទ្ធផល ។ អ៊ីចឹងប្រសិនណាជាយើងពន្លឿនសវនាការហ្នឹងឲ្យលឿន គឺថាខ្ញុំឯកភាពហើយ ប៉ុន្តែឲ្យវាពាក្យពីរហ្នឹង ឲ្យវាស៊ីគ្នាផង ឲ្យវាមានតុល្យភាពជាមួយគ្នាផង ។ ពាក្យថា *អេហ្វេសិនស៊ី* ហ្នឹងមួយម៉ាត់ហ្នឹង គឺថា ប្រសិទ្ធភាព។ ប្រសិទ្ធភាពហ្នឹងគឺថា បើយើងចំណាយពេលតិច ចំណាយមនុស្សតិច ចំណាយធនធានតិច អាហ្នឹងគឺថា យើងដំណើរការទៅមានប្រសិទ្ធិផលហើយ បើចំណាយពេលតិច ធនធានតិច មនុស្សតិច ប្រាក់កាសតិចហ្នឹងប្រសិទ្ធផល ។

[១១:១៤:២៥]

តែសួរថា ប្រសិទ្ធផលគឺចំណាយពេលវេលា លោកព្រះរាជអាជ្ញាគាត់ថា លើកឡើងវាខ្លីណាស់ពេលវេលាហ្នឹងខ្លីណាស់ តែសួរថាតើវាមានប្រសិទ្ធភាព ឬអត់ ទាក់ទងពីបញ្ហាហ្នឹង? បើសិនណាជាវាមិនមានប្រសិទ្ធភាពទេ យើងគិតធ្វើយ៉ាងម៉េច? អ៊ីចឹង ខ្ញុំសូមលើកពីបញ្ហាខ្លះៗ ទាក់ទងទៅនឹងផលលំបាក ដែលខ្ញុំបានសង្កេតឃើញកន្លងមកនៅក្នុងសវនាការនេះគឺថា ទីមួយ ទាក់ទងទៅនឹងការបកប្រែតែដូចពីព្រឹកមិញ ដូចជា វាមានប្រសិទ្ធផលហើយ ។ ការបកប្រែហ្នឹងលឿនបំផុត អ្នកបកប្រែអត់ពូតវ៉ា

អីថា ត្រូវមាននិយាយឲ្យយឺតៗទេ គឺថាទៅរហូតអញ្ចឹងទៅ ប៉ុន្តែនៅដំណាក់ពេលសវនាការ អ្នកបកប្រែ គាត់ថា ឲ្យអ្នកបកប្រែគាត់ថា ឲ្យអ្នកនិយាយយឺតៗមកវិញ និយាយយឺតៗ ដើម្បីបកប្រែទៅឲ្យបានច្បាស់ ការបកប្រែឲ្យបានច្បាស់ គឺជាប្រសិទ្ធភាព ។ អ៊ីចឹង បើយើងចង់បានប្រសិទ្ធភាពបកឲ្យយឺត តែវាបាត់បង់អាប្រសិទ្ធផលហ្នឹងណា៎ ពេលវេលាចំណាយពេលច្រើន នេះគឺជាឧបសគ្គ ហ្នឹងបញ្ហាឧបសគ្គទីមួយ ។

ឧបសគ្គទីពីរទៀតគឺថា កន្លងមកគឺយើងធ្វើសវនាការហ្នឹង ទៅតាមប្រព័ន្ធពីរ គឺប្រព័ន្ធស៊ីវិលឡ ផង និងខមិនឡ ផង គឺសួរទាំងអស់គ្នា សួរដេញដោល ។ ហើយទាក់ទងទៅនឹងការសួរហ្នឹងទៀត យើងចំណាយពេលក៏ច្រើន ។ ដល់ពេលចំណាយពេលច្រើន យើងអត់បានដឹងថា អ្នកសួរចំនួនប៉ុន្មាន អ្នកណាសួរចំនួនប៉ុន្មានទេ ។ ខ្ញុំមិនបន្ទោសទៅខាងជនជាប់ចោទទៀតទេ គឺថាយើងប្រើសំណួរឲ្យខ្លី ដល់ពេល (សុំទោសបើសិនជាប៉ះពាល់) តែគាត់ចំណាយពេលវែងយកមកឆ្លើយ គឺថាអ៊ីចឹង យើងមិនអាចកំណត់បាន ។ ឧទាហរណ៍ថាចៅក្រម កំណត់ឲ្យមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីសួរកន្លះម៉ោងទៅមួយម៉ោង ។ អ៊ីចឹង សំណួររបស់ខ្ញុំ ត្រូវតែកន្លះម៉ោង ទៅមួយម៉ោង ប៉ុន្តែ អត់បានគិតទៅថា គាត់ឆ្លើយទៅប៉ុន្មានម៉ោងទេ ។ បើខ្ញុំជម្រាបចៅក្រមថា ខ្ញុំឆ្លើយ សួរមួយម៉ោង តែដល់ពេលគាត់រៀបរាប់វែងទៅ អ៊ីចឹងវាឡើងទៅមួយម៉ោង ខ្ញុំសុំកន្លះម៉ោង វាឡើងទៅមួយម៉ោង ។ អ៊ីចឹងវាអាចខុសអញ្ចឹង នេះការប៉ាន់ប្រមាណពេលវេលា ។

អ៊ីចឹងបានថា ការប៉ាន់ប្រមាណពេលវេលាហ្នឹង ខ្ញុំបាទសូមជម្រាប ឧទាហរណ៍មួយទៀតថា យើងសួរសាក្សីម្នាក់ សាក្សីម្នាក់ហ្នឹង យើងថា ចំណាយពេលក្នុងមួយថ្ងៃ ហើយប្រសិនណាជាខ្ញុំគិតទៅសាក្សីមួយ អំឡុងរយៈពេលមួយថ្ងៃ ថាមានប្រាំមួយម៉ោងកន្លះក្នុងមួយថ្ងៃ ។ អាហ្នឹងបើខ្ញុំនិយាយខុស សុំជួយកែខ្ញុំផង ។ ក្នុងមួយថ្ងៃប្រាំមួយម៉ោងកន្លះ អ៊ីចឹងយើងថា សួរសាក្សីមួយថ្ងៃ។ ប៉ុន្តែ យើងអត់បានដកអាពេលសម្រាកពីរដងទេ ព្រឹកម្ភៃនាទី ល្ងាចម្ភៃនាទី អស់សែសិបនាទីបាត់ ។ អ៊ីចឹង បើខ្ញុំគិតទៅនៅសល់តែប្រាំម៉ោងហាសិបនាទី ។ ហើយអត់បានគិតថា ភាគីទាំងឡាយហ្នឹងសុំបញ្ចាំង ឯកសារនៅលើ *ស្គ្រីន* ទៀត ។ អាការបញ្ចាំងឯកសារនៅលើ*ស្គ្រីន*នេះ ចំណាយពេលប្រហែលជាប្រាំទៅដប់នាទីទៀត មិនទាន់បានគិតទៅការជំទាស់របស់ភាគីទាំងសងខាងទៀត។ មិនទាន់បានគិតទៅដល់ការដែលសហចៅក្រមហ្នឹង ចូលទៅធ្វើការពិចារណាទៀត ។ បើសិនជាគិតដល់អាហ្នឹងទៀត គឺថាមិនដល់ប្រាំម៉ោង គឺថាចំណាយពេលច្រើនណាស់ អាហ្នឹងបញ្ហាមួយទៅ ។

[១១:១៧:៤៦]

ហើយលើកដូចជា បញ្ហាដូចជាថ្ងៃនេះអ៊ីចឹង ថ្ងៃនេះយើងកំណត់ថា យើងប្រជុំដើម្បីចាត់ចែងសវនាការ ប៉ុន្តែយើងអត់បានគិតថា យើងឲ្យសាក្សីមកស្បថទេ សាក្សីមកស្បថចំណាយពេលយើងអស់មួយម៉ោង អ៊ូ!កន្លះម៉ោងបាត់ហើយ ។ អាហ្នឹង គ្រាន់តែឧទាហរណ៍ ដែលខ្ញុំសូមលើកពីផលលំបាកជូនថា អង្គជំនុំជំនុំជម្រះពិចារណា ។

ហើយការសួរទៀត ទាក់ទងទៅនឹងការសួរដេញដោល យើងសួរសាក្សីបដិបក្ខក៏ដោយ យើងត្រូវប្រើវិធីសាស្ត្រមួយគេហៅថា ការសួរខ្វែង ហៅ *ក្រូសអិចសាមីណេសិន* យើងប្រើវិធីសាស្ត្រហ្នឹង ។ អ៊ីចឹង វិធីសាស្ត្រហ្នឹង គឺថាយើងអត់បានប្រើឲ្យត្រឹមត្រូវជាក់លាក់ទេ យើងត្រូវពង្វាង ។ ឧទាហរណ៍ថា យើងសួរសំណួរអីមួយអ៊ីចឹងទៅ ដើម្បីឲ្យគាត់ឆ្លើយទៅ យើងរៀបរាប់សឹងតែប្រាំទៅដប់នាទី ហើយគ្រាន់តែឲ្យសាក្សី ឬជនជាប់ចោទឆ្លើយថា តើលោកឯកភាពជាមួយនឹងខ្ញុំទេ ឬក៏មិនឯកភាព? តើខ្ញុំយល់ហ្នឹងត្រូវទេ? ឬក៏ខ្ញុំយល់ហ្នឹងមិនត្រូវទេ? នេះគឺជាឧបសគ្គដែលថា យើងសួរគាត់ដោយប្រើការអធិប្បាយដ៏វែង ដើម្បីឲ្យគាត់ឆ្លើយតែមួយម៉ាត់ នេះគឺជាឧបសគ្គដែរ ។

បញ្ហាមួយទៀត បញ្ហាអង្គហេតុព្រមព្រៀងគ្នា ។ អង្គព្រមព្រៀងគ្នា គឺថាយើងបានព្រមព្រៀងគ្នាហើយៗ ។ អ៊ីចឹង សួរថាតើនៅពេលសវនាការហ្នឹង យើងគួរតែលើកយកមកដេញដោលទៀតដែរឬទេ? ប៉ុន្តែបើសិនជាណាយើងមិនលើកយកមកដេញដោល ស្រាប់តែភាគីម្ខាងៗទៀតថា សុំឲ្យដាក់ភស្តុតាងនេះដើម្បីជជែកគ្នា ។ អ៊ីចឹង យើងចំណាយពេលអ្នកហ្នឹងទៀត ។ អង្គហេតុ ដែលទាក់ទងនឹងអង្គហេតុហ្នឹង ។ អាការបញ្ឆាំងនៅក្នុងស្លាយហ្នឹងទៀត គឺថានៅពេលនេះគឺយើងធ្វើ *ក្រូសអិចសាមីណេសិន* ហ្នឹងគឺថា អត់បានទេ ។ អ៊ីចឹង យើងត្រូវការបញ្ឆាំងក្នុងស្លាយ អាបញ្ឆាំងក្នុងស្លាយនេះ គឺជាការសួរភ្ញាក់ គេហៅថា *អ៊ុមភិចមិន* អង់គ្លេសហៅ *អ៊ុមភិចមិន* គឺជាការសួរភ្ញាក់ ដើម្បីឲ្យគាត់ឆ្លើយថា មិនមែនទេ ប៉ុន្តែឯកសារនេះមានអ៊ីចឹងហើយលោក ព្រម មិនព្រម ។ ដូច្នេះ យើងត្រូវប្រើអាហ្នឹងទៀតដល់ពេលប្រើអាហ្នឹងទៅ គឺដូចជាឧបសគ្គមួយដ៏វែង ដែលយើងធ្វើឲ្យយើងពិបាកក្នុង-- ត្រូវចំណាយពេល ហើយបើសិនជាយើងចំណាយពេលទៅ វាបាត់បង់អាដែង *អែលវីហ្វេនស៊ី* ប្រសិទ្ធផល ព្រោះយើងចំណាយពេល ហើយបើសិនយើងមិនធ្វើអាហ្នឹងទេ វាបាត់បង់ *អែសហ្វីសទីវណេស* ប្រសិទ្ធភាពនោះបាត់បង់ ។ ហើយនេះគឺជាបញ្ហា អ៊ីចឹងសួរថា តើយើងពន្លឿនសវនាការហ្នឹងដោយយ៉ាងម៉េច? ទាល់តែយើងគិតបានគ្រប់គ្រាន់ ខ្ញុំគ្រាន់តែដាក់ជាគំនិតទេ បើសិនជាអាចយកទៅពិចារណាបាន ឧទាហរណ៍សាក្សី

ម្តងទៀត ថាយើងចំណាយពេលប្រាំម៉ោងកន្លះ សួរអំពីអី? ឧទាហរណ៍សួរថា ពីវិធានបទថាការអនុវត្ត គោលនយោបាយនៅស-២១ យើងកំណត់តែហ្នឹងមួយ ហើយមានពេលយើងដល់ពេលសម្រាកទៅ នៅសល់តែប្រាំម៉ោងហាសិបនាទីទេ ។ ហើយយើងដឹងថាភាគីណាសួរខ្លះ? វាអាចៗដល់មានមនុស្ស ទៅដល់ដប់នាក់ អាចសួរនៅហ្នឹង ជួនកាលចៅក្រមពីរនាក់ ព្រះរាជអាជ្ញាពីរនាក់ បួន ភាគីដើមបណ្តឹង រដ្ឋប្បវេណីថែមបួននាក់ទៀតទៅ ហើយភាគីខាងមេធាវីការពារទៀតទៅ ។ ដូច្នេះ បើម្នាក់ចំណាយ ពេលកន្លះម៉ោង ក៏លើសក្នុងមួយថ្ងៃដែរ លើសមួយថ្ងៃ។ ហើយមិនមែនចំណាយតែកន្លះម៉ោងប៉ុណ្ណឹង អាចចំណាយដល់មួយម៉ោង ដល់ពេលចំណាយលើសពីមួយម៉ោង វាខ្វះប្រសិទ្ធផលហ្នឹង ។ ព្រោះយើង ចំណាយពេលច្រើន អានេះទាក់ទងទៅនឹងរឿងថាពន្លឿនសវនាការទៅ ដល់ពេលហើយទៅ វាខ្វះ ប្រសិទ្ធភាព ។ បាទ, ជម្រាបជូនពីបញ្ហាទាំងហ្នឹង ។

ទាក់ទងមួយទៀត បើសិនណាជាយើងមានការរិះគន់ ខ្ញុំជឿថាមានការរិះគន់ សូម្បីតែខ្ញុំក៏ឮដែរ លោកប្រធាន ខ្ញុំក៏សារភាពដែរ ឮថាសវនាការរបស់យើងហ្នឹង មានការយឺតយ៉ាវ ពន្យារអ៊ីចឹង ។ អ៊ីចឹង នៅក្នុងសាលាក្តីរបស់យើងហ្នឹង ខ្ញុំបានដឹង បានឮថា មានបណ្តាញសារព័ត៌មានផ្នែកខាងផ្សព្វផ្សាយទៅ ឲ្យសាធារណជនដឹងក្នុងហ្នឹង ។ វាគួរតែផ្សព្វផ្សាយអាហ្នឹងឲ្យគេដឹងបានច្បាស់លាស់ថា ដំណើរការនីតិ វិធីនេះយ៉ាងម៉េច គេឲ្យយល់អំពីបញ្ហាហ្នឹងដើម្បីឲ្យគេដឹងថាការដែលយើងធ្វើហ្នឹងឲ្យបានហ្មត់ចត់ ។

អ៊ីចឹង ខ្ញុំសំណូមពរថា ធ្វើយ៉ាងម៉េចសុំឲ្យមានសវនាការហ្នឹងគឺថាលឿនក៏ដោយ ប៉ុន្តែកុំឲ្យបាត់ បង់ប្រសិទ្ធភាព ។ អ៊ីចឹង សូមអរគុណ ។

[១១:២២:៣៧]

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី ដែលបានផ្តល់យោបល់ ចូលរួមមតិយោបល់ក្នុងបញ្ហានេះ ។

សូមអញ្ជើញតទៀត ។ សូមអញ្ជើញលោកស្រីមេធាវី ។

**លោកស្រី វ៉ាបេសាន់ជ្រាតាណា៖**

ជាបឋមពាក់ព័ន្ធទៅនឹងរយៈពេលដែលលើកមកពិភាក្សា ដែលយើងគ្រោងទុករហូតដល់ខែធ្នូ ដោយអង្គជំនុំជម្រះ ហើយសហព្រះរាជអាជ្ញាចាត់ថា ខែតុលា នោះ ហើយយើងនឹងពិភាក្សាទៅដល់ បញ្ហានេះ យើងត្រូវយល់ពីភាពចាំបាច់របស់អង្គជំនុំជម្រះរបស់សាលាដំបូង ហើយនិងការងារដែលខ្លួន កំពុងតែប្រឈមមុខ ហើយគឺវាអាស្រ័យទៅលើយើងអស់គ្នាដើម្បីពិភាក្សា ថាតើយើងត្រូវធ្វើដូចម្តេច

ឲ្យប្រសើជាងនេះ? ប៉ុន្តែ យើងយល់យ៉ាងច្បាស់អំពីការប៉ុនប៉ងថា ឲ្យមានការជំនុំជម្រះឲ្យបានចប់ ឲ្យបានឆាប់ ដូចដែលស្នើឡើងដោយសហព្រះរាជអាជ្ញានៅចុងខែតុលា នោះ។ ប៉ុន្តែ ដោយមិនបានបញ្ជាក់អំពីកាលបរិច្ឆេទឲ្យច្បាស់ទេនោះ តាមពិតនោះគឺថាយើងត្រូវបង្កើតនូវកាលកំណត់ជាក់លាក់មួយចំនួនដែលថា ដែលមិនត្រូវបានគោរពទេ ប៉ុន្តែ បើសិនជាយើងមានកាលបរិច្ឆេទដែលអនុញ្ញាតឲ្យយើងនៅក្នុងការអនុវត្តទៅបាន ដោយសារថាយើងធ្វើការងារជាអ្នកស្ម័គ្រចិត្តទេ ។ យើងមកធ្វើការនៅទីនេះគឺថាយើងអនុវត្តដោយស្ម័គ្រចិត្ត ហើយត្រូវយើងចង់បានគំនិត ថាតើត្រូវវិធីអនុវត្តដូចម្តេច? ទាក់ទងទៅនឹងការជំនុំជម្រះខ្លួនឯងហ្នឹង គឺថាអាចអនុញ្ញាតអង្គជំនុំជម្រះហ្នឹងប្រើនូវថាមពលមួយចំនួន គឺថាបើមិនបានកំណត់ពេលវេលាជាក់លាក់ទេ ហើយនិងរយៈពេលចាំបាច់មួយចំនួន អ៊ីចឹងហើយដើម្បីឲ្យយើងបានដឹងថា តើយើងនឹងអនុវត្តដូចម្តេច? អ៊ីចឹងសំណើសុំឲ្យមានការកំណត់ៗជាក់លាក់នោះ គឺជាគំនិតផ្តួចផ្តើមមួយល្អ ។ ទាក់ទងទៅនឹងរយៈពេលកំណត់សម្រាប់សួរសំណួរនោះ ការណ៍នេះតម្រូវឲ្យមានការត្រៀមរៀបចំជាច្រើនមុន ។ ខ្ញុំសូមបញ្ជាក់ថា ចំពោះខ្ញុំ ខ្ញុំយល់ថាគឺមានគំនិតល្អ ដើម្បីនឹងផ្តល់ពេលវែងច្រើន ព្រោះថាវាអាស្រ័យទៅលើអ្វីដែលបានអនុវត្តនៅទីនេះ ដែលថារយៈពេលនឹងអាចជាអ្វីដែលវានឹងជាស្មាន បើទោះជាកំណត់មុនក៏ដោយ ។

[១១:២៥:៤០]

អ៊ីចឹងគឺថាបើដាក់កាលកំណត់ គឺថាយើងត្រូវគោរពតាមការកំណត់ដែលព្រមព្រៀងហ្នឹង អ៊ីចឹងគឺអង្គជំនុំជម្រះបានស្គាល់ហើយថា យើងមិនបំពានពេលវេលានៃការសួរនោះទេ ។ ប៉ុន្តែ តាមពិត ដែលខ្ញុំមិនជឿថា ខ្ញុំត្រូវមានសំណួរខ្លីជាងមុន និងធ្វើឲ្យនីតិវិធីមានរយៈពេលខ្លី និងមិនប្រឹងប្រែងខ្លាំងនោះទេ ប៉ុន្តែ ខ្ញុំនឹងពិនិត្យមើលបញ្ហាមួយដែលទាក់ទងទៅនឹងអង្គហេតុ ដែលទាក់ទងទៅនឹងស-២១ ដែលតាមពិតនេះជាចំណុចខ្លឹមសារសំខាន់នៃការជំនុំជម្រះ ។ ដូច្នេះអ្វីៗត្រូវតែបញ្ជាក់ឲ្យច្បាស់ យើងចូលឲ្យដល់ស៊ីជម្រៅ ដោយគោរពទៅតាមនីតិវិធីដំណើរការនេះ ។ អ៊ីចឹងហើយយើងស្នើសំណើវិសោធនកម្មវិធាន ៨៧ នោះ ទាក់ទងទៅនឹងការបង្ហាញនូវភស្តុតាងនោះ គឺថាអាចនឹងជួយសម្រួលឲ្យអង្គជំនុំជម្រះហ្នឹងអាចដំណើរការទៅមុខបាន ។ អ៊ីចឹងការដែលធ្វើសង្ខេបឯកសារនោះ គឺថា យើងមិនយល់ជំទាស់ទេ ហើយយើងមិនមានមតិយល់ជាក់លាក់ទេចំពោះបញ្ហានេះ ។ ប៉ុន្តែ ទាក់ទងទៅនឹងការវិវត្តជាទូទៅនៃដំណើរការសវនាការ ដោយពិចារណាលើការពន្លឿននីតិវិធីនោះ យើងឯកភាពទាំងស្រុងថា យើងបានដឹងពីបញ្ហានេះ ប៉ុន្តែវាមិនមែនជាបញ្ហាដែលថាខូចប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណីនោះទេ ។

ខ្ញុំមានការស៊ើបអង្កេតពីរ ហើយយើងមិនអាច ទីមួយ មិនអាចបំព្រួញ។ ហើយខ្ញុំជឿថា យើងមិនអាចបំព្រួញការអះអាងរបស់ជនរងគ្រោះនោះទេ គឺថាម្នាក់ៗដែលនៅក្នុងក្រុមយើង យើងមានអ្នករួចរស់រានជីវិតពីរបបហ្នឹង ហើយនេះគឺជាធាតុផ្សំពិសេសមួយ នេះគឺជាចំណុចសំខាន់តាមគោលការណ៍ប្រវត្តិ-សាស្ត្រ ។ ដូច្នេះ វាមានការសំខាន់ មិនសម្រាប់តែពលរដ្ឋកម្ពុជាប៉ុណ្ណោះទេ ប៉ុន្តែចំពោះពិភពលោកទាំងមូលនោះដែរ ។ ខ្ញុំជឿថាតម្លៃនៃសក្ខីកម្មនៃអ្នករស់រានមានជីវិតពីរបបនោះ គឺថាមិនអាចត្រូវបានកាត់បន្ថយនោះទេ ។ នេះគឺជាចំណុចមួយដែលខ្ញុំចង់លើកឡើង ។

ហើយតាមពិតយើងត្រូវផ្តោតពេលវេលាដោយចាំបាច់ ដើម្បីទទួលការស្តាប់រឿងហ្នឹង គឺថាមិនត្រឹមតែជនរងគឺថាអ្នកខ្លះមកពីអ៊ឺរ៉ុប មកពីប្រទេសបារាំង គេមានអ្វីៗដើម្បីជម្រាបអង្គជំនុំជម្រះ ហើយគេមានសាច់ញាតិផ្ទាល់ដែលត្រូវបាត់បង់ជីវិត ហើយគេចង់បញ្ជាក់បំភ្លឺអំពីបញ្ហាទុក្ខសោករបស់គេ អ្វីដែលកើតឡើងទៅហ្នឹងគឺថាអ្វីកើតឡើងសាមសិបឆ្នាំមកហើយនោះ ដើម្បីស្វែងរកការពិត ដើម្បីឲ្យគេអាចពន្យល់ដែលនឹងបំភ្លឺមួយនៅកន្លែងនេះ ដែលមានសារប្រយោជន៍ ។ អ៊ីចឹងគឺថាមានការព្រួយបញ្ហាដែលទាក់ទងមួយ គឺថាមិនគប្បីបន្ថយ ឬក៏បន្ថយអំណាចពាក្យសម្តីរបស់ជនជាប់ចោទនោះទេ ។

[១១:២៩:០៣]

ចំណុចចុងក្រោយដែលខ្ញុំចង់លើកឡើងដែរនោះ គឺដូចដែលបានពន្យល់ទាក់ទងទៅនឹងសាក្សី ឬក៏អ្នករួចរស់មានជីវិតនៅ ។ ចំណុចនេះគឺថានេះជាចំណុចមួយ ដែលវាមានស្ថានភាពមួយដែលគាត់មានការបាក់ស្មារតី ដែលគាត់ចង់បង្ហាញ ចំពោះអ្នកទាំងអស់នេះ កាលណាយើងកំណត់កាលបរិច្ឆេទរួចហើយ យើងមិនអាចប្រើសេរីភាពថាឲ្យគេរង់ចាំយូរពេកនៅក្រោយនោះទេ យើងអាចបញ្ជាក់ថាយើងមិនអាចធ្វើថ្ងៃនេះទេ ថ្ងៃក្រោយយើងនឹងអញ្ជើញនៅពេលក្រោយ ។ បើយើងធ្វើបែបនេះជាញឹកញាប់ ខ្ញុំគិតថាគេមានការលំបាក ថាតើដំណើរការយុត្តិធម៌នោះ វាមានដំណើរការយ៉ាងម៉េច? ប៉ុន្តែ បើសិនជាយើងធ្វើដូច្នេះញឹកញាប់គឺថាគេអាចនឹងយល់ច្រឡំអំពីចំណាត់ការ ។ ហើយអ៊ីចឹង គឺថាយើងអាចនឹងបាត់បង់ឱកាសនឹងស្តាប់មតិរបស់គេ ។ អ៊ីចឹងហើយយើងត្រូវគោរពសិទ្ធិរបស់គេ កាលណាកាលបរិច្ឆេទកំណត់ហើយ យើងត្រូវតែគោរពៗតាមកាលបរិច្ឆេទនោះ ដើម្បីគោរពសិទ្ធិរបស់ជនរងគ្រោះទាំងអស់នោះ ។ នេះជាសេចក្តីសង្កេត ដែលខ្ញុំចង់ជម្រាបអង្គជំនុំជម្រះនៅថ្ងៃនេះ ។

**ប្រធានអង្គជំនុំ៖**

អរគុណៗលោកស្រីមេធាវី ដែលលើកឡើងចាប់អារម្មណ៍នេះ ។ ហើយមានបញ្ហាពីរ តាមខ្ញុំគិត

ទៅបញ្ហាដែលការលើកឡើងរបស់ព្រះរាជអាជ្ញា ដែលការប៉ុនប៉ងនឹងចង់ឲ្យអង្គជំនុំជម្រះហ្នឹងកំណត់ផែនការនៃធ្វើសវនាការក្នុងរឿងទីមួយនេះ ។ កំណត់ចុងក្រោយគឺឲ្យចប់នៅក្នុងដំណាច់ខែតុលា ឆ្នាំ ២០០៩ ហើយលោកស្រីដែលបានលើកឡើងអំពីបញ្ហាពាក់ព័ន្ធនឹងកិច្ចពិភាក្សាហ្នឹងដែរ បានមិននិយាយចូលជ្រៅពាក់ព័ន្ធជាមួយនឹងសំណើ ឬក៏ចំណាប់អារម្មណ៍របស់តំណាងសហព្រះរាជអាជ្ញាដែលបានលើកឡើងនេះទេ ដោយមានលើកហេតុផលផ្សេងៗទៀត ដែលមានលក្ខណៈជាទូទៅ ។ នៅក្នុងនោះក៏មានទម្រង់នៃការពារ ឬក៏ទុកឱកាសដល់ភាគីដើមបណ្តឹងរដ្ឋប្បវេណី ជាពិសេសអ្នករស់រានមានជីវិតពីរបបនោះឯង ឲ្យគាត់បានបញ្ចេញនូវសំឡេងនៅសេចក្តីថ្លែងការណ៍ ទុក្ខសោកដែលគាត់បានមានពីយូរមកហើយនោះ នៅក្នុងអំឡុងពេលសវនាការ ។ ខ្ញុំគិតថា អរគុណ ។ ប៉ុន្តែ បញ្ហានេះវាមានភាពមិនស៊ីគ្នារវាងការលើកឡើងរបស់សហព្រះរាជអាជ្ញា ដែលប៉ុនប៉ងថាជំរុញនៅក្នុងការកំណត់ ថ្ងៃ៣១ ខែតុលា ឆ្នាំ២០០៩នោះ ពីព្រោះថាភាពហ្នឹង វាខុសគ្នាត្រង់ថា ទុកឱកាសដើម្បីឲ្យគាត់មានឱកាសគ្រប់គ្រាន់នៅក្នុងការសម្តែងនូវថ្លែងអ្វីដែលគាត់បានជួបប្រទះ ឬបទពិសោធន៍ដែលគាត់ធ្លាប់ជួបប្រទះនៅក្នុងរបបនុ៎ង ។ ហើយប្រសិនជាយើងធ្វើអ៊ីចឹង គឺវាអាចវែង អាហ្នឹងបញ្ហាមួយ ។

ទីពីរ គឺមួយទៀត អស់លោក លោកស្រី បានលើកឡើងថា អង្គជំនុំជម្រះមិនគប្បីធ្វើការលើកសវនាការចំពោះការស្តាប់ ការសេចក្តីថ្លែងការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី ឬក៏អ្នករស់រានមានជីវិតនៅក្នុងរបបនោះ ឬក៏នៅក្នុងស-២១ នោះទេ ។

[១១:៣២:០០៣]

បញ្ហានេះ ខ្ញុំសូមបំភ្លឺថា ទីមួយ ខ្ញុំបានធ្វើប្រធានតុលាការខេត្តបាត់ដំបង កម្ពុជានេះដប់ប្រាំមួយឆ្នាំ ។ បទពិសោធន៍ ដប់ប្រាំមួយឆ្នាំរបស់ខ្ញុំ ខ្ញុំអ្នកជាកំណត់កាលបរិច្ឆេទនៅក្នុងដំណើរការសវនាការទាំងអស់ នៅក្នុងដែនសមត្ថកិច្ច នៅក្នុងដែនដីខេត្ត ប្រហែលជាលោកមេធាវី ហុង គឹមសួន បានយល់ពីព្រោះលោកធ្លាប់ធ្វើការងារនៅបាត់ដំបងដែរ ។ ការគណនាទំហំរឿងនៅក្នុងក្តីនេះ ទោះបីមួយសប្តាហ៍ ឬក៏លើសពីមួយសប្តាហ៍តិចតួច ការគណនារបស់ខ្ញុំស្ទើរតែមិនខុសទេ។ ការគណនានៅក្នុងចំណាត់រឿងក្តីស្ទើរតែមិនខុសទេ បើខុសត្រឹមតែតិចតួចប៉ុណ្ណោះ អាចពន្យារពេល ឬក៏អាចលឿនជាងការកំណត់មួយព្រឹកអីប៉ុណ្ណឹងទេ។ ប៉ុន្តែ ហេតុផលនេះ គឺដល់ពេលថាយើងគណនាទៅ វាអត់ត្រូវ ដូចការគណនារបស់ខ្ញុំបានគិតឃើញសព្វគ្រប់ម៉ោង ពេល គុណគួរហើយហ្នឹង បានយើងកំណត់ចេញ អញ្ជើញដាក់កំណត់កាលបរិច្ឆេទ ស្តាប់អ្នករស់រានមានជីវិត ដែលយើងបានធ្វើរួចហើយ ។

ប៉ុន្តែ ដូចខ្ញុំបានជម្រាបអ៊ីចឹង គឺថាដល់ពេលដំណើរការប្រព្រឹត្តទៅ មានបញ្ហាចម្រូងចម្រាស់ជាច្រើន ។ ទីមួយ គឺការជជែកដេញដោលនៅទីនេះ វែង ដោយសារការចូលរួមពីអ្នកដែលត្រូវមានសិទ្ធិក្នុងសួរដេញដោលនេះច្រើនអ្នក ។ ទីពីរ ដោយសារការបកប្រែភាសា ។ ទីបី វប្បធម៌ខុសគ្នា ដោយសារការប្រើ ការនិយាយ ការសួរនាំហ្នឹងគឺថាមានការនិយាយរឿងបញ្ចប់បួនដប់មីនុតហើយ បានឱ្យឆ្លើយមួយម៉ាត់អ៊ីចឹង នេះជារឿងមួយដែលកម្ពុជាក៏កម្រជួបណាស់ សំណួររបៀបនេះ ។

ហើយបញ្ហានេះ ដែលថាវានាំឱ្យមានការបញ្ហោគណនាឡើងវិញ ដែលឡើងវិញ ដែលខ្ញុំគិតថាហេតុផលគណនាព្រឹកមិញ ដែលខ្ញុំថាវាអ្វីដែលខ្ញុំបានគិតហ្នឹងមិនត្រូវទេ ដោយការគិតមិនត្រូវហ្នឹងហើយ បានជាការគិតចុងក្រោយនេះ យើងគិតថាកម្រិតរហូតដល់ខែ១២ ឯណោះ ដើម្បីកំណត់ថាគណនានេះក៏នៅតែតឹងដែរ នៅប្រឈមដែរ ថានឹងអាចមានបញ្ហាមិនចប់ដែរ បើសិនជាធ្វើដូចពីមុន ។ ប៉ុន្តែ ដោយសារបទពិសោធថ្ងៃនេះ ឃើញថាព្រះរាជអាជ្ញាក៏គេប្ដេជ្ញាចិត្ត ខាងព្រះរាជអាជ្ញាប៉ុនប៉ងថានឹងប្រឹងប្រែងជំរុញល្បឿននេះឱ្យវាឆាប់រហ័ស ។

[១១:៣៤:១៣]

បញ្ហាទីពីរ ក៏មានការមតិគាំទ្រទាំងខាងសហព្រះរាជអាជ្ញា ទាំងមេធាវីការពារ តំណាងដើមបណ្ដឹងរដ្ឋប្បវេណីដែលបានលើកឡើងអំមិញ គឺគាំទ្រលើការវិសោធនកម្មដែលអង្គជំនុំជម្រះសាលាដំបូងស្នើវិសោធនកម្មលើវិធាន៨៧.៣, ៨៧.៦ ដែលប៉ុនប៉ងក្នុងការដាក់បញ្ហានេះទៅ ដោយល្បឿនក្នុងការឱ្យតម្លៃនូវការពិនិត្យភស្តុតាងចាត់ទុកថា បានពិនិត្យភស្តុតាងនៅក្នុងករណីដែលនឹងបកស្រាយដោយលោកស្រីចៅក្រមបន្តិចទៀត ។

បញ្ហាមួយទៀតហ្នឹង គឺអង្គហេតុព្រមព្រៀង។ បញ្ហានេះក៏យើងកំពុងសិក្សាដែរ វារឿងប្លែកសម្រាប់ខាងខ្ញុំដែរ ហើយប្រហែលជាអ្នកទាំងអស់គ្នា ក៏មានរឿងប្លែកដែរ ។ អ៊ីចឹង ខ្ញុំអរគុណណាស់ ប៉ុន្តែ ខ្ញុំចង់ឱ្យមតិផ្សេងទៀតហ្នឹង មានការចាប់អារម្មណ៍ថា គួរតែត្រូវបានឧបមាថា គាំទ្រដោយដែលលើកឡើងដោយតំណាងសហព្រះរាជអាជ្ញា ដែលថា គួរតែត្រូវបានបញ្ចប់យ៉ាងឆាប់រហ័សបំផុតត្រឹមថ្ងៃ៣១ ខែតុលា ឆ្នាំ២០០៩នេះ នេះជាការកាលបរិច្ឆេទនៃការកំណត់ចប់ការដេញដោលរឿងក្ដីនេះ គិតបូកទាំងសេចក្ដីសន្និដ្ឋានរបស់ភាគីផង ។ ដោយចប់ត្រឹមថ្ងៃនេះ ។ ចំពោះការរៀបរៀងសាលក្រមរឿងផ្សេងទៀត ឬមួយហេតុផលថា អាចគណនាទៅខុសពីហ្នឹង ហើយដោយមូលហេតុអី? ហើយបើសិនបើថា ឯកភាព ឬមួយតំណាងសហព្រះរាជអាជ្ញា តើការវិធីសាស្ត្រ ឬក៏ក្បួនខ្នាតរបៀបម៉េច?

វិធីរបៀបណាដែលអាចជួយផ្តល់មកដល់មតិយោបល់ដល់អង្គជម្រះ ដើម្បីឲ្យអង្គជម្រះហ្នឹងមានមូលដ្ឋានយកពិចារណា ដើម្បីគ្រប់គ្រងដឹកនាំសវនាការហ្នឹងឲ្យឆាប់រហ័ស តាមគំនិតនិងទស្សនៈយោបល់របស់អស់លោក លោកស្រី ។ រីករាយគ្រប់មធ្យោបាយ ឬមតិយោបល់ដែលផ្តល់ដល់អង្គជម្រះធ្វើយ៉ាងណាឲ្យការកាត់ក្តីរឿងនេះបានឆាប់រហ័ស ហើយនិងប្រកបដោយភាពយុត្តិធម៌ នោះគឺជាការគាំទ្រពេញទំហឹង ពីខាងអង្គជម្រះ ហើយអង្គជម្រះចង់បានណាស់បញ្ហានេះ ។

សូមអញ្ជើញ ។

**លោក វីលៀម ស្មីត៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំនឹងនិយាយដោយសង្ខេបទាក់ទងទៅនឹងការគណនា ដែលយើងបានបញ្ជាក់ខាងដើមនោះ ថាយើងសូមអរគុណ និងសុំឲ្យថា មានចំណុចជាក់លាក់ដ៏សំខាន់ ដើម្បីអ្នកដែលរួចរស់ជីវិតពីស-២១ និងផ្តល់ពេលស្មើគ្នាទៅហ្នឹងសាក្សីផ្សេងៗទៀត យ៉ាងហោចណាស់បើអាចធ្វើទៅបាន ។ តាមការគណនាបែបនោះ យើងមិនយល់ច្រឡំទេ យើងបានរាប់នៅក្នុងសំណើកាលវិភាគដែលយើងកំណត់ហ្នឹង ។ អ្វីដែលខ្ញុំចង់ជម្រាបនោះ គឺថាវាមានខុសគ្នារវាងអ្នកដែលរស់រានជីវិតពីស-២១ ហើយមានព័ត៌មានជាភស្តុតាងដែលត្រូវផ្តល់មកតុលាការលើបញ្ហាជាក់លាក់មួយចំនួនហ្នឹងក៏ដូចជាសាច់ញាតិរបស់គេ គឺថាចំណុចនេះសំខាន់សម្រាប់ដំណើរការយើង ។ ប្រហែលថា ឲ្យគាត់និយាយសង្ខេបជាងអ្វីដែលអ្នកដែលរួចរស់ពីស-២១ ។ អ៊ីចឹងគឺក្រុមអ្នកសាច់ញាតិនោះ ថាគេអាចផ្តល់សេចក្តីថ្លែងការណ៍ដោយសង្ខេបហ្នឹង ប៉ុន្តែ អ្នកដែលរស់រានមានជីវិតនោះ គាត់ត្រូវការពេលច្រើននិងពន្យល់ថ្លាថ្លែងនោះ ។

[១១:៣៧:៣៩]

**លោកស្រី ស៊ីលឃីស្ទូត ហ្សីនស្ពី៖**

លោកប្រធាន! ខ្ញុំសូមស្នើសំណើមួយចំនួនទាក់ទងប្រើពេលរហូតដល់ថ្ងៃពិសាបាយថ្ងៃត្រង់ អ៊ីចឹងគឺថាផ្នែកប្រធានខាងផ្នែកគាំពារការពារក្តីនោះ គាត់គឺ យើងឯកភាពថាយើងថា ដំបូងសូមឲ្យប្រធានខាងផ្នែកគាំពារការពារក្តីមានមតិ ហើយបន្ទាប់មកបញ្ហាហ្នឹងយើងខាងមេធាវីដើមបណ្តឹងរដ្ឋប្បវេណីនឹងតទៅទៀត បន្ទាប់ពីពិសារបាយថ្ងៃត្រង់នេះ ។ នេះជាសំណើដើម្បីយើងលើកមតិយោបល់របស់យើងសូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោក ហុង គឹមសួន ។

**លោក ហុង គឹមសួន៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំបាទសូមចូលរួមជាមតិដើម្បីឲ្យច្បាស់អ្វីដែលយើងជជែកថ្ងៃនេះ យើងចង់បានដំណើរការសវនាការនេះឲ្យលឿន ហើយឲ្យមានខ្លឹមសារដែលប្រជាពលរដ្ឋ ឬយើងហៅថា ជនរងគ្រោះ ដែលគាត់តាមដាននិងមតិសាធារណជនទាំងអស់ ថាតើសវនាការនេះបាន--

សុំទោសលោកប្រធាន ដោយសារខាងលោកស្រីចង់មានការពិភាក្សាបន្តិច អ៊ីចឹងខ្ញុំបាទសូមលើកតែបន្តិចទេ ព្រោះលោកស្រី ស៊ីលឃី គាត់បានស្នើរួចហើយ ។

ខ្ញុំបាទចង់បញ្ជាក់អ៊ីចេះថា នៅដើម ខ្ញុំហៅថាដើមទីចុះ ដើមដំបូងនៃថ្ងៃបើកសវនាការថ្ងៃ៣១ មីនា ២០០៩ នេះ ។ យើងបានជជែកអំពីអង្គហេតុដែលព្រមព្រៀង អ៊ីចឹងក្នុងនេះ ដូចខ្ញុំបាទបាន ដែលយល់ជ្រាបមកហើយ លោកប្រធាន និងលោកព្រះរាជអាជ្ញា ក៏លោកបានលើកឡើងដែលថា ចង់បានឲ្យលឿនហើយឲ្យប្រសិទ្ធភាពហួតដល់លោកព្រះរាជអាជ្ញាសុំឲ្យបានចប់ថ្ងៃ៣១ ខែតុលា ២០០៩ នេះ ។ អ៊ីចឹងខ្ញុំបាទយល់ឃើញថា ការជជែកលម្អិតលើរឿងនេះ ខ្ញុំបាទស្របតាម ស៊ីលឃី គាត់លើកឡើងអម្បាញ់មិញ ប៉ុន្តែគ្រាន់ថាការចាប់អារម្មណ៍របស់ខ្ញុំបាទ យល់ឃើញទៅលើចំណុចអង្គហេតុដែលព្រមព្រៀងនេះ គឺវាទាក់ទងជាមួយនឹងវិធាន៨៧.៣ ដែរ ។ អ៊ីចឹង តើយើងកំណត់យកថា ដែលព្រមព្រៀងហើយគ្រាន់តែលើបង្ហាញនៅក្នុងអង្គសវនាការសួរទៅលោក កាំង ហ្គេកអ៊ាវ ហៅ ឌុច ដែលគាត់ព្រមនោះ បើជំទាអត់ឲ្យពន្យល់ខ្លីៗមកហ្នឹង ពេលវេលាយើងកាត់បន្ថយមកវិញ ។ ប៉ុន្តែ លម្អិតតទៅទៀត ខ្ញុំបាទហ្នឹងបញ្ជាក់ជូនទៅទៀត ដោយសារ ស៊ីលឃី គាត់ចង់ឲ្យមានការពិភាក្សាដើម្បីយកចំណុចសំខាន់ ដើម្បីជម្រាបជូនបន្ទាប់ពីសម្រាកថ្ងៃត្រង់ ។ សូមអរគុណ ។

[១១:៤០:៤១]

**ប្រធានអង្គជំនុំ៖**

ខ្ញុំចង់បានមតិផ្សេងទៀតដោយសារ យើងបានជម្រាបហើយថា បញ្ហាការស្នើសុំធ្វើវិសោធនកម្មលើមាត្រា លើវិធាន៨៧.៣ ហើយ៨៧.៦(ថ្មី) ដែលស្នើឡើងដោយអង្គជំនុំជម្រះសាលាដំបូងទៅៗ អង្គប្រជុំៗពេញអង្គ ដែលនឹងធ្វើនៅខែ៩ នោះ គឺយើងបានត្រៀមរួចហើយ ហើយខ្លឹមសារនុ៎ង គឺយើងបាននឹងជូនដល់ទៅលោកស្រីចៅក្រមដើម្បីធ្វើការបកស្រាយ ។ អានុ៎ងជាការមធ្យោបាយមួយក្នុងចំណោម

មធ្យោបាយផ្សេងទៀត ។ ឥឡូវ មធ្យោបាយនេះយើងកុំអាលគិត បានន័យថា យើងនៅមានគំនិតបន្ថិចទៀតយើងអាចក្តាប់បញ្ហានេះ ដោយសារវាជាការប៉ុនប៉ងធ្វើវិសោធនកម្ម ។ ទីមួយ តើមានការគាំទ្រអត់? ទីពីរ ខ្លឹមសារនៃការដែលយើងបានលើកឡើងនេះ តើពេលដែលអនុវត្តហ្នឹង យើងចាប់អនុវត្តនៅពេលណា? ពីព្រោះដល់ខែ៩ ឬក៏រហូតដល់ពាក់កណ្តាលខែ៩ ឯណោះ ទម្រាំតែស្ពាតរ ដើម្បីយកមកអនុវត្ត ។ អ៊ីចឹង អំឡុងពេលដែលយើងប្រជុំនេះទៅរហូតដល់ពេលខែ៩ នោះ ដល់ពេលស្ពាតរយើងធ្វើម៉េច? អាហ្នឹងយើងនឹងពិភាក្សាគ្នា ។ ប៉ុន្តែគន្លឹះ បញ្ហាគន្លឹះផ្សេងទៀតដើម្បីឲ្យអង្គប្រជុំហ្នឹង អស់លោកដែលភាគីចូលហ្នឹង ជួយផ្តល់យោបល់មកថា តើមធ្យោបាយណាដែលយើងកត់សម្គាល់កន្លងមក ជាមូលហេតុយឺត? យឺតដោយសារអង្គជម្រះសាលាដំបូង ឬក៏យឺតដោយសារមូលហេតុអី? ហើយបើសិនជាយឺតដោយសារមូលហេតុអី យើងគួរតែកាត់យ៉ាងម៉េច? យើងគួរតែរៀបយ៉ាងម៉េច? ដើម្បីឲ្យវាមានមតិយោបល់ធ្វើការកត់ត្រាខាងអង្គជំនុំជម្រះសាលាដំបូងនឹងធ្វើការពិភាក្សាយ៉ាងលម្អិត ហើយនងកំណត់ជាគោលការទូទៅ នៃដំណើរការហ្នឹងឲ្យបានឆាប់រហ័ស ។

ហើយមួយទៀត ដែលខ្ញុំចង់ឲ្យប៉ុនប៉ងហ្នឹង ដើម្បីពន្យល់ថា តើគាំទ្រទេ? អង្គជម្រះចង់ឲ្យអស់លោកភាគីគាំទ្រលើមតិយោបល់របស់សហព្រះរាជអាជ្ញាហើយ ដែលបានលើកឡើងកំណត់នៅថ្ងៃ៣១ ខែតុលា ឆ្នាំ២០០៩ នោះ ។ ប៉ុន្តែ សំណួរសួរថាធ្វើម៉េច ដើម្បីធ្វើឲ្យធានាក្នុងការត្រឹមហ្នឹងចប់នោះ? ពីព្រោះគណនាកន្លងមកវាអត់ត្រូវសោះ វាគណនាទៅវាសល់ពេលទេ វាគណនា គឺអត់គ្រប់រហូត ។ គណនាប៉ុន្មានខែនេះ យើងចោលរហូតដល់ពីរ-បីសប្តាហ៍នោះ ដែលយើងខកខានមិនបានធ្វើសវនាការដោយសារមូលហេតុអ៊ីចឹង ។ ហើយរហូតដល់មានបញ្ហាចម្រូងចម្រាស់នឹងការកំណត់ថា គេបរិច្ឆេទថាអញ្ជើញគេមកចូលធ្វើសវនាការហើយ ហើយត្រូវលើកទៅវិញនែ៎ គឺនាំឲ្យមានការអាក់អន់ចិត្តអីអ៊ីចឹង។ អានេះលក្ខខណ្ឌនៃការងារ គឺរបៀបធំៗធេងពេក ដែលយើងមិនអាចគណនាត្រូវ ។

[១១:៤៤:០៥]

ជាបន្តនេះ គឺសំណូមពររបស់មេធាវីការពារក្តី ក៏ដូចជាលោកស្រី ស្ទូតហ្វីនស្កី ដែរ បានចាប់អារម្មណ៍អំពីការពាក់ព័ន្ធទៅនឹងប្រធានអង្គភាពគាំពារការពារក្តីនេះ ។ អ៊ីចឹង យើងនិងអង្គជម្រះផ្តល់វេទិកានេះជូនទៅគាត់ ពីព្រោះបញ្ហានេះក៏ជាកត្តាកំណត់នៃដំណើរការរបស់អង្គជម្រះយើងដែរ ប្រសិនជាមានបញ្ហាហិរញ្ញវត្ថុ បញ្ហាថវិកាមែននោះហ្នឹង គឺវាមានឥទ្ធិពលធ្ងន់ធ្ងរណាស់ដល់ដំណើរការប្រព្រឹត្តទៅ ប្រក្រតីភាពនៃដំណើរការសវនាការរបស់យើងនោះ ។ ប៉ុន្តែ ដើម្បីឲ្យបានច្បាស់ពីបញ្ហានេះ ខ្ញុំសូម

ប្រគល់វេទិកាជូនទៅលោកស្រី ខាតរ៉ាយថ៍ ដើម្បីមានការពាក់ព័ន្ធនឹងសំណួរមួយចំនួន ឬក៏ជម្រាបព័ត៌-មានគាត់មួយចំនួន នូវអ្វីដែលអង្គប្រជុំបានប៉ុនប៉ងនូវការប្រជុំ នៅក្នុងអង្គប្រជុំនេះ មុននឹងគាត់ឡើងមានមតិ ។ សូមអញ្ជើញលោកស្រីចៅក្រម ។

**ចៅក្រម ស៊ីលយ៉ា ខាតរ៉ាយថ៍៖**

សូមអរគុណជាច្រើន ដែលលោកបានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំរៀបចំសវនាការ តាមសំណើរបស់អង្គជំនុំជម្រះ ។ បញ្ហាដែលយើងពិភាក្សា ដូចដែលលោកបានប្រមូលដឹងខ្លះៗហើយ គឺរយៈពេលនៃការធ្វើសវនាការ បច្ចុប្បន្ននេះលោកប្រធានបានធ្វើការគណនាទៅឃើញថា តាមល្បឿនបច្ចុប្បន្នរបស់យើងហ្នឹង ការផ្តល់សក្ខីកម្មនឹងបន្តរហូតទៅដល់ខែធ្នូ នឹងយ៉ាងលឿនបំផុតហើយ ខែធ្នូ ឆ្នាំ២០០៩ ។ នោះមិនមែនមានន័យថា យើងគិតថា សេចក្តីសន្និដ្ឋានបញ្ចប់របស់ភាគីទាំងអស់មិនធ្វើបានមុនឆ្នាំ២០១០នោះទេ ។ អ៊ីចឹងហើយ យើងបានសួរយោបល់ទៅភាគីពាក់ព័ន្ធទាំងអស់ ដែលថា តើមានមធ្យោបាយអ្វីយើងអាចនឹងកែលម្អបញ្ហានេះទេ ហើយយើងបានទទួលសំណើមួយចំនួន ដូចជាការកំណត់ រយៈពេលកំណត់ទៅលើសវនាការ ការកំណត់ឡើងវិញនូវពេលវេលា ដើម្បីឲ្យសមស្របទៅតាមកាលពេលវេលាកំណត់ ដែលលើកឡើងដោយសហព្រះរាជអាជ្ញា ត្រឹមថ្ងៃ៣១ ខែតុលា នោះ ។ អ៊ីចឹង គឺថាយើងនឹងតទៅសេចក្តីលម្អិតតទៅទៀត យើងនឹងពិភាក្សាពីចំណុចធ្វើវិសោធនកម្មវិធាន៨៧.៣ ហើយយើងបានអញ្ជើញឲ្យភាគី ដើម្បីឲ្យទទួលនូវការណែនាំផ្អែកទៅលើវិសោធនកម្មវិធាននោះ គឺថា យើងមិនអាចផ្តល់មតិយោបល់ទេរហូតដល់យើងមានកិច្ចប្រជុំពេញអង្គនៅក្នុងខែកញ្ញា ។

អ៊ីចឹង និយាយដោយសង្ខេប គឺថានេះឯងគឺអ្វីដែលយើងបានពិភាក្សា ដើមបណ្តឹងរដ្ឋប្បវេណីបានស្នើថា សុំឲ្យអញ្ជើញលោក ដោយសារលោកនឹងមានមតិយោបល់ទៅបញ្ហាលើថវិកា ឬបញ្ហាផ្សេងៗទៀត ដែលប៉ះពាល់ដល់ផ្នែកគាំពារការពារក្តី ប្រសិនបើលោកមានចម្ងល់សំណួរ ឬសំណួរ សូមលើកឡើង ។

**លោក រីឆាត រ៉ូជឺ៖**

សូមអរគុណលោកស្រីចៅក្រម ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

ចំណុចទាក់ទងទៅនឹងលំដាប់លំដោយ ខ្ញុំមិនចង់ឲ្យថា ឲ្យម្នាក់ៗយើងមានការឯកភាពនៅថ្ងៃ៣០ ខែតុលា ហើយដូចដែលសហព្រះរាជអាជ្ញាយល់ អ៊ីចឹងហើយមិនមែនមុនការស្នើយោបល់ពីខាង

អង្គភាពគាំពារការពារនោះទេ ។ ប៉ុន្តែ មេធាវីមិនឯកភាពទៅលើកាលបរិច្ឆេទហ្នឹង គឺថាវាវែង គឺថាយូរពេក អាស្រ័យហេតុនេះហើយ យើងមិនចង់ឲ្យមានការពិភាក្សាថា ថ្ងៃ៣០ ខែធ្នូ ឬថ្ងៃ៣០ ខែតុលា មុនពេលដែលមេធាវីខាងការពារមុនលើកសំណើរបស់ខ្លួនហ្នឹង ។ កាលបរិច្ឆេទទាំងពីរនេះ គឺថា ដូចជាវែងពេក ដូចជាឆ្ងាយពេក ដែលជាងអ្វីដែលយើងគ្រោង ។ នេះជាគំនិតរបស់មេធាវីការពារ ។ សូមអរគុណ ។

**លោក អាឡាំង វែនណឺ៖**

លោកប្រធាន! ខ្ញុំសូមជម្រាបដោយខ្លីថា ក្រុមរបស់ខ្ញុំតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណី៤០ ហើយយើងក៏និយាយថា គិតថាកាលបរិច្ឆេទដែលគ្រោងហ្នឹង គឺថាឆ្ងាយណាស់ វែងណាស់ ។ គឺថាចុងខែតុលា មិនអាចចាត់ទុកថា ជាសំណើសម្រាប់ពិភាក្សាទេ ។ ពីព្រោះថា គឺថាយើងប្រកាន់ថា ការកំណត់បែបនោះ គឺវាវែងពេកនោះទេ វែងនោះ ។ តាមពិតដែលខ្ញុំមិនចង់និយាយពេលនេះទេ ប៉ុន្តែចង់ជម្រាបឲ្យបានច្បាស់ ហើយយើងក៏មិនឯកភាពកាលបរិច្ឆេទនេះទេ ខ្ញុំនឹងពន្យល់នៅពេលក្រោយ ។ ប៉ុន្តែ ខ្ញុំសូមបញ្ជាក់នេះជាចំណុចដែលយើងឯកភាពទេ ។

**លោក វីលៀម ស្មីត៖**

ខ្ញុំមិនចង់បានការឯកភាពទៅលើកាលបរិច្ឆេទដូចកំណត់ទេ គឺថា នេះគឺជាកាលបរិច្ឆេទចុងក្រោយដែលយើងខ្ញុំចង់បាន ។ ហើយយើងចង់ចុងក្រោយ ប៉ុន្តែ យើងចង់ចប់មុននឹង ប៉ុន្តែបើថា យ៉ាងយូរបំផុតត្រឹមថ្ងៃ៣០ ខែតុលា ហ្នឹង ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

ប៉ុន្តែ ខ្ញុំឃើញថាមិនច្បាស់ទេ ។ នេះយើងឃើញថា យើងមានសំណើមួយពីសហព្រះរាជអាជ្ញា មិនមែនជាសេចក្តីសម្រេចរបស់អង្គជំនុំជម្រះទេ ដូច្នេះ ល្បឿនដែលយើងទៅថ្ងៃនេះ គឺថាម្នាក់ៗឡើងមកនិយាយដែលមិនទាន់អញ្ជើញបានឲ្យនិយាយផង ។

អ៊ីចឹងហើយ យើងនឹងមិនអាចបញ្ចប់កិច្ចប្រជុំរៀបចំសវនាការថ្ងៃនេះទេ ។ អ៊ីចឹង សូមឲ្យខាងតំណាង ខាងផ្នែកគាំពារការពារក្តី ដើម្បីឲ្យលោកលើកឡើងអំពីបញ្ហាថវិកា ឬក៏បញ្ហាផ្សេងទៀតមុននឹងយើងចូលទៅដល់កិច្ចប្រជុំរបស់យើង ហើយសូមឲ្យភាគីបញ្ចេញមតិយោបល់លើអ្វីៗដែលភាគីលើកឡើងនៅថ្ងៃនេះ ។

**លោក រីឆាត រ៉ូជឺរ៖**

សូមអរគុណ ខ្ញុំមានលទ្ធភាពនឹងបញ្ជាក់ជូនបញ្ហានេះក្នុងនាម ខាងថវិកា ។ ហើយគាត់បានផ្តល់ថវិកាគម្រោងមួយដែលមើលទៅមានការលំបាក ។ អ៊ីចឹងហើយ គឺថាខ្ញុំបានជ្រើសរើសយកចំណុចដែលងាយស្រួលមួយដើម្បីជម្រាបជូន ។ មេធាវីត្រូវបានចុះកិច្ចសន្យាដោយ *យូអិន* ដើម្បីការពារជនជាប់ចោទរហូតដល់ចប់រឿងក្តី ដែលរាប់បញ្ចូលទាំងបណ្តឹងសារទុក្ខ បណ្តឹងឧទ្ធរណ៍ផង ។ អ៊ីចឹង *យូអិន* គឺថាមានកាតព្វកិច្ចនឹងចំណាយលុយសម្រាប់មេធាវីក្នុងរយៈកាលហ្នឹង រាប់ទាំងបណ្តឹងឧទ្ធរណ៍ និងសារទុក្ខផង ។

ប្រសិនបើការជំនុំជម្រះយូរជាងការកំណត់ គឺថាមិនបង្កើតឲ្យហួសពេលកំណត់នោះវាមានបញ្ហាទេ អ៊ីចឹងហើយថា ថវិកាហ្នឹង នឹងបន្ថែមមូលនិធិទាក់ទងទៅនឹងផ្នែកគាំពារការពារក្តីហ្នឹង ។ អ៊ីចឹងគឺមានការកម្រិតនៃចំនួននៃមេធាវីដែលយើងអាចបង់ចំណាយបាន ហើយយើងមានការពិភាក្សារវាងផ្នែកគាំពារ ការពារក្តី ហើយនិងមេធាវី ក្រុមមេធាវីការពារ ហើយនិងផ្នែកខាងថវិកា និងហិរញ្ញវត្ថុ គឺថាមានថវិកាសម្រាប់ទូទាត់ដោយមេធាវី សហមេធាវី ហើយផ្នែកអ្នកគ្រប់គ្រងរឿងក្តី ហើយនិងមេធាវីពីររូបនោះ ។ សូមអរគុណ ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

ឥឡូវនេះ គឺថាចំណោទហ្នឹងថាតើមេធាវីការពារចង់មានមតិយោបល់អ្វីនៅពេលនេះ ឬក៏ខាងមេធាវីដើមបណ្តឹងរដ្ឋប្បវេណីចង់ផ្តល់មតិយោបល់ ។ លោកមេធាវី រូ តើលោកមានមតិយោបល់អ្វីទេ? តើលោកចង់និយាយបន្ទាប់ពីខាងដើមបណ្តឹងរដ្ឋប្បវេណី មេធាវីដើមបណ្តឹងរដ្ឋប្បវេណីនិយាយ ឬយ៉ាងដូចម្តេច?

[១១:៥២:៤៦]

**លោក ការ សាវុត្ថ៖**

សូមគោរពលោកប្រធាន! ចំពោះខ្ញុំ ខ្ញុំយល់ថា ការលើកឡើងរបស់លោកព្រះរាជអាជ្ញាអន្តរជាតិថាពន្លឿនដើម្បីឲ្យចប់នៅខែតុលា នៅ៣០ ខែតុលា ឆ្នាំ២០០៩ ក៏ប៉ុន្តែ យើងមើលសាច់ការលម្អិតពីដំណាក់មួយ ទៅដំណាក់មួយ ឃើញថាស្មុគស្មាញលឿនទៅដូចវាមិនកើត ។ ដូច្នេះ ខ្ញុំយល់ថា មិនអាចចប់នៅថ្ងៃទី៣១ ខែតុលា ឆ្នាំ២០០៩ បានទេ ។

អ៊ីចឹទេ ខ្ញុំសំណូមពររបស់ខ្ញុំ គឺថាសូមឲ្យដាក់កំណត់បញ្ចប់នៅចុងខែធ្នូ ខែ១២ ឆ្នាំ២០០៩ ។

ព្រោះថាបើសិនជាដាក់នៅថ្ងៃទី៣១ ខែតុលា ឆ្នាំ២០០៩ ហើយដំណើរការវាអត់បានចប់នៅថ្ងៃទី៣១ ខែតុលា ឆ្នាំ២០០៩ តើលោកប្រធាន តើអង្គជំនុំជម្រះសាលាដំបូង ត្រូវទទួលការរិះគន់ពីមតិមហាជន ឬអត់? បើយើងប្រាប់គេថាចប់ថ្ងៃហ្នឹង ខែហ្នឹង ដល់ថ្ងៃនុំងអត់ចប់ មិនភូតគេទៀត ។ ក៏ប៉ុន្តែ បើសិនជាយើងថា នែចប់នៅខែធ្នូ ចុងខែធ្នូ ២០០៩ ហើយប៉ុន្តែបើយើងពន្លឿន ទៅយើងអាចចប់នៅខែតុលាក្តី ខែ១១ ក្តី ល្អ គ្រាន់បើជាងយើងភូតគេ។ អានេះជាមតិទីមួយរបស់ខ្ញុំ ។

ទីពីរ ការដែលយើងពន្លឿន យើងខំពន្លឿនហើយក៏ប៉ុន្តែការពន្លឿនរបស់យើងនេះ កុំឲ្យប៉ះពាល់ដល់ការរកយុត្តិធម៌មិនបានល្អ នេះជាសំណូមពរទីមួយ ។ ទីពីរ គិតគូរសូមឲ្យអង្គសវនាការគិតគូរ ដល់សុខភាពរបស់ជនជាប់ចោទផង ពីព្រោះកន្លងមកយើងឃើញថា គាត់ម៉ោង១១អីហ្នឹង ពេទ្យហុចថ្នាំមកឲ្យគាត់ហើយ ព្រោះបើគិតទៅប៉ុន្មាននាក់ អ្នកសួរហើយបាញ់ទៅរកគាត់តែម្នាក់ ។ ដូច្នេះ ការឆ្លើយរបស់គាត់ជួនកាលទៅវាអាចច្រឡំ វាអ៊ីចេះ វាអាចអ៊ីចុះ ។ ដូច្នេះ វាប៉ះពាល់ទៅដល់ការរកយុត្តិធម៌ ។ ដូច្នេះ ខ្ញុំជឿថា ការពន្លឿនពេក ក៏វាប៉ះពាល់ដល់ការរកយុត្តិធម៌ដែរ ហើយវាប៉ះពាល់ដល់សុខភាពរបស់ជនជាប់ចោទ ។

មួយទៀត មិនគួរ ខ្ញុំថាមិនគួរកម្រិតម៉ោងៗ ថានែអ្នកឯង លោកនេះនិយាយប៉ុណ្ណេះ លោកនោះនិយាយប៉ុណ្ណោះ ខ្ញុំថាមិនគួរកម្រិតម៉ោងទេ ប៉ុន្តែ កម្រិតសំណួរ សំណួរណាច្រំដែលសូមកុំឲ្យសួរ ។ គាត់សួរវែងមែន ប៉ុន្តែ សំណួររបស់គាត់វាសំខាន់សម្រាប់រកយុត្តិធម៌ឲ្យគាត់រកទៅ បើសំណួរអត់ប្រយោជន៍ អាហ្នឹងសូមកុំឲ្យសួរ វាច្រំដែល ។

ហើយចំណុចទីបួន គឺខ្ញុំបាទបានស្នើតាំងពីចូលមកប្រជុំដំបូង ខ្ញុំស្នើសុំថា ឲ្យក្នុងមួយសប្តាហ៍ហ្នឹង ជំនុំជម្រះតែបីថ្ងៃបានហើយ ទុកពេល ។ ទីមួយ វាសុខភាពរបស់ជនជាប់ចោទ ។ ទីពីរ ព្រោះឲ្យគាត់មើលឯកសារផង សុខភាពគាត់ផង រួចអ៊ីចឹងទេ គឺអង្គសវនាការអត់ព្រមទេដាក់ច័ន្ទ អង្គារ ពុធ ព្រហស្បតិ៍ ។ ប៉ុន្តែ អម្បាញ់មិញនេះបើខ្ញុំស្តាប់មិនច្រឡំទេ លោកស្រីចៅក្រមបានប្រកាសថា បីថ្ងៃក្នុងមួយសប្តាហ៍ ហើយក្នុងមួយខែយើងធ្វើតែពីរសប្តាហ៍ទេ ។ អាហ្នឹង គឺខ្ញុំសូមឯកភាពទាំងស្រុង ។ សូមអរគុណ ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

ខ្ញុំយល់ថា លោក រ៉ូ មិនមានអ្វីបន្ថែមទេ លោកប្រធានបង្ហាញថា គាត់រីករាយឲ្យដើមបណ្តឹងរដ្ឋប្បវេណីបញ្ចាក់បន្ទាប់ពីអាហារថ្ងៃត្រង់ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

លោកស្រីចៅក្រម! ខ្ញុំនឹងនិយាយបន្ទាប់ពីដើមបណ្តឹងរដ្ឋប្បវេណី តំណាងដើមបណ្តឹងរដ្ឋប្បវេណីនិយាយ ។ បាទ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

ដូចខ្ញុំអាចបញ្ជាក់តិចអម្បាញ់មិញ អាចភ័ន្តច្រឡំ លោកមេធាវី ការ សារុត្ត ប្រហែលជាការដែលយើងកំពុងតែគិតគូរនេះ ហើយមកពិភាក្សានេះ គឺថាការប៉ុនប៉ងរបស់អង្គជំនុំជម្រះថា នឹងប្រើប្រាស់ពេលវេលានៅក្នុងដំណើរការសវនាការហ្នឹង បានន័យថា ក្នុងមួយខែៗ យើងធ្វើគ្រប់សប្តាហ៍ទាំងអស់ ប៉ុន្តែ ការប៉ុនប៉ងមួយ គឺធ្វើឆ្លាស់គ្នារវាងសប្តាហ៍នីមួយៗហ្នឹង គឺរវាងធ្វើដំណើរសវនាការមួយសប្តាហ៍បួនថ្ងៃ ហើយនិងសប្តាហ៍បន្ទាប់បីថ្ងៃ ហើយបន្ទាប់មកបួនថ្ងៃ ហើយនិងសប្តាហ៍បន្ទាប់បីថ្ងៃ ។ នេះជាបញ្ហាដែលយើងគិតគូរទីមួយ ។

បញ្ហាទីពីរ ដោយសារបញ្ហាមួយទៀតថា មានមតិយោបល់ថា ដើម្បីពន្លឿន គឺគប្បីថាកាត់បន្ថយបានន័យថា បួន បួន បី បួន បានន័យថា នៅក្នុងសប្តាហ៍ទីបីនៃខែនីមួយៗធ្វើតែបីថ្ងៃទេ ហើយសប្តាហ៍ផ្សេងទៀតធ្វើបួនថ្ងៃដដែល ។ អ៊ីចឹង បើសិនជាអាចពិចារណាហ្នឹង គឺថាមានធ្វើឆ្លាស់គ្នារវាងក្នុងមួយខែហ្នឹង យើងធ្វើជាប់ដូចគ្នា ប៉ុន្តែ មួយសប្តាហ៍យើងធ្វើតែបួនថ្ងៃ ហើយសប្តាហ៍បន្ទាប់ធ្វើបីថ្ងៃ បន្ទាប់មកបួនថ្ងៃ បន្ទាប់មកបីថ្ងៃ យើងអាចធ្វើឆ្លាស់គ្នា ហ្នឹងគ្រាន់តែមានការពិចារណាអ៊ីចឹង ហើយក៏សង្ឃឹមថានឹងបានមតិយោបល់ពីអស់លោកដែរអំពីបញ្ហាអស់លោក លោក ស្រីដែលចូលរួមដែរដើម្បីបញ្ហានេះ ។ ប្រសិនបើយើងការពន្យារច្រើនពេក យើងក៏កំពុងប្រឈមនូវការរិះគន់ពីការពន្យារពេលផងនោះ គឺវិតតែបញ្ហាដែរ ។ នេះគឺប្រឹងប្រែងទាំងអស់គ្នា ខ្ញុំសូមឲ្យមានការចាប់អារម្មណ៍អ៊ីចឹង។

[១១:៥៩:៣២]

ហើយអំមិញនេះសុំកុំមានការភ័ន្តច្រឡំ បញ្ហាដែលខ្ញុំលើកឡើងគ្រាន់តែជាការបង្ហាញថា ជាការលើកឡើងរបស់សហព្រះរាជអាជ្ញា គាត់ត្រូវការគិតគូរគាត់អ៊ីចឹង ។ អ៊ីចឹងតើគំនិតអ្នកផ្សេងមាន ការគិតគូរអ៊ីចឹងដែរឬទេ? ឬក៏គិតខុសៗពីហ្នឹង? ហើយហេតុអី? ហើយដូចខ្ញុំបានជម្រាបអ៊ីចឹងខ្ញុំគាំទ្រជានិច្ចអង្គជំនុំជម្រះគាំទ្រជានិច្ចនូវបញ្ហាថា ការកំហិតឲ្យបានឆាប់រហ័សដែលអាចធ្វើទៅបាន ។ ប៉ុន្តែ សូមប្រាប់វិធីសាស្ត្រដល់អង្គជំនុំជម្រះបានយល់ដឹងផងអំពីថាតើធ្វើរបៀបណា? ដើម្បីឲ្យវាទៅបានល្អឲ្យហើយលឿននោះ នេះជាការចង់បាន ។ ជួនកាលយើងនិយាយល្អ និយាយមាត់អ្នកណាក៏ថា ចង់លឿន

ដែរ ប៉ុន្តែ សកម្មភាពវាផ្ទុយពីពាក្យថា ចង់បានលឿននោះ ។ នេះហើយដែលយើងកត់សម្គាល់ ។ អ៊ីចឹងបានលឿនហើយ សូមឲ្យអំពីវិធីសាស្ត្រនៃរបៀបធ្វើយ៉ាងណាឲ្យលឿនផង ។ នេះជាបច្ចេកទេស ទាំងការកត់សម្គាល់នូវបទពិសោធន៍កន្លងមក ទាំងបទពិសោធន៍នៅក្នុងប្រទេសរបស់លោក ដែលលោកបានជួបប្រទះពីមុន ទាំងបទពិសោធន៍ជាអន្តរជាតិដើម្បីយើងលើកយកមកបញ្ចូលគ្នា យើងរកមធ្យោបាយដើម្បីចាត់ការឲ្យបានលឿន ឲ្យបានយុត្តិធម៌ រលូន អត់មានការរអាក់រអួលដូចពេលដែលយើងធ្វើដំបូងៗនោះទេ នេះជាបំណងប្រាថ្នា ។

ដោយសារដល់ម៉ោងត្រូវសម្រាកអាហារថ្ងៃត្រង់ហើយ អ៊ីចឹងយើងខ្ញុំសូមប្រកាសសម្រាកការប្រជុំរបស់យើងត្រឹមនេះ ។ ហើយសូមអញ្ជើញអ្នកចូលរួមទាំងអស់ អញ្ជើញ ចូលរួមពិភាក្សាបន្តទៀតនៅវេលារសៀលចាប់ពីម៉ោងមួយកន្លះ ។

*[កិច្ចប្រជុំសម្រាកពី ១២:០១ នាទី ដល់ម៉ោង ១៣:៣៧ នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។ យើងបន្តដំណើរការពិភាក្សារបស់យើងបន្តទៅទៀត ហើយដោយការប៉ុនប៉ងរបស់យើងថា ពន្លឿនមែនទែន ពន្លឿនទៅដល់នីតិវិធីដំណើរការសវនាការ ហើយយកមូលដ្ឋាននៃអង្គប្រជុំនេះ តែសូម្បីតែកិច្ចប្រជុំនេះពន្លឿនទៅមិនរួចផង មួយព្រឹកហើយ ទើបតែបានតិចតួច បើធៀបនឹងរបៀបវារៈដែលបានលើកឡើង ឬក៏បញ្ហាដែលបានលើកឡើង នេះក៏គួរកត់សម្គាល់ដែរ ។

អ៊ីចឹងទេបញ្ជូនទៅភាគីអ្នកតំណាងដើមបណ្តឹងរដ្ឋប្បវេណីជាបន្តទៀត ។ ហើយខ្ញុំសុំមានការ គឺទីមួយ គឺនិយាយឲ្យខ្លី ហើយឲ្យចំបញ្ហាថា អំពីកាលវេលាដែលបានលើកឡើង ហើយជម្រាបថា ការលើកឡើងរបស់សហព្រះរាជអាជ្ញា គឺគ្រាន់តែជាការគិតគូរជាចំណុចរបស់គាត់ប៉ុណ្ណោះ ចំណែកឯខាងអស់លោក លោកស្រីភាគីផ្សេងទៀតហ្នឹង គឺជាគិតរបស់ខ្លួនឯងហ្នឹងថា យ៉ាងដូចម្តេច ។ ហើយទីពីរគឺដូចខ្ញុំជម្រាបអ៊ីចឹង សូមបញ្ហាអំពីមធ្យោបាយ ឬក៏វិធីដែលនាំឲ្យអាចថា ពន្លឿនផង កុំឲ្យតែយើងនិយាយថា ចិត្តចង់បាន ប៉ុន្តែរបៀបធ្វើ របៀបម៉េចមិនដឹងទេ ស្រេចតែអង្គជំនុំជម្រះទៅ។ បើខ្ញុំចង់បានស្អែកឲ្យចប់។ ប៉ុន្តែអង្គជំនុំជម្រះធ្វើម៉េចធ្វើទៅ ។ ដូច្នេះ សូមឲ្យវាមានជាការផ្តល់នូវអនុសាសន៍ ឬក៏គំនិតល្អៗ ដើម្បីយើងធ្វើការកត់ត្រា ឬពិភាក្សា ។ ហើយមួយទៀត បញ្ហាអម្បាញ់មិញ បញ្ជាក់ឡើងវិញ

ដោយសារការដែលយើងធ្វើសវនាការនេះ បានឆ្លើយតបពីខាងភាគី ខាងការិយាល័យរដ្ឋបាលរួចហើយ អំពីការគាំទ្រដោយឥតក្ខខណ្ឌនៃដំណើរការប្រព្រឹត្តទៅអង្គសវនាការនៅក្នុងឆ្នាំនេះរហូតដល់ដាច់ឆ្នាំ ។ ប្រសិនបើត្រូវធ្វើដូច្នេះហ្នឹង គឺថាគាំទ្រឥតលក្ខខណ្ឌទេ គឺបានន័យថា ប្រឹងប្រែងអស់លទ្ធភាពក្នុងការបញ្ចៀសមិនឲ្យមានបញ្ហារំខានដោយសារការឈប់សម្រាក ឬក៏រាំកងរបស់មន្ត្រីខាងរដ្ឋបាលទេ អានេះតាមការយល់ឃើញដែលខ្ញុំបានក្តាប់បាន ។ អ៊ីចឹងវាអត់មានបញ្ហាអីទៀតទេ ។

បញ្ហាដែលយើងគិតផងដែរ ថាតើលទ្ធភាពនៃការធ្វើសវនាការ ដែលខ្ញុំបានលើកឡើងការប៉ុនប៉ងរបស់អង្គជំនុំជម្រះហ្នឹង គ្រាន់តែបង្ហើប ផ្តួចផ្តើមគំនិតថា មានការប្រែប្រួលបន្តិចបន្តួច គឺសវនាការមួយសប្តាហ៍ធ្វើបួនថ្ងៃឆ្លាស់គ្នាបីគ្នា បានន័យថា ក្នុងសប្តាហ៍មួយខែហ្នឹង គឺមានពីរសប្តាហ៍ធ្វើសវនាការបីថ្ងៃហើយនិងពីរសប្តាហ៍ធ្វើសវនាការបួនថ្ងៃ ដោយធ្វើឆ្លាស់គ្នា បួនបីៗ ។ ហើយមានគំនិតមួយទៀត ដោយថាដោសារការចង់កេងល្បឿនឲ្យលឿនហ្នឹង គឺថាបួនៗ បីបួនៗ បានន័យថា នៅក្នុងសប្តាហ៍ទាំងបួននៃខែនីមួយៗហ្នឹង គឺយើងធ្វើបីសប្តាហ៍ហ្នឹង តែសប្តាហ៍ទីបីនៃខែទេ ។ អ៊ីចឹង គ្រាន់តែឲ្យមានការចាប់អារម្មណ៍ ដើម្បីកំណត់បញ្ហានេះឲ្យច្បាស់លាស់ ដើម្បីឲ្យយើងធ្វើការមួយទៀត រឿងម៉ោង ពេលម៉ោងធ្វើការងារ ដើម្បីកុំឲ្យថា ម៉ោងសម្រាក ឬក៏ម៉ោងចូល ម៉ោងចេញអីហ្នឹង ពីព្រោះមានបញ្ហាខ្លះ គឺយើងបានទទួលព័ត៌មាន ជាការរិះគន់ពីភាគី ជាក្រៅទេ មិនមែនជាចំហទេ ជាការកត់សម្គាល់ឃើញថា មានបញ្ហានៅក្នុងការអនុវត្តត្រឹមត្រូវនៃកាលវេលារបស់អង្គជំនុំជម្រះអីជាដើម ។ អាហ្នឹងយើងបានទទួលព័ត៌មានពីបទពិសោធន៍កន្លងមកនេះ ក៏អរគុណដែរនៅការផ្តល់ព័ត៌មានហ្នឹង ។ ប៉ុន្តែ មានករណីខ្លះដូចថា មានភាពស្មុគស្មាញនៃការសម្រេចពិភាក្សាអ៊ីចឹង ដល់ប្រជុំគ្នាពិភាក្សាកំណត់ថាដប់ប្រាំមីនុត ឬក៏ម្ភៃមីនុតហ្នឹង អាចពិភាក្សាចប់ហើយ ដល់ពិភាក្សាម្ភៃមីនុត អត់ចប់ទៀត។ អ៊ីចឹងបានអាចពន្យារពេលដល់ដប់មីនុត ឬក៏ដប់ប្រាំមីនុត មុននឹងចូលមក ដើម្បីឲ្យបានលទ្ធផលសម្រេចថា យ៉ាងម៉េចនៅពេលដែលជំទាស់ ឬបញ្ហាផ្សេងៗ ដើម្បីឲ្យការដោះស្រាយទៅមុខ ។

[១៣:៤១:៤២]

អ៊ីចឹងការគណនាពេលវេលានៅតែមានបញ្ហា ។ អ៊ីចឹងហើយបានយើងលើកបញ្ហាពីពេលម៉ោងពីថ្ងៃអីៗ ហើយនេះជាថ្ងៃរួម ហើយនឹងជាការព្យាករណ៍ទុកទាំងអស់គ្នា ហើយនិងរកវិធីដើម្បីចង់បានមតិយោបល់ល្អពីភាគី ដើម្បីឲ្យការប្រព្រឹត្តិទៅហ្នឹងបានឆាប់រហ័យនិងបានត្រឹមត្រូវ ។ មិនមែនឆាប់ហើយ អត់ទទួលលទ្ធផល គឺអត់ទទួលយកបានទេ ។ យុត្តិធម៌ហើយ ឆាប់រហ័សផង ។

សូមអញ្ជើញ ។

**លោកស្រី ស៊ីលឃីស្ទូត ហ្សីនស្តី៖**

អរគុណលោកប្រធាន ។ ខ្ញុំចង់ចេញជាយោបល់ដំបូងខ្លីមួយ គឺថា អង្គជំនុំជម្រះចេញសេចក្តីសម្រេច ឬក៏សម្រេចបែបណានោះទេថា គំនិតរបស់ដើមបណ្តឹងរដ្ឋប្បវេណីនោះ គឺមិនចង់បានតែ ត្រឹមតែសវនាការដែលលឿននោះទេ ។ ប៉ុន្តែ ក៏ចង់ឲ្យដឹងដែលថា អ្នកដែលចូលរួមនៅក្នុងសវនាការនោះឲ្យដឹងពីរឿងលម្អិតនៅក្នុងដំណើរការនេះ ។ អ៊ីចឹង អង្គជំនុំជម្រះគួរតែយកចិត្តទុកដាក់ទៅលើការចាប់អារម្មណ៍នេះ គឺថាមិនសម្រាប់តែដើមបណ្តឹងរដ្ឋប្បវេណីប៉ុណ្ណោះទេ គឺរួមទាំងសាធារណជននៅទូទាំងប្រទេសកម្ពុជាផងដែរ ។ ហើយទីពីរនោះ គឺថា នេះគឺជាសវនាការដំបូងបង្អស់សម្រាប់អង្គជំនុំជម្រះវិសាមញ្ញ ហើយដូចដែលលោកប្រធានបានមានប្រសាសន៍កាលពីព្រឹកមិញនោះគឺថា អង្គជំនុំជម្រះត្រូវការពេលវេលាដើម្បីធ្វើការសម្រេច ធ្វើការពិនិត្យទៅលើភស្តុតាង ឬក៏ទៅលើឯកសារច្រើនៗទៀត ។ ហើយប៉ុន្តែអ្វីដែលសំខាន់នោះ គឺយើងត្រូវជម្រាបទៅខាងសាធារណជនថា ហេតុអ្វីបានជាអង្គជំនុំជម្រះត្រូវការពេលវេលាច្រើន ដើម្បីពិនិត្យរឿងទាំងនោះថា តើហេតុអ្វីបានជាយឺតអ៊ីចឹង? ហើយព្រោះហេតុថាសវនាការហ្នឹង គឺទាមទារជាគំរូមួយសម្រាប់សាធារណជនផងដែរ ។ ហើយចំណុចទីបីនោះ គឺថា គឺខ្ញុំចង់ឆ្លើយតបទៅខាងព្រះរាជអាជ្ញា មិនដឹងថាតើខ្ញុំយល់ត្រឹមត្រូវដែរឬទេ? គឺដំណើរការនៅក្នុងប្រព័ន្ធស៊ីវិលឡនោះ គឺថាទាមទារឲ្យមានសវនាការដែលមានរយៈពេលខ្លីនោះ ។ ក្នុងករណីដែលជារឿងធំនេះ គឺយើងចៀសមិនផុតទេ ដើម្បីឲ្យដំណើរការវា-- ព្រោះថាយើងត្រូវការមើលទៅលើឯកសារច្រើនដែលទាក់ទងទៅនឹងរឿងក្តីទាំងនេះ ។

ហើយចំណុចចុងក្រោយ ប្រហែលជាចុងក្រោយហើយ គឺខ្ញុំចង់ឲ្យអង្គជំនុំជម្រះទុកនូវទឡ្ហីករណ៍ផ្ទាល់ខ្លួនរបស់ភាគីមួយឡែកសិន ដែលថាចង់ឲ្យមានដំណើរការទៅមុខកាន់តែលឿននោះ ។ ព្រោះថា បើធ្វើអ៊ីចឹង អាចធ្វើឲ្យមានការបាត់បង់ក្នុងការបង្ហាញភស្តុតាង ឬក៏ឯកសារដែលសំខាន់ៗដែលដាក់នៅចំពោះមុខអង្គជំនុំជម្រះ ។ ហើយឥឡូវនេះ ខ្ញុំចង់និយាយថា សវនាការដែលមានដំណើរការលឿន គឺជាអ្វីដែលដើមបណ្តឹងរដ្ឋប្បវេណីចង់បានផងដែរ ។

[១៣:៤៦:២០]

ខ្ញុំនឹងមិនចូលទៅចំណុចលម្អិតដែលបានលើកឡើងដោយសហព្រះរាជអាជ្ញានោះទេ ថាតើទៅលើឯកសារអីខ្លះនោះ ។ គឺថាមានឯកសារជាច្រើន ហើយនិងអត្ថបទសារព័ត៌មានជាច្រើនពេក ហើយខ្ញុំ

អាចយល់ថា ជាបញ្ហាមួយខ្ញុំមិនគប្បីលើកឡើងជាថ្មីម្តងទៀតទេ ។ ប៉ុន្តែ ដើម្បីនឹងលើកឡើងនូវគំនិតនេះ នៅភស្តុតាងនេះ យើងគប្បីពិចារណា ។ ហើយទាក់ទងអំពីពេលវេលាជាក់ស្តែង ដែលជាពេលវេលាកំណត់ដើម្បីឲ្យភាគីសម្តែងមតិនោះ នេះគឺជាគោលជំហរដែលខ្ញុំមិនឯកភាពតាមទេ ខ្ញុំត្រូវ គឺថាត្រូវផ្អែកទៅលើការគ្រប់វិន័យរបស់ភាគីមួយៗ។ ប៉ុន្តែ ខ្ញុំសង្កេតឃើញថាភាគីម្នាក់ៗ ដែលខ្ញុំបានឃើញថាមានការរំឮកដោយសហព្រះរាជអាជ្ញា ត្រូវបានបញ្ជាក់ថា ដប់ប្រាំមីនុត ប៉ុន្តែ ពិនិត្យទៅឃើញថា គាត់ប្រើពេលច្រើននាទី ។ ខ្ញុំមិនយល់ទាស់ទេ ប៉ុន្តែ សូមឲ្យប្រធានមេត្តាប្រកាសពេលវេលាថា អ្នកណានិយាយបានប៉ុន្មាននាទី ដូចជាលោកស្រីចៅក្រម ខាតវ៉ាយថ៍ បញ្ជាក់ថា តើសួរជាមុនថា តើត្រូវការពេលនិយាយប៉ុនណា? ដើម្បីឲ្យយើងគោរពទៅតាមអ្វីដែលយើងបានបញ្ជាក់ដូចជាយើងអាចនឹងស្នើសុំ ឬក៏អាចនឹងត្រូវការប្រាំ ឬដប់មីនុត នៅក្នុងបរិបទនេះ ។ ហើយខ្ញុំក៏សុំក៏ត្រូវពឹងផ្អែកទៅលើជនជាប់ចោទដែរដើម្បីឲ្យគាត់ឆ្លើយឲ្យបានជាក់លាក់ ហើយជាក់ស្តែងច្បាស់លាស់ឲ្យខ្លី កុំឲ្យចំណាយពេលច្រើនពេក ។ ហើយខ្ញុំពិនិត្យឃើញថា វាមានបញ្ហា-- អត់ទេ ខ្ញុំសូមបន្តនៅទីនេះទៀតថា មានតែគំនិតមួយដែលខ្ញុំស្នើខ្ញុំស្នើសុំបន្តតាមនីតិវិធីនេះ ដោយភាគីមួយៗ គឺថាគោរពវិន័យដោយខ្លួនឯង កុងត្រូលខ្លួនឯង គ្រប់គ្រងខ្លួន មុនពេលអង្គជំនុំជម្រះកំណត់ពេលសម្រាប់ឲ្យភាគីចោទសួរនូវសំណួរនោះ ។

[១៣:៤៨:៥២]

ខ្ញុំសូមអនុញ្ញាតផ្តល់យោបល់មួយ ហើយទៅលើសំណើដែលលើកឡើងដោយសហព្រះរាជអាជ្ញា ដែលខ្ញុំពិនិត្យឃើញថា វាមានបញ្ហាចម្រូងចម្រាស់ គឺចំណុចមួយដែលថា សាក្សីត្រូវជូនដំណឹងដោយមន្ត្រីច្បាប់អំពីសេចក្តីថ្លែងការណ៍ ឬកំណត់ហេតុដែលបានពីការសួរសម្ភាសន៍ពីមុន ហើយនិងត្រូវប្រគល់អត្ថបទនោះគាត់ ហើយពិភាក្សាជាមួយគាត់តាមរបៀបមួយដែលលោកបញ្ជាក់នោះ ។ ចំណុចនេះ គឺថាអាចនឹងជាអាចនឹងមានឥទ្ធិពលមួយ នេះជាបញ្ហាដែលមួយយើងគប្បីពិភាក្សានៅទីនេះដែរ ។ នេះខ្ញុំពិនិត្យជាដំបូងទៅ ខ្ញុំឃើញថា ខ្ញុំមិនយល់ស្របជាមួយគាត់ទេ ហើយអាចនឹងនាំឲ្យមានបញ្ហាចំពោះសាក្សីមួយចំនួន ដែលថាគាត់អាចនឹងយល់ថាជា ឥទ្ធិពល ឬសម្ពាធអីទៅលើគាត់ ។

ចំណុចមួយទៀត ដែលខ្ញុំចង់លើកឡើងនោះគឺថា ដើម្បីឲ្យមានការយល់ដឹងបន្ថែមទៀត ។ ដើម្បីចៀសវាងការសួរសំណួរដដែលទៅជនជាប់ចោទ នៅពេលដែលសាក្សីនោះបង្ហាញខ្លួនក្នុងតុលាការ ។ អ៊ីចឹងវិធីសាស្ត្រនេះ គឺថាដែលលើកឡើងដោយសហព្រះរាជអាជ្ញានេះ គឺល្អ ប៉ុន្តែបើយើងអនុវត្តទៅគប្បីតែមានការអនុញ្ញាតឲ្យសួរ ហើយនឹងតទល់ជាមួយនឹងជនជាប់ចោទ នៅពេលដែលសួរសំណួរជាលើក

ដំបូងទៅលើបញ្ហាមួយ ហើយដែលបានប្រឈមតទល់ជាមួយរួចហើយ ជាមួយកំណត់ហេតុលាយ-លក្ខណ៍អក្សររបស់សាក្សីនោះ ។ ប៉ុន្តែ ឥឡូវនេះមិនត្រូវបានអនុញ្ញាតទេ ពីព្រោះថាសាក្សីហ្នឹងបង្ហាញខ្លួននៅពេលក្រោយ ។ ប៉ុន្តែ ប្រសិនបើមានការតទល់គ្នា ការជំទាស់គ្នាទៅលើបញ្ហាណាមួយដែលអង្គហេតុដែលជនជាប់ចោទគាត់មិនយល់ព្រមនោះគឺថា អាចអនុញ្ញាតឲ្យភាគីដើម្បីធ្វើការតទល់មុនពេលដែលសាក្សីនោះមកបង្ហាញខ្លួន ផ្អែកទៅលើកំណត់ហេតុជាលាយលក្ខណ៍អក្សរពីការសម្ភាសនោះ ។ បើមិនដូច្នេះទេ គឺថាអាចនឹងវាមានការផ្ទុយគ្នា រវាងសេចក្តីថ្លែងការណ៍របស់សាក្សីនៅក្នុងតុលាការ ហើយនិងថ្លែងការណ៍របស់ជនជាប់ចោទ ។

[១៣:៥១:៣៦]

ខ្ញុំសូមស្នើបន្ថែមទៀតថា ប្រហែលជាអាចនឹងវិធានការតិចជាងដើម្បីឲ្យយើងសន្សំពេលវេលានៅក្នុងពេលសវនាការដែលអាចនឹង អាចសន្សំធនធានរបស់តុលាការដែរ ដែលថា ចំណុចដែលខ្ញុំសូមអញ្ជើញអង្គជំនុំជម្រះឲ្យអនុញ្ញាតឲ្យភាគីឲ្យធ្វើថ្លែងការណ៍ ដោយផ្ទាល់មាត់លើបញ្ហាច្បាប់ដែលលើកឡើងមកពិភាក្សា ជាជាងក្នុងការកំណត់ដែលរយៈពេលកំណត់ខ្លីមួយអាទិត្យ ។ សូមឲ្យដាក់ឆ្លើយបតនឹងបញ្ហានេះ គោលជំហរនេះ ហើយចម្លើយមិនគប្បីច្រើនជាងពីរទំព័រ ។ ដូច្នេះ ការបង្គាប់បែបនេះដោយសារថា មានបញ្ហានៃការបកប្រែនៅផ្នែកគ្រប់គ្រងតុលាការ ។ ចំពោះយើងខ្ញុំវិញ នៅពេលដែលយើងមកចូលរួមសវនាការពេញមួយថ្ងៃនៅតុលាការ យើងមានការលំបាកក្នុងការបំពេញលក្ខខណ្ឌដែលបង្គាប់នោះ លើកលែងតែយើងបានដឹងជាមុនដើម្បីសម្តែងមតិទៅលើបញ្ហាអង្គច្បាប់ដែលអង្គជំនុំជម្រះតម្រូវ ។ បើធ្វើដូច្នោះ គឺថាអាចនឹងសន្សំធនធាន យើងអាចនឹងចៀសវាងនិងការយឺតយ៉ាវក្នុងការដាក់សារណាជាលាយលក្ខណ៍អក្សរនោះផង ។

ជាគោលការណ៍ខ្ញុំមិនសូមស្នើឡើងទេថា ការពិនិត្យមើលទៅលើសវនាការនេះ ដោយកំណត់ទៅលើកាលបរិច្ឆេទមួយចំនួនដែលបានស្នើឡើង ដូចជាថ្ងៃទី៣១ ខែតុលា ឬមួយក៏នៅចុងឆ្នាំនេះ ពីព្រោះអី? តាមទស្សនៈរបស់ខ្ញុំនោះគឺថា យុត្តិធម៌ ហើយបើសិនជាភាគីនីមួយៗ គឺគោរពវិន័យដោយខ្លួនឯងហ្នឹង គឺថាយុត្តិធម៌ហ្នឹង អាចនឹងត្រូវបានគេធ្វើឡើង ។ ហើយចំណុចនេះអាចនឹងនាំឲ្យរកឃើញ នាំទៅរកមានការប្រញាប់ប្រញាល់ក្នុងការបង្ហាញភស្តុតាង ដែលភស្តុតាងទាំងអស់នោះ ត្រូវតែយកមកពិភាក្សានៅក្នុងសវនាការ ។ ហើយប្រសិនបើយើងធ្វើដោយប្រញាប់ ដូច្នោះ គឺមិនមែនដើម្បីបម្រើគោលបំណងរបស់តុលាការនេះទេ ។

[១៣:៥៤:១០]

ខ្ញុំសូមធ្វើសំណើឡើងថា យើងគួរតែមានការប្រជុំទាក់ទងទៅនឹងការរៀបចំសវនាការម្តងទៀតក្នុងរយៈពេលមួយឆ្នាំ ដើម្បីពិនិត្យមើល ។ គឺស្នើសុំឲ្យភាគីទាំងហ្នឹង ផ្តោតអារម្មណ៍ទៅលើចំណុចពាក់ព័ន្ធនានា និងសំណួរណាដែលសំខាន់ៗ ហើយបើសិនជាយើងពិនិត្យមើល តើគួរតែមានការប្រែប្រួលអ្វីទៅលើដំណើរការនីតិវិធី? ហើយបន្ទាប់មកទើបយើងនឹងព្យាយាមសម្រេចកិច្ចការទាំងនុ៎ងនៅក្នុងការប្រជុំការរៀបចំសវនាការម្តងទៀត ប្រហែលនៅសប្តាហ៍ចុងក្រោយ បើសិនជាមានផ្លាស់ប្តូរបែបនោះ ។

ខ្ញុំក៏ចង់បញ្ចេញមតិយោបល់ផងដែរ ទៅលើសំណើដែលបានស្នើឡើងទាក់ទងទៅនឹងវិសោធនកម្មនៃវិធានផ្ទៃក្នុង ហើយនិងសេចក្តីណែនាំ ដែលអង្គជំនុំជម្រះបានស្នើឡើងទៅតាមការយល់ដឹងរបស់ខ្ញុំនៅចំពោះមុខគណៈកម្មការវិធាននិងនីតិវិធីផ្ទៃក្នុង ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

តើខ្ញុំអាចសូមកាត់បន្តិចទេអ្នកស្រី ស្វូតហ្សីនស្គី ពីព្រោះអីគឺថាយើងមិនទាន់បានដល់ចំណុចនេះទេ នៅលើរបៀបវារៈ ពីព្រោះនឹងពន្យល់បន្ថែមទៀតទាក់ទងទៅនឹងការផ្លាស់ប្តូរវិធាន ។

**លោកស្រី ស៊ីលឃីស្វូត ហ្សីនស្គី៖**

មិនអីទេ ។ អ៊ីចឹងខ្ញុំនឹងបង្អង់សិនទៅលើចំណុចនេះ ។ ឥឡូវនេះ ខ្ញុំសូមលើកឡើងនូវចំណុចមួយទៀតដែលខ្ញុំចង់និយាយ ។ អ៊ីចឹងបើយើងមើលតាមរបៀបវារៈនោះ គឺភាពអាចចូលរួមបានរបស់មេធាវី ហើយនិងរបស់បុគ្គលិក ។

សម្រាប់ក្រុមខ្ញុំវិញ ខ្ញុំអាចនិយាយបានថា គឺថា ក្រុមរបស់យើងអាចមានវត្តមាននៅគ្រប់ពេលវេលាដោយមិនមែនការកំណត់នូវបរិច្ឆេទកំណត់អ្វីទេ ពីព្រោះពួកយើងបានមកធ្វើការនៅទីក្រុងភ្នំពេញ។ ហើយខ្ញុំក៏មិនដឹងដែរថា នៅក្នុងរបៀបវារៈនេះ តើយើងគួរតែបញ្ចេញទស្សនៈនៅពេលក្រោយ ឬ ទៅលើលក្ខខណ្ឌនៃការងារដែលអាចជាបញ្ហាសម្រាប់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី? ដែលលក្ខខណ្ឌមួយចំនួនគឺថា យើងមិនទទួលយកបានទេ ។ ហើយយើងចង់បានមតិយោបល់ពីខាងផ្នែករដ្ឋបាល ឬក៏សេចក្តីណែនាំពីខាងរដ្ឋបាលដែលយើងគួរតែពិភាក្សាអំពីចំណុចអស់ទាំងហ្នឹង ។

[១៣:៥៦:៥៦]

ឯកសារដើម

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

ខ្ញុំក្រវីក្បាល ពីព្រោះខ្ញុំយល់ថា បញ្ហាហ្នឹងនេះវាអត់ពាក់ព័ន្ធទៅនឹងការប្រជុំផ្នែករៀបចំសវនាការទេ ។

**លោកស្រី ស៊ីលឃី ស្ទូតហ្ស៊ីនស្គី៖**

ខ្ញុំគិតថា រឿងនេះវាទាក់ទងទៅនឹងភាពដែលអាចចូលរួមបានរបស់មេធាវី ហើយចំណុចនេះត្រូវបានឡើងច្រើនដងមកហើយ ។ អ៊ីចឹងខ្ញុំអាចទុកសំណុំរឿងនេះ មួយកន្លែងសិន ហើយនៅពេលក្រោយខ្ញុំនឹងអាចស្នើទៅខាងផ្នែករដ្ឋបាលឲ្យផ្តល់នូវលទ្ធភាពមួយចំនួនសម្រាប់ឲ្យពួកយើងអាចធ្វើការបាន ពីព្រោះអីស្ថានភាពបច្ចុប្បន្ននេះ បញ្ហាមួយចំនួនគឺថាយើងមិនអាចទទួលយកបានទេ ។ ខ្ញុំសូមលើកឡើងទាក់ទងទៅនឹងការងារសម្រាកមិនធ្វើសវនាការ ដូចខាងក្រោយនេះ៖

នៅពេលដែលខ្ញុំសម្គាល់ឃើញទៅលើការកំណត់ការបរិច្ឆេទដែលបានស្នើឡើង ដោយសហព្រះរាជអាជ្ញា ប៉ុន្តែ អង្គជំនុំជម្រះសាលាដំបូងបានរៀបចំផែនការ ហើយបានពិចារណាទៅលើការធ្វើសវនាការហ្នឹង ដែលអាចអូសបន្លាយពេលវែងជាងខែតុលា ។ ហើយបានរៀបចំផែនការរហូត ហើយនិងមានផែនការសម្រាប់ការសម្រាកមិនធ្វើសវនាការផងដែរ ។ ខ្ញុំដឹងថា បុគ្គលិកភាគច្រើននៅក្នុងតុលាការនេះពាក់ព័ន្ធនឹងផ្នែករដ្ឋបាលនៅក្នុងតុលាការ និងខាងផ្នែកបកប្រែផងដែរ គឺជាការលំបាកណាស់ក្នុងការធ្វើការរយៈពេលវែង ហើយបើសិនជាយើងត្រូវបន្តសវនាការរហូតដល់ខែធ្នូនោះ ឬក៏ចុងឆ្នាំនេះ គឺជាការពិបាកណាស់ ។ បើសិនយើងមិនធ្វើការឈប់សម្រាកផ្អាកសវនាការ ឬក៏ការសម្រាកវិស្សមកាលអន្តរ-ជាតិរយៈពេលវែងណាមួយ ។

ដូច្នេះ យើងគួរតែមានពេលវេលាចាំបាច់ ដើម្បីសម្រាកនឹងអាចត្រឡប់មកវិញ ដើម្បីធ្វើការបន្តទៀត ។ ដូច្នេះ បុគ្គលិកមួយចំនួននៅក្នុងតុលាការនេះ គឺមិនដែលយកវិស្សមកាលរយៈពេលវែងជាច្រើន ។

ខ្ញុំក៏សម្គាល់ផងដែរ ថាអង្គជំនុំជម្រះសាលាដំបូងនេះ គិតថាសវនាការនឹងបន្តយូរជាងថ្ងៃខែដែលបានលើកឡើងរួមបញ្ចូលទាំងការពិចារណាទៅលើការសម្រាកមិនធ្វើសវនាការ ហើយបើសិនជាចំណុចនេះមិនត្រូវការទេនោះ មានន័យថា អាចនឹងបញ្ចប់នូវចុងខែតុលា ឬក៏នៅចុងឆ្នាំ ។ ក៏ប៉ុន្តែ គួរតែបញ្ចូលនៅក្នុងផែនការផងដែរ រហូតដល់ចុងខែតុលានេះ ដោយសារខ្ញុំវាយតម្លៃថានៅមានបញ្ហានីតិវិធីមួយចំនួនទៀតដែលកើតមាននៅក្នុងតុលាការនេះ ដែលត្រូវតែដោះស្រាយ ហើយដែលត្រូវការចំណាយពេល

វេលាដើម្បីដោះស្រាយបញ្ហាអស់ទាំងនុ៎ង ។ ហើយដូច្នេះប្រហែលជាបញ្ហាហ្នឹង បើសិនជាយើងមិនបញ្ចូលមកនៅក្នុងការគិតគូរដល់ពេលវេលាសម្រាប់សាក្សីមកផ្តល់សក្ខីកម្មទេនោះ អ៊ីចឹងគឺថាមានបញ្ហាជាច្រើនផ្សេងទៀត ដែលយើងគួរតែយកមកពិចារណា ។

ហើយចំណុចចុងក្រោយមួយទៀត--

អ៊ីចឹងមកដល់ពេលនេះគឺ ខ្ញុំបានលើកឡើងនូវចំណុចទាំងអស់ ដែលខ្ញុំបានលើកឡើងហើយ ។ នៅឃ្លាចុងក្រោយមួយទៀតដែលខ្ញុំចង់និយាយ គឺខ្ញុំចង់សូមសេចក្តីណែនាំពីអង្គសវនាការថា តើបើសិនជានៅពេលណាមួយនោះ? តើអង្គជំនុំជម្រះសាលាដំបូងចង់ឲ្យការធ្វើសំណើទាក់ទងទៅនឹងសំណងហ្នឹងយ៉ាងដូចម្តេច? តើចង់ឲ្យខាងមេធាវីដើមបណ្តឹងរដ្ឋប្បវេណីហ្នឹងធ្វើសំណើទាក់ទងទៅនឹងសំណងយ៉ាងម៉េចទៅដល់អង្គជំនុំជម្រះសាលដំបូង ពីព្រោះវិធានអត់មានធ្វើចែងច្បាស់លាស់ទេ អំពីចំណុចអស់ទាំងហ្នឹង ។ ដូច្នេះ ខ្ញុំចង់បានសេចក្តីណែនាំពីអង្គជំនុំជម្រះសាលាដំបូង អំពីការដាក់ស្នើសុំទៅលើសំណងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនេះ ហើយថាតើត្រូវសរសេរពិស្តារយ៉ាងណាទាក់ទងនឹងសំណើបែបនេះ? ប៉ុន្តែខ្ញុំគិតថា ខ្ញុំមិនទាន់ត្រូវការចម្លើយនៅថ្ងៃនេះ ឬថ្ងៃស្អែកទេ គឺថាត្រូវការចម្លើយនៅពេលក្រោយ ។ សូមអរគុណ ។

[១៤:០១:៤៦]

**ប្រធានអង្គជំនុំ៖**

អរគុណលោកស្រីមេធាវី ដែលបានលើកឡើង ហើយការវិភាគរបស់លោកស្រីដែលបានគិតគូរដល់ចំណុចជាច្រើន ហើយខ្ញុំក៏សូមជម្រាបព័ត៌មានថា ចំណុចទាំងអស់នេះអង្គជំនុំជម្រះបានគិតគូរពិចារណា ហើយកំណត់ចូលទៅក្នុងការវិភាគរួមរួចហើយអស់ គ្រាន់តែនៅកិល១វំកិលនៃនីតិវិធីទៅតាមបី ពីរខែម្តង ឬក៏បីខែម្តងនេះ ។ យើងមិនអាចគណនាទាំងស្រុងអ៊ីចឹងបានទេ យើងមានកាលវិភាគរួមមួយប៉ាន់ស្មានថានឹងដល់ចប់ ហើយនិងការរំកិលនីតិវិធី ។ ហើយក៏បញ្ហាទាំងអស់នេះ ក៏ជាបញ្ហាមួយដែលកាលពី ការធ្វើកាលវិភាគបឋមដំបូងនោះក៏យើងអត់ទាន់បានគិតដល់ដែរ ថាតើចំណាយពេលយ៉ាងម៉េចនៃការចូលរួម? ហើយធ្វើដំណាក់កាលណានោះ?

ឥឡូវយើងមានអស់ហើយ ប៉ុន្តែ យើងអត់ទាន់បានត្រូវសម្រេចនៅពេលនេះទេ ព្រោះដោយសាររឿងនេះ វារឿងនៅក្រោយ ប្រហែលជាយើងត្រូវការជួបជុំគ្នាម្តងទៀត មុនពេលដែលយើងឈានទៅដល់ដំណាក់កាលនោះ ។ យើងនឹងអាចមានការជួបប្រជុំគ្នាជាថ្មីម្តងទៀត អំពីរៀបចំដំណើរការនេះ

ព្រោះមានបញ្ហាពាក់ព័ន្ធមួយចំនួនផ្សេងដែរ ដែលត្រូវចាំបាច់ក្នុងការធ្វើ ដូចជាការដែលសន្និដ្ឋានចុងក្រោយជាដើម ។

ជាកិច្ចបន្ត សូមមេធាវីអ្នកតំណាងដើមបណ្តឹងរដ្ឋប្បវេណីផ្សេងទៀត ប្រសិនបើមានយោបល់គឺសូមអញ្ជើញ បើចង់មានយោបល់ពាក់ព័ន្ធនឹងបញ្ហារបៀបវារៈដែលបានលើកឡើងនេះ ។

[១៤:០៣:២៥]

**លោក អាឡាំង វែនណឺ៖**

លោកប្រធាន លោក លោកស្រីចៅក្រម! ជាដំបូងខ្ញុំសូមអរគុណដែលបានផ្តល់ពេលវេលាឲ្យខ្ញុំឡើងនិយាយ និងស្វែងរកមតិយោបល់ពីមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ។ អ៊ីចឹងជាដំបូង គឺខ្ញុំមានមតិយោបល់មួយចំនួនដែលខ្ញុំមិនលើកឡើង ទោះបីជាខ្ញុំអាចឯកភាព ឬក៏មិនឯកភាពជាមួយមេធាវីដទៃទៀតក៏ដោយ ។ បើអ៊ីចឹងការចង់ស្វែងយល់ដឹងរបស់លោកស្រីចៅក្រម អំពីស្ថានភាពរបស់យើងខ្ញុំដែលជាការគួរឲ្យពេញចិត្តណាស់ ហើយខ្ញុំនឹងស៊ីពេលប្រហែលជាដប់ប្រាំនាទីតែប៉ុណ្ណោះ ។ ហើយខ្ញុំនឹងនិយាយយោងទៅលើចំណុចសំខាន់ចំនួនបី ហើយខ្ញុំនឹងចំណាយពេលពីរបីនាទី ដើម្បីពន្យល់ចំណុចនេះនីមួយៗ ។

ជាដំបូង ចំណុចសំខាន់ជាងគេ ដូចជាលោក លោកស្រីចៅក្រម បានដឹងហើយដើមបណ្តឹងរដ្ឋប្បវេណីបានរង់ចាំអស់រយៈពេលសាមសិបឆ្នាំមកហើយ ។ ហើយជនជាប់ចោទនិងជនត្រូវចោទមួយចំនួនគឺជាមុនចាស់ ហើយខ្លះស្លាប់បាត់ទៅហើយ។ ដូច្នេះ ពេលវេលាគឺជាកត្តាសំខាន់មួយ ។ ដូច្នេះដើមបណ្តឹងរដ្ឋប្បវេណីរបស់យើងយល់ថា នេះជាបញ្ហាបន្ទាន់មួយ ហើយខ្ញុំចង់ឲ្យលោក លោកស្រីចៅក្រមយកចំណុចនេះមកពិចារណាផងដែរ ។ ប្រសិនបើដើមបណ្តឹងរដ្ឋប្បវេណីណាមួយស្លាប់នោះ ហ្នឹងគឺជាសេចក្តីវន្ធត់មួយនៅក្នុងសហគមន៍របស់គេ ពីព្រោះពួកគេបានរង់ចាំ រយៈពេលសាមសិបឆ្នាំមកហើយដើម្បីចូលរួមនៅក្នុងសវនាការនេះ ។ ហើយខ្ញុំក៏មិនចង់ឲ្យមានដើមបណ្តឹងរដ្ឋប្បវេណីណាបានស្លាប់ទៅទៀតដែរ ។ ហើយកាលពីខែ *អុកតូប៊ី* ២០០៨ នោះគឺខ្ញុំនិង លោក ខាន បានតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីចំនួនប៉ែតសិបភាគរយ ហើយខ្ញុំក៏ធ្វើការនៅ ឡាអេ ផងដែរ ទីក្រុងឡាអេ ផងដែរ ។ ហើយខ្ញុំបានឯកភាពមកទីនេះ ។ ហើយចំណែកឯ ផ្នែកគាំពារជនរងគ្រោះនោះ បានប្រាប់យើងខ្ញុំថាសវនាការនោះ គឺប្រហែលជាស៊ីពេលបីទៅបួនខែតែប៉ុណ្ណោះ ហើយពួកខ្ញុំ មកទីនេះ គឺមកដោយស្ម័គ្រចិត្ត គឺកាលពីខែតុលា ២០០៨ នៅពេលលោក ការីមខាន បានមកដោយកិច្ចព្រមព្រៀងជាមួយខ្ញុំនោះ

គឺកិច្ចព្រមព្រៀងរវាងយើងខ្ញុំទាំងពីរហើយនិងតុលាការនោះ គឺយើងសន្មតថា សវនាការស៊ីពេលបីទៅបួនខែប៉ុណ្ណោះ ហើយពេលនោះ គឺថាយើងដាក់ចិត្តថានឹងធ្វើការដោយស្ម័គ្រចិត្ត ក្នុងរយៈពេលបីបួនខែប៉ុណ្ណោះ។ នេះហើយ គឺជាការពិតដែលខ្ញុំសូមលើកឡើង។ ក៏ប៉ុន្តែ ដប់មួយខែកន្លង មកបន្ទាប់ពីការចូលរួមនៅក្នុងដំណើរការនីតិវិធីនេះ គឺថាយើងមិនមានគោលជំហរមួយដែលយើងអាចចូលរួមបានតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណី៤០ភាគរយម្នាក់ ដោយស្ម័គ្រចិត្តបាននោះទេ ។ ហើយចំណុចមួយទៀត យើងខ្ញុំសង្ឃឹមថាសវនាការនេះគួរតែបញ្ចប់នៅថ្ងៃទី៣០ ខែកញ្ញា ហើយខ្ញុំគាំទ្រទៅលើចំណុចទាំងអស់ដែលបានលើកឡើងដោយសហព្រះរាជអាជ្ញា ។ ហើយខ្ញុំចង់ថែមបន្តិចទៀត អំពីចំណុចសំខាន់មួយទៀតដែលថា សវនាការហ្នឹងអាចនឹងត្រូវបានបញ្ចប់នៅចុងខែកញ្ញា ហើយមិនមែននៅចុងខែតុលាទេ ហើយខ្ញុំនឹងបង្ហាញអំពីចំណុចអស់ទាំងហ្នឹង ។

[១៤:០៧:០៨]

ចំណុចទីមួយ គឺថា ដើមបណ្តឹងរដ្ឋប្បវេណីរបស់យើង ហើយដោយសារនេះគឺជាកិច្ចប្រជុំអសាធារណៈ ខ្ញុំមិនចង់បញ្ចេញឈ្មោះគាត់ទេ ប៉ុន្តែ គឺថាដើមបណ្តឹងរដ្ឋប្បវេណីរបស់យើងខ្ញុំហ្នឹង គឺមានខ្លះគាត់ឈឺ ហើយខ្លះគាត់កាន់តែចាស់ហើយ គាត់អាយុ៧០ហើយម្នាក់នុ៎ង ហើយគាត់ឈឺទៀត ។ ហើយខ្លះទៀតនុ៎ង គឺក៏មានអាយុ៧៦ឆ្នាំ ចាស់ហើយឈឺទៀត។ ហើយមានម្នាក់ទៀតគាត់អាយុ៨៤ឆ្នាំ ដូច្នេះ ដើមបណ្តឹងរដ្ឋប្បវេណីរបស់យើង ភាគច្រើន គឺជាមនុស្សចាស់ហើយឈឺ ហើយពួកគាត់អស់ទាំងហ្នឹង គឺថាគាត់មានចិត្តទន្ទឹងចង់ឃើញនូវលទ្ធផលនៃសវនាការនេះណាស់ ចង់ឱ្យឃើញ សវនាការនេះបានបញ្ចប់ ហើយគឺខ្ញុំមិនបន្ទោសទៅលើនរណាគេម្នាក់ទេ ក៏ប៉ុន្តែ ខ្ញុំចង់ឱ្យមើលឃើញថា នេះគឺជាបញ្ហាបន្ទាន់បង្ខំដែលយើងត្រូវពិចារណា ។

ហើយចំណុចទីពីរ ដែលខ្ញុំចង់លើក ដោយខ្ញុំសូមទោស ដែលខ្ញុំលើកបញ្ហានេះឡើង ប៉ុន្តែ គឺថាលោកស្រីចៅក្រមបានយល់ដឹងហើយអំពីពេលវេលា ទាក់ទងទៅនឹងបញ្ហាអស់ទាំងនេះ ។ ហើយទាក់ទងទៅនឹងខាងផ្នែកសារព័ត៌មាន។ ផ្នែកសារព័ត៌មានហ្នឹង បានព្យាយាមស្វែងរកមតិយោបល់របស់យើងខ្ញុំ ប៉ុន្តែ គឺថាពួកយើងតែងតែមិននិយាយអ្វីទាំងអស់។ ប៉ុន្តែការពិតនោះ គឺថា យើងបានឯកភាពមកតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណីនៅទីនេះ ពីព្រោះនៅពេលនុ៎ង មានការធានាសម្រាប់ពួកយើងខ្ញុំថាសវនាការនឹងបន្ត ហើយនិងចប់ក្នុងរយៈពេលទៅបីទៅបួនខែតែប៉ុណ្ណោះ ។ ហើយអាស្រ័យទៅលើកិច្ចព្រមព្រៀងនុ៎ងហើយ ដែលពួកយើងទាំងអស់គ្នាបានព្រមព្រៀង មកធ្វើការដោយស្ម័គ្រចិត្តនៅក្នុង

តុលាការនេះ ។

ដូច្នេះ សម្រាប់យើង គឺវាជាបញ្ហាលំបាកណាស់មកហើយ ។ ហើយបើសិនជាសវនាការហ្នឹងអាចបញ្ចប់បានមុនរដូវក្តៅនោះ គឺថា យើងនឹងអាចរកវិធីមួយដើម្បីស្វែងរកអ្នកតំណាងផ្នែកច្បាប់នោះទៀត ក៏ប៉ុន្តែ បើសិនជាមិនអាចបញ្ចប់បានត្រឹមរដូវក្តៅនោះទេ គឺថាយើងត្រូវរកនរណាផ្សេងទៀតមកតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណី ពីព្រោះអ្វី គឺថាបញ្ហានេះជាបញ្ហាមួយដែលលំបាកណាស់ ពីព្រោះមិនមានលុយកាក់ដើម្បីឧបត្ថម្ភដល់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីទេ ។ សម្រាប់អ្នកដទៃទៀត គឺថាគាត់មានប្រាក់បៀវត្សរ៍ដែលមានកម្រិត P3 P4 ឬក៏ P5 នោះ ហើយនេះគឺសម្រាប់តែសំណុំរឿងទីមួយតែប៉ុណ្ណោះផង ។ ហើយខ្ញុំក៏ជឿដែរថា នេះគឺជាការទទួលខុសត្រូវរបស់លោក លោកស្រីចៅក្រមផងដែរ ដើម្បីឲ្យខាងផ្នែករដ្ឋបាលឆ្លើយមក ហេតុអ្វីបានជាយើងជាមេធាវីដើមបណ្តឹងរដ្ឋប្បវេណីមិនមានប្រាក់បៀវត្សរ៍ ឬក៏មិនមានប្រាក់គ្រប់គ្រាន់ដើម្បីរៀបចំធ្វើកិច្ចការរបស់យើងនោះ ។ នេះមិនមែនជាការគំរាមកំហែងទេ ប៉ុន្តែ នេះគឺជាការពិតដែលយើងកំពុងតែប្រឈមមុខនៅពេលបច្ចុប្បន្ននេះ ។

[១៤:១០:០៨]

ដូច្នេះ បើសិនជាផុតរដូវក្តៅនេះហើយមិនមានដំណោះស្រាយនោះ គឺមានន័យថា យើងមិនអាចបន្តតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីបានទៀតទេ ។ យើងបានឮពីសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណីរបស់សហព្រះរាជអាជ្ញាកាលពីព្រឹកមិញនេះដែលថា សវនាការនឹងអាចបញ្ចប់នៅក្នុងកំឡុងពេលសមរម្យមួយដែលមិនធ្វើឲ្យប៉ះពាល់ និងដើម្បីជាការចៀសវាងស្តាប់នូវភស្តុតាងទាំងអស់ ។ យើងខ្ញុំជឿថា យើងអាចធ្វើឲ្យសវនាការនេះបន្តដំណើរបានលឿនទៅមុខ ហើយនឹងអាចបញ្ចប់បាននៅត្រឹមចុងខែកញ្ញានេះ។

យើងខ្ញុំសង្ឃឹមថា ដំណើរទាំងអស់ដែលសហព្រះរាជអាជ្ញាបានលើកឡើង គឺវាមានហេតុផលសមរម្យបំផុត ។ ជាពិសេសទាក់ទងទៅនឹងវិធាននីតិវិធី ទាក់ទងនឹងភាពដែលអាចផ្លាស់ប្តូរបាន ទាក់ទងទៅនឹងការបកប្រែ បកស្រាយវិធានផ្ទៃក្នុង គឺថាយើងខ្ញុំព្រមព្រៀងទាំងស្រុងជាមួយនឹងសហព្រះរាជអាជ្ញា ។ ហើយសំណើអស់ទាំងហ្នឹង ឬក៏ភាគច្រើននៃសំណើអស់ទាំងហ្នឹង គឺគួរតែត្រូវបានឯកភាពទាំងអស់ ហើយខ្ញុំមិនចង់បន្ថែមទៀតទេ ។

ខ្ញុំអាចនិយាយថា តំណាងឲ្យក្រុមរបស់ខ្ញុំ គឺខ្ញុំព្រមទទួល ព្រមព្រៀងជាមួយនឹងមតិយោបល់និងការកម្រិតទៅលើម៉ោងដើម្បីឡើងនិយាយ គឺយើងចង់បានសវនាការមួយដែលដំណើរការទៅលឿនហើយនិងមានសេរីភាពក្នុងការបញ្ចេញមតិផងដែរ ដែលបញ្ចេញដោយសមហេតុសមរម្យ ។ គឺថាយើង

ព្យាយាមសហការ ក្នុងចំណោមមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីទាំងបួនក្រុម គឺថាយើងបានពិភាក្សាគ្នា គឺយើងអាចកម្រិត យើងអាចឯកភាពទៅលើកម្រិតនៃការនិយាយ បើសិនជាការកម្រិតហ្នឹង គឺវាត្រូវបានបែងចែកពេលវេលាដោយយុត្តិធម៌ ដោយស្មើៗគ្នា។ ហើយពេលហ្នឹងលោកចៅក្រម ប្រហែលជាអាចនឹងយល់ព្រមថា មនុស្សគ្រប់ៗគ្នានៅតាមក្រុមត្រូវតែគោរពទៅតាមការកំណត់ពេលវេលាបែបនោះ ។ បើសិនជាយើងធ្វើការបែងចែកច្បាស់លាស់បែបនេះ ពីព្រោះនេះគឺជាលក្ខខណ្ឌដែលបានត្រូវធ្វើឡើងដើម្បីឲ្យសវនាការហ្នឹងមានដំណើរលឿនទៅមុខ ។

ហើយចំណុចតូចមួយរវាង ដែលជាភាពខុសគ្នារវាងយើងខ្ញុំ ហើយនិងខាងសហព្រះរាជអាជ្ញានោះ គឺថាយើងចង់ឲ្យខាងសហព្រះរាជអាជ្ញាធ្វើការបង្ហាញប្រាប់យើងនូវបញ្ជីឈ្មោះសាក្សី គឺថាយើងបានដឹងហើយនៅពេលមុន ។ ប៉ុន្តែ យើងមិនអាចដឹងថាតើសាក្សីនោះនឹងនិយាយអំពីអ្វីទេ ។ គឺយើងត្រូវការបញ្ជីមួយដែលមាន ដែលវែង សាក្សីមួយចំនួនត្រូវបានកោះហៅ ប៉ុន្តែយើងសង្ឃឹមថានៅពេលដែលយើងបានឮ សាក្សីទីមួយ ទីពីរ ឬក៏ទីបី ពេលនុំងខាងសហព្រះរាជអាជ្ញាប្រហែលជាអាចនឹងពេញចិត្តទៅសក្ខីកម្មទាំងហ្នឹង ហើយបានយល់ដឹងអំពីភស្តុតាងដែលត្រូវការចាំបាច់ ហើយខាងយើងនេះក៏សប្បាយចិត្ត បើសិនជាយល់ឃើញថា ភស្តុតាងហ្នឹងត្រូវបានបង្ហាញរួចហើយនោះ ហើយយើងគិតថាបើសិនជានេះជា លទ្ធភាពដើម្បីឲ្យធ្វើទៅបាន គឺដើម្បីឲ្យខាងសហព្រះរាជអាជ្ញាធ្វើការ ។ បើអ៊ីចឹងមានន័យថា ខាងសហព្រះរាជអាជ្ញាអាចស្នើឲ្យធ្វើការពិភាក្សាជាមួយភាគីផ្សេងៗទៀតជាអសាធារណៈដើម្បីបង្ហាញទៅលើភស្តុតាងដែលបានផ្ដល់ជាសក្ខីកម្មដោយសាក្សីអស់ទាំងនុ៎ង ។

បើសិនជាសហព្រះរាជអាជ្ញាស្វែងរកការកាត់បន្ថយបញ្ជីឈ្មោះសាក្សីអស់ទាំងនុ៎ង ទាក់ទងទៅនឹងដំណើរការស-២១ ជាដើម ។ ឧទាហរណ៍ គឺដែលថា នឹងអាចស៊ីពេលដ៏ច្រើននោះ ហើយយើងយល់ថានេះជាវិធីមួយដែលអាចកាត់បន្ថយការចំណាយពេលលើសវនាការផងដែរ ។ បញ្ហា គឺមិនមែនជាបញ្ហាដែលថាការសួរសំណួរច្រើននោះទេ ប៉ុន្តែបញ្ហាគឺថា ហើយខ្ញុំមិនបន្ទោសទៅលើនរណាម្នាក់នោះទេ នេះគ្រាន់តែនេះគឺជាការពិតដែលៗកើតមានឡើង គឺមិនមានអន្តរាគមន៍គ្រប់គ្រាន់ពីខាងលោក លោកស្រីចៅក្រមនោះទេ ។

[១៤:១៤:១៨]

តុលាការនេះបានចាប់ផ្ដើមឡើងនៅសវនាការ បានចាប់ផ្ដើមនៅថ្ងៃ៣១ ខែមីនា ឥឡូវនេះគឺរហូតដល់ថ្ងៃទី១០ ខែនេះទៅហើយ តើយើងបានចំណាយពេលប៉ុន្មានសប្ដាហ៍មកហើយ? ហើយតើក្នុងរយៈ

ពេលប៉ុន្មានសប្តាហ៍នេះ? តើយើងបានអង្គុយពេញក្នុងមួយសប្តាហ៍ពីថ្ងៃច័ន្ទដល់ថ្ងៃព្រហស្បតិ៍ប៉ុន្មានសប្តាហ៍មកហើយ? គឺបានតែប្រាំសប្តាហ៍តែប៉ុណ្ណោះ ពីព្រោះអីនៅសប្តាហ៍ទីមួយ គឺយើងមានសវនាការតែបីថ្ងៃតែប៉ុណ្ណោះ បន្ទាប់មកទៀត គឺមាន*ហូលីដេ* រយៈពេលសប្តាហ៍ ហើយក្រោយមកទៀតមានការឈប់សម្រាកមិនធ្វើសវនាការ ។ ហើយកាលពីសប្តាហ៍មុន ទីមួយដល់ទីបួន គឺថាមិនមានសវនាការ ហើយថ្ងៃនេះក៏មិនមានសវនាការទៀតដែរ ។

នេះជាកត្តាមួយទៀតដែលយើងត្រូវពិចារណា ពីព្រោះ គឺថាមិនមានការកម្រិត ទៅលើការឡើងនិយាយ ក៏ប៉ុន្តែ យើងក៏មើលផងដែរ ថាគឺថាមានន័យថាយើងមិនបានអង្គុយនៅក្នុងសវនាការឲ្យបានគ្រប់គ្រាន់ ដើម្បីឲ្យសវនាការហ្នឹងបន្តនោះ ។

អ៊ីចឹងទាក់ទងទៅនឹងចំណុចនេះ គឺថាយើងខ្ញុំគាំទ្រជំហររបស់ខាងសហព្រះរាជអាជ្ញាដែលយើងប្រហែលជាអាច មិនធ្វើ ឬក៏យើងអាចបន្តសវនាការនៅថ្ងៃបុណ្យសម្រាក ។ ឧទាហរណ៍ ថ្ងៃទី១៨នៃខែនេះជាដើម ។ ដូច្នេះ យើងខ្ញុំចង់ស្នើឲ្យខាងសវនាការហ្នឹង ខាងអង្គជំនុំជម្រះបន្តបើកសវនាការនៅថ្ងៃទី១៨នេះ គឺយើងខ្ញុំមិនចង់ឲ្យមានការឈប់សម្រាកច្រើនពេកទេ ហើយយើងខ្ញុំក៏មិនគាំទ្រទៅលើការបើកសវនាការបីថ្ងៃមួយសប្តាហ៍ បួនថ្ងៃមួយសប្តាហ៍ឆ្លាស់គ្នាបែបនេះដែរ ។ ប្រហែលជាខ្ញុំនិយាយញាប់ពេកក៏មិនដឹង សូមទោសបើសិនជាខ្ញុំអ៊ីចឹង មកពីខ្ញុំភ្លេចខ្លួន ។

យើងឯកភាពជាមួយសហព្រះរាជអាជ្ញា ដើម្បីឲ្យមានសវនាការ ទោះបីជានៅថ្ងៃបុណ្យសម្រាកក៏ដោយ ហើយប៉ុន្តែមិនគប្បីបន្ថយចំនួនថ្ងៃសវនាការទេ ប៉ុន្តែផ្ទុយទៅវិញប្រហែលជាក្នុងខែសីហា ដែលយើងមិនបានធ្វើដំណើរលឿនទេ យើងសូមអនុញ្ញាតឲ្យមានសវនាការនៅព្រឹកថ្ងៃសុក្រ ដែលអាចយើងឲ្យខាងរដ្ឋបាលក្នុងការផ្តល់នូវការគាំទ្របណ្តោះអាសន្ន និងជំនួយមួយចំនួន ហើយដោយស្មោះត្រង់យើងមិនមានពេលវេលាគ្រប់គ្រាន់នៅក្នុងបន្ទប់សវនាការទេ ។ ហើយយើងត្រូវតែមានដំណោះស្រាយទល់នឹងបញ្ហានេះ ដូច្នេះ សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ជាថ្មីម្តងទៀត យើងត្រូវធ្វើការប្តេជ្ញាហើយជាបន្ទុកដែលត្រូវរួមទាំងអស់គ្នា ។

[១៤:១៧:១១]

យើងជាអ្នកការពារផលប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី យើងបានធ្វើការប្តេជ្ញា ហើយឲ្យអស់ពីសមត្ថភាពរបស់យើង ដើម្បីពិនិត្យមើលជនរងគ្រោះ ហើយនិងអ្នកនៅរស់រានមានជីវិត ហើយនិងគឺថាឲ្យនិយាយទៅតាមលទ្ធភាពដែលគេចង់ ។ អ៊ីចឹងហើយ មិនមែនជាទីកន្លែងដែលថាគេនិយាយ

ច្រើនម៉ោងៗឲ្យហួសហេតុពេកនោះទេ ដែលថាគេៗមានអ្វីនៅក្នុងទ្រូងដែលលាក់កប់ជាយូរមកហើយនោះ ។

ដោយសារនិយាយរឿងហ្នឹង គឺថាយើងតម្រូវរឿងយើងសុំ គឺថាមានតែដើមបណ្តឹងរដ្ឋប្បវេណីប្រាំមួយទេ ដែលបានឱកាសក្នុងការនិយាយ ហើយប្រសិនជាមានរបៀបវារៈសូមឲ្យលោកចៅក្រមដាក់ចំណុចនេះប្រហែលជាៗគំនិត មានពេលដែលយើងត្រូវការកន្លះថ្ងៃសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីប្រាំមួយនាក់របស់យើង ។ ចំពោះម្នាក់ៗឲ្យគាត់បាននិយាយ ។ ខ្ញុំជឿថា ប្រសិនបើម្នាក់គាត់បានពេលនិយាយ ដើម្បីសម្តែងពីមតិរបស់គាត់គឺថាគ្រប់គ្រាន់ ។

លោកចៅក្រមជាទីគោរព! ដែលខ្ញុំសូមស្នើ សូមឲ្យលោកចៅក្រមមេត្តាម៉ឺងម៉ាត់ជាងនេះ ជូនកាលភាគីគឺថាអាចនឹងឡើងនិយាយដោយមិនមានការអនុញ្ញាតពីលោកប្រធានផងពេលខ្លះ ។

**ប្រធានអង្គជំនុំ៖**

អស់ម៉ោងហើយ ។ ឥឡូវ អស់ម៉ោងហើយព្រោះលោកកំណត់ដប់ប្រាំនាទី ឥឡូវកាលកំណត់ដែលសុំគឺអស់ម៉ោងហើយ ។ អ៊ីចឹងដល់ពេលប្រធានតុលាការត្រូវធ្វើការម៉ឺងម៉ាត់ហើយ ។ សូមអញ្ជើញតទៀតអ្នកផ្សេង ។

លោក ហុង គឹមសួន អាចចំណាយពេលប៉ុន្មានមីនុត? ដប់ប្រាំមីនុតដូចគេទេ? អាចចាប់មុនបានបើក្រោយមិនបានទេណ៎ា កុំឲ្យបន្ទោសខ្ញុំ ឥឡូវ ខ្ញុំមិនទទួលរងការបន្ទោសទេ ។ ខ្ញុំនឹងប្រើអំណាចឆន្ទានុសិទ្ធិក្នុងនាមខ្ញុំជាប្រធាន ហើយអត់ផ្អត់យូរហើយដែរ ។

[១៤:១៩:២៧]

**លោក ហុង គឹមសួន៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំបាទមិនប៉ានសន្យាខ្លួនឯងអ៊ីចឹងទេ ព្រោះតាំងពីដើមមកខ្ញុំមិនដែលប៉ានសូមទោស ព្រោះមិនអាចកំណត់បានដូចលោកប្រធានរៀបចំកម្មវិធីអ៊ីចឹងដែរ ប៉ុន្តែ ខ្ញុំបាទក៏គោរពទៅតាមពេលវេលាដែលលោកប្រធានយល់ថា មតិ ឬក៏ការកត់សម្គាល់របស់ខ្ញុំបាទមិនចូលទៅក្នុងអង្គហេតុ ឬក៏ទៅក្នុងគម្រោងនៃការនិយាយ ។

ខ្ញុំបាទបានស្តាប់មុននេះបន្តិច លោកប្រធានបានមានប្រសាសន៍ថា យើងនិយាយឲ្យចំថាកុំនិយាយថាចង់ឲ្យបានឆាប់ៗ តែវិធីនៃឆាប់នោះវាយ៉ាងម៉េច?

ខ្ញុំបាទក៏នៅមានកង្វល់ដែលត្រូវលើកឡើងថា ជាការជូនជាយោបល់ទៅលោកប្រធាន ដើម្បីឲ្យ

ឃើញថា ឧទាហរណ៍បើថាយើងនឹងជិះកង់ ឲ្យវាទៅទាន់ឲ្យឆាប់ទៅ វាធាក់កង់ និងប្រើកម្លាំងប៉ុនណា? អ៊ីចឹងបើការសួរតទល់គ្នាហ្នឹង សួរយ៉ាងម៉េច? កុំអូសបន្លាយពេលវែងឆ្ងាយឬយ៉ាងម៉េច? នេះអ្វីដែលខ្ញុំចង់លើកឡើងជាឧទាហរណ៍តិចៗ ។ អ៊ីចឹងដែលការទៅចូលរួមយោបល់របស់ខ្ញុំបាទ គឺការសាកសួរដែលខ្ញុំបាទឃើញកន្លងមក គឺទាក់ទងជាមួយនឹងមន្ត្រីជំនាញ ឬអ្នកជំនាញដែលចូលមក គឺសួរច្រើនមែនទែន ។ ហើយដែលពេលវេលាអូសបន្លាយរហូត លោកប្រធានត្រូវការពេលវេលាពិភាក្សាគ្នានឹងពេលដែលមានភាគីជំទាស់ ។

អ៊ីចឹង អ្វីដែលខ្ញុំបាទយល់ឃើញហ្នឹងគឺថា ពិនិត្យទៅលើបញ្ជីឈ្មោះសាក្សី បញ្ជីឈ្មោះជនរងគ្រោះជាដើមបណ្ដឹងដែលត្រូវឡើងថ្លែងនោះ ។ ខ្ញុំថាបើប្រៀបធៀបប្រហែលជាសាក្សីដែលមកបំភ្លឺទាក់ទងនឹងការប្រតិបត្តិការនៅថ្ងៃមុខនេះវាមានពេលវេលាដែលដេញដោលគ្នាច្រើនជាងទៅវិញ ។ អ៊ីចឹងខ្ញុំបាទចាប់អារម្មណ៍អំពីសាក្សីដែលទាក់ទិននឹងការប្រតិបត្តិការនេះច្រើនជាង បូកជាមួយអ្នកជំនាញដែលមានឈ្មោះនៅខាងក្រៅនេះ ។ អ៊ីចឹងខ្ញុំបាទយល់ឃើញថា ជាការយល់ឃើញខ្ញុំបាទ សាក្សីជំនាញដែលមានឈ្មោះតាមក្រោយទៀត មិនដឹងថាលោកប្រធានដាក់កម្មវិធីយ៉ាងម៉េចទេ? មាន ដេវីដ ឆេនដ៍ល័រ ឬ ដនឡុប ប៉ុន្មាននាក់ទៀត និងខាងលោកវេជ្ជបណ្ឌិតខាងផ្នែកចិត្តសាស្ត្រនោះ ។

អ៊ីចឹង ខ្ញុំបាទគិតថា បើសិនជាការថ្លែងរបស់គាត់បានលឿន ឬក៏បានច្បាស់ អាហ្នឹងវាចំណេញពេល ហើយការសាកសួរ បើសិនជាលោកប្រធានយល់ឃើញថា ចំណុចនៅក្នុងសេចក្ដីថ្លែង ឬក៏ការជម្រាបជូនរបស់អ្នកជំនាញពីក្នុងឯកសារទំព័រណាទៅដល់ទំព័រណា វាទាក់ទងជាមួយនឹងអង្គហេតុដែលយើងដេញដោល អាចកំណត់ពេលប៉ុន្មាននោះ ខ្ញុំបាទយល់ជាវាការកាត់បន្ថយពេលវេលា ។ ព្រោះការសរសេរសៀវភៅរបស់អ្នកជំនាញ អាចសរសេរ គេហៅថាជាការច្នៃប្រឌិតសិល្បៈដើម្បីឲ្យបានវែងផងតែយើងគិត ខ្ញុំបាទគិតថា យកចំណុចដែលទាក់ទិនជាមួយនឹងអង្គហេតុដែលនឹងត្រូវនិយាយនៅថ្ងៃ ឬក៏សប្ដាហ៍ខាងមុខ នេះមួយទៀត ។

[១៤:២២:៣២]

ចំពោះការកំណត់សាក្សី ដែលជាអ្នកប្រតិបត្តិក្រោមបង្គាប់លោក កាំង ហ្កេកអ៊ាវ ហៅ ឌុច នៅក្នុងមន្ទីរស-២១ ឬក៏ជើងឯក ខ្ញុំបាទគិតថាមិនអាចកំណត់ពេលវេលាឲ្យបានកាន់តែខ្លីទេ ប៉ុន្តែបើធ្វើបានខ្លី ខ្ញុំបាទយល់ឃើញថា គាត់ថ្លែងការណ៍រួចហើយ តើលោក កាំង ហ្កេកអ៊ាវ ហៅ ឌុច នោះ គាត់យល់ព្រមជាមួយនោះទេ ? ហើយចម្ងល់របស់ខាងយើងខ្ញុំ និងភាគីមិនដូចគ្នាទេ សំខាន់គឺប្រជាពលរដ្ឋ និង

ជនរងគ្រោះចង់ដឹង ការប្រតិបត្តិការនៅក្នុងមន្ទីរស-២១ និងមុននឹងយកជនរងគ្រោះទៅសម្លាប់នោះធ្វើយ៉ាងម៉េចៗ ហើយ គឺស្មើរតែអស់ចិត្តហើយ ។

ហ្នឹងខ្ញុំបាទយល់ថា វាខ្លីមកវិញ នេះបើដើម្បីខ្លី ។ ហើយមួយទៀត ចំពោះខាងជនរងគ្រោះជាដើមបណ្តឹងដែលគាត់ឡើងថ្លែង ខ្ញុំបាទយល់ឃើញថា ដូចលោក គង់ ពិសី មានប្រសាសន៍ពីព្រឹកដែរថា គាត់អាចថ្លែងនៃរឿងរ៉ាវរបស់គាត់ បើសិនជាលោកជាជនរងគ្រោះ ជាដើមបណ្តឹងដែលបានរួចជីវិតពី ស-២១ អាចវែងបន្តិចដូចក្នុងកម្មវិធីដាក់មួយថ្ងៃ បូកបញ្ចូលទាំងការថ្លែងរបស់គាត់ និងការសួរដេញដោល ។ តើសាក្សីដែលគាត់មិនមែនបានរួច-- (សូមទោស) ជនរងគ្រោះ ឬដើមបណ្តឹងដែលគាត់មិនមែនរស់នៅក្នុង ស-២១ រួចជីវិតនោះ ប្រហែលជាខ្លីជាងនោះ កាន់តែឆ្ងាយ កាន់ខ្លីជាងនោះទៅទៀតហើយ ។

អ៊ីចឹង អ្វីដែលខ្ញុំចង់លើកឡើងនេះគឺចង់ឆ្លើយឲ្យចំនឹងសំណួរលោកប្រធានថា ធ្វើយ៉ាងម៉េច ដើម្បីឲ្យខ្លី ហើយឲ្យមានន័យនោះ? អ៊ីចឹងខ្ញុំបាទថា ពង្រួញការសួររបស់សាក្សីដែលជាអ្នកអនុវត្តផ្ទាល់នៅ ស-២១ ឬជើងឯក ឬព្រៃស ដែលមានចំនួនប៉ុន្មាននាក់នេះ ។ ខ្ញុំលើកឡើងវិញដដែល គាត់ថ្លែងអំពីការសកម្មភាពរបស់គាត គាត់ត្រូវធ្វើយ៉ាងម៉េចៗ ឲ្យឃើញ ឲ្យបានស្តាប់ទាំងក្នុងអង្គសវនាការ ទាំងសាធារណជន ។ ហើយការសួរមកវិញ គឺជាគំនិតខ្ញុំចង់ប្រៀបធៀបថា តើអ្វីដែលគាត់បានធ្វើ គាត់អនុវត្តនោះ លោក ឌុច គាត់ទទួលស្គាល់ ឬមិនទទួលស្គាល់? ហើយសាក្សីទាំងអស់-- (សូមទោស) ខាងភាគីទាំងអស់ដែលចូលរួម ថាការនិយាយរបស់គាត់ប៉ុណ្ណឹង យើងល្មមស្តាប់បានទេ បើយើងជជីកឡើងវិញទៀត គាត់ថាគាត់បានធ្វើប៉ុណ្ណឹងឯង ។ គេប្រើគាត់ ឧទាហរណ៍ថា គាត់ដឹកជញ្ជូនទៅដល់ចង ឬក៏ចងហើយ រុំមុខដាក់ទៅក្នុងឡាន ដឹកដាក់ចុះហើយយកទៅវាយចោល ។ គ្រាន់តែថាការវាយចោលដូចលោក កាំង ហ្គេកអ៊ាវ ដូចគាត់តែងមានប្រសាសន៍ហើយថា គេធ្វើយ៉ាងម៉េចខ្លះ? គឺដូចនៅម-១៣ អាហ្នឹងស្តាប់បានហើយ ដឹងថាមនុស្សហ្នឹងគឺស្លាប់ដោយការធ្វើទារុណកម្មម៉េចៗបន្តិច ។ សមតែគាត់បានអនុវត្តព្រោះថា សូម្បីតែជនរងគ្រោះដែលរស់នៅសល់សព្វថ្ងៃនេះ ក៏គាត់មិនបានទៅឃើញរបៀបសម្លាប់ទេ គាត់គ្រាន់តែថ្លែងអំពីទុក្ខលំបាករបស់គាត់តែប៉ុណ្ណោះទេ ។

អានេះខ្ញុំថាបើសិនជាលើកឲ្យឃើញថាការថ្លែងការណ៍ហើយ សួរថាភាគីព្រមព្រៀងតែប៉ុណ្ណឹងទេ? ខ្ញុំបាទគិតថាប្រហែលជាខ្លីមកវិញ ។ នេះជាមតិយល់ឃើញរបស់ខ្ញុំបាទ ដែលជួយចូលរួមជាយោបល់ ។ សូមអរគុណ ។

[១៤:២៥:៤៩]

**ប្រធានអង្គជំនុំ៖**

អរគុណលោក ហុង គីមសួន ហើយមិនបានអរគុណលោក អាឡាំង វ៉ែនណឺ អំមិញណ៎ា ។ អរគុណលោក អាឡាំង វ៉ែនណឺ ហើយដែលបានចាប់អារម្មណ៍ ។ ប៉ុន្តែ ខ្ញុំសូមជម្រាបអ៊ីចេះ ហើយក្រែងលោអាចមានការភ័ន្តច្រឡំ លើកឡើងអំពីការខាក់ខានមិនធ្វើសវនាការរបស់អង្គជំនុំជម្រះកន្លងមក ដោយហេតុថា អង្គបុរេបានស្នើសុំកក់សាលសវនាការនេះ ទុកសម្រាប់មួយឆ្នាំរបស់គេរួចហើយ ដោយលិខិតផ្លូវការមួយជូនមក ។ អ៊ីចឹងយើងអត់ប៊ានទេ ពេលដែលទៅសួរគេ គេថានឹងមានលទ្ធភាពក្នុងការធ្វើការសវនាការនេះ ។ អ៊ីចឹងហើយបានជាដល់ពេលយើងថ្ងៃមួយទល់ថ្ងៃប្រាំ ខែប្រាំមួយហ្នឹង ស្រាប់តែគេអត់ធ្វើសវនាការ ។ ចុះយើងបានសម្រេចរួចហើយ យើងសួរគេ ។ ដោយបទពិសោធន៍នេះហើយបានជាថ្មីៗនេះ ដល់ខែប្រាំពីរ យើងព្យាយាមសួរគេ ។ ឥឡូវនេះ ខាង *ភី.ធី.ស៊ី (PTC)* ក៏មិនទាន់ប្រាកដដែរ ប៉ុន្តែ គេប៉ាន់ស្មានថា គេនឹងអាចធ្វើសវនាការក្នុងអំឡុងយ៉ាងយូរតែបីថ្ងៃទេ ។ អ៊ីចឹងបានយើងសួរអ្នកឯងយកថ្ងៃណា? គេថាឥឡូវគេអាចយកថ្ងៃចុងក្រោយ ពុធ ព្រហស្បតិ៍ សុក្រ អ៊ីចឹងបានយើងសុខចិត្តដាក់ពីរថ្ងៃក៏យើងជ្រៀតដាក់នៅក្នុងខែប្រាំពីរនេះដែរ ។ នេះគឺសប្តាហ៍ទីបួននៅខែប្រាំពីរនេះ ដោយសារមូលហេតុអ៊ីចឹង ។

ទីពីរ យើងសួរថា ហេតុបានជា *ភី.ធី.ស៊ី* មានបន្ទប់សវនាកាមួយដែរ ម៉េចក៏មកជ្រៀតជ្រែកនៅក្នុង យកសាលនេះដែរ? បញ្ហាមិនមែនតែ *ភី.ធី.ស៊ី* ទេ បើសិនជាយើងធ្វើពីរព្រមគ្នា ផ្នែកខាងគាំទ្រនេះដែលរដ្ឋបាល ខាងបកប្រែអីនេះវាអត់មានសមត្ថភាពអាចធ្វើបានទេ ។ នេះការឆ្លើយតបរបស់ខាងរដ្ឋបាលគេមិនអាចមានលទ្ធភាពធ្វើម្តងពីរសវនាការអ៊ីចឹងបានទេ ។

នេះហើយដែលយើងនាំឱ្យវាមានបញ្ហា ហើយដោយសារបទពិសោធន៍នៃការអាក់ខានរបស់គាត់ទើបយើងព្យាយាមសួរគាត់ ហើយមិនមែនសួរតែម្តងទេណ៎ា ។ ការប្រែងប្រែងសួរ គឺថាយើងសួរព្យាយាមរហូតដល់ច្រើនដង ល្មមតែបានលទ្ធផលពីរថ្ងៃហ្នឹងឯង ទី២៧, ២៨ ដែល *ភី.ធី.ស៊ី* គ្រោង ហើយយើងកំណត់ថាយកថ្ងៃហ្នឹង យកចំណែកថ្ងៃហ្នឹង កុំឱ្យអាក់ខានយកមកធ្វើសវនាការនោះ ។ ហ្នឹងជម្រាបឱ្យបានយល់ ។

ហើយបញ្ហាមួយទៀតដែលបានលើកឡើងអំមិញ ប្រហែលជាយើងមិនអាចធ្វើបានទេ នៅក្នុងដំណើរការប្រព្រឹត្តទៅនៃការឈប់សម្រាកបុណ្យជាតិរបស់គេ ដែលបានកំណត់ដោយច្បាប់នោះ ។ អា

នោះជាការរំលោភសិទ្ធិធ្ងន់ធ្ងរលើច្បាប់ការងារ ដែលមានការពាក់ព័ន្ធទៅលើសិទ្ធិនៃមន្ត្រីរាជការ ដែលត្រូវទទួលការឈប់សម្រាក ។ ដូចថាថ្ងៃ១៨ អ៊ីចឹង យើងមិនអាចធ្វើដំណើរការសវនាការបានទេ ។

[១៤:២៨:១៨]

ដោយឡែក ខ្ញុំអរគុណប្រសិនជាមានការចាប់អារម្មណ៍ថា ទាមទារថាប្រាំថ្ងៃគួរធ្វើសវនាការប្រាំថ្ងៃនោះ ប៉ុន្តែទំហំនៃសមត្ថភាព និងលទ្ធភាពរបស់អង្គជំនុំជម្រះគឺមានបញ្ហា ដោយសារបញ្ហាទាក់ទិនជាមួយនឹងការជំទាស់និងការណែនាំផ្សេងៗ ដែលលើកឡើងដែលមានលក្ខណៈស្មុគស្មាញ ។ ពេលខ្លះគឺយើងអាចដោះស្រាយបានភ្លាម រឿងបញ្ហាធម្មតា ប៉ុន្តែបញ្ហាជាច្រើននៅទីនេះគឺបញ្ហាស្មុគស្មាញមែនទែន ដែលទាមទារឲ្យមានការស្រាវជ្រាវ ទាំងកម្រិតច្បាប់ជាតិ ហើយនិងពិសេសគឺទម្លាប់អន្តរជាតិ ដែលគេធ្លាប់អនុវត្តនៅបណ្ដាតុលាការអន្តរជាតិជាច្រើនយមកគិតគូរពិចារណាដើម្បីរៀបចំសម្រេច ។ ការគិតគូររបៀបនេះមិនងាយដូចយើងបានគិតនោះទេ នេះជាបញ្ហាដែលយើងទាមទារថាយើងនឹងលៃលកពេលវេលានេះ ។

ហើយអរគុណណាស់ដែលប៉ុនប៉ងនឹងការប្រឹងប្រែង ក៏ដូចគ្នា បើសិនជាគំនិតជាបុគ្គលខ្ញុំ គឺខ្ញុំអាចធ្វើអ៊ីចឹងបាន តែបើគិតជាក្រុមការងារក្នុងនាមជាមនុស្សជាតិ ជាមន្ត្រីរាជការដែលត្រូវទទួលការឈប់សម្រាកឲ្យសមរម្យ ដើម្បីឲ្យមានឱកាស សុខភាពល្អ និងធ្វើការងារបាន មានកម្លាំងពលលំាំងរឹងប៉ឹង ហើយមានឱកាសសម្រាកខ្លះនោះគឺយើងមិនអាចធ្វើដូច្នេះបានទេ ។ យើងនឹងប្រឹងប្រែងធ្វើក្នុងក្របខ័ណ្ឌនៃការប្រតិបត្តិការងារ ពេលវេលាដែលច្បាប់បានតម្រូវ ។ យើងលៃនៅក្នុងអំឡុងប៉ុណ្ណឹង ។

តទៅនេះសូមប្រគល់វេទិកាទៅខាងមេធាវីការពារក្ដី ដូចជាអត់មានបញ្ហាអីទេ ឬក៏មានបញ្ហាអី?

អញ្ជើញ សូមអញ្ជើញកញ្ញាមេធាវី ។

**កញ្ញា ទី ស្រ៊ីនណា៖**

សូមអរគុណលោកប្រធានដែលអនុញ្ញាតឲ្យខ្ញុំសូមមានយោបល់ខ្លះទៅលើបញ្ហាការសង្កេតនេះ។ ទាក់ទងនឹងរយៈពេល តាំងពីព្រឹកមករហូតមកដល់ថ្មើរនេះ តាមការសង្កេតរបស់ខ្ញុំ ខ្ញុំយល់ឃើញថាពាក់ព័ន្ធទៅនឹងការកាត់ពន្លឿននីតិវិធីនៅក្នុងសវនាការនេះ សង្កេតឃើញថាមានការផ្ដោតអារម្មណ៍តែទៅលើដើមបណ្ដឹងរដ្ឋប្បវេណី ក៏ដូចជាសាក្សីនិងអ្នកជំនាញ ការសាក្សីសួរទៅលើសាក្សី និងអ្នកជំនាញតែងតែផ្ដោតអារម្មណ៍ទៅលើថា ការចោទសួរទៅលើជនជាប់ចោទ ក៏ដូចជាទៅលើអ្នកជំនាញ តែងតែប្រើរយៈពេលវែង ប្រើសំណួរវែង ហើយនិងមានភាពច្រំដែល ។ ប៉ុន្តែ ខ្ញុំអត់បានសង្កេតឃើញថា

ភាគីទាំងអស់បានលើកឡើងពីបញ្ហាសិទ្ធិរបស់ជនជាប់ចោទនៅក្នុងការឆ្លើយទៅនឹងសំណួរ ។

ខ្ញុំសង្កេតឃើញថាកន្លងមក ខ្ញុំឃើញថា ជនជាប់ចោទនៅពេលដែលគាត់ឆ្លើយទៅសំណួរ គាត់តែងតែប្រើរយៈវែង គឺនៅពេលដែលសំណួរមួយចោទសួរទៅគាត់ទៅ គាត់ឆ្លើយប្រើរយៈយ៉ាងតិចណាស់ក៏ដប់-ដប់ប្រាំនាទីទៅម្ភៃនាទីដែរ ។ ហើយអ៊ីចឹងនាងខ្ញុំគ្រាន់ឃើញថា នេះគឺជាបញ្ហាមួយដែលនាំឲ្យមានការពន្យឺតនីតិវិធីមួយដែរ ។ ដូច្នេះហើយ ខ្ញុំគ្រាន់តែចង់សូមសួរទៅលោកប្រធាន ហើយនិងសូមឲ្យមានការ និងស្នើសុំឲ្យប្រធានធ្វើដំណោះស្រាយទៅលើបញ្ហាហ្នឹង ទាក់ទងទៅនឹងសិទ្ធិរបស់ជនជាប់ចោទនៅក្នុងឆ្លើយ ។ ព្រោះថាកន្លងមក គាត់ចម្លើយ រាល់ចម្លើយរបស់គាត់ គាត់តែងតែឆ្លើយ មុននឹងគាត់ធ្វើការឆ្លើយតបទៅនឹងសំណួររបស់ភាគី គាត់តែងតែធ្វើការឆ្លើយពង្វាង ហើយទើបបានគាត់ចូលដល់សាច់រឿង គាត់បានគាត់ឆ្លើយ ។

អ៊ីចឹងនាងខ្ញុំគ្រាន់តែចង់សូមសួរទៅលោកប្រធានថា ពាក់ព័ន្ធទៅនឹងសិទ្ធិនេះ នៅពេលដែលគាត់ឆ្លើយបែបនេះ តើភាគីមួយណា ឬក៏ខាងលោកប្រធាន ឬក៏ខាងភាគីដែលបង្កើតជាសំណួរហ្នឹង មានសិទ្ធិនៅក្នុងការបង្អាក់គាត់ ដើម្បីថាប្រាប់ទៅគាត់ ថាតើសូមឲ្យឆ្លើយខ្លី ឬមួយក៏សូមឲ្យគាត់ហ្នឹងឆ្លើយឲ្យចំនឹងសំណួរ ដើម្បីចៀសវាងកុំឲ្យនីតិវិធីហ្នឹងកាន់តែលឿនតទៅ ។

សូមលោកប្រធានជួយដោះស្រាយទៅលើបញ្ហានេះផង ព្រោះការសង្កេតឃើញរបស់ខ្ញុំកន្លងមកគឺខ្ញុំឃើញបញ្ហាហ្នឹងកើតមានឡើង ហើយភាគច្រើនៗតែរឹតបណ្តឹងលើដើមបណ្តឹងរដ្ឋប្បវេណី ក៏ដូចជាខាងសូម្បី-- បើនិយាយឲ្យចំទៅ គឺដើមបណ្តឹងរដ្ឋប្បវេណី ក៏ជាខាងព្រះរាជអាជ្ញា គឺខាងពួកយើងក៏ព្យាយាមធ្វើយ៉ាងណាខ្នះខ្នែងយ៉ាងណាដើម្បីរបៀបចំឲ្យនីតិវិធីនេះក៏កាន់តែលឿនដែរ រហូតដល់ខាងលោកព្រះរាជអាជ្ញាហ្នឹងក៏បានលើកឡើងរកវិធីសាស្ត្រដើម្បីកាត់បន្ថយនីតិវិធី ដើម្បីកុំមានការ យឺតយ៉ាវតទៅទៀត ។ អ៊ីចឹង គាត់ក៏បានព្យាយាមកាត់បន្ថយបញ្ជីឈ្មោះសាក្សី ដើម្បីកុំឲ្យមានសាក្សីច្រើននាក់ដើម្បីធ្វើការសួរដេញដោលទៅសាក្សីច្រើននាក់តទៅទៀត ។ អ៊ីចឹង គឺជានីតិវិធីមួយកាត់បន្ថយនីតិវិធីហើយ ប៉ុន្តែ ជាក់ស្តែង ដោយឡែកទៅវិញទាក់ទងនឹងជនជាប់ចោទ ក៏មានខាងភាគីណាមួយពិចារណាទេ ។ អ៊ីចឹងនាងខ្ញុំសូមឲ្យលោកប្រធានដោះស្រាយទៅលើបញ្ហានេះ ។ សូមអរគុណ ។

[១៤:៣៣:១៣]

**ប្រធានអង្គជំនុំ៖**

អរគុណ នូវការលើកឡើងនូវយោបល់ដ៏ល្អនេះ ។ ប៉ុន្តែ ការគិតជាបុគ្គលខ្ញុំ ខ្ញុំបានពិចារណាលើ

បញ្ហានេះ ខ្ញុំបានទទួលព័ត៌មាននេះជាប្រភពច្រើនដែរ ។ ប៉ុន្តែ ខ្ញុំបានថ្លឹងថ្លែងរវាងសិទ្ធិការពារខ្លួនរបស់ជនជាប់ចោទ មានច្បាប់ឯណាតម្រូវឲ្យថាសួរអី ឆ្លើយហ្នឹង។ វាអត់មានទេ ។ វាជាសិទ្ធិការពារខ្លួន ។ សួរថាគេឆ្លើយដោះសារថា មិនត្រូវនឹងសំណួររបស់ខ្ញុំ ។ មិនត្រូវ ឬមិនត្រូវមិនមែនអ្នកសម្រេចទេ អង្គជំនុំជម្រះទេសម្រេចថាជឿ ឬក៏មិនជឿ នូវការឆ្លើយដោះស្រាយនឹងសំណួរនេះ ។ នេះដែលជាបញ្ហាបច្ចេកទេសនៅក្នុងការសួរ។ ជាការពិតណាស់ ករណី គឺវាមានបញ្ហាដូចខ្ញុំបានលើកឡើងពីព្រឹកហើយ។ ការសង្កេតឃើញៗថា វាមានបញ្ហាជាច្រើនគឺគាត់ដោយសារ គាត់ជាអ្នកគ្រូគណិតវិទ្យា គាត់តែងតែការបកស្រាយដោយមានឧទាហរណ៍ មានការផ្ទុះបញ្ចាំង អាហ្នឹងបញ្ហា ។

តើយើងកំហិតទេ បើសិនជាការផ្ទុះបញ្ចាំងនេះឲ្យលេចច្បាស់លាស់នូវអ្វីដែលជាការដោះសាររបស់គាត់ គឺមានលក្ខណៈច្បាស់លាស់ កាន់តែច្បាស់លាស់ឡើងនោះ ។ បញ្ហាមួយទៀត គឺអាចមានបញ្ហាដែរ គឺដូចជាម្សិលមិញ យើងបានឃើញថាគាត់ឆ្លើយថា អត់ទេ អត់ដឹងទេ ប៉ុន្តែគាត់បានបញ្ជាក់ថាមូលហេតុនៃការមិនដឹងនេះ គឺដោយសារគាត់រវល់ទៅធ្វើទីនេះទីនោះអ៊ីចឹង ធ្វើការងារផ្សេងៗ ដែលមិនដឹង ឬក៏មិនបានស្តាប់វិទ្យុ ។ អាហ្នឹងក៏យើងត្រូវពិចារណាដែរ ថាបើចម្លើយរបៀបអ៊ីចឹង គឺយើងនឹងមិនឲ្យឆ្លើយទេ ។ តែបើសិនជាចម្លើយនៃការបង្ហាញហេតុផល ដើម្បីឆ្លើយនឹងសំណួរ នេះជាវិធីក្នុងការដោះសាររបស់ជនជាប់ចោទ ។ តើយើងសិទ្ធិនេះយើងកំហិតទេ? ហើយបើមានច្បាប់ឯណាកំហិត ខ្ញុំជាបច្ចេកទេស ធ្លាប់ធ្វើកិច្ចការហ្នឹង ដូចជាការយល់ដឹងរបស់ខ្ញុំដូចជាមិនដល់កំហិតថា តម្រូវថាសួរអីឆ្លើយហ្នឹងទេ ។ ភាសាសួរអីឆ្លើយហ្នឹង ដូចជាអាចប្រើប្រាស់បានទេនៅក្នុងតុលាការនេះ? អាចតុលាការផ្សេង ដូចជានៅតុលាការជាតិ ខ្ញុំធ្លាប់ស្តាប់ឮបញ្ហានេះ ដែលអន្តរជាតិគេកត់សម្គាល់ថា ជាតុលាការដែលអន់ថយ ។ អ៊ីចឹងគេនាំតុលាការគំរូមកនេះ ។ ដល់ពេលនាំគំរូមក ហើយយើងចង់ថា ឥឡូវសួរអីឆ្លើយហ្នឹង ។ មិនឲ្យផុតពីសំណួរដែលត្រូវសួរទេ តើវាអាចយកជាគំរូបានទេនូវបញ្ហានេះ? នេះជាបញ្ហាដែលយើងគិតគូរ ។

ខ្ញុំក៏បានទទួលព័ត៌មាននេះពីមជ្ឈដ្ឋានមួយចំនួនដែរ ប៉ុន្តែការគិតគូររបស់ខ្ញុំ គឺអ៊ីចឹង។ ប៉ុន្តែបញ្ហានេះខ្ញុំមិនអត្តនោម័តិទេ ខ្ញុំនឹងពិគ្រោះជាមួយនឹងអង្គជំនុំជម្រះដើម្បីធ្វើការបកស្រាយបញ្ហានេះ ថាតើយើងគួរតែកំហិតគាត់របៀបម៉េច? ការកំហិតគាត់ ការរិតត្បិតនូវការដោះសារ ដូចជាអាចមានបញ្ហានៅតាមការយល់ឃើញរបស់ខ្ញុំ ជាសិទ្ធិការពារខ្លួនរបស់ជនជាប់ចោទ អានេះជារឿង ។

[១៤:៣៦:០០]

អ៊ីចឹងបញ្ហាវាអាចផ្សំគ្នាដែរ ប្រសិនបើយើងសួរខ្លី សួរច្បាស់ ដូចជាគាត់ឆ្លើយច្បាស់ដែរ ។ ខ្ញុំសួរគាត់ច្រើនសំណួរដែរ ដូចជាមិនវែងផង ។ ទាំងសំណួរក៏ដូចជានិងទាំងចម្លើយដូចមិនវែងទេ ឬក៏ជាភាសាសាមញ្ញពេកមិនអាចនាំឲ្យអស់លោក លោកស្រីមិនយល់មិនដឹង ។ បើខ្ញុំសួរគាត់ដូចជាម្សិលមិញពីរសំណួរដូចជាចំណាយពេលវេលាតែប៉ុន្មានមីនុតប៉ុណ្ណោះ ។ ទាំងសំណួរទាំងឆ្លើយ ដូចជាមិនជាលំបាកទេចំពោះខ្ញុំជាភាសាខ្មែរ ប៉ុន្តែ ក្រែងលោបកប្រែភាសាបរទេសទៅ វាមានន័យស្រាលពេកអ៊ីចឹងអីមិនដឹងទេ ។ ខ្ញុំក៏ចេះមិនដល់ដែរ ចេះកម្រិតត្រឹមតែជាតិប៉ុណ្ណឹងទេ ។ អញ្ជើញ ។

**លោក ការ សាវុត្ថ៖**

សូមអរគុណលោកប្រធាន។ តើក្នុងការពិភាក្សាយើងនេះ ជនជាប់ចោទមានសិទ្ធិនឹងធ្វើសំណូមពរ និងឆ្លើយអ្វីបានទេទាន?

**ប្រធានអង្គជំនុំ៖**

បាន ។

**លោក ការ សាវុត្ថ៖**

បាទៗ ។ អ៊ីចឹងខ្ញុំសូមឲ្យជនជាប់ចោទធ្វើសំណូមពរទៅលោកប្រធាន ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោក កាំង ហ្គេកអ៊ាវ តើមានសំណូមពរអ្វីទៅ ដើម្បីធ្វើការចូលរួមនៅក្នុងកិច្ចប្រជុំនេះ?

[១៤:៣៧:១៩]

**ជនជាប់ចោទ៖**

លោកប្រធានជាទីគោរព! ខ្ញុំសូមអរគុណលោកប្រធាន ដែលអនុញ្ញាតឲ្យខ្ញុំមានមតិ ។ ទីមួយខ្ញុំសូមជូនអង្គសវនាការយើងទាំងមូល យល់អំពីអាកប្បកិរិយានយោបាយរបស់ខ្ញុំចំពោះសាក្សី ។ កន្លងរួចមកហើយ លោកប្រធាន ហើយនិងអង្គសវនាការទាំងមូលឃើញហើយ ។ សាក្សីដែលនាំមកនៅទីនេះមានបីនាក់ ។ សម័យម-១៣ សាក្សីទីមួយ ខ្ញុំប៉ាន់ប្រមាណខុស ។ តែចូលមកដល់ខ្ញុំសង្កេតតាំងពីក្បាលដល់ចុងជើង តាំងពីគាត់អញ្ជើញមកដល់ត្រង់នុ៎ង ។ ខ្ញុំថា អូ៎!ខុសហើយ ។ តែសង្កេតឃើញគាត់មានប្រសាសន៍មួយម៉ាត់ពីរ អ្ហែ! មនុស្សនេះមានទុក្ខ ។ ត្រូវតែទទួលស្គាល់ទុក្ខវេទនារបស់គាត់ជំនាន់នុ៎ង ។ សួរដេញដោយចុះឡើងបានដឹងថា អូ៎!ជាគាត់ហ្នឹងអ៊ីចឹង ។ នេះសាក្សីមួយ ទីមួយ គឺKW30 ។

ដល់សាក្សីទីពីរ ខ្ញុំដឹងដោយបានអានឯកសារយូរហើយ ជាសាក្សីក្លែងក្លាយទេ ។ ខ្ញុំនិយាយដោយត្រង់ជូនសវនាការទាំងមូលចុះ ។ ខ្ញុំចង់តែហៅសាក្សីត្អូកផង ។ ខ្ញុំ ដល់អ៊ីចឹងទៅ គ្នាឆ្លើយតាម ន៎ កំណត់ហេតុរបស់ចៅក្រមជំនុំជម្រះ ហ្នឹងត្រឹមត្រូវហើយ ។ ខ្ញុំក៏និយាយតាមនុ៎ងទាំងអស់គ្នា លោកចៅក្រមដែលលោកមានមតិដេញដោលសួរក៏អ៊ីចឹង ។ ដូច្នេះ សាក្សីទីពីរនេះ អង្គសវនាការឃើញហើយ អាកប្បកិរិយារបស់ខ្ញុំយ៉ាងម៉េច ។ ឯកចំណែកសាក្សីទីបី ជាកូនចៅចាស់របស់ខ្ញុំមែន ។ ខ្ញុំទទួលស្គាល់ភ្លាម ។

**អ្នកបកប្រែ៖**

*(មីក្រូហ្វូនរបស់-- អត់ឮ)*

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះ យើងជជែកគ្នាហ្នឹងអំពីរឿងមធ្យោបាយនៃការចូលរួមដើម្បីដំណើរការប្រព្រឹត្តទៅនៃអង្គសវនាការ ធ្វើយ៉ាងណាឲ្យបានឆាប់រហ័ស ។ ដែលបានដាក់របៀបវារៈរួចហើយ បើការចង់ចូលរួមមតិយោបល់ គឺចូលរួមក្នុងកម្រិតដែលនៅក្នុងរបៀបវារៈ បញ្ហានុ៎ងដូចជាចាកឆ្ងាយពីរបៀបវារៈនៃការប្រជុំ ។ ឥឡូវហ្នឹង បានបញ្ហាពាក់ព័ន្ធជាមួយនឹងខាងមេធាវីការក្ដីហ្នឹង ការពារជនជាប់ចោទហ្នឹង ការពារតំណាងដើមបណ្ដឹងរដ្ឋប្បវេណីហ្នឹង គឺគាត់មានការពាក់ព័ន្ធជាមួយនឹងជនជាប់ចោទរឿងការសួរនាំទៅលោកនិយាយពង្វាង ។ ពង្វាងទៅ ឬក៏ចម្លើយហ្នឹងវាវែង ការដែលអាចត្រូវឆ្លើយខ្លី ឆ្លើយចំបញ្ហា ឆ្លើយខ្លីហើយឆ្លើយវែងបញ្ហា ឬក៏គេហៅថាឆ្លើយពង្វាងជាច្រើនអ៊ីចឹង ថាវាលោកអាចតបបញ្ហាហ្នឹងយ៉ាងម៉េច? ជាសិទ្ធិ ឬក៏ជាទម្លាប់យ៉ាងម៉េច ឬក៏របៀបយ៉ាងម៉េច? អាហ្នឹងបញ្ហាដែលយើងអនុញ្ញាតឲ្យនៅក្នុងក្របខ័ណ្ឌនៃបញ្ហាប៉ុណ្ណឹង ។

[១៤:៤០:២០]

ក្នុងរបៀបវារៈដែលយើងដាក់ប៉ុនប៉ងនការជជែកនេះ នៃការចូលរួមនេះ។ ឧបមាថា ឥឡូវមេធាវីហ្នឹង គាត់ថាធ្វើសវនាការហ្នឹងវាច្រើនពេក ព្រោះគាត់ថា បើធ្វើតិចហ្នឹងគឺថា វាគិតដល់លោកដែលមានត្រូវការសម្រាក ត្រូវការអីច្រើនអ៊ីចឹង។ គាត់សំណូមពរព្រឹកមិញ គាត់និយាយរហូតដល់រីករាយ បើសិនជាសវនាការធ្វើតែក្នុងមួយខែតែពីរសប្ដាហ៍ឯណោះ ។ ដោយសារការស្ដាប់មានការភ័ន្តច្រឡំអ៊ីចឹង ។ ហើយដល់ពេលខាងមេធាវី អាឡាំង វ៉ែនណឺ គាត់ថា គាត់គួរតែធ្វើការសវនាការទាំងថ្ងៃបុណ្យ ហើយបើថ្ងៃសុក្រហ្នឹង បើថាបួនថ្ងៃកន្លះ បើមិនបានដល់៥ថ្ងៃ គឺបួនថ្ងៃកន្លះឯណោះ ។ អ៊ីចឹង តើវាពាក់ព័ន្ធ

យ៉ាងម៉េចទេលើបញ្ហា ដែលយើងបានជជែកពិភាក្សានេះ? កុំឲ្យយល់ជ្រៅទៅលើបញ្ហាផ្សេងក្រៅពីនេះ។

**ជនជាប់ចោទ៖**

អរគុណលោកប្រធាន ខ្ញុំសូមបន្តទៅទៀត ។ ទីមួយ អំពីបញ្ហាសាក្សី ។ សាក្សីខ្លះស្រួលៗជម្រាបការពិតជូនអង្គសវនាការ ។ ដូច្នេះ ឆាប់ រឿងអីក៏ដោយឆាប់ដែរ ប៉ុន្តែសាក្សីខ្លះមកចេញដូច KW31 អ្ហូ!យ៉ាប់ណាស់ យ៉ាប់យកឯកសារមកបដិសេធគាត់ ពិបាកនឹងរកឯកសារមកបដិសេធគាត់ ។ ដូច្នេះ វាទាមទារពេលវេលាដែរ ។ ទាមទារដឹងសាក្សីមុន ទាមទារដឹងឯកសារខ្លះមុន ។ នេះជារឿងពិតដែលខ្ញុំចង់និយាយ។ ដូចឯកសារដែលខាងព្រះរាជអាជ្ញាបង្ហាញខ្ញុំម្សិលមិញអំពីជនជាតិខ្មែរប៉ុន្មាននាក់នោះ ។ ឃើញភ្លាម ខ្ញុំស្គាល់អក្សរខ្ញុំភ្លាម ទទួលភ្លាមចប់ ។ នេះឯកសារមួយច្បាស់លាស់របស់ស-២១ ។

ឯកសារមួយទៀត 159/4.10 ខ្ញុំមិនដែលឃើញទេ ឯកសារពីមុនហ្នឹង ។ គ្រាន់តែក្រឡេកឃើញអក្សររបស់ខ្ញុំនៅហ្នឹងភ្លាម ខ្ញុំទទួលស្គាល់ភ្លាម ។ បញ្ហាហ្នឹងគឺស្អី?

ដូច្នេះ បញ្ហាបានឯកសារមកមុន បញ្ហាបានពិចារណា ជាការចាំបាច់ដើម្បីឲ្យចម្លើយហ្នឹងវាឆាប់ ។ ដូច្នេះ បើសាក្សីចេញមកចាក់ត្លុករបៀប KW31 ទេ ខ្ញុំរកកាត់ខ្ចីមិនកើតទេ ។ អាហ្នឹងទាមទារឲ្យវាវែងបន្តិច ។ នេះសូមជម្រាបបញ្ជាក់ដូច្នោះ សុំមេត្តាឲ្យបានដឹងឯកសារមុន ឲ្យបានអានហើយឲ្យបានរកឯកសារសម្រាប់ស្អីដែលត្រូវបដិសេធ ។ បដិសេធដោយឈរលើឯកសារ ។ ទទួលស្គាល់ដោយឈរលើឯកសារ គឺយកការពិតជាធំ ។ នេះការងាររបស់ខ្ញុំ ។

ដូច្នេះ សរុបមក ដោយត្រឹមត្រូវ ដោយ--

[១៤:៤២:៥០]

**លោកស្រី ស៊ីលឃីស្ទួត ហ្សីនស្គី៖**

លោកប្រធានខ្ញុំសូមជំទាស់នៅពេលនេះ ខ្ញុំបានឮថា គឺប្រើពាក្យសាក្សីត្លុកកំប្លែង ហើយខ្ញុំគិតថាជនជាប់ចោទមិនមានសិទ្ធិក្នុងការចាត់ទុកថាសាក្សីណាម្នាក់ជាសាក្សី *ក្លោន* ជាសាក្សីត្លុកកំប្លែងនោះទេ ។ ដូច្នេះ សូមឲ្យលោកប្រធានប្រាប់ទៅខាងជនជាប់ចោទហ្នឹង ឲ្យជ្រើសរើសពាក្យឲ្យបានសមគួរនៅពេលប្រើ នៅក្នុងបន្ទប់សវនាការនិយាយទាក់ទងទៅនឹងសក្សី ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកស្រីមេធាវី ។ ដូច្នេះ មែន ហើយជនជាប់ចោទអាចមានការ ពុះកញ្ជ្រោលនឹងការប្រើច្រើនលើកច្រើនសាដែរដែលមានមិនសមរម្យ ។ សូមឲ្យរៀបចំពាក្យណាដែលល្អៗ ដែលសមរម្យ

សម្រាប់សម្រើប្រាស់នៅក្នុងអង្គប្រជុំ កុំឲ្យមានការប៉ះពាល់លើកិត្តិយស លើអ្នកដទៃនៅក្នុងអង្គប្រជុំ អីណ៎ា ។

**ជនជាប់ចោទ៖**

ការដឹងខ្លួនមុន ដើម្បីរកឯកសារបដិសេធ ។ ស្អីដែលមិនមែន ព្រោះយើងឈរនៅលើមូលដ្ឋាននៃសេចក្ដីពិត ។ បើវាពិតឲ្យរកបានឯកសារ ខ្ញុំសម្រាប់ជូនតុលាការថា អាហ្នឹងវាពិតរបស់ស-២១ មែន ខ្ញុំក៏ទទួល រួចបើវាមិនពិត ក៏ខ្ញុំត្រូវតែរកឯកសារទប់ទល់ដែរ ។ ជម្រាបដែរ ថាអាហ្នឹងឈរលើឯកសារហ្នឹង រឿងហ្នឹងវាមិនពិតទេ ។ ដូច្នេះ សូមឲ្យបានដឹងមុន បើមិនឲ្យបានដឹងមុនទេ ពិបាករកឯកសារទប់ទល់ណាស់ រឿងខ្លះដែលប្រឌិតមក ។ ពិបាកមែនទែន យូរមែនទែន ។ ហើយរឿងហ្នឹង ជាអំពល់វរល់ដែលធុញទ្រាន់បំផុត ។ រឿងអីដែលពិត ជូនអីមួយភ្លែតទេ ។ ឧទាហរណ៍ដូចអី រឿងខ្មែរទៅបរទេសប៉ុន្មាននាក់ហ្នឹង ។

ដូច្នេះ សរុបមកទីមួយ ក្នុងកិច្ចដំណើរការសវនាការឲ្យបានលឿន ខ្ញុំឃើញសុំឲ្យមានការជួយជ្រោមជ្រែងទាំងអស់គ្នា ជាពិសេសពីខាងអយ្យការ មេត្តាផ្ដល់ឯកសារឲ្យខ្ញុំឲ្យបានគ្រប់គ្រាន់ អ្វីដែលចង់សួរ អ្វីដែលឲ្យខ្ញុំបំភ្លឺសូមមេត្តាផ្ដល់ឯកសារមកឲ្យបានគ្រប់គ្រាន់ ។ ជូនអីវាប្រថុចញ៉ុច ដូចថ្ងៃណោះប៉ុន្តែក្រឡេកទៅឃើញអក្សរខ្លួនឯងភ្លឹប ទទួលស្គាល់ភ្លាម ។ អារឿងហ្នឹងអ៊ីចឹង អត់ប្រកែកទេ ។ ដូច្នេះសូមឲ្យយល់អំពីបញ្ហាថា យើងទាំងអស់គ្នារកសេចក្ដីពិត ។ តើឧក្រិដ្ឋកម្មធំនាន់ហ្នឹងខ្ញុំបានធ្វើវាពិតកម្រិតណា? ខ្ញុំទទួល ។

[១៤:៤៥:២៣]

ដូច្នេះ សំណូមពរទីមួយ ដើម្បីពន្លឿនយុត្តិវិធីយើង គឺធ្វើម៉េចឲ្យខ្ញុំមានឯកសារ ហើយពេលវេលាឲ្យបានគ្រប់គ្រាន់ អានឯកសារ ពិចារណាឯកសារ ។ ទាំងអស់គ្នាឈរលើសេចក្ដីពិត ។ ឧទាហរណ៍ដូចរឿងកុនម្សិលមិញអ៊ីចឹង លោកព្រះរាជអាជ្ញាបង្ហាញ ។ មុនដំបូង ខ្ញុំថា ហ៊ី ចាប់អារម្មណ៍ដូចការ៉ូត្សដ្ឋយ៉ាងម៉េច? ហើយខាងក្រោយម៉េច? ដល់ទៅឮសំឡេង ខ្ញុំថា អ៊ូ!មិនមែនទេ ។

ដូច្នេះវាឆ្លើយភ្លាមៗអ៊ីចឹង ។ ស្អីក៏ដោយឲ្យតែសួរច្បាស់ ខ្ញុំឆ្លើយច្បាស់ ។ ស្អីក៏ដោយឲ្យតែមានឯកសារមកមុនច្បាស់លាស់ ខ្ញុំឆ្លើយច្បាស់លាស់ ។ នេះអត់ប្រកែកទេ ក៏ប៉ុន្តែ រឿងអីខ្លះវាកប់កិនរឿងនយោបាយ ។ ដូច ស្រីណា សុំទោសខ្ញុំមិនឆ្លើយតបនឹងនាងទេណ៎ា ។ ប៉ុន្តែ ដូចជាមានសួរខ្ញុំថ្ងៃណោះថាមនុស្សពីរនាក់ឈ្លោះគ្នា ម្ដេចក៏ទៅចម្បាំងជាមួយប្រទេស ទាល់ពន្យល់ប្រវត្តិសាស្ត្រវែងបន្តិច

សុំទោសណ៎ា ខ្ញុំអត់តបតអីទេ ។

សំណួរមិត្ត អ៊ូ!សំណួរនាងក៏ត្រូវការឲ្យខ្ញុំឆ្លើយវែង សូមទោសណ៎ា ។ ដូច្នេះសុំទោស សរុបមកវិញ ខ្ញុំសុំធ្វើម៉េចជួយខ្ញុំឲ្យបាននេះ ។ ហើយចំពោះពេលវេលា ខ្ញុំទុកជូនអង្គជំនុំជម្រះលោកពិចារណាចុះប៉ុន្មានថ្ងៃយ៉ាងម៉េច ស្អីយ៉ាងម៉េច ខ្ញុំដាក់ខ្លួនជូន ក៏ប៉ុន្តែគ្រាន់តែថា កាលណាសុខភាពខ្ញុំវត់ទៅមិនរួច អាហ្នឹងគឺគ្រាន់សុំអង្វរក្រោយ អាហ្នឹងសុំជម្រាបអ៊ីចឹង ។ ដូច្នេះ សុំចប់ ។

**ប្រធានអង្គជំនុំ៖**

អរគុណលោក កាំង ហ្គេកអ៊ាវ ដែលបានលើកឡើងពីបញ្ហានេះ ហើយសហព្រះរាជអាជ្ញាដូចជាខ្ញុំគិតទៅឃើញថាគាត់ក៏បានយល់អំពីបញ្ហានេះដែរ ដោយសារបទពិសោធន៍កន្លងមកនេះ គឺមានការមិនដឹងជាមុនមែន ។ ហើយមានបញ្ហាភ្លាមៗដែលនាំឲ្យមានបញ្ហាលំបាកដែរក្នុងនីតិវិធី ។

អញ្ជើញលោកមេធាវីការពារក្តី ។

[១៤:៤៧:៣៣]

**លោក ហ្វ្រង់ស្វ័រ រូ៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំនឹងមិននិយាយអ្វីឲ្យលើសពីអ្វីដែលខាងសហព្រះរាជអាជ្ញា និងមេធាវីដើមបណ្តឹងរដ្ឋប្បវេណីបាននិយាយនោះទេ ។ អ៊ីចឹង បើសិនជាយើងគិតពីម៉ោងដែលខាងសហព្រះរាជអាជ្ញាហើយនិងមេធាវីដើមបណ្តឹងរដ្ឋប្បវេណីនិយាយនោះ គឺប្រហែលជាមួយម៉ោងកន្លះហើយ។ ហើយដកម៉ោងដែលលោក ការ សាវុត្ថ និយាយហ្នឹង អ៊ីចឹងមានន័យថា ខ្ញុំអាចមានពេលប្រហែលជាមួយម៉ោងដើម្បីនិយាយឯណោះ ប៉ុន្តែ ខ្ញុំចង់ប្រាប់ទៅលោក លោកស្រីចៅក្រមថា ខ្ញុំនឹងមិនស៊ីពេលដល់មួយម៉ោងនោះទេ ។ ខ្ញុំមានការកត់សម្គាល់មួយចំនួនដែលខ្ញុំត្រូវធ្វើ ជាពិសេសខ្ញុំក៏មានសំណើមួយចំនួនផងដែរ ។

ដំបូងខ្ញុំចង់និយាយថា សម្រាប់ការជំនុំជម្រះមួយដែលបន្តទៅមុខនោះ គឺថានឹងអាចត្រូវរាំងស្ទះនូវចំណុចណាមួយ ហើយបើជាសិនដូច្នេះមែននោះ គឺជាសញ្ញាមួយដ៏អាក្រក់ ជាចំណុចមួយដ៏អាក្រក់សម្រាប់ប្រជាជនកម្ពុជា និងសម្រាប់សហគមន៍អន្តរជាតិទាំងមូល ។ ហើយដូចជាលោក លោកស្រីចៅក្រមបានដឹងហើយ នៅក្រៅប្រទេសកម្ពុជានេះ សវនាការនេះក៏កំពុងតែត្រូវបានតាមដានដោយសហគមន៍អន្តរជាតិផងដែរ ។ ជាពិសេស គឺតាមរយៈមេធាវី ហើយនិងគណៈវិនិច្ឆ័យផ្សេងៗទៀតនៅតុលាការព្រហ្មទណ្ឌអន្តរជាតិ ហើយពួកគេតាមដានយ៉ាងយកចិត្តទុកដាក់ទៅលើដំណើរការរបស់សវ-

នាការនេះ ។ ទៅលើរបៀបដែលអង្គសវនាការយើងធ្វើការគ្រប់គ្រង និងធ្វើការវិនិច្ឆ័យក្តីទៅលើជនជាប់ចោទទីមួយ នៅក្នុងអំឡុងសមរម្យណាមួយនោះ ។

អ្វីដែលខ្ញុំលើកឡើងនេះ គ្រាន់ជាការរំឭកដល់លោក លោកស្រីចៅក្រមថា គឺថាយើងមិននៅឯកកោតែឯងទេ យើងមិនមែនមានតែឯងទេនៅលើពិភពលោកយើងនេះ ។ យើងគឺជាតុលាការមួយនៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិជាច្រើនទៀត ដែលកំពុងតែដំណើរការ ។

ហើយគ្រប់ៗរូប បុគ្គលគ្រប់ៗរូប ដែលមានវត្តមាន គឺយើងព្យាយាមស្វែងរកនូវសេចក្តីសន្និដ្ឋានមួយ ដើម្បីឲ្យកិច្ចការស្វែងរកយុត្តិធម៌នេះបន្តដំណើរទៅមុខបាន ។ ដូចដែលខ្ញុំនិយាយអ៊ីចឹង គឺដើម្បីយុត្តិធម៌ ទាក់ទងទៅនឹងព្រហ្មទណ្ឌអន្តរជាតិ ទាក់ទងទៅនឹងយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិនុ៎ង គឺកាតព្វ-កិច្ចក្នុងការទទួលបាននូវជោគជ័យ និងទទួលបាននូវសេចក្តីសន្និដ្ឋានបញ្ចប់នៃសវនាការនោះ ។ ហើយខ្ញុំក៏សូមរំឭកផងដែរថា បើសិនជាសវនាការនេះចេះតែអូសបន្លាយពេលទៀតនោះ គឺយើងនឹងអាចប្រឈមមុខនឹងបញ្ហាបន្ថែមទៀត ទាក់ទងទៅនឹងការឃុំខ្លួនបណ្តោះអាសន្នរបស់ជនជាប់ចោទ ។

[១៤:៥១:១១]

ខ្ញុំក៏សូមរំឭកដល់លោកស្រីចៅក្រមផងដែរ យើងបានស្នើទៅអង្គជំនុំជម្រះ បានស្នើឲ្យធ្វើការដោះលែងគាត់ឲ្យនៅក្រៅឃុំប៉ុន្តែមិនទាន់បានទទួលចម្លើយនៅឡើយទេ ។ ហើយឥឡូវនេះ គឺយើងបានឆ្លងហួសរយៈពេលដប់ឆ្នាំៗនៃការឃុំខ្លួនបណ្តោះអាសន្នរបស់គាត់ទៅហើយ ។ ហើយថ្ងៃនេះ អង្គសវ-នាការនេះជាបច្ច័យអាក្រក់នោះ ក៏ជាការចូលរួមនៅក្នុងការពន្យារបន្ថែមទៀត លើការឃុំខ្លួនបណ្តោះអាសន្នរបស់គាត់ ។ ដូច្នេះ យើងមិនគួរបំភ្លេចនៅចំណុចនេះទេ ។

ហើយមុននឹងយើងខ្ញុំបង្ហាញនូវសំណើមួយចំនួននោះ ខ្ញុំចង់បង្ហាញនូវការអង្កេតមួយផ្សេងទៀត គឺខ្ញុំក៏បានឯកភាពទៅលើចំណុចដែលបានលើកឡើងដោយលោកអាឡាំង វ៉ែនណឺ ដែរ ។ ហើយជាការពិតណាស់គាត់ និយាយបានត្រឹមត្រូវនៅពេលដែលគាត់និយាយថា គឺថា យើងទាំងអស់គ្នាហ្នឹងបានទទួលព័ត៌មានថា យើងនឹងចូលរួមនៅក្នុងសវនាការៗមួយដែលស៊ីពេលយ៉ាងច្រើនបីខែតែប៉ុណ្ណោះ ។ ដូច្នេះហើយគឺយើងបានរៀបចំខ្លួនយើង សម្រាប់ការគិតបែបនោះ ។ ហើយពួកយើងមួយចំនួនបានរៀបចំពេលវេលាដូច្នោះ ពីព្រោះយើងបានទទួលបានការធានាថា បន្ទាប់ពីការស៊ើបអង្កេតរយៈពេលជាងមួយឆ្នាំមកហើយនោះ គឺមិនមានការចាំបាច់ក្នុងការធ្វើការជំនុំជម្រះលើសពីបីខែនោះទេ ។ ហើយដោយសារឥឡូវនេះ យើងកំពុងតែប្រជុំមានលក្ខណៈអសាធារណៈ ហើយលោក អាឡាំង វ៉ែនណឺ ក៏បានលើកឡើង

នូវចំណុច គឺថាដាក់មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីកំពុងតែប្រឈមមុខនោះ ។ ហើយខ្ញុំអាចគាំទ្រយ៉ាងពេញលេញទៅលើសំណើ ដែលបានគាត់លើកឡើងទាក់ទង សំណើដែលគាត់បានធ្វើទៅខាងការិយាល័យរដ្ឋបាល។ ខ្ញុំយល់ថា គឺវាមិនមានភាពប្រក្រតីទាំងអស់ ដែលភាគីមួយចំនួនទទួលបានប្រាក់បៀវត្សរ៍សម្រាប់ការងាររបស់ពួកគាត់ ហើយភាគីមួយចំនួនទៀត គឺថាគាត់ធ្វើការដោយស្ម័គ្រចិត្ត។ នេះជាភាពអប្រក្រតីមួយដែលមិនអាចទទួលយកបាន ។

[១៤:៥៣:៤៥]

ហើយថាឥឡូវនេះ យើង ការប្រជុំរបស់យើងមានលក្ខណៈជាអសាធារណៈ ។ ខ្ញុំក៏សូមបង្ហាញអំពីស្ថានភាពផ្ទាល់ខ្លួនរបស់ខ្ញុំដែរ ។ កាលពីខែកក្កដា ឆ្នាំទៅ ខ្ញុំត្រូវបានកោះហៅ ដើម្បីឱ្យធ្វើការនៅខាងផ្នែកការពារក្ដីនៅក្នុងតុលាការឡេបាណុន កាលពីឆ្នាំទៅ ហើយដែលសវនាការនឹងចាប់ផ្ដើមនៅខែតុលា ហើយនិងដែលត្រូវបញ្ចប់នៅខែមករា ។ ហើយដែលឈរលើមូលដ្ឋានហ្នឹងហើយ ខ្ញុំបានទទួលនូវការស្នើឡើងនោះ ។ ដោយយល់ទៅលើពេលវេលាដូច្នេះ ខ្ញុំក៏សង្ឃឹមថា ខ្ញុំមិននឹងដាក់មកធ្វើការនៅក្នុងតុលាការនេះ ហើយដែលអាចបញ្ចប់បាននៅក្នុងរយៈពេលដែលបានកំណត់នោះ ។ ក៏ប៉ុន្តែ ឥឡូវនេះគឺពេលវេលាចេះតែអូសបន្លាយ ។ ដូច្នេះ ខ្ញុំត្រូវតែព្យាយាមរៀបចំកិច្ចការនៅទីនេះផង ហើយនិងរៀបចំកិច្ចការសម្រាប់សវនាការនៅប្រទេសលីបង់ផង ។ ដូច្នេះ ឥឡូវនេះខ្ញុំនឹងសូមលើកឡើងនូវសំណើជាក់ស្ដែងមួយចំនួន ។ សំណើជាក់ស្ដែងច្បាស់លាស់ដែលខ្ញុំចង់លើកឡើងរួមគ្នានេះគឺ សូម្បីតែជនជាប់ចោទក៏បានលើកឡើងផង ។ នៅពេលដែលគាត់និយាយថា គាត់ចង់បាន ចង់ដឹងឯកសារ ដែលខាងសហព្រះរាជអាជ្ញា នឹងប្រើប្រាស់ឯកសារអ្វីនោះ នៅក្នុងអំឡុងពេលដែលគាត់នឹងលើកឡើងនោះ ។ ហើយចង់ដឹងថា តើក្នុងអំឡុងពេលស៊ើបអង្កេតនោះ ខាងសហព្រះរាជអាជ្ញានោះ ធ្វើអ្វីខ្លះ? កិច្ចការអ្វីខ្លះ? ហើយតើមានឯកសារអ្វីខ្លះដើម្បីត្រូវបង្ហាញដល់ជនជាប់ចោទ? បើសិនជាមានឯកសារបង្ហាញដល់គាត់ គឺគាត់នឹងមានឱកាស ដើម្បីសិក្សាទៅលើឯកសារអស់ទាំងនុ៎ង ហើយនឹងអាចផ្ដល់ចម្លើយអាស្រ័យទៅលើឯកសារអស់ទាំងនោះ ហើយនឹងអាចធ្វើដូច្នេះបានដោយមានវត្តមានរបស់ខាងសហព្រះរាជអាជ្ញា ។

ហើយខ្ញុំជឿថា ដំណោះស្រាយទីមួយ ដើម្បីឱ្យសវនាការនេះបន្តទៅមុខនោះ គឺវិលត្រឡប់ទៅរកអ្វីដែលបាននិយាយ និងបានធ្វើនៅក្នុងអំឡុងពេលនៃការស៊ើបអង្កេត ។ ហើយប្រសិនបើយើងផ្ដោតអារម្មណ៍តែទៅលើភស្តុតាង ដែលត្រូវបានឮ បានស្ដាប់នៅក្នុងអំឡុងពេលស៊ើបអង្កេតនោះ គឺយើងនឹង

អាចចំណេញពេលវេលាបានច្រើន ។ ហើយអត្ថប្រយោជន៍ដែលយើងទទួលបានពីការស៊ើបអង្កេតនោះ និងពីខាងសហចៅក្រមស៊ើបអង្កេតទាំងពីរនាក់នោះ ដែលពួកគាត់បានពិនិត្យមើលទៅលើជ្រុងជ្រោយទៅលើធាតុផ្សំនានា ទៅលើសេចក្តីថ្លែងការណ៍នានា និងទៅលើការពិភាក្សាដេញដោលជាមួយនឹងសាក្សី និងការប្រព្រឹត្តិ ការធ្វើឡើងវិញនៅទួលស្លែងជាដើម ។ ហើយពួកគេបានធ្វើកិច្ចការអស់ទាំងនុ៎ងហើយ នៅចុងបញ្ចប់នៃកិច្ចដំណើរការស៊ើបអង្កេត គេបានបញ្ចេញនូវឯកសារមួយដែលយើងបានដឹងគ្រប់គ្នាហើយ ។ ហើយឯកសារនោះ គឺមានឈ្មោះថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលត្រូវបានដាក់បង្ហាញនៅចំពោះមុខអង្គសវនាការនេះ ។ ហើយនុ៎ងឯង គឺជាឯកសារខ្លឹមនៃអ្វីៗទាំងអស់ ដែលត្រូវគេបានធ្វើនៅក្នុងអំឡុងពេលនៃការស៊ើបអង្កេតជាងមួយឆ្នាំនោះ ។ សម្រាប់យើងខ្ញុំវិញខ្ញុំយល់ថា គឺមានភស្តុតាងគ្រប់គ្រាន់ហើយនៅក្នុងសំណុំរឿង ដើម្បីបញ្ជូន ឌុច មកជំនុំជម្រះនៅចំពោះមុខអង្គជំនុំជម្រះនេះ ។ អ៊ីចឹង ហេតុអ្វីបានជាយើងមិនធ្វើតាមវិធីហ្នឹង ពីព្រោះគឺថា លោក លោកស្រីចៅក្រម មានឱកាសដើម្បីសិក្សាសំណុំរឿងហ្នឹងហើយ ។

បើសិនជាយើងធ្វើដូច្នេះមែន មានន័យថា យើងនឹងអាចចំណេញពេលវេលាបានលឿនៗជាងនេះពីរឬក៏បីដង ។ ហើយហេតុអ្វីបានជាអាចលឿនបានជាងពីរឬក៏បីដងនោះ? ជាឧទាហរណ៍តែមួយគត់ក៏បានដែរ ។ ខ្ញុំនឹងបង្ហាញជូន ។ លោក គ្រេក អេតឆេសាន់ នៅពេលដែលគាត់មកផ្តល់សក្ខីកម្មហើយនៅពេលដែលយើងនិយាយអំពីសំបុត្រ ដែល ស៊ូ ម៉េត បានបញ្ជូនមក ហើយដែលមានបញ្ចូលនៅក្នុងសំណុំរឿងរួចហើយនោះ គឺខាងសហព្រះរាជអាជ្ញាបានលើកឡើងឲ្យធ្វើការពិភាក្សាគ្នាដេញដោលទៅលើសំបុត្រទាំងប្រាំបួននោះ ទៅលើអ្នកជំនាញរបស់គាត់ ។ ហើយខ្ញុំសុំនិយាយម្តងទៀត គឺថាអ្នកជំនាញនោះ គឺជាសហសេវិករបស់គាត់ ។ ហើយដែលសហសេវិកហ្នឹងឯង ជ្រើសរើសយកលិខិតតែបីមកតែប៉ុណ្ណោះ ។ ហើយគាត់យល់ថា នេះជាចំណុចគ្រប់គ្រាន់ហើយដើម្បីបង្ហាញអំពីចំណុចដែលគាត់ចង់បង្ហាញ ។ នេះគឺជាអ្វីដែលខាងចៅក្រមស៊ើបអង្កេតបានធ្វើនៅដំណាក់កាលដំបូងនៃសំណុំរឿង គឺក្នុងចំណោមឯកសារមួយម៉ឺនប្រាំមួយពាន់ឯកសារនុ៎ង គឺថាសហចៅក្រមស៊ើបអង្កេតមិនត្រូវការឯកសារទាំងអស់នោះទេ គឺយើងត្រូវការដាក់ឯកសារណាដែលសំខាន់ៗដូចដែលលោក គ្រេក អេតឆេសាន់ បានលើកឡើង ស្នើឡើងដូច្នោះ ។ ហើយនៅក្នុងសំណុំរឿងនេះ គឺយើងមើលឃើញច្បាស់ហើយ លោក គ្រេក អេតឆេសាន់ បានលើកឡើងនូវចំនួនឯកសារដែលយល់ថាជាឯកសារសំខាន់តែប៉ុណ្ណោះ ។ មានន័យថា គាត់បោះបង់ចោលនូវឯកសារពីរភាគបីចោលទៅហើយ មានន័យថាពីរភាគបីនោះ គឺជា

ឯកសារដែលមិនចាំបាច់ ។ ហើយការបោះបង់ចោលឯកសារពីរភាគបីបែបនេះ គឺមានន័យថា ជាការបោះបង់ចោលនូវពេលវេលា ដែលយើងត្រូវចំណាយទៅលើភស្តុតាងទាំងនោះ ។

[១៥:00:0៥]

ឥឡូវនេះ យើងពិនិត្យមើលនៅក្នុងដីកាបញ្ជូនរឿងមកជំនុំជម្រះ ដូចដែលសហព្រះរាជអាជ្ញាបានដឹងហើយថា វាមានការងារពិសេសក្នុងការពិនិត្យមើលដកចេញពីដីកាហ្នឹង មួយកថាខណ្ឌម្តងៗ គឺថាត្រូវចំណាយពេលបីខែ ក្នុងការធ្វើការជាមួយជនជាប់ចោទ ។ ហើយពិនិត្យកថាខណ្ឌនីមួយៗ ហើយជនជាប់ចោទឆ្លើយថា គាត់ព្រម ។ លោកដឹងហើយថា ហើយខ្ញុំតែងតែនឹកឃើញដែរថា ហើយរំឭកដោយការិយាល័យសហព្រះរាជអាជ្ញា ហើយខ្ញុំក៏នៅចាំដែរថា នៅទីនេះយើងស្ថិតនៅក្នុងនីតិវិធីរបស់ប្រព័ន្ធច្បាប់ស៊ីវិលឡូ ប៉ុន្តែ ប្រសិនបើយើងដំណើរការទៅតាមប្រព័ន្ធខំមិនឡូវិញនោះ ការជំនុំជម្រះនេះ គឺថា អាចនឹងចំណាយពេលតែប្រាំបីថ្ងៃ តែប្រាំបីថ្ងៃទេ ។ ដូចដែលខ្ញុំស្នើជូនទៅអង្គជំនុំជម្រះនោះ ដោយប្រើយុត្តិសាស្ត្ររបស់សាលាក្តីអន្តរជាតិ ដែលមានលក្ខណៈវិនិច្ឆ័យបី ថាតើវាមានការសារភាពពីពិរុទ្ធភាពដែលស្នើដោយ ស្ម័គ្រចិត្តដោយសេរីដែរឬទេ? ទីពីរ ថាតើត្រូវបានផ្តល់ឡើងក្នុងរបៀបមួយដែលមានព័ត៌មានគ្រប់គ្រាន់? ហើយលក្ខខណ្ឌទីបី ថាតើគ្មានលក្ខខណ្ឌដែរឬទេ? នៅក្នុងនោះ ហើយបើអង្គជំនុំជម្រះបានពិនិត្យមើលលក្ខណៈវិនិច្ឆ័យក្នុងចំណោមទាំងបីនេះ ហើយយើងអាចនឹងពិនិត្យថា ការសារភាពទទួលពិរុទ្ធភាពហ្នឹង គឺថាអាចនឹងប្រើពេលតែមួយថ្ងៃ ឬពីរថ្ងៃ ដើម្បីធ្វើការពីការដាក់ទោស ការកាត់ទោសនោះ ។ ហើយអាចទាក់ទងនឹងពិនិត្យមើលពីបុគ្គលិកលក្ខណៈរបស់បុគ្គល ហើយនិងពិនិត្យមើលកត្តាដោះបន្ទុកមួយចំនួន ។ អ៊ីចឹងហើយខ្ញុំគិតថា អាចមាននូវការអត្ថប្រយោជន៍ខុសពីប្រព័ន្ធនៅក្នុងខំមិនឡូ និងស៊ីវិលឡូ នៅក្នុងន័យនេះ ។

[១៥:0២:១៦]

ចំណុចមួយទៀតដែលយើងអាចពិនិត្យមើលថា អ្វីជាការគាំទ្រទៅប្រព័ន្ធខំមិនឡូនោះ ហើយលោកសហព្រះរាជអាជ្ញា ស្មីត នោះគឺថាបានរំឭកយើងហើយថ្ងៃនេះថា នៅក្នុងយុត្តាធិការព្រហ្មទណ្ឌអន្តរជាតិដែលថា មានអានុភាពច្រើនទៅខាងប្រព័ន្ធខំមិនឡូនោះ គឺថាខ្ញុំជូនជាឧទាហរណ៍អំពីរឿងក្តីដែលខ្ញុំបានពាក់ព័ន្ធក្នុងពេលថ្មីៗនេះ គឺថា បីសប្តាហ៍សម្រាប់ការពិនិត្យឯកសារភស្តុតាងរបស់សហព្រះរាជអាជ្ញា ពិនិត្យមើលបង្អង់មួយខែ ហើយអ៊ីចឹងហើយ រយៈពេលបីខែទៀតសម្រាប់មេធាវីការពារ ។ អ៊ីចឹងហើយពីដំបូងនេះ យើងពីដំបូង បើប្រព័ន្ធខាំមិនច្បាប់នៅក្នុងការជំនុំជម្រះក្នុងអន្តរជាតិហ្នឹង គឺប្រើ

ពេលវែង ហើយក៏អាចត្រូវដែរដែលយើងនិយាយថា បច្ចុប្បន្ននេះ គឺគេបានពន្លឿននីតិវិធីនេះយ៉ាងឆាប់។ តើយើងឥឡូវនេះ នៅក្នុងដំណើរការក្នុងការបង្ហាញឲ្យគេឃើញថាជាប្រព័ន្ធជំនុំជម្រះបែបស៊ីវិលឡច្រើនជាងឬទំនើបជាងប្រព័ន្ធខំមិនឡ ឬយ៉ាងម៉េច? ដូច្នេះ គឺគេអាចនឹងគំនិតផ្ទុយទៅនឹងបញ្ញាញ្ញាណមួយចំនួននៅក្នុងអន្តរជាតិ។ ដូច្នេះ ថាតើយើងអង្គជំនុំជម្រះយើងអាចនឹងសម្រេចភ្លាមៗក្នុងការទទួលស្គាល់នូវអង្គហេតុដែលថា អាចឲ្យយើងសន្សំពេលសប្តាហ៍ប៉ុណ្ណោះទេ គឺថាអាចនឹងបានដល់សន្សំដល់ខែទៀតផងនៅក្នុងដំណើរការនីតិវិធី ។ អ៊ីចឹង ខ្ញុំសុំរំឭកលោកចៅក្រមថា យើងមិនចាំបាច់រង់ចាំក្នុងការអនុម័តវិសោធនកម្មថ្មីនោះទេ គឺថាយើងមានយុត្តាធិការពេញលេញ ហើយក្នុងពេលណាមួយក៏ដោយលោកចៅក្រមមានសិទ្ធិដើម្បីធ្វើសេចក្តីសម្រេចផ្ទាល់ខ្លួន ។ ខ្ញុំសូមអនុញ្ញាតជូនជាឧទាហរណ៍មួយ ដកចេញអំពីតុលាការព្រហ្មទណ្ឌអន្តរជាតិប្រទេសរ្វ៉ាន់ដា ដែលខ្ញុំបានធ្វើការជាមួយមេធាវី ហើឡ្វញ៉ាក់ ហើយយើងបានទៅកាន់ប្រទេសរ្វ៉ាន់ដា ហើយយើងបានទទួលនូវសេចក្តីថ្លែងការណ៍លាយលក្ខណ៍អក្សរដោយសាក្សីនៅក្នុងប្រព័ន្ធមួយដែលថា យើងត្រូវធ្វើការស៊ើបអង្កេតដោយខ្លួនឯង ។

[១៥:០៤:៤៦]

យើងបានទទួលកំណត់ហេតុសួរចម្លើយពីសាក្សីមួយ ដែលយើងមិនចង់ទៅ *វូសា* ដោយសារមានហេតុផលសន្តិសុខនោះ ។ ហើយនៅក្នុងវិធានរបស់តុលាការ *អាយស៊ីធីអ័រ* នោះបាននិយាយថា ធ្វើឲ្យយើងប្រើសេចក្តីថ្លែងការណ៍លាយលក្ខណ៍អក្សររបស់សាក្សី អាចទទួលប្រើជាភស្តុតាងបាន ។ ប៉ុន្តែ អង្គជំនុំជម្រះនោះ គឺបានធ្វើសេចក្តីសម្រេចដោយខ្លួនឯង ហើយបានសម្រេចថា ដោយអង្គហេតុបង្ហាញឲ្យឃើញថា សេចក្តីថ្លែងការណ៍របស់សាក្សីនេះ មិនត្រូវបានធ្វើឡើងៗតាមនីតិវិធីរបៀបធម្មតាទេ ហើយគឺជារដ្ឋភាគីមួយ នេះតាមច្បាប់របស់បារាំង ។ ហើយសាលាក្តីនោះនិយាយថា ហើយឯកសារនេះ អាចទទួលយកបាន ហើយសាលាក្តីអាចទទួលយកបានជាភស្តុតាងទោះបីជាវិធានផ្ទៃក្នុងមិនចែងថា ឲ្យធ្វើដូច្នោះក៏ដោយ ។ ក៏ប៉ុន្តែ ផ្អែកទៅលើយុត្តិសាស្ត្របែបនេះ គឺថាកិច្ចប្រជុំពេញអង្គបញ្ជាក់សុពលភាពនូវនីតិវិធីនេះ ។ ហើយបានធ្វើវិសោធនកម្មទៅលើវិធានហ្នឹង ប៉ុន្តែ គឺចៅក្រមទេ ដែលជាអ្នកធ្វើសេចក្តីសម្រេចពីដំបូង ។ តាមសេចក្តីសម្រេចនោះគឺថា ឯកសារនោះ ផ្អែកលើកាលៈទេសៈនោះគឺថាអាចទទួលយកបាន ។

ខ្ញុំអាចជូនជាឧទាហរណ៍មួយទៀត ជាការពន្យល់មួយទៀត នេះគឺថាវាស្របទៅនឹងអំពីការតស៊ូមតិមួយដែលខ្ញុំហៅថា ភាពចាំបាច់វាមិនទាក់ទងអ្វីទៅនឹងរឿងក្តីរបស់យើង ខ្ញុំគ្រាន់តែបំភ្លឺ នៅពេល

ដែលខ្ញុំនិយាយអំពីស្ថានភាពនៃការចាប់បាច់នៅក្នុងយុត្តាធិការមួយ ខ្ញុំនៅចាំថានៅក្នុងច្បាប់បារាំងចំណុចនេះ សញ្ញាណនេះមិនកើតមានទេ គឺចៅក្រមនៅក្នុងយុត្តាធិការនោះជាអ្នកបង្កើតនូវគំនិតហ្នឹងឡើង ។ ហើយក្រោយមកក្លាយទៅជាច្បាប់។ គំនិតនេះ ត្រូវបានយកមកប្រើបញ្ចូលទៅក្នុងក្រមព្រហ្មទណ្ឌដោយនីតិបញ្ញត្តិ ។ អ៊ីចឹង គឺថាមិនមែនជាកត្តាចង្អុលបង្ហាញឲ្យរង់ចាំកិច្ចប្រជុំពេញអង្គនៅក្នុងខែកញ្ញា ឬធ្នូ ដើម្បីសម្រេចលើអង្គហេតុក្នុងរឿងនេះទេ ។

ដូច្នេះ មានវិធីសាស្ត្រពីរយ៉ាង ដើម្បីជាដំណោះស្រាយទៅលើអ្វីជាបញ្ហាដែលយើងមាន គឺថា មាត្រា៣៣ នៃកិច្ចព្រមព្រៀងបានចែងថា ដោយលោក ស្មឹត បានលើកឡើងពីព្រឹកមិញនោះ ក្នុងករណីដែលមិនមានចែងនៅក្នុងច្បាប់កម្ពុជា អង្គជំនុំជម្រះអាចយោងទៅរកច្បាប់អន្តរជាតិ ប្រសិនបើភស្តុតាងបង្ហាញថា បើច្បាប់កម្ពុជាបែបនោះ មិនមានចែងអំពីការសារភាព ពិរុទ្ធភាពទេ យើងត្រូវពិនិត្យមើលច្បាប់អន្តរជាតិ ។ ហើយយើងស្នើថា ពិនិត្យមើលវិធាន៦៩ នៃតុលាការព្រហ្មទណ្ឌអន្តរជាតិ ។ កិច្ចព្រមព្រៀង ជាកិច្ចព្រមព្រៀងច្រើន ដែលទាក់ទងទៅនឹងភស្តុតាងហ្នឹង សហព្រះរាជអាជ្ញា និងមេធាវីការពារអាចឯកភាពគ្នាថា អង្គហេតុដែលប្រើនៅក្នុងដីកាបញ្ជូនរឿងឲ្យជម្រះនោះ ។ ហើយខ្លឹមសារនៃឯកសារនោះ មានក្បៀសមួយ សក្ខីកម្មដែលទទួលបានពីសាក្សី ឬក៏អ្វីផ្សេងទៀត ជាធាតុផ្សំនៃភស្តុតាងមិនត្រូវបានផ្ទុយជំទាស់ទេ ។

[១៥:០៩:០៥]

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

យើងមិនទាន់បានឈានទៅដល់របៀបវារៈ ដូចដែលយើងគ្រោងទុកទេ ដូចដែលខ្ញុំជម្រាបជូនលោកហើយ ទាក់ទងនឹងគោលការណ៍ណែនាំ ដែលយើងនឹងដាក់ឲ្យអនុវត្ត ដាក់ស្នើនូវវិសោធនកម្មមុននឹងអនុម័តដោយកិច្ចប្រជុំពេញអង្គនោះ ។ អ៊ីចឹងយើងបានគ្រោងនឹងអនុវត្តនីតិវិធីនេះហើយ វិធាននេះហើយ អ៊ីចឹងខបញ្ញត្តិដែលលោកដកស្រង់ហ្នឹង គឺជាគំនិតមួយ ដែលស្របនឹងអ្វីដែលយើងគ្រោងនេះឯង ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

សូមអរគុណលោកស្រីចៅក្រម ។ ដូច្នេះ ប្រសិនបើភាគី សហព្រះរាជអាជ្ញា មេធាវីការពារឯកភាពក្នុងចំណោមខ្លួននោះហើយ ដើម្បីស្នើជូនអង្គជំនុំជម្រះអំពីការព្រមព្រៀងលើអង្គហេតុទាំងឡាយនោះសំណើរបស់ខ្ញុំហ្នឹង គឺដូចតទៅនេះ៖

ដើម្បីឲ្យលោក លោកចៅក្រម ឬក៏ភាគីសួរទៅជនជាប់ចោទ អំពីអង្គហេតុដែលមិនទាន់បានពិនិត្យនោះទេ ដើម្បីឲ្យជនជាប់ចោទអាចនឹងបញ្ជាក់ពីចំណុចមួយចំនួន ដែលគាត់ថា ព្រម ឬមិនព្រមនោះ នៅក្នុងក្របខ័ណ្ឌនៃការសួរទៅលើជនជាប់ចោទ ដោយអង្គជំនុំជម្រះ ។ បន្ទាប់ពីនោះមក ហើយផ្អែកលើរឿងនេះឯង គប្បីតែឲ្យត្រង់ៗ ហើយសង្កត់ធ្ងន់ទៅលើអ្វីដែលមិនទាន់បានឯកភាព ទៅលើអង្គហេតុ និងដូចដែលខ្ញុំបញ្ជាក់ផងដែរ គប្បីតែសួរឲ្យត្រង់ៗ ឲ្យច្បាស់ៗ ជាពិសេស សម្រាប់សហព្រះរាជអាជ្ញាផងដែរ ។ ហើយទុករយៈពេលសម្រាប់ទុក ដោយឡែកនូវសាក្សីនិងឯកសារ សម្រាប់ផ្ដល់ឲ្យគាត់ជាមុនផង ។ ហើយស្របជាមួយនឹងដែរ យើងអាចនឹងពិនិត្យមើលក្នុងវិធាន៨៥ ដែលថា លោកប្រធាន អាចនឹងដកចេញនូវនីតិវិធីណា ដែលធ្វើឲ្យពន្យារពេលនីតិវិធី ហើយនិងបង្ហាញឲ្យរកឃើញការពិតទេ អញ្ចឹងតើយើងត្រូវការអនុវត្តពន្លឿននីតិវិធីដែលកៅសិបភាគរយនៃអង្គហេតុដែលជនជាប់ចោទដែលចោទប្រកាន់លើជនជាប់ចោទនោះ អ៊ីចឹងហើយផ្អែកទៅលើការគណនាបានកំណត់ហើយ យើងត្រូវដឹងឲ្យបានច្បាស់ថា ប្រសិនបើការជំនុំជម្រះនោះ ត្រូវប្រើពេលវែងដូចដែលយើងប៉ុនប៉ងក្នុងព្រឹកនេះរហូតដល់ចុងឆ្នាំនេះ នោះនឹងអាចមានន័យថា ឌុច ការជំនុំជម្រះរបស់ ឌុច នោះ គឺការជំនុំជម្រះរបស់ជនដែលបានសារភាពទទួលពិរុទ្ធភាពនោះ គឺថាអាចនឹងរយៈពេលវែងរហូតដល់ទៅប្រាំបួនខែ គឺថាអាចតម្រូវឲ្យចៅក្រមហ្នឹងអាចនឹងធ្វើសវនាការគឺថា៣៦ខែ ។ អ៊ីចឹង គឺថាបើមានជោគល្អបំផុតនោះ គឺថាពេលខ្លះ ចំណុចមួយខ្ញុំមិនអាចនៅតការងារនៅទីនេះទេ អ៊ីចឹងហើយគឺថា យើងត្រូវតែបង្ហាញសារឲ្យបានច្បាស់ ។

[១៥:១២:៥០]

ឥឡូវនេះ ខ្ញុំត្រឡប់មកសំណើជាក់ស្ដែងរបស់ខ្ញុំវិញ ប្រសិនបើអង្គជំនុំជម្រះត្រូវសម្រេច ប្រកាន់យកនូវវិធីមួយដែលច្បាស់ ដែលចាំបាច់ ដើម្បីធានាឲ្យសហព្រះរាជអាជ្ញាលើកឡើងឲ្យច្បាស់ អំពីភស្តុតាង នោះថាតើយើងត្រូវធ្វើដូចម្ដេចបាន? ហើយខ្ញុំស្នើថា សាក្សីទាំងឡាយដែលសហព្រះរាជអាជ្ញាដែលចង់រក្សាទុកនៅលើបញ្ជីនោះ ហើយខ្ញុំគឺថាប្រហែលជាពាក់កណ្ដាល មិនមែនជាពីរភាគបី នៃសាក្សីគឺថាដែលហើយផ្អែកនេះឯង គឺសាក្សីដែលនៅសេសសល់ដែលអាចនឹងកោះអញ្ជើញមក ។

អ៊ីចឹង នៅក្នុងវិធាន៩០ បានចែងច្បាស់ថា ចៅក្រម ឬអង្គជំនុំជម្រះ ចោទសំណួរដោយខ្លួនយល់ថា មានការចាំបាច់ ដែលជាផលប្រយោជន៍ដើម្បីស្វែងរកការពិត ហើយខ្លួនមានកាតព្វកិច្ច ដើម្បីសំណួរជាចំហ គឺជាសំណួរដោះបន្ទុក ឬសំណួរដាក់បន្ទុក ។ ហើយដែលថា យើងចិតនៅក្នុងប្រព័ន្ធច្បាប់

ស៊ីវិល ដូចដែលលោក ស្មីត បាននិយាយ គឺថាភារកិច្ចរបស់ចៅក្រមហ្នឹង គឺថាអាចចោទសួរដើម្បីបង្ហាញភស្តុតាងពីពិរុទ្ធភាព ហើយនិងការដោះបន្ទុកការដោះបន្ទុកនោះផងដែរ ។ អ៊ីចឹង ដែលយើងបន្តឲ្យវែងទៅទៀត ហើយយើងពិនិត្យមើលដោយសហព្រះរាជអាជ្ញា ដើម្បីការពិនិត្យសួរដោយដើមបណ្តឹងរដ្ឋប្បវេណីទៀត ។ តើនោះជាការជំនុំជម្រះយុត្តិធម៌ដែរឬទេ? ខ្ញុំជឿជាក់ថា ទាក់ទងទៅលើតែវិធីមួយដែលមានកិច្ចរួមគ្នាជាក់ស្តែងមួយក្នុងចំណោមយើងទេ ដើម្បីឲ្យយើងឯកភាពនូវកាលកំណត់ជាក់លាក់ម៉ឺងម៉ាត់មួយដែលថា ឲ្យភាគីសួរសំណួរ ដែលសួរហើយសំណួរនេះ គឺថា ជាមានលក្ខណៈបង្ហាញព័ត៌មានបន្ថែម ដូចថា ជាការពិនិត្យមើលភស្តុតាងដោះបន្ទុក ឬភស្តុតាងដាក់បន្ទុក ដើម្បីឲ្យសហព្រះរាជអាជ្ញា ដាក់បន្ថែមនូវធាតុផ្សំដាក់បន្ទុកនិងដោះបន្ទុក ។ ហើយនិងដើមបណ្តឹងរដ្ឋប្បវេណីបន្ថែមទៀត ហើយឲ្យគេផលិតនូវភស្តុតាង ខាងមេធាវីដែលថា អាចនឹងបង្ហាញនូវភស្តុតាងដោះបន្ទុកបន្ថែម ដើម្បីចៀសវាងកុំឲ្យចំណាយពេលច្រើនម៉ោង ។

[១៥:១៥:២៨]

លោកចៅក្រមជាទីគោរព! ក្នុងការចោទសួរអំពីភស្តុតាងដាក់បន្ទុកនិងដោះបន្ទុកហ្នឹងគឺថា អាចនឹងទាក់ទងទៅនឹងចំណុច គឺថាទៅលើតែចំណុច ដែលជនជាប់ចោទគាត់មិនយល់ព្រម ។ អ៊ីចឹងគឺថាចំពោះពេលសាមសិបមីនុត ទៅឲ្យសហព្រះរាជអាជ្ញាសួរសំណួរបន្ថែម ហើយដើមបណ្តឹងរដ្ឋប្បវេណីរួមគ្នានោះ គឺថាអាចនឹងប្រើពេលសាមសិបមីនុតសួរបន្ថែម។ អ៊ីចឹងហើយអាចដើម្បីឲ្យគេឯកភាពក្នុងចំណោមខ្លួនគេ មុននឹងសួរ ។ ហ្នឹងគឺថាអាចនឹងធ្វើឲ្យយើងសន្សំពេលយ៉ាងច្រើនបំផុតនៅក្នុងហ្នឹង ។ ហើយគេក៏អាចនឹង គេឯកភាពក្នុងចំណោមខ្លួនគ្នាគេ ក្នុងវគ្គនីមួយៗ គឺថាមានតែម្នាក់ក្នុងចំណោមក្រុមៗទាំងអស់ហ្នឹងគឺសួរក្នុងនាមក្រុមផ្សេងទៀត។ គឺថា នេះមិនមែនជាការលំបាកក្នុងការអនុវត្តទេ ។ បន្ទាប់មកមេធាវី ក៏អាចនឹងមានពេលដូចគ្នាសាមសិបមីនុត បូកសាមសិបមីនុតពីរដងទៅ គឺថាបានមួយម៉ោង ។ អ៊ីចឹង គឺក្រោយពីការសួរដែលយើងអនុវត្តហើយនោះ ពេលវេលាដែលបែងចែកទៅឲ្យភាគីនោះ គឺថាសមស្របទាំងអស់គ្នា ។

ដូច្នេះ លោក លោកស្រីចៅក្រម ហើយមានបញ្ហាជាក់ស្តែងអនុវត្តបានមួយចំនួន ដែលខ្ញុំស្នើឡើងដើម្បីពិនិត្យមើលគ្រប់ទិដ្ឋភាពទាំងអស់ ហើយទំហំនៃកិច្ចសវនាការដោយយុត្តិធម៌ ជាពិសេសបញ្ហាសំខាន់ពីរ មួយគឺថាយើងមានការស៊ើបអង្កេតរួចហើយ ហើយបានទទួលលទ្ធផល ដោយជាដីកាបញ្ជូនរឿងឲ្យជម្រះ ។ ហើយយើងមានជនជាប់ចោទ ឯកភាពទៅលើអង្គហេតុកៅសិបភាគរយនៅក្នុង

ដីកាបញ្ជូនរឿងទៅជម្រះនោះហើយ ។ អ៊ីចឹងហើយគឺ យើងឈានដល់ដំណាក់កាលមួយទៀត ។ រីឯដើមបណ្ដឹងរដ្ឋប្បវេណី ក៏បានផ្ដល់ជាមតិយោបល់ ហើយជាក់ស្ដែងណាស់ ហើយគឺទាក់ទងទៅនឹងអាទិភាពសម្រាប់សវនាការ ។

ការជំនុំជម្រះនេះ គឺយើងត្រូវចាំផងដែរថា អង្គហេតុថា គឺថាដើម្បីបណ្ដឹងរដ្ឋប្បវេណី ដែលយើងត្រូវធ្វើសវនាការពួកគាត់ ប្រសិនបើអនុញ្ញាតឲ្យសវនាការនេះចេះតែអូសបន្លាយតទៅទៀត វាអាចនឹងផ្ដល់លទ្ធផលមួយដែលថា បើយើងកម្រិតសិទ្ធិរបស់ការធ្វើសវនាការ គឺថាអាចនឹងពន្យារពេល ប៉ុន្តែវាមិនបំពេញទៅតាមគោលដៅដែលថា ការជំនុំជម្រះយុត្តិធម៌ទេ ។ យើងត្រូវការពេលដើម្បីស្ដាប់ដើមបណ្ដឹងរដ្ឋប្បវេណី ខ្ញុំក៏សូមចង់ជម្រាបបញ្ជាក់ដែរថា ប្រសិនបើដើមបណ្ដឹងរដ្ឋប្បវេណី ជាអកុសលនោះ គាត់បានទទួលមរណភាព ដោយសារគាត់ចាស់ជរា ។ អ៊ីចឹងមេធាវីការពារក៏ដោយ ក៏ទទួលស្គាល់ដែរ គឺថាការកន្លងផុតទៅនៃពេលវេលា ក៏ធ្វើឲ្យបាត់សាក្សីមួយសំខាន់របស់ខ្លួនដែរ គឺសាស្ត្រាចារ្យ ហិន រីយើង នោះ ។

[១៥:១៨:៥៤]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះប្រកាសសម្រាកដប់ប្រាំមីនុតសិន ដោយស្របពេលត្រូវការផ្លាស់ប្ដូរនូវឌីវីឌី ដែលបានអស់ហើយផង ហើយមិនដឹងថាចប់ពេលណា អ៊ីចឹង សម្រាកកណ្ដាលទីបណ្ដោយទៅ ដើម្បីឲ្យវាស្របពេលជាមួយនឹងការអស់ឌីវីឌីថតសំឡេង ថតរូបភាព ។

*[កិច្ចប្រជុំសម្រាកពីម៉ោង ១៥:១៩ នាទីដល់ម៉ោង ១៥:៣៣នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។

យើងបន្តកិច្ចប្រជុំពិភាក្សារបស់យើងតទៅទៀត ហើយអង្គជំនុំជម្រះសូមថ្លែងអំណរគុណដល់ការលើកឡើងរបស់មេធាវីការពារក្ដី លោក ហ្វ្រង់ស្វ័រ រូ ដោយបានលើកឡើងនូវបទពិសោធន៍ជាច្រើនដែលមានគោលបំណងក្នុងការជំរុញល្បឿននៃដំណើរការសវនាការយើងនេះ ប្រកបដោយប្រសិទ្ធភាព និងបានឆាប់រហ័សនោះ ។ ហើយព័ត៌មាននេះ គឺអង្គជំនុំជម្រះស្ដាប់បាន ហើយនិងព័ត៌មាននេះគឺសព្វ

គ្រប់សមល្មមនឹងយកអាចទៅពិភាក្សាពិចារណាបានហើយ ហើយដោយសារប្រធានបទមួយទៀតដែលជាប្រធានបទរបៀបវារៈពិសេស ដែលមានលក្ខណៈរួមផ្សំក្នុងការជំរុញដំណើរការនីតិវិធីសវនាការ ។ លោកត្រូវការពេលវេលានិយាយទៀត?

ខ្ញុំគិតថា ភាគច្រើនមនុស្សដែលនិយាយគឺឃើញនិយាយថា ចង់បានលឿន ប៉ុន្តែដល់ពេលការអនុវត្តដូចជាមិនលឿនដូចមាត់និយាយ ។

**លោក ហ្វ្រង់ស្វ័រ រ៉ូ៖**

សូមអរគុណលោកប្រធាន ។ ហើយខ្ញុំនឹងប្រើពេលតិចជាងមួយម៉ោង ដូចខ្ញុំបញ្ជាក់ខាងដើម ប៉ុន្តែតាមពិតខ្ញុំបានបញ្ចប់ក្នុងរយៈពេលប្រាំមីនុតតែប៉ុណ្ណោះ លោកប្រធាន ។

ខ្ញុំចង់ផ្តល់សេចក្តីសន្និដ្ឋាន ដោយជម្រាបថា យើងប្រហែលជានៅក្នុងចំណុចដ៏សំខាន់មួយនៅក្នុងការជំនុំជម្រះរបស់យើង នៅក្នុងខណៈពេលវិជ្ជមាន ។ សូមអរគុណចំពោះកិច្ចប្រជុំរៀបចំសវនាការដែលអង្គសវនាការ ដែលអង្គជំនុំជម្រះបានផ្តល់ឱកាសយើងចូលរួមក្នុងមតិ ហើយខ្ញុំសន្និដ្ឋានសរុបទៅលើសំណើបីយ៉ាង ដែលខ្ញុំបានលើកឡើង៖

ទីមួយ អង្គជំនុំជម្រះ គប្បីធ្វើសេចក្តីសម្រេចក្នុងការទទួលស្គាល់នូវអង្គហេតុ ដែលថា នេះក្នុងគំនិតនៃចៅក្រមព្រហ្មទណ្ឌ--យុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ ហើយនិងជាបូកបញ្ចូលនូវអ្វី ដែលបន្ថែមទៅលើបញ្ហាហ្នឹង ខ្ញុំនឹងមានសេចក្តីរីករាយ ។

ចំណុចទីពីរ ពាក់ព័ន្ធទៅនឹងការពិភាក្សាទាំងអស់ដែលនៅសេសសល់ ដែលមិនទាន់បានទទួលស្គាល់ ដោយជនជាប់ចោទនោះ គឺថាអង្គជំនុំជម្រះគប្បីកំណត់ពេលដើម្បីនិយាយ ហើយសុំឱ្យដើមបណ្តឹងរដ្ឋប្បវេណីឱ្យគោរពនូវពាក្យសំណើដែលខ្ញុំបានលើកឡើងខាងដើមថា ដើម្បីឱ្យយើងចំណេញពេលពីការសំណើនេះ ។ ហើយខ្ញុំសូមរំឭកផងដែរ ថាអ្វីដែលខ្ញុំបានចាប់ផ្តើមនោះ ហើយខ្ញុំនិយាយៗនឹងនិយាយឡើងវិញ គឺថានីតិវិធីរបស់យើងហ្នឹងត្រូវបានតាមដានដោយពិភពលោកទាំងមូល យើងគឺជាសាលាក្តីទីមួយដែលដាក់បញ្ចូលឱ្យមានការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី ។ ដូច្នេះ សូមលោកប្រធាន លោកចៅក្រម ធានាថាឱ្យយើងអនុវត្តឱ្យបានប្រសើរបំផុតតាមដែលអាចធ្វើទៅបាន ដើម្បីចៀសវាងថានៅពេលចប់សវនាការថា ធ្វើឱ្យគ្រប់ៗគ្នាអាចនឹងនឿយហត់ ឬក៏អស់កម្លាំង ដោយសារសវនាការនោះវាវែងពេក ។ អ៊ីចឹងហើយអង្គហេតុដែលថា អង្គហេតុដែលយកមកប្រឆាំងនឹងជនជាប់ចោទ ក៏ដូចគ្នាអ្វីដែលជនរងគ្រោះគេលើកឡើងត្រូវការនោះដែរ ។ អ៊ីចឹងហើយនៅទីបញ្ចប់នៃសវនាការ

នេះ យើងពិភាក្សា ហើយយើងនឹងពិចារណាការដាក់ទោស ហើយមេធាវីនឹងមានវិភាគទានច្រើននៅក្នុងហ្នឹង ហើយខ្ញុំសូមបញ្ចប់ដោយបញ្ជាក់ជូនលោកប្រធាន និងអង្គប្រជុំថា យើងនឹងគោរពទៅតាមគោល-ការណ៍នេះ ។

[១៥:៣៧:៥៣]

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី ។ ហើយជាកិច្ចបន្តនេះ សូមប្រគល់វេទិកាជូនទៅ លោកស្រីចៅក្រមខាតរាយច៍ ដើម្បីធ្វើការជម្រាបដល់អង្គប្រជុំអំពីការគោលបំណងនូវការស្នើសុំវិសោធនកម្ម និងខ្លឹមសារអត្ថន័យនិងក្នុងការស្នើសុំវិសោធនកម្ម និងការអនុវត្តនូវវិធាន៨៧.៣ និង៨៧.៦ ។

សូមអញ្ជើញលោកស្រី ។

**ចៅក្រម ស៊ីលយ៉ា ខាតរ៉ាយច៍៖**

សូមអរគុណលោកប្រធាន ។ កាលពីម្សិលមិញ យើងខ្ញុំបានជម្រាបព័ត៌មានដល់ភាគីពាក់ព័ន្ធនានាអំពីវិសោធនកម្ម២ចំណុច លើវិធាន៨៧ ដែលនឹងត្រូវបានពិចារណានៅក្នុងកិច្ចប្រជុំពេញអង្គ នៅថ្ងៃទី៧ ដល់ថ្ងៃទី ១១ ខែកញ្ញា ។ ហើយខ្ញុំមិនរំឭកឡើងវិញ អំពីសំណើវិសោធនកម្មនោះទេ ពីព្រោះអីកាលម្សិលមិញនោះ គឺភាគីពាក់ព័ន្ធនានាបានទទួលនូវវិសោធនកម្មនោះរួចហើយ ប៉ុន្តែខ្ញុំចង់បញ្ចេញមតិយោបល់ខ្លីៗទៅលើសំណើទាំងនោះ ។ ប្រសិនបើ វិធាននុ៎ងត្រូវបានអនុម័តនឹងមិនចូលជាធរមានទេរហូតទល់ថ្ងៃទី២០ ឬ២១ ខែកញ្ញា ឯណោះ ។ ដូច្នេះ មានន័យថា អង្គជំនុំជម្រះបានសម្រេចចេញសេចក្ដីណែនាំមួយដែលនឹងដាក់វិសោធនកម្មនៃវិធាននេះ ឲ្យដំណើរការភ្លាមៗតែម្ដង ។ ខ្ញុំបានស្នើឲ្យភាគីពាក់ព័ន្ធនានាកុំឲ្យបញ្ចេញមតិយោបល់ទៅលើសេចក្ដីណែនាំ លើកលែងតែការស្នើសុំឲ្យបញ្ជាក់ពីចំណុចណាមួយ ឬមួយក៏មានបញ្ហាចម្បងជាមួយនឹងសំណើទាំងនោះ ។ សេចក្ដីណែនាំ គឺមានគោលបំណងដើម្បីធ្វើឲ្យបានប្រសើរនូវប្រសិទ្ធភាពនៃសវនាការ ហើយនេះគឺជាចំណុចចម្បង ដែលយើងបានពិភាក្សាគ្នាអស់រយៈពេលពេញមួយថ្ងៃនៅថ្ងៃនេះ ។

ចំណុចទីមួយ ទាក់ទងនៅនឹងសំណើវិសោធនកម្មនេះទៅលើវិធាន៨៧.៣ ។ ពាក្យដែលថាប្រសិនបើត្រូវបានទទួលស្គាល់ ឬក៏បង្ហាញសមស្រប ត្រូវបានដាក់បញ្ចូលនៅក្នុងអនុវិធាននោះ ។ អ៊ីចឹងការកំណត់អត្តសញ្ញាណ ឬសមស្របនោះ គឺអាចបញ្ចូលទៅនឹងចំណងជើងនៃឯកសារនោះលេខឯកសារហើយនិងលេខយោងជាប្រព័ន្ធអេឡិចត្រូនិក ។ ហើយអង្គជំនុំជម្រះសាលាដំបូងនឹងរក្សាសិទ្ធិក្នុងការស្នើ

ឲ្យភាគីពាក់ព័ន្ធណាមួយដែលដាក់បង្ហាញឯកសារនៅចំពោះអង្គសវនាការ ទៅតាមវិធីបែបនេះ ដើម្បីផ្តល់នូវសេចក្តីសង្ខេប ឬក៏អាននៅក្នុងសវនាការ ។ ក៏ប៉ុន្តែ វិធីនៃការទទួលស្គាល់ឯកសារនោះគឺជាវិធីមួយដែលអង្គជំនុំជម្រះចង់ប្រើប្រាស់ជាង ។ នៅពេលដែលឯកសារនោះមានឧបសម្ព័ន្ធៗនោះត្រូវបានចាត់ទុកថាជាផ្នែកនៃឯកសារនោះ ។

ចំណុចទីពីរ ពាក់ព័ន្ធទៅនឹងអនុវិធានទី៨៧.៦ ទាក់ទងទៅនឹងការព្រមព្រៀងគ្នាទៅលើអង្គហេតុដែលបានចោទប្រកាន់នៅក្នុងដីកាឲ្យបញ្ជូនរឿងឲ្យជំនុំជម្រះ ។ ភាគីទាំងអស់ហ្នឹងត្រូវបានស្នើឲ្យពិចារណាទៅលើចំណុចថា នៅពេលដែលមានការព្រមព្រៀងទៅលើអង្គហេតុ ពួកគេត្រូវរកមើលឯកសារចំនួនបី ដែលពួកគេចាត់ទុកថាជាឯកសារសំខាន់ដើម្បីគាំទ្រដល់អង្គហេតុដែលបានព្រមព្រៀងគ្នានីមួយៗ ហើយត្រូវដាក់បង្ហាញនូវឯកសារអស់ទាំងនោះនៅចំពោះមុខអង្គសវនាការ ។ អង្គជំនុំជម្រះសាលាដំបូងនឹងធ្វើការបង្ហាញថា តើអង្គហេតុនុ៎ង នឹងត្រូវបានបញ្ជាក់ដោយភស្តុតាងដែរឬក៏អត់?

[១៥:៤២:២៨]

អង្គជំនុំជម្រះចង់សង្កត់បញ្ជាក់ទៅលើឃ្លានេះ នៅពេលដែលមានសំណើ ហើយកិច្ចព្រមព្រៀងទៅលើអង្គហេតុបែបនេះ គឺថាអាចនឹងត្រូវបានដកយកចេញនៅមុនសវនាការ ។ ហើយនេះមិនមែនជាវិធានដាច់ខាតទាំងស្រុងតែមួយមុខនោះទេ នេះគ្រាន់តែជាសេចក្តីណែនាំតែប៉ុណ្ណោះ ។ ដូច្នេះ ខ្ញុំចង់ដឹងនៅពេលនេះ ថាតើមានភាគីណាមួយចង់ធ្វើការស្នើសុំឲ្យបញ្ជាក់បន្ថែមទៅលើចំណុចណាមួយ ឬក៏មានបញ្ហាធំដុំទៅលើសេចក្តីណែនាំនេះ? ចុះខាងសហព្រះរាជអាជ្ញាវិញ យ៉ាងម៉េចដែរ?

**លោក វីលៀម ស្មីត៖**

សូមអរគុណលោកស្រីចៅក្រម ។

វិសោធនកម្មទៅលើវិធាន៨៧.៦ ការដាក់ពាក្យបន្ថែមទៅលើឯកសារ ដែលយ៉ាងច្រើនបីបំផុតសម្រាប់គាំទ្រទៅលើអង្គហេតុដែលបានព្រមព្រៀងគ្នានោះ ។ ខាងសហព្រះរាជអាជ្ញានឹងមានការចាប់អារម្មណ៍ ដោយថាឯកសារចំនួនបីយ៉ាងច្រើនបំផុត ដើម្បីគាំទ្រទៅលើចំណុចណាមួយនៃអង្គហេតុដែលបានព្រមព្រៀងគ្នានោះ ។ គឺថាប្រហែលជាមិនអាចគ្រប់គ្រាន់ដើម្បីបង្ហាញ អំពីចំណុចហ្នឹង ឲ្យហួសពីចំណុចវិមតិសង្ស័យ ។ ក៏ប៉ុន្តែ នៅពេលដែលខ្ញុំមើលទៅលើវិសោធនកម្មវិធាន៨៧.៣ លោកស្រីចៅក្រមបាននិយាយថា នៅក្នុងសេចក្តីណែនាំ ភាគីអាចដាក់ឯកសារណាមួយ ហើយនេះជាសំណើរបស់ខាងសហព្រះរាជអាជ្ញាដែលថា សហព្រះរាជអាជ្ញាគួរមិនត្រូវបានកំណត់ទៅលើ កម្រិតទៅលើឯកសារ

ចំនួនបី សម្រាប់អង្គហេតុនីមួយៗនោះទេ ខាងសហព្រះរាជអាជ្ញា គួរតែមានសិទ្ធិដាក់នូវឯកសារមួយចំនួន ដើម្បីបង្ហាញអំពីភស្តុតាងអំពីអង្គហេតុនោះ ឲ្យហួសពីវិមតិសង្ស័យ ។ ពីព្រោះអង្គហេតុមួយចំនួន អង្គហេតុមួយចំនួនធំទុំងហ្នឹង គឺជាអង្គហេតុដែលស្មុគស្មាញ មិនមែនជាអង្គហេតុធម្មតានោះទេ វាពាក់ព័ន្ធទៅនឹងលក្ខខណ្ឌនិងស្ថានភាពនៅស-២១ ទាក់ទងទៅនឹងចំនួនប្រជាជននៅស-២១ ទៅលើការធ្វើទារុណកម្ម ។ ឧទាហរណ៍ថា មានការព្រមព្រៀងទៅលើការធ្វើទារុណកម្ម ពីព្រោះការធ្វើទារុណកម្មហ្នឹងវាមានលក្ខណៈរាលដាល ។ ហើយបើសិនជាយើងជាមានឯកសារតែចំនួនបី ដើម្បីបង្ហាញថាមានអំពើទារុណកម្មចំនួនបីបានមានកើតឡើងឬក៏ត្រូវបានប្រព្រឹត្តនោះ គឺហាក់ដូចជាមិនគ្រប់គ្រាន់ដើម្បីបង្ហាញអំពីភស្តុតាងដែលជាតម្រូវការចាំបាច់ដើម្បីបង្ហាញថា អង្គហេតុហ្នឹងពិតជាកើតមានដោយហួសពីវិមតិសង្ស័យ ។

[១៥:៤៥:៤១]

ដូច្នេះ នេះជាការបារម្ភរបស់ខាងសហព្រះរាជអាជ្ញាថា នៅក្នុងតុលាការនេះយើងត្រូវចាំថាជនជាប់ចោទនោះ គាត់បានទទួលសារភាពទៅលើអំពើឧក្រិដ្ឋអស់ទុំងមួយចំនួនហើយ។ ក៏ប៉ុន្តែ បើសិនជាពិនិត្យទៅលើផ្នែកច្បាប់វិញនោះ យើងត្រូវមើលឲ្យឃើញថា តើមានអំពើណាមួយដែលគាំទ្រដល់អង្គហេតុដែលបានព្រមព្រៀងគ្នានោះ? ខ្ញុំគិតថា ប្រហែលជាវាសាមញ្ញជាង នៅក្នុងរឿងក្តីណាមួយដែលមានរឿងហេតុមួយកើតឡើង ហើយវាមិនមានពាក់ព័ន្ធនូវសកម្មភាពច្រើន ឬក៏អំពើ ឬអត្តចរិកច្រើននោះ ។

ខាងសហព្រះរាជអាជ្ញាសូមស្នើឡើងថា ខាងសហព្រះរាជអាជ្ញាគួរតែមិនត្រូវបានកម្រិតនៅក្នុងការដាក់សេចក្តីថ្លែងការណ៍ ដើម្បីគាំទ្រទៅលើអង្គហេតុណាមួយដែលអាចជាឯកសារលើសពីចំនួនបី ។ យើងខ្ញុំនឹងមិនជំទាស់ លោកស្រីចៅក្រម គឺថាដោយសារវិសោធនកម្មនេះ គឺខាងសហព្រះរាជអាជ្ញាសូមនឹងធ្វើការពិចារណាទៅលើវិសោធនកម្មដែលដាក់កម្រិតទៅលើឯកសារចំនួនបី សម្រាប់អង្គហេតុមួយនេះ ព្រោះម្សិលមិញនេះ យើងអត់មានបានអត្ថបទពេញលេញ ទៅលើវិសោធនកម្មនេះទេ ហើយយើងនឹងគិតពីឥទ្ធិពលនៃការធ្វើវិសោធនកម្មនោះ ពីព្រោះយើងនឹងពិនិត្យមើលទៅលើកម្រិតនៃការបង្ហាញអំពីភស្តុតាងនោះ ដើម្បីឲ្យបង្ហាញឲ្យឃើញថា អង្គហេតុនោះពិតជាកើតមានហួសពីវិមតិសង្ស័យមែន ។ ដូច្នេះ យើងខ្ញុំសូមរក្សាសិទ្ធិទៅលើចំណុចនេះ ។

[១៥:៤៧:៣៩]

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

ប្រហែលជាខ្ញុំអាចនិយាយនៅឃ្លានេះបានថា លោក វីលៀម ស្មីត នេះគឺជាសេចក្ដីណែនាំតែប៉ុណ្ណោះ ។ ហើយខាងអង្គជំនុំជម្រះទទ្ទឹងរង់ចាំថា អង្គហេតុដែលលើកឡើងដោយខាងសហព្រះរាជអាជ្ញា និង/ឬក៏ភាគីពាក់ព័ន្ធផ្សេងៗនោះ នឹងអាចត្រូវការឯកសារលើសពីចំនួនបី ។ ប៉ុន្តែការកំណត់ហ្នឹងគឺកំណត់ឯកសារចំនួនបី ហើយបើសិនជាឯកសារលើសពីហ្នឹងត្រូវការទៀតនោះ ។ មានន័យថាការដាក់បង្ហាញជូនបន្ថែមនឹងអាចត្រូវទទួលយកបានដោយអង្គជំនុំជម្រះសាលាដំបូង ។ ដូច្នេះ នេះគ្រាន់តែការណែនាំប៉ុណ្ណោះ ដែលកំណត់ទៅលើចំនួនឯកសារដែលមានចំនួនបីនេះ ។ ហើយខាងសហសេវិកដែលជាអ្នកមកពីខាងប្រព័ន្ធស៊ីវិលឡនោះ ក៏កំណត់ដែលថា នោះមិនមែនមានន័យថា អង្គជំនុំជម្រះត្រូវការឯកសារតែបីដើម្បីសម្រេចទៅលើចំណុចនោះ គឺមានន័យថា អង្គជំនុំជម្រះអាចនឹងពិចារណា ឬក៏ពិភាក្សាទៅលើឯកសារផ្សេងៗទៀត ដែលមាននៅក្នុងសំណុំរឿង ។

**លោក វីលៀម ស្មីត៖**

សូមអរគុណចំពោះការពន្យល់របស់លោកស្រីចៅក្រម ។ ខ្ញុំគិតថា សេចក្ដីបារម្ភនោះគឺថា ឧទាហរណ៍ ប្រសិនបើអង្គជំនុំជម្រះសម្រេចថា ដូចដែលបានលើកឡើងដោយខាងមេធាវីការពារ ការសួរសំណួរហ្នឹង គឺត្រូវបានកត់កាត់បន្ថយ ឬក៏ផ្ដោតអារម្មណ៍តែទៅលើចំណុចដែលមិនចុះសម្រុងនឹងគ្នា ។ ដូច្នេះ ជាចំណុចសំខាន់ណាស់សម្រាប់តុលាការនេះ គឺដើម្បីធ្វើការបង្ហាញនូវអ្វីដែលបានកើតឡើងនៅស-២១ ពីព្រោះបើសិនជាយើងពិចារណាតែទៅលើចំណុចដែលចម្រូងចម្រាស់គ្នានោះ គឺមិនមែនមានការបង្ហាញអំពីការពិត អំពីមុខងាររបស់តុលាការនេះទេ ។ នោះមានន័យថា គឺមានន័យថាជនជាប់ចោទគាត់គ្រាន់តែនិយាយថា បាទ! រឿងហ្នឹងកើតមានឡើងមែន ។ ហើយជាការពិតណាស់ ជនជាប់ចោទ មិនមានវត្តមានរាល់ពេល នៅពេលដែលអំពើទាំងនោះបានកើតឡើងនោះទេ ។ ដូច្នេះ ការសួរសំណួរ គឺការបង្ហាញអំពើអស់ទាំងនោះ ។

ហើយប្រសិនបើខាងសហព្រះរាជអាជ្ញា អាចធ្វើសំណើក្នុងការដាក់ឯកសារបន្ថែមទៀត ដើម្បីគាំទ្រដល់អង្គហេតុជាក់លាក់ណាមួយនោះ គឺយើងនឹងមិនមានការជំទាស់ទៅលើសេចក្ដីណែនាំនេះទេ ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

សូមអរគុណលោក ស្មីត នេះ ។ គឺជាការចាំបាច់ដើម្បីនិយាយថា សំណើដ៏ល្អប្រសើរមួយចំនួនត្រូវបានធ្វើឡើងនៅថ្ងៃនេះ ប៉ុន្តែវានៅដើមពេក យើងមិនទាន់អាចកំណត់ថា តើយើងត្រូវបញ្ចូលចំណុច

អស់ទាំងហ្នឹង នៅក្នុងសេចក្ដីណែនាំរបស់យើងសម្រាប់ភាគីពាក់ព័ន្ធនានាទេ ។ តើមានការបញ្ចេញមតិយោបល់អ្វីទេ? តើមានការបង្ហាញស្នើឲ្យបង្ហាញឲ្យបានច្បាស់ ឬក៏មានចំណុចអីធ្ងន់ធ្ងរដើម្បីបង្ហាញទាក់ទងទៅនឹងចំណុចដែលខ្ញុំបានលើកនេះទេ?

លោកស្រី វ៉ាបេសាន់ជ្រាតាណា លោកស្រីបានងើបឡើងមុនគេ ។

**លោកស្រី វ៉ាបេសាន់ជ្រាតាណា៖**

សូមអរគុណ ។ ខ្ញុំចង់ស្នើឲ្យមានការបញ្ជាក់មួយមិនមែនជាការបដិសេធទេ គ្រាន់តែជាការស្នើសុំឲ្យមានការបញ្ជាក់ នៅពេលដែលយើងនិយាយអំពីឯកសារចំនួនបីនោះ គឺថាមានឯកសារដែលជាការស៊ើបអង្កេតនៅក្នុងសំណុំរឿងរួចទៅហើយ ថាតើឯកសារបីដែលចង់និយាយនេះ បើតាមលោកស្រីចៅក្រមវិញមានន័យថា នោះគឺជាឯកសារដែលមានរួចស្រេចនៅក្នុងសំណុំរឿងដែលបានស៊ើបអង្កេតរួចហើយ ឬក៏ជាឯកសារថ្មី? ពីព្រោះយើងដឹងហើយថា យើងដឹងអំពីឯកសារដែលមាននៅក្នុងឯកសារដែលបានធ្វើការអង្កេតរួចហើយ ។ ប៉ុន្តែ យើងនិយាយអំពីឯកសារបីនេះ យើងមិនដឹងថា ឯកសារបីហ្នឹង គឺជាឯកសារថ្មី ឬក៏យ៉ាងម៉េច? បើសិនជាមានការបញ្ជាក់ឲ្យបានច្បាស់បន្ថែមទៀតទាក់ទងទៅនឹងអំពើ ឬក៏ការប្រព្រឹត្តិទៅនៅក្នុងអំឡុងពេលស៊ើបអង្កេត ឬក៏យ៉ាងម៉េចនោះ?

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយធ៌៖**

សូមអរគុណ ។ អង្គជំនុំជម្រះមិនទាន់មានឱកាសធ្វើការពិភាក្សាឲ្យបានលម្អិតអំពីចំណុចនេះទេ ប៉ុន្តែខ្ញុំអាចធ្វើការបង្ហាញដែលថា នេះមិនមែនមានបំណងដើម្បីកម្រិតសិទ្ធិដែលភាគីនីមួយៗមាននោះទេ ដែលមានស្ថិតនៅក្នុងក្រោមវិធាននេះ ក្នុងការបង្ហាញនូវភស្តុតាងថ្មី ។ នេះគឺជាការបកស្រាយរបស់ខ្ញុំ ប៉ុន្តែ អាចនឹងធ្វើការកែប្រែនៅពេលក្រោយ ។

ឥឡូវនេះ ខ្ញុំសូមជូនវេទិកាឲ្យទៅមេធាវី ស្ទួតហ្វ៊ីនស្ដី ។

**លោកស្រី ស៊ីលឃី ស្ទួតហ្វ៊ីនស្ដី៖**

ជាដំបូង ខ្ញុំសូមឲ្យស្នើឲ្យមានការបញ្ជាក់ ។ លោកស្រីចៅក្រមបាននិយាយថា អង្គជំនុំជម្រះសាលាដំបូង នឹងអាចពិនិត្យមើលសំណុំរឿងណាមួយក៏បានដែរ ដែលមាននៅក្នុងសំណុំរឿង ។ ឯកសារណាមួយដែលមាននៅក្នុងសំណុំរឿងក៏បានដែរ ។ ហើយសំណួររបស់ខ្ញុំនេះ គឺថាតើមានន័យថា លោកលោកស្រីចៅក្រមអាចធ្វើសេចក្ដីសម្រេចចិត្តដោយអាស្រ័យទៅលើឯកសារណាមួយដែលមាននៅក្នុងសំណុំរឿងដែលមិនត្រូវបានបង្ហាញនៅចំពោះមុខអង្គជំនុំជម្រះទេ នេះគ្រាន់ជាការលើកឡើងបញ្ជាក់ឲ្យ

ច្បាស់តែប៉ុណ្ណោះ លោកស្រីចៅក្រម ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

ការយល់ដឹងរបស់ខ្ញុំហ្នឹង គឺថាអង្គជំនុំជម្រះសាលាដំបូងយើងខ្ញុំនេះ នៅក្នុងអំឡុងពេលសួរចម្លើយអាចយោងទៅលើឯកសារផ្សេងៗ ហើយឯកសារដែលបានយោងនៅពេលសួរចម្លើយនោះ គឺចាត់ទុកថា ត្រូវបានបង្ហាញជូននៅចំពោះមុខអង្គសវនាការរួចហើយ ។ ឥឡូវខ្ញុំនិយាយអំពីឯកសារដែលបានកំណត់ចំនួនយ៉ាងច្រើនបីដែលត្រូវបានដាក់បង្ហាញដោយភាគីណាមួយសម្រាប់ការសួរដេញដោល។

**លោកស្រី ស៊ីលឃី ស្ទួតហ្វ៊ីនស្គី៖**

សូមអរគុណ ។ សូមស្នើឱ្យមានការបញ្ជាក់នូវចំណុចមួយទៀត ។ គឺឯកសារទាំងបីដែលលោកស្រីបាននិយាយនេះ អាចត្រូវដាក់បង្ហាញដូចដែលលោកស្រី ដូចដែលបានចែងនៅក្នុងវិធាន៨៧.៣ ដោយមានចំណងជើងនិងលេខផ្សេងៗជាដើមមែនទេ?

ហើយបន្ទាប់មកទៀត ខ្ញុំសូមស្នើឱ្យបញ្ជាក់នូវចំណុចមួយទៀត ទាក់ទងទៅហ្នឹងស្ថានភាពនៃសេចក្តីណែនាំនោះ ។ តើសេចក្តីណែនាំនោះគ្រាន់តែដូចជា ចាត់ទុកជាអនុសាសន៍ ឬក៏សេចក្តីបញ្ជាក់បន្ថែមទៅលើវិធាន ឬក៏ជាអ្វីលោកស្រីចៅក្រមអាចបញ្ជាក់បានទេ?

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

សម្រាប់ខ្ញុំជាអ្នកនិយាយភាសាអង់គ្លេសផ្ទាល់នោះ អ៊ីចឹង សេចក្តីណែនាំហ្នឹង គឺវាមានន័យតែប៉ុណ្ណឹងឯង ។ មានន័យថា គឺអង្គជំនុំជម្រះសាលាដំបូង ផ្តល់សេចក្តីណែនាំដល់ភាគីនានាហ្នឹង ថាតើត្រូវធ្វើយ៉ាងម៉េចនៅពេលដែលធ្វើការបង្ហាញអំពីឯកសារនៅចំពោះអង្គជំនុំជម្រះសាលាដំបូង? ប្រសិនបើលោក លោកស្រីចៅក្រម ឬក៏ភាគីធ្វើមិនដឹងមិនឮចំពោះសេចក្តីណែនាំនោះ ពេលហ្នឹងឯងអង្គជំនុំជម្រះនឹងរំឭកដល់ភាគីនោះអំពីសេចក្តីណែនាំនេះ ។

[១៥:៥៦:០៧]

**លោកស្រី ស៊ីលឃី ស្ទួតហ្វ៊ីនស្គី៖**

សូមអរគុណចំពោះការពន្យល់នេះ ។ ឥឡូវនេះ ខ្ញុំសូមធ្វើសំណើមួយដើម្បីអត្ថប្រយោជន៍ក្នុងការចូលរួម-- ខ្ញុំសូមនិយាយឡើងវិញ ។

តុលាការនេះ មិនត្រឹមតែមានភារកិច្ចក្នុងការជំនុំជម្រះជនជាប់ចោទនោះទេ ក៏ប៉ុន្តែតុលាការនេះក៏មានភារកិច្ចចូលរួមនៅក្នុងការស្វែងរកការពិត ដែលអង្គហេតុមួយចំនួនត្រូវបានឯកភាពរួចហើយ

ដូចជា៨០ ឬក៏៨៥ភាគរយនោះ ។ ក៏ប៉ុន្តែ តែថា អង្គហេតុអស់ទាំងហ្នឹង គួរតែត្រូវបានបង្ហាញឲ្យបានពិស្តារជាងនេះ ។ ដូច្នេះ ខ្ញុំសូមស្នើថា គួរតែបញ្ចូលនៅក្នុងសំណើរនេះផងដែរ នូវវិធីណាមួយដើម្បីផ្តល់ឱកាសបើសិនជាការចាំបាច់ ហើយដើម្បីជាអត្ថប្រយោជន៍សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី និងសម្រាប់សាធារណជននោះ គឺធ្វើការចងក្រងនូវឯកសារមួយចំនួនដើម្បីជាលទ្ធភាពមួយ ដើម្បីបង្ហាញអំពីអង្គហេតុដែលបានព្រមព្រៀងគ្នានោះ ថាតើចំណុចណាខ្លះទៅដែលមានបញ្ជាក់ក្នុងអង្គហេតុហ្នឹង ថាគាត់បានព្រមព្រៀង ឬក៏មិនបានព្រមព្រៀង?

ដូច្នេះ ដូចជាការបង្ហាញអំពីរូបភាពមួយដែលមានជារូបភាពពណ៌អំពីអ្វីដែលបានកើតមានឡើងនៅមន្ទីរស-២១ ហើយបើសិនជាអង្គជំនុំជម្រះសាលាដំបូងអាចធ្វើបានដូច្នេះ គឺជាការប្រើសើរ ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

សូមអរគុណ ហើយអង្គជំនុំជម្រះសាលាដំបូងនឹងពិចារណាទៅលើសំណើនេះ ។

**លោក អាឡាំង វែនណឺ៖**

ខ្ញុំចង់បង្ហាញថាអ្វីៗ គឺសម្រាប់ខ្ញុំច្បាស់លាស់ហើយ ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

សូមអរគុណ ។ តើមេធាវីការពារក្តីមានមតិយោបល់អ្វីទេ?

[១៥:៥៨:៥៣]

**លោក ហ្វ្រង់ស្វ័រ រូ៖**

សូមអរគុណលោកស្រីចៅក្រម ។ ខ្ញុំសូមនិយាយថា ខ្ញុំដូចជាមានបញ្ហាក្នុងការយល់ដឹង បញ្ហាដើម្បីយល់អំពីសេចក្តីបារម្ភរបស់ខាងសហព្រះរាជអាជ្ញា ពីព្រោះអីបើសិនជាយើងពិនិត្យមើលទៅលើការព្រមព្រៀងទៅលើការស្នើសុំកាត់បន្ថយ ឬក៏ទទួលស្គាល់ទោសនោះ ។ ជនជាប់ចោទបានទទួលស្គាល់អង្គហេតុទាំងនោះរួចហើយ ហើយមានន័យថា អំពើបែបហ្នឹង គឺវាមានតម្លៃដាក់បន្ទុក ។ ហើយខ្ញុំសូមឲ្យយោងទៅលើវិធាន៨៧.៥ ដែលជាវិធានដែលមានចែងនៅពេលបច្ចុប្បន្ននេះ គឺចម្លើយសារភាពគឺនឹងទទួលបានការពិចារណា ឬក៏តម្លៃដូចគ្នាពីអង្គជំនុំជម្រះចាត់ថា ចាត់ទុកជាភស្តុតាង ។ អ៊ីចឹងបើសិនជាអង្គហេតុទាំងនោះ គឺថា ជនជាប់ចោទហ្នឹង គាត់ទទួលស្គាល់ពិរុទ្ធភាពហ្នឹងហើយ ហើយមានឯកសារបន្ថែមចំនួនបីបន្ថែមទៀតហ្នឹង មិនយល់ថា វាគ្រប់គ្រាន់ទេឬ? សម្រាប់ខ្ញុំ ខ្ញុំយល់ថា វាគ្រប់គ្រាន់ហើយ ។ មានន័យថា ឯកសារដែលបានលើកឡើងនេះ គឺវាគ្រប់គ្រាន់ហើយសម្រាប់ខ្ញុំ ពីព្រោះអី

នៅក្នុងប្រព័ន្ធខំមិនឡ គឺយើងមិនចាំបាច់បន្ថែមឯកសារទៀតទេ បើសិនជាយើងមានកិច្ចព្រមព្រៀង ជាមួយជនជាប់ចោទហើយនោះ ។

ដូច្នេះ ខ្ញុំជឿថា ឯកសារបន្ថែមចំនួនបីទៀតនោះ គឺវាច្រើនទៀតទៅហើយ ហើយខាងសហព្រះរាជអាជ្ញាវិញ បើសិនជាធ្វើការដើម្បីសម្រេចយក បានទទួលលទ្ធផល គឺដើម្បីកាត់បន្ថយនូវពេលវេលា។ ហើយនេះមានន័យថា មិនមែនយើងចង់ គ្រាន់តែចង់កាត់បន្ថយពេលវេលា គឺដើម្បីទទួលបានលទ្ធផល នៅពេលជាមួយគ្នាផងនោះដែរ ។ ហើយខាងមេធាវីការពារក្តី ក៏សូមស្នើផងដែរ ថាតើស្ថានភាពរបស់សាក្សីនោះវាយ៉ាងម៉េចដែរ? ប្រសិនបើយើងត្រូវអនុវត្តទៅតាមសេចក្តីណែនាំនេះ មានន័យថាតើអង្គជំនុំជម្រះហ្នឹង ចង់ស្តាប់សក្ខីកម្មរបស់សាក្សីតែទៅលើចំណុចមួយចំនួនទេឬ? ដែលមានន័យថា តែទៅលើចំណុចដែលនិយាយអំពីអង្គហេតុដែលមិនព្រមព្រៀងគ្នា ឬក៏យ៉ាងម៉េច?

[១៦:០២:២០]

ឧទាហរណ៍ថា មានសាក្សីម្នាក់ ឬក៏ពីរនាក់ អាចត្រូវយកមកផ្តល់សក្ខីកម្ម ពីព្រោះអីដោយសារភាពទាក់អារម្មណ៍នៃសវនាការនេះ ឬក៏យ៉ាងម៉េច? ខ្ញុំឯកភាពទៅលើចំណុចអស់ទាំងនេះ បើសិនជាមានការកម្រិតបែបនេះ ។ ក៏ប៉ុន្តែ បើសិនជាយើងធ្វើហួសពីនេះ ខ្ញុំយល់ថាជាការធ្វើច្រើនពេកហើយ ហើយនឹងធ្វើឲ្យការពិភាក្សាដេញដោលគ្នានោះវាកាន់វែងឆ្ងាយ ហើយដូចជាមិនបានលទ្ធផលអ្វីទេក្នុងការស្វែងរកការពិតនោះ ។

អ៊ីចឹងនៅក្នុងសេចក្តីណែនាំនោះ ខ្ញុំយល់ថា នឹងជាអត្ថប្រយោជន៍ណាស់ប្រសិនបើយើងធ្វើការបង្ហាញការកម្រិតទៅលើសាក្សីចំនួនពីរ ឬក៏បី ចំពោះទៅលើអង្គហេតុដែលបានឯកភាពគ្នាហើយនោះ។ ហើយបើសិនជាសហព្រះរាជអាជ្ញាមិនមានការភ័ន្តច្រឡំនោះទេ ផ្អែកនៅក្នុងប្រព័ន្ធខំមិនឡ មានន័យថា សក្ខីកម្មមួយអាចចាត់ថា គ្រប់គ្រាន់ហើយ បើសិនជាសក្ខីកម្មនោះមានការគាំទ្រដោយសក្ខីកម្មណាមួយទៀតនោះ ។

ដូច្នេះមានន័យថា យើងត្រូវការតែបញ្ជាក់ឲ្យបានច្បាស់អំពីសក្ខីកម្មណាមួយដើម្បីបង្ហាញអំពីចំណុចនោះ ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

សូមអរគុណ ចំពោះការលើកឡើងនេះ ហើយអង្គជំនុំជម្រះនឹងពិចារណាទៅលើការលើកឡើងអស់ទាំងនេះ ។ លោកប្រធាន គឺនៅមានចំណុចមួយទៀត ដែលមាននៅក្នុងរបៀបវរៈ តើលោកប្រធាន

ចង់ឲ្យខ្ញុំធ្វើបន្តទៀត ឬក៏យ៉ាងម៉េច? ឬក៏លោកប្រធានចង់សួរសំណួរនេះ?

សហព្រះរាជអាជ្ញាយ៉ាងម៉េចដែរ?

**លោក វីលៀម ស្មីត៖**

លោកប្រធាន លោកស្រីចៅក្រម បើសិនជាខ្ញុំអាចនិយាយយ៉ាងខ្លី ឆ្លើយតបទៅហ្នឹងវិសោធនកម្ម ឬក៏ទាក់ទងសេចក្ដីណែនាំថ្មីមួយនេះ ។

សហព្រះរាជអាជ្ញាពិតជាមានការបារម្ភអំពីការដាក់កម្រិតចំនួនទៅលើឯកសារចំនួនបី សម្រាប់ការចោទប្រកាន់ដែលបានព្រមព្រៀងគ្នារួចមកហើយនោះ ពីព្រោះយើងត្រូវបង្ហាញឲ្យហួសពីវិមតិសង្ស័យ ហើយជាចំណុចសំខាន់ណាស់ ហើយសេចក្ដីណែនាំក៏ជាចំណុចសំខាន់ដែរ ហើយវិសោធនកម្មក៏ជាចំណុចសំខាន់ដែរ ហើយបើសិនជាយើងធ្វើការកម្រិតចំនួនលើឯកសារតែបីចំពោះអង្គហេតុណាមួយនោះ ។ ខ្ញុំសូមឱកាសឲ្យខាងសហព្រះរាជអាជ្ញាមានឱកាសដើម្បីពិចារណាទៅលើចំណុចនេះ ហើយ និងធ្វើការដាក់ជូនជាលាយលក្ខណ៍អក្សរទាក់ទងទៅនឹងសេចក្ដីណែនាំនេះ ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

សូមអរគុណលោកសហព្រះរាជអាជ្ញា ។ ពិតណាស់ អង្គជំនុំជម្រះពិតជាបានដឹងអំពីសេចក្ដីបារម្ភរបស់ខាងសហព្រះរាជអាជ្ញា ហើយអង្គជំនុំជម្រះក៏ហ្នឹងពិចារណាផងដែរនូវការដាក់ជូនពីខាងសហព្រះរាជអាជ្ញានៅពេលបន្តបន្ទាប់ទៀតនោះ ។ មានន័យថា ការដាក់ជូនជាលាយលក្ខណ៍អក្សរពីខាងសហព្រះរាជអាជ្ញា ហើយមានន័យថា គឺត្រូវការការដាក់ជូនបែបនេះជាលាយលក្ខណ៍អក្សរពីខាងមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីនិងមេធាវីការពារក្ដីផងដែរ ។ ហើយមានន័យថា អង្គជំនុំជម្រះនឹងត្រូវចំណាយពេលវេលាដើម្បីពិចារណាពិនិត្យទៅលើចំណុចអស់ទាំងហ្នឹង ហើយជាការខាតពេលវេលាផងដែរ ។ អ្វីដែលលោកបាននិយាយនោះ គឺជាមតិមួយដែលសម្រាប់ឲ្យយើងយកមកពិចារណា ហើយអង្គជំនុំជម្រះនឹងពិចារណាត្រូវស្វែងរកមតិយោបល់បន្ថែមទៀត ពីខាងសហព្រះរាជអាជ្ញា ។

[១៦:០៥:០០]

**ប្រធានអង្គជំនុំ៖**

យើងនៅមានរបៀបវារៈមួយទៀតដែលយើងនៅមិនទាន់បានពិភាក្សាគ្នា ។ ហើយគឺការបែងចែកនូវពេលវេលាសម្រាប់ដើមបណ្ដឹងរដ្ឋប្បវេណី ដែលបានជ្រើសរើសឲ្យមកថ្លែងការណ៍ចំពោះមុខអង្គជំនុំជម្រះតាមសំណើរបស់មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី ដូចជាខាងភាគីទាំងអស់ ដូចជាមិនទាន់បាន

ពាក់ព័ន្ធស៊ីជម្រៅលើបញ្ហានេះទេ ។ ហើយដើម្បីបានច្បាស់យើងនៅមានសល់ពេលវេលាដប់ប្រាំនាទីដែរ ហើយសូមជូននាទីទៅលោកស្រីចៅក្រម ដើម្បីធ្វើការពន្យល់ និងធ្វើការជាមួយអស់លោក លោកស្រី ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន ។ នេះជាសំណួរដែលអង្គជំនុំជម្រះចង់ដាក់តាំងទៅលើដើមបណ្តឹងរដ្ឋប្បវេណី ដែលពួកគេមានបំណងចង់ធ្វើការពិភាក្សាជាមួយគ្នាឯងមុននឹងផ្តល់ចម្លើយមកឲ្យអង្គជំនុំជម្រះ ។ នេះគឺជាសំណួរដ៏សាមញ្ញមួយដែលត្រូវយកទៅពិភាក្សា ។ ដើមបណ្តឹងរដ្ឋប្បវេណីហ្នឹង គឺត្រូវបានផ្តល់នូវរយៈពេលចំនួនប្រាំថ្ងៃធ្វើការ ដើម្បីធ្វើការបង្ហាញ ឬក៏ឧទ្ទេសនាមរបស់ខ្លួននៅក្នុងអំឡុងពេលសវនាការ ។

សំណួរគឺថា តើក្រុមដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ហ្នឹងអាចធ្វើការបែងចែកពេលវេលាក្នុងចំណោមដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់នោះ ដោយមិនចាំបាច់ឲ្យមានអន្តរគមន៍ពីអង្គជំនុំជម្រះសាលាដំបូងបានដែរឬទេ? បើសិនជាអាចធ្វើបាននោះ គឺអាចជូនដំណឹងមកយើងខ្ញុំនៅសប្តាហ៍ក្រោយ ។

**លោក អាឡាំង វ៉ែនណឺ៖**

ប្រហែលជាខ្ញុំច្រឡំក៏មិនដឹង នៅពេលដែលលោកស្រីនិយាយថា លោកស្រីទុកឱកាសឲ្យប្រាំថ្ងៃហ្នឹង គឺលោកស្រីទើបជូនដំណឹងឲ្យយើងនៅពេលនេះ ឬក៏បើសិនជាសេចក្តីសម្រេចនោះបានផ្ញើយូរមកហើយ ឬក៏មិនមានការប្រាស្រ័យទាក់ទងគ្នាបានច្បាស់លាស់នោះ គឺថាពួកខ្ញុំមិនទាន់បានដឹងអំពីការចាត់ពេលវេលាប្រាំថ្ងៃសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីនៅឡើយទេ ។ តើខ្ញុំអាចសុំឲ្យមានការបញ្ជាក់បន្ថែមទៅលើចំណុចនេះទេ?

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

គឺមានចែងនៅក្នុងឯកសារ E57 អ៊ីចឹងនៅពេលដែលខ្ញុំនិយាយយោងទៅលើចំណុចនេះ គឺយើងមិនសង្ឃឹមថា ដើមបណ្តឹងរដ្ឋប្បវេណីនឹងឆ្លើយភ្លាមៗនោះទេ ។ យើងចង់ឲ្យដើមបណ្តឹងហ្នឹង ធ្វើការពិភាក្សាក្នុងចំណោមដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ដោយមិនចាំបាច់ឲ្យមានការរៀបចំការជួបជុំពីអង្គជំនុំជម្រះសាលាដំបូងនោះ ។ ហើយបើសិនជាអាចធ្វើការពិភាក្សាគ្នាបាន ហើយផ្តល់ចម្លើយឲ្យមកអង្គជំនុំជម្រះសាលាដំបូងនៅសប្តាហ៍ក្រោយនឹងអាចជាប្រយោជន៍ដ៏ល្អ ។ តើច្បាស់លាស់ ឬនៅលោកវ៉ែនណឺ?

[១៦:០៨:១១]

**លោក អាឡាំង វ៉ែនណឺ៖**

បាទ, ពួកយើងខ្ញុំនឹងធ្វើដូច្នោះ ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

លោកប្រធាន អ៊ីចឹងបញ្ហាដែលមាននៅច្រើនទៀត លោកប្រធានយល់យ៉ាងម៉េចដែរ?

**ប្រធានអង្គជំនុំ៖**

រាងនឿយហត់ហើយដែរ ហើយបញ្ហាមួយចំនួនទៀត យើងដូចជានៅមានពេលច្រើនទៀត ដើម្បីធ្វើការប្រជុំរបៀបនេះ ហើយប្រហែលជាក្នុងអំឡុងពេលប្រព្រឹត្តទៅហ្នឹង នឹងជួបបញ្ហាទៅពីរបីខែក្រោយមក ក្រោយទៀតនោះ ហើយអ៊ីចឹងខ្ញុំគិតថា ពេលវេលាសមរម្យហើយគួរតែត្រូវបានបញ្ចប់នៅកិច្ចប្រជុំត្រៀមរៀបចំសវនាការនៅពេលនេះហើយ ។

អស់លោក លោកស្រីជាសមាជិក សមាជិកា នៃអង្គប្រជុំព្រមទាំងអ្នកចូលរួមគាំទ្រនៅក្នុងកិច្ចប្រជុំរៀបចំសវនាការទាំងអស់ជាទីរាប់អាន ។ ក្នុងនាមចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូង ខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះលទ្ធផលដែលបានសម្រេចតាមរយៈកិច្ចប្រជុំរយៈពេលពេញមួយថ្ងៃកន្លងមកនេះ ។ អង្គជំនុំជម្រះសង្កេតឃើញថា កិច្ចប្រជុំនេះបាន មានការចូលរួមយ៉ាងផុសផុលពីសំណាក់សហព្រះរាជអាជ្ញា មេធាវីដើមបណ្តឹងរដ្ឋប្បវេណី មេធាវីការពារក្តី ជនជាប់ចោទ និងផ្នែកការិយាល័យរដ្ឋបាលផងដែរ ។ កិច្ចប្រជុំរៀបចំនេះពិតជាជួយដល់អង្គជំនុំ ជម្រះសាលាដំបូងក្នុងការរៀបចំដំណើរការសវនាការចាប់ពេលនេះទៅពេលខាងមុខ ។

ឆ្លងតាមកិច្ចប្រជុំពិភាក្សានេះ យើងបានកត់សម្គាល់នូវបញ្ហាមួយចំនួនដែលត្រូវដោះស្រាយ ដែលបានពិភាក្សាលើបញ្ហាដែលបានចង្អុលបង្ហាញដោយអង្គជំនុំជម្រះសាលាដំបូង ដែលបានបំភ្លឺនូវបញ្ហាមួយចំនួនដែលចោទសួរដោយភាគី និងបានដឹងនូវអំពីបញ្ហាថ្មីៗមួយចំនួនទៀតដែលលើកឡើងដោយភាគីដែលបានចូលរួមមតិយោបល់ ។ ក្រោយពីបញ្ចប់នូវកិច្ចប្រជុំនេះទៅ អង្គជំនុំជម្រះសាលាដំបូងនឹងយកព័ត៌មានដែលបានទទួលពីកិច្ចប្រជុំនេះ ក៏ដូចជាមតិយោបល់ដែលភាគីបានចូលរួម និងផ្នែកការិយាល័យរដ្ឋបាលផងដែរ ទៅធ្វើការពិភាក្សាលម្អិត ដើម្បីកំណត់នូវកាលបរិច្ឆេទ សម្រាប់សវនាការឲ្យបានច្បាស់លាស់ ចាត់ការដំណើរការនីតិវិធីប្រកបដោយភាពរលូននិងបានឆាប់រហ័ស ។

ជាទីបញ្ចប់ ជំនួសមុខឲ្យអង្គជំនុំជម្រះសាលាដំបូង ខ្ញុំសូមថ្លែងអំណរគុណដល់សហព្រះរាជអាជ្ញា ដល់មេធាវីការពារក្តី មេធាវីដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ ព្រមទាំងមន្ត្រីបុគ្គលិកចំណុះឲ្យ

ការិយាល័យរដ្ឋបាល សន្តិសុខ អនុរក្សពន្ធនាគារ និងមន្ត្រីទាំងអស់ដែលបានគាំទ្រនៅក្នុងកិច្ចប្រជុំនេះ ។ ក្នុងនោះមានទាំងអ្នកបកប្រែភាសាផង ដែលបានខិតខំអស់ពីកម្លាំងកាយចិត្តក្នុងការជួយក្នុងកិច្ចប្រជុំនេះ ធ្វើឲ្យលទ្ធផលនៃកិច្ចប្រជុំនេះបានជោគជ័យ ។ ខ្ញុំសូមជូនពរដល់អស់លោក លោកស្រី នាងកញ្ញាមានសុខភាពល្អ ប្រាជ្ញាឈ្លាសវៃ និងសម្រេចជោគជ័យក្នុងមុខងារភារកិច្ច ។

ខ្ញុំសូមប្រកាសបិទកិច្ចប្រជុំចាប់ពីពេលនេះតទៅ ៕

*[កិច្ចប្រជុំបញ្ចប់នៅម៉ោង ១៦:១២ នាទី]*